# មីលិន្ទបញ្ហា

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា

ប្រែនិងរៀបរៀង

ខ្សែទី ១

ព.ស ២៤៧៧

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្ហូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២៤៨.១៨

# មីលិន្ទបញ្ហា

ព្រះគ្រូវិបុលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា

ប្រែនឹងរៀបរៀង

ខ្សែ ១

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

BUDDHIST INSTITUTE
LIBRARY
០០៧៦/០៦

BIBLIOTHEQUE ROYALE DU CAMBODGE

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង់
ព.ស. ២៤៧៧

www.budinst.gov.kh www.elibraryofcambodia.org

# MILINDAPANHA

## TRADUIT DU PALI EN CAMBODGIEN

PAR

PREAS KROU VIMALAPANNA (OUM-SOU)
ACHAR A LA Bibliothèque Rorale

VOL I.

CETTE EDITION A REÇU L' APPROBATION
DU CONSEIL DES MINISTRES

PHNOM-PENH
IMPRIMERIE DU GOUVERNEMENT
1929

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការឿង

ទំព័រ

សេចក្តីរាងក្នុងសៀវភៅ . . . . . . . . . . . . . . . . . . . . . . ១
សេចក្តីផ្តើម . . . . . . . . . . . . . . . . . . . . . . . . . . . ៧
បណាមគាថា ពាក្យនមស្សការព្រះរតនត្រ័យ . . . . . . . . . . . . . . . ១០
អារព្ភកថា ពាក្យព្រារព្ធគម្ពីរមិលិន្ទបញ្ហា របស់ព្រះបិដកចុឡាភ័យ អ្នកតែងគម្ពីរ.. ១២
ពោលអំពីព្រះពុទ្ធត្រាស់ កាលស្តេចនិព្វាន. . . . . . . . . . . . . . . . . . ១៥
ព្រះពុទ្ធត្រាស់ព្រះវង្សប្រាប់ព្យាករណ៍ព្រះនាគសេនថេរនឹងព្រះបាទមិលិន្ទ. . . . . ១៨
ព្រះបិដកចុឡាភ័យ សរសើរកិត្តិគុណព្រះនាគសេនថេរ នឹងព្រះបាទមិលិន្ទ. . . . ១៩
ពោលអំពីគម្ពីរមិលិន្ទបញ្ហាមាន ៦ ស្ថាន. . . . . . . . . . . . . . . . . . ២២
បុព្វយោគកថា ពណ៌នារឿងខាងដើមដែលនឹងបានប្រស្នាវិសជ្ជនា.. . . . . . . . ២៥
ពោលអំពីព្រះនាគសេនថេរនឹងព្រះបាទមិលិន្ទសាងកុសលក្នុងអតីតជាតិជាមួយគ្នា. ២៦
ពោលអំពីបវត្តិព្រះបាទមិលិន្ទ . . . . . . . . . . . . . . . . . . . . . ៣០
ព្រះបាទមិលិន្ទស្តេចទ្រង់ពោងទៅសួរបញ្ហាគ្រូទាំង ៦. . . . . . . . . . . . . ៣៤
ព្រះបាទមិលិន្ទទ្រង់ព្រះដំរិះរកអ្នកប្រាជ្ញអាចដោះស្រាយបញ្ហាព្រះអង្គមិនបាន . . . ៣៨
ព្រះអស្សគុត្តថេរអោយប្រជុំព្រះអរហន្តមកពិសេសរកលោកដែលអាចដោះស្រាយបញ្ហាបាន. . . . ៣៩
ព្រះអរហន្ត ១០០ កោដិទៅថ្វាយព្រះពរព្រះឥន្ទ. . . . . . . . . . . . . . . ៤១
ព្រះឥន្ទទទួលព្រះពរនឹងព្រះអរហន្តសូមអញ្ជើញមហាសេនទេវបុត្ត. . . . . . . ៤៣
ព្រះអរហន្តបង្គាប់អោយព្រះរោហណថេរទៅចាំទូន្មាននាគសេនកុមារ. . . . . . . ៤៦
មហាសេនទេវបុត្តចុតិចុះមកកើតក្នុងត្រកូលសោណុត្តរព្រាហ្មណ៍. . . . . . . . . ៤៦
ព្រះរោហណថេរទៅទូន្មានសោណុត្តរព្រាហ្មណ៍. . . . . . . . . . . . . . . . ៤៧
នាគសេនកុមាររៀនត្រ័យវេទ. . . . . . . . . . . . . . . . . . . . . . ៥១
ព្រះរោហណថេរ [illegible] អាការនឹងនាគសេនកុមារ . . . . . . . . . . . . . ៥៤
នាគសេនកុមារលាបិតាមាតាចេញបព្វជ្ជា ជាសាមណេរ. . . . . . . . . . . . ៥៨
នាគសេនសាមណេររៀនព្រះអភិធម្មបិដក. . . . . . . . . . . . . . . . . . . ៦០
នាគសេនសាមណេរទៅរកព្រះអរហន្ត ១០០ កោដិ. . . . . . . . . . . . . . ៦៣
នាគសេនសាមណេរឧបសម្បទ. . . . . . . . . . . . . . . . . . . . . . . ៦៣
ព្រះរោហណថេរបង្គាប់អោយព្រះនាគសេនភិក្ខុទៅទូន្មានព្រះបាទមិលិន្ទ. . . . . ៦៥
ព្រះនាគសេនភិក្ខុទៅរកព្រះអស្សគុត្តថេរ. . . . . . . . . . . . . . . . . . ៦៦
ព្រះនាគសេនភិក្ខុទៅឆាន់នូវគេហស្ថានស្រីជាឧបដ្ឋាកព្រះអស្សគុត្តថេរ. . . . . . ៦៨

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអស្សគុត្តថេរ អារាធនាព្រះនាគសេនភិក្ខុទៅរៀនព្រះត្រៃបិដក អំពីព្រះធម្មរក្ខិត ឯក្រុងបាតលីបុត្ត. . . . . . . . . . . . . . . . . . . . . . . . . . . ៧០
ព្រះនាគសេនភិក្ខុសំដែងព្រះអភិធម្មដល់សេដ្ឋីម្នាក់ ដែលប្រទះកណ្ដាលផ្លូវ . . . ៧៣
ព្រះនាគសេនភិក្ខុរៀនព្រះត្រៃបិដកអំពីព្រះធម្មរក្ខិត . . . . . . . . . . . . . . . . ៧៧
ព្រះនាគសេនភិក្ខុបានសំរេចព្រះអរហត្តផល. . . . . . . . . . . . . . . . . . . . ៧៨
ព្រះអរហន្តបញ្ជូនព្រះនាគសេនថេរអោយទៅឈ្នះព្រះបាទមិលិន្ទ. . . . . . . ៨១
ព្រះបាទមិលិន្ទស្ដេចទ្រង់ពោលទៅសួរបញ្ហាព្រះអាយុបាលថេរ ឯសង្ខេយ្យបរិវេណ.. ៨៥
ព្រះនាគសេនថេរមកអាស្រ័យនៅជាមួយនឹងព្រះអាយុបាលថេរ. . . . . . . . . ៩៣
ព្រះបាទមិលិន្ទស្ដេចទ្រង់ចោងទៅរកព្រះនាគសេនថេរ. . . . . . . . . . . . . ៩៧
ព្រះបាទមិលិន្ទទតព្រះនេត្រឃើញព្រះនាគសេនថេរកោនឲ្យបរិយញាប់ញ័រធំប្រប់. . ១០០

## បឋមវគ្គ

១ . នាមបញ្ហា សួរថាលោកម្ចាស់ឈ្មោះអ្វី ឈ្មោះនាគសេនដោយសេចក្ដីថាយ៉ាងដូចម្ដេច . . . . . . . . . . . . . . . . . . . . . . . . . . . . ១០២
២.វស្សបញ្ហា សួរវស្សា និងសួរថាវស្សាទាំងនោះរាប់យកលោកម្ចាស់ដែរ ឬ ។ រាប់យកតែឆ្នាំទេ. . . . . . . . . . . . . . . . . . . . . . . . . ១១៥
៣.វេរព្យតិក្ខបដិភាណបញ្ហា សួរថាបព្វជ្ជាមានប្រយោជន៍ដូចម្ដេច. . . . . . ១១៨
៤.អនន្តកាយបញ្ហា អនន្តកាយអាមាត្យសួរថា ឈ្មោះនាគសេននោះចាត់ជាសត្វជាបុគ្គលមិនបានទេឬ. . . . . . . . . . . . . . . . . . . . . . . . ១២៣
៥.បព្វជ្ជាបញ្ហា សួរថាបព្វជ្ជារបស់លោកម្ចាស់មានប្រយោជន៍យ៉ាងដូចម្ដេច . . ១២៩
៦.បដិសន្ធិគហណបញ្ហា សួរថាសត្វដែលស្លាប់ហើយ នឹងមិនកាន់យកបដិសន្ធិ គឺមិនកើតទៀតទេឬ. . . . . . . . . . . . . . . . . . . . . . . . . . ១៣១
៧.មនសិការបញ្ហា សួរថាបុគ្គលដែលមិនបដិសន្ធិគឺមិនកើតទៀតនោះ ដោយយោនិសោមនសិការដូចម្ដេច . . . . . . . . . . . . . . . . . . . . . . . ១៣២

www.budinst.gov.kh www.elibraryofcambodia.org

៨.មនសិការលក្ខណបញ្ហា សួរថាយោនិសោមនសិការនោះ មានលក្ខណៈយ៉ាងដូចម្តេច. . . . . . . . . . . . . . . . . . . . . . . . . . . ១៣៤
៩.សីលបតិដ្ឋានលក្ខណបញ្ហា សួរថាលក្ខណៈដែលនឹងបាននិព្វានមានអ្វីជាទីតាំង.. ១៣៦
១០.សទ្ធាលក្ខណបញ្ហា សួរថាសទ្ធាមានលក្ខណៈដូចម្តេច. . . . . . . . . . ១៤២
១១.វីរិយលក្ខណបញ្ហា សួរថាព្យាយាមមានលក្ខណៈដូចម្តេច . . . . . . . . . . ១៤៧
១២.សតិលក្ខណបញ្ហា សួរថាសតិមានលក្ខណៈដូចម្តេច . . . . . . . . . . . ១៥០
១៣.សមាធិលក្ខណបញ្ហា សួរថាសមាធិមានលក្ខណៈដូចម្តេច . . . . . . . . . ១៥៥
១៤.បញ្ញាលក្ខណបញ្ហា សួរថាបញ្ញាមានលក្ខណៈដូចម្តេច. . . . . . . . . . . ១៥៨
១៥.នានាឯកកិច្ចករណបញ្ហា សួរថាកុសលធម៌មានស្ថានផ្សេងគ្នា អោយសំរេចប្រយោជន៍ដូចគ្នាបានដែរឬ . . . . . . . . . . . . . . . . . . . ១៦១

## ទុតិយវគ្គ

១.ធម្មសន្តតិបញ្ហា សួរថាមនុស្សនិងសត្វ កាលដើមដំបូងកើតជាអ្វីប៉ុណ្ណោះ លុះដល់ធំពេញវ័យក្រៀងក្លាយទៅជាអ្វីទៀតឬ. . . . . . . . . . . . . . . . . . . ១៦៣
២.នប្បដិសន្ធិគណោបញ្ហា សួរថាអ្នកដែលមិនកើតទៀតដឹងខ្លួនឬទេ ថាយើងនឹងមិនកើតទៅទៀតដូច្នេះ. . . . . . . . . . . . . . . . . . . . . . ១៧១
៣.ញាណបញ្ញាបញ្ហា សួរថាញាណបង្កើតក្នុងសន្តានអ្នកណា អ្នកនោះបានកើតការបញ្ញា ឬអ្វី.. . . . . . . . . . . . . . . . . . . . . . . ១៧៤
៤.បរិនិព្វានបញ្ហា សួរថាអ្នកដែលមិនបានកើតទៀតនោះនឹងបានសោយទុក្ខ ឬមិនបានសោយទេ. . . . . . . . . . . . . . . . . . . . . . . ១៨៣
៥.សុខវេទនាបញ្ហា សួរថាសុខវេទនានឹងជាកុសលឬអកុសលឬថាជាអព្យាក្រឹត.. ១៨៧
៦.នាមរូបបដិសន្ធិគហណបញ្ហា សួរថាធម្មជាតិអ្វីអោយសត្វលោកកាន់យកនូវបដិសន្ធិ. . . . . . . . . . . . . . . . . . . . . . . . . . ១៩១
៧.បុនប្បដិសន្ធិគហណបញ្ហា សួរថាលោកម្ចាស់នឹងកាន់យកបដិសន្ធិ គឺនឹងកើតតទៅទៀតដែរ. . . . . . . . . . . . . . . . . . . . . . . . . ២០៤
៨.នាមរូបបញ្ហា សួរថានាមធម៌និងរូបធម៌ គឺអ្វី. . . . . . . . . . . . . . ២០៧
៩.ទីឃមទ្ធានបញ្ហា សួរថាកាលដែលវែងឆ្ងាយនាំអោយយឺតយូរនោះគឺអ្វី. . . . ២០៩

www.budinst.gov.kh www.elibraryofcambodia.org

# តតិយវគ្គ


១.អទ្ធានបញ្ហា សួរថាធម្មជាតិអ្វី ជាឫសនៃកាលដ៏ជាអតីតនឹងបច្ចុប្បន្ន នឹងអនាគត. . . . . . . . . . . . . . . . . . . . . . . . . . ២១០

២.បុរិមកោដិបញ្ហា សួរថាដែលពោលថាទីបំផុតខាងដើមមិនប្រាកដនោះ អាចតាំងពីកនាលរួចថយក្រោយទៅបានដល់អតីតកាលឬ. . . . . . . . . . . . . ២១៣

៣.កោដិយាបុរិមបញ្ហា សួរថាទីបំផុតខាងដើមនៃកាលដែលប្រាកដនោះដូចម្តេច..២២២

៤.សង្ខារជាយនបញ្ហា សួរថាសំខារធម៌ ធម្មជាតិអ្វី ដែលមាននៅនឹងបង្កើតឡើងទៀត. . . . . . . . . . . . . . . . . . . . . . . . . . . ២២៤

៥.ភវន្តានំសំខារបញ្ហា សួរថាសំខារខ្លះដែលមិនធ្លាប់កើតមាននឹងអាចកើតមានឡើងបាន ឬមិនបានទេ. . . . . . . . . . . . . . . . . . . . . ២៤៨

៦.វេទគូបញ្ហា សួរថាសភាវអ្វីដែលហៅថាវេទគូ . . . . . . . . . . . . . . . ២៣៩

៧.ចក្ខុវិញ្ញាណបនៅវិញ្ញាណបញ្ហា សួរថាចក្ខុវិញ្ញាណកើតក្នុងទីណា មនោវិញ្ញាណក៏តាមទៅកើតក្នុងទីនោះឬ . . . . . . . . . . . . . . . . . . . . ២៤៨

៨.ផស្សលក្ខណបញ្ហា សួរថាផស្សមានលក្ខណៈដូចម្តេច. . . . . . . . . . . . ២៥៦

៩.វេទនាលក្ខណបញ្ហា សួរថាវេទនាកាលកើតមានលក្ខណៈដូចម្តេច. . . . . . ២៦១

១០.សញ្ញាលក្ខណបញ្ហា សួរថាសញ្ញាកាលកើតមានលក្ខណៈដូចម្តេច. . . . . . ២៦៣

១១.ចេតនាលក្ខណបញ្ហា សួរថាចេតនាមានលក្ខណៈដូចម្តេច. . . . . . . . . . ២៦៥


www.budinst.gov.kh www.elibraryofcambodia.org

# ព្រះរាំពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ភះបេរ | ភរបេះ | ១២ | ១២ |
| ប្លេស | ខ្ទេស | ១៤ | ១៧ |
| ឧត្តរក្ខុរ | ឧត្តរកុរុទ្វីប | ២៦ | ១០ |
| ពះរើនាបានឡើយ | មិនអាចពណ៌នាបានឡើយ | ២២ | ៤ |
| ពត្រៈវត្រ | វត្រ | ២៣ | ៦ |
| បុប្ផបយោគ | បុព្វយោគ | ២៩ | ១ |
| សុខប | សុក្ខុប | ៣០ | ៥ |
| អភះភាគត | អនាគត | ៣០ | ១៤ |
| កាព្យឆ្លោង | កាព្យឃ្លោង | ៣២ | ៤ |
| អវិធិ | អវិធី | ៣៥ | ៥ |
| មិតវដ៏ថៃ | មិតរមិថៃ | ៣៨ | ១០ |
| កដង្កុរ | កជង្គរ | ៤៦ | ៦-១៦ |
| តាប្ញឹកប្ញ | តាបិធិកប្ញ | ៤៧ | ១១ |
| កដង្កុរ | កជង្គរ | ៤៩ | ៦ |
| នៅកាករ | នូវការ | ៥០ | ៨ |
| ឡូះ | ក៏ឡូស | ៥២ | ៤ |
| សិល្បសាស្ត្រ | សិល្បសាស្ត្រ | ៥២ | ៦ |
| កដង្កល | កជង្គល | ៥៤ | ១៣ |
| វត្តិបេណេ | វត្តិតលេណោ | ៦៣ | ១៧ |
| កន្លារេ | កណ្តាល | ៦៦ | ១៧ |
| ការកុសលៈ | ការកុសល | ៧៤ | ៨ |
| សំគាល់ថា | សំគ័លថា | ៧៦ | ៩ |
| ហេតុភន្តេ | ហ៉េតុភន្តេ | ៧៨ | ១៦ |
| បញ្ចនកាយិកោ | បញ្ចនិកាយិកោ | ៨៣ | ៤ |
| ព្រះភោបេនត្ស | ព្រះអេះភោភេនត្ស | ៨៤ | ១៦ |
| ធម្មចារិ | ធម្មចារី | ៨៥ | ១៣ |

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សបចារិ | សប្ឋចារិ | ៨៥ | ១៤ |
| សង្ឃបវត្តការ | សង្ឃបវត្តការ | ៨៩ | ១៥ |
| តប្ពីរបញ្ចោ | តប្ពីរបញ្ចោ | ៨៤ | ៩ |
| បដិសេធ | បដិសេធន៍ | ១១០ | ១២ |
| ព្រះនិព្វន | ព្រះនិព្វានះ ១ | ១១១ | ១៩ |
| គ្របប្រការ | គ្រប់ប្រការ ១ | ១១១ | ១១៥ |
| បនុស្សនិករ | បនុស្សនិករ | ១២០ | ៦ |
| ទេវនិករ | ទេវនិករ | ១២០ | ៦ |
| អរហត្ត | អរហត្ត | ១២៥ | ៧ |
| និភាសេត្វា | និភាសេត្វា | ១២៦ | ១៦ |
| អ្នកខ្លះ | អ្នកបួសពួកខ្លះ | ១៣០ | ១២ |
| សាក្យបុត្រ | សក្យបុត្រ | ១៣១ | ៦ |
| ថាជាពេក្ខុណោ | ជាបេក្ខុណោ | ១៣៤ | ៦ |
| ពាធុ | កព្លោសី | ១៣៩ | ១២ |
| ពាក្យលើសថាអ្នកដែល ។ល។ ព្រះនិព្វន | | ១៣៥ | ១៤ |
| សបប្បដ្ឋាន | សបប្បធាន | ១៣៦ | ១៥ |
| វិជជយេជជន្តិ | វិជជយេជជន្តិ | ១៤០ | ១៧ |
| បដហតី | បជហតិ | ១៤៨ | ៧ |
| គិថាសព្វ័បបង់ | គិជាកិរិយាសព្វ័បបង់ | ១៦១ | ១៣ |
| សត្វហានជើងពីរក៏ជា | សត្វហានជើងពីរក៏ក្លាយទៅជា | ១៦២ | ១៥ |
| ពេលព្រក | ពេលព្រឹក | ១៦៨ | ៥ |
| ក្សត្រធិរាជ | ក្សត្រាធិរាជ | ១៧៤ | ១ |
| បញ្ញាវា | បញ្ញវា | ១៧៤ | ១៤ |

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ចក្ខុំ | ចុក្ខំ | ១៧៩ | ១៦ |
| គណនា | គួរនា | ១៧៨ | ១០ |
| ឫស | ឫស | ១៨០ | ១០ |
| ប្រព្រិត | ប្រព្រឹត្ត | ១៨៤ | ១៣ |
| ហានបានយកឯណោ | មិនបានយកឯណា | ១៩៣ | ៨ |
| មិនបាន | មិនបានព្រោះ | ២០០ | ១២ |
| រំលាយខន្ធ | ទំលាយខន្ធ | ២០១ | ៩ |
| មិនហាននៅឡើយ | មិនហានឡើយ | ២១០ | ៩ |
| ប៉ះ | ប៉ុស | ២១៨ | ១០ |
| ប្រកង | ពង្កង | ២២៩ | ៦ |
| ដិកយកដី | ជីកយកដី | ២៣០ | ៩ |
| ត្រងពណើនា | ព្រងពណើនា | ២៣៧ | ៩ |
| បុក | ប៉ុះ | ២៤ | ៨ |
| សណ្ឋោ | សន្យា | ២៤៩ | ១០ |

ត្រង់ទំព័រ ១៥៣ បន្ទាត់ ១៧ នោះកែតម្រូវហើយ មិនបានដកសេចក្ដីដើមចេញដក ខាងក្បាលបន្ទាត់ផង ហើយត្រូវយកអក្សរ ( ន ) ចេញដាក់កន្លែងអក្សរ ( ប ) វិញ ។

www.budinst.gov.kh www.elibraryofcambodia.org

## សេចក្តីខាងមុខសៀវភៅ

សៀវភៅមិលិន្ទបញ្ហានេះ កើតឡើងក្នុងឆ្នាំថោះនពស័ក ពុទ្ធសករាជ ២៤៧០ វស្សា ត្រូវគ្នានឹងគ្រិស្តសករាជ ១៩២៧ ។

ឯគុណសម្បត្តិ ដែលនឹងអោយកើតឡើងជាសៀវភៅនេះនោះ គឺកើតដោយគុណ ៣ យ៉ាង គឺទីស្ថានព្រះរាជបណ្ណាល័យហោត្រៃនេះកើតឡើងជាប្រធានដើមហេតុ១ ដោយអ្នកគ្រប់គ្រងព្រះរាជស្ថាននោះត្រូវការប្រាថ្នានឹងអោយមានសៀវភៅបែបនេះឡើងនោះ ១ ដោយអ្នកដែលទទួលភារជាអ្នកពាក់តែងរៀបរៀងសៀវភៅក្នុងព្រះរាជមន្ទីរនោះ ពេញចិត្តនឹងរាថិប្រាថ្នាក្នុងគម្ពីរមិលិន្ទបញ្ហានោះ ១ លុះសម្បត្តិទាំង ៣ ប្រការនេះ មកជុំគ្នាវេលាណា ក៏បណ្តាលអោយផ្តួចផ្តើមកើតឡើងប្រាកដជារូបជានាមសៀវភៅនេះបាន ។

ឯអ្នករក្សាព្រះរាជបណ្ណាល័យនោះបានជាមានប្រាថ្នាចង់អោយកើតសៀវភៅមិលិន្ទបញ្ហានេះ ជាពាក្យសម្រាយខ្មែរសម្រាប់ជាតិអ្នកស្រុកខ្មែរនេះនោះព្រោះបានឃើញបានដឹងថាគម្ពីរមិលិន្ទបញ្ហានេះជាគម្ពីរបំភ្លឺសេចក្តីដល់អ្នកកាន់ពុទ្ធសាសនា

www.budinst.gov.kh www.elibraryofcambodia.org

អោយឆាប់ចូលចិត្តស្តាប់បានដោយងាយ ព្រោះគម្ពីរនោះមានពាក្យបុប្ផាវិសជ្ជនា ចោទន៍ឆ្លើយ វិនិច្ឆ័យសេចក្តីកង្ខាសង្ស័យស្រេចៗ ក្នុងនោះស្រាប់មិនបាច់ព្រួយពីពអោយយឺតយូរពេលឡើយហើយបានដឹងថា ពួកអ្នករៀនពុទ្ធសាសនាក្នុងប្រទេសទាំងឡាយដទៃក៏គេតែងមានសៀវភៅបែបនេះ ស្ទើរតែនឹងគ្រប់ស្រុករស់ហើយពីជាសៀវភៅបោះពុម្ពសម្រាយសម្រាប់ជាតិរបស់គេ ដូចយ៉ាងស្រុកចិនគេបានប្រែសេចក្តីក្នុងគម្ពីរមិលិន្ទបញ្ហា ដែលជាភាសាសំស្ក្រឹត ឬភាសាប្រក្រិតចេញមកជាភាសាចិន ទុកសម្រាប់ស្រុកគេ តាំងពីរវាងពុទ្ធសករាជ ១២៤៣ នឹង ១៧៤៣នៅមានរហូតដល់មកសព្វថ្ងៃនេះ ឯសេចក្តីមិលិន្ទបញ្ហារបស់អ្នកប្រាជ្ញចិននោះ ហើយនឹងមិលិនបញ្ហាដែលជាភាសាបាឡីនេះមានសេចក្តីប្រហែល ៗ.គ្នា មានប្លែកគ្នាបន្តិចបន្តួចតែត្រង់របៀបរៀបរៀងខ្លះប៉ុណ្ណោះ ទោះបីស្រុកអឺរុប ដូចយ៉ាងស្រុកអង់គ្លេស បារាំងសេស ក៏មានបរិបូរណ៍ឬទាំងស្រុកយ៉ាងជិតបន្ទាប់គ្នានឹងស្រុកខ្មែរយើងនេះគឺស្រុកសៀមនោះឯងក៏គេមានសៀវភៅបោះពុម្ពបែបនេះជាសម្រាយយម្រាប់ជាតិរបស់គេយូរយារណាស់មកហើយ ក៏ឃើញនៅតែស្រុកខ្មែរយើងនេះ មិនទាន់មានសៀវភៅនេះ

www.budinst.gov.kh www.elibraryofcambodia.org

បោះពុម្ពជាសម្រាយនៅឡើយ. ឃើញមានតែសម្រាយដែលចារឹកនឹងស្លឹករឹតហើយនឹងបាឡីសុទ្ធផងឃើញថាជាការលំបាកនឹងបានមើលរាល់គ្នាអោយចេះដឹងឆាប់ណាស់ ។

ម៉្យាងទៀតអ្នកប្រាជ្ញទាំងឡាយ ដែលលោកចេះដឹងភាសាច្រើន មានភាសាបាឡី និង សំស្ក្រឹតជាដើម លោកបានពិនិត្យមើលប្រស្នាធម៌អាថ៌ក្នុងគម្ពីរនេះទៅ ក៏ឃើញថាជារបស់រុងរឿងថ្លៃថ្លាមានដំឡៃពេកណាស់ គួរតែអោយមានជាសៀវភៅសម្រាយបោះពុម្ពឡើង ។

ក៏ជំនុំគម្ពីរទាំងឡាយក្នុងពុទ្ធសាសនានេះ ដែលជាគម្ពីរកើតខាងក្រោយគម្ពីរនិកាយទាំង ៥ នោះ នឹងរកគម្ពីរណាអោយមានសេចក្តីធម៌អាថ៌ពិតប្រាកដដូចគម្ពីរនេះពុំមាន មានតែគម្ពីរ ២ ទៀត ដែលកើតក្រោយគម្ពីរនេះ គឺគម្ពីរវិសុទ្ធិមគ្គដែលជាស្នាដៃព្រះពុទ្ធឃោសាចារ្យ លោកបានរៀបរៀង ១ នឹងគម្ពីរព្រះអភិធម្មត្ថសង្គហ ដែលជាស្នាដៃព្រះអនុរុទ្ធាចារ្យលោកបានតាក់តែងនោះ ១ ទើបមានសេចក្តីជ្រាលជ្រៅយ៉ាងសុខុម ជាគម្ពីរភាព គួរនឹងអោយស្ងើចអោយសរសើរនូវធម៌អាថ៌ក្នុងគម្ពីរនោះ ព្រមទាំងរបៀបរៀបបាឡីនោះ ក៏ឥតទាស់

www.budinst.gov.kh www.elibraryofcambodia.org

អោយឆាប់ចូលចិត្តស្តាប់បានដោយងាយ ព្រោះគម្ពីរនោះមាន ពាក្យបុច្ឆាវិសជ្ជនា ចោទន៍ឆ្លើយ វិនិច្ឆ័យសេចក្តីកង្ខាសង្ស័យ ស្រេច១ ក្នុងនោះស្រាប់មិនបាច់ព្រួយពីតអោយយឺតយូរពេល ឡើយហើយបានដឹងថា ពួកអ្នករៀនពុទ្ធសាសនាក្នុងប្រទេស ទាំងឡាយដទៃក៏គេតែងមានសៀវភៅបែបនេះ ស្ទើរតែនឹង គ្រប់ស្រុករស់ហើយពីជាសៀវភៅបោះពុម្ពសម្រាយសម្រាប់ ជាតិរបស់គេ ដូចយ៉ាងស្រុកចិនគេបានប្រែសេចក្តីក្នុងគម្ពីរ មិលិន្ទបញ្ហា ដែលជាភាសាសំស្រ្កឹត ឬភាសាប្រក្រិតចេញមក ជាភាសាចិន ទុកសម្រាប់ស្រុកគេ តាំងពីរវាងពុទ្ធសករាជ ១២៤៣ នឹង ១៧៤៣នៅមានរហូតដល់មកសព្វថ្ងៃនេះ ឯ សេចក្តីមិលិន្ទបញ្ហារបស់អ្នកប្រាជ្ញចិននោះ ហើយនឹងមិលិន បញ្ហាដែលជាភាសាបាឡីនេះមានសេចក្តីប្រហែល ៗ គ្នា មាន ប្លែកគ្នាបន្តិចបន្តួចតែត្រង់របៀបរៀបរៀងខ្លះប៉ុណ្ណោះ ទោះ បីស្រុកអឺរុប ដូចយ៉ាងស្រុកអង់គ្លេស បារាំងសេស ក៏មាន បរិបូរណ៍ឬទាំងស្រុកយ៉ាងជិតបន្ទាប់គ្នានឹងស្រុកខ្មែរយើងនេះ គឺស្រុកសៀមនោះឯងក៏គេមានសៀវភៅបោះពុម្ពបែបនេះជា សម្រាយម្រាប់ជាតិរបស់គេយូរយារណាស់មកហើយ ក៏ ឃើញនៅតែស្រុកខ្មែរយើងនេះ មិនទាន់បានសៀវភៅនេះ

www.budinst.gov.kh www.elibraryofcambodia.org

បោះពុម្ពជាសម្រាយនៅឡើយ ឃើញមានតែសម្រាយដែលចារឹកនឹងស្លឹករិតហើយនឹងបាឡីសុទ្ធផងឃើញថាជាការលំបាកនឹងបានមើលរាល់គ្នាអោយចេះដឹងឆាប់ណាស់ ។

ម៉្យាងទៀតអ្នកប្រាជ្ញទាំងឡាយ ដែលលោកចេះដឹងភាសាច្រើន មានភាសាបាឡី និង សំស្ក្រឹតជាដើម លោកបានពិនិត្យមើលប្រស្នាធម៌អាថ៌ក្នុងគម្ពីរនេះទៅ ក៏ឃើញថាជារបស់រុងរឿងថ្លៃថ្លាមានដំឡៃពេកណាស់ គួរតែអោយមានជាសៀវភៅសម្រាយបោះពុម្ពឡើង ។

ក៏ជំនុំគម្ពីរទាំងឡាយក្នុងពុទ្ធសាសនានេះ ដែលជាគម្ពីរកើតខាងក្រោយគម្ពីរនិកាយទាំង ៥ នោះ នឹងរកគម្ពីរណាអោយមានសេចក្តីធម៌អាថ៌ពិតប្រាកដដូចគម្ពីរនេះពុំមាន មានតែគម្ពីរ ២ ទៀត ដែលកើតក្រោយគម្ពីរនេះ គឺគម្ពីរវិសុទ្ធិមគ្គដែលជាស្នាដៃព្រះពុទ្ធឃោសាចារ្យ លោកបានរៀបរៀង ១ នឹងគម្ពីរព្រះអភិធម្មត្ថសង្គហ ដែលជាស្នាដៃព្រះអនុទ្ធាចារ្យលោកបានតាក់តែងនោះ ១ ទើបមានសេចក្តីជ្រាលជ្រៅយ៉ាងសុខុម ជាគម្ពីរភាព គួរនឹងអោយស្ញើចអោយសរសើរនូវធម៌អាថ៌ក្នុងគម្ពីរនោះ ព្រមទាំងរបៀបរៀបបាឡីនោះ ក៏ឥតទាស់

www.budinst.gov.kh www.elibraryofcambodia.org

ខុសអ្វីឡើយ ហេតុនេះហើយបានជាអ្នករក្សាព្រះរាជបណ្ណាល័យប្រាថ្នាអោយកើតឡើងជាសៀវភៅនេះ ។

ម្យ៉ាងទៀត លោកដែលទទួលភារជាអ្នករៀបរៀងសៀវភៅ នឹងផ្ទៀងផ្ទាត់ធម៌វិនាទិក្នុងសាលាហៅត្រៃព្រះរាជបណ្ណាល័យកម្ពុជានោះសោត លោកក៏គាប់អធ្យាស្រ័យនឹងសេចក្តីធម៌ក្នុងគម្ពីរនេះពេកណាស់ លោកតែងនឹងសំដែងសរសើរនូវគុណធម៌ក្នុងគម្ពីរនេះថា ជាធម៌មានប្រយោជន៍ធំដល់អ្នកកាន់ពុទ្ធសាសនាប្រហែល ១ គ្នា នឹងគម្ពីរវិសុទ្ធិមគ្គហើយនឹងគម្ពីរអភិធម្មត្ថសង្គហនោះដែរ លោកមិនគ្រាន់តែគាប់អធ្យាស្រ័យទទេប៉ុណ្ណោះឡើយ គឺលោកបានទាំងរៀបរៀងសេចក្តីធម៌អាថិក្នុងគម្ពីរព្រះវិសុទ្ធិមគ្គត្រង់សមថកម្មដ្ឋានភាវនានោះជាសៀវភៅ ១ ឈ្មោះថាសមាធិនិទ្ទេសគឺជាសៀវភៅសរសេរដែមិនទាន់បានបោះពុម្ពនៅឡើយ ដោយមិនទាន់មានឱកាសល្មមនឹងឡើងកាន់ពុម្ពបានហើយ បានទាំងរៀបរៀងសេចក្តីក្នុងគម្ពីរព្រះអភិធម្មត្ថសង្គហ ជាសេចក្តីសម្រាយឈ្មោះថាសៀវភៅអភិធម្មត្ថសង្គហដូចឈ្មោះដើមនោះ ១ផងជាបន្ទាល់នៃសេចក្តីពេញចិត្តរបស់លោក គួរតែអោយយើងឃើញថាមែនផង ហើយសៀវភៅអភិធម្មត្ថសង្គហនោះបានលើកឡើងកាន់ពុម្ពហើយជាស្រេច ក្នុងពុទ្ធសករាជ ២៤៦៩

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវគ្នានឹងគ្រិស្តសករាជ ១៩២៦ ។

ក្នុងទីបញ្ចប់សេចក្តីនេះ សូមថ្វាយព្រះរាជកុសលដែលកើតអំពីធម្មទាននេះ ចំពោះព្រះករុណាជាម្ចាស់ជីវិតព្រះចៅក្រុងកម្ពុជា នឹងឧទ្ទិស្សកុសលសម្ភារនេះជូនដល់ទៅមហានគរក្រុងបារាំងសេស អោយបានសេចក្តីចំរើនរុងរឿងគ្រប់យ៉ាងតទៅ ។

ព្រះរាជបណ្ណាល័យកម្ពុជាក្រុងភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

## សេចក្តីផ្តើម

គម្ពីរមិលិន្ទបញ្ហានេះកើតឡើងក្នុងពុទ្ធសករាជប្រមាណ ៥០០ឆ្នាំ ព្រះគន្ថរចនាចារ្យដែលជាអ្នកតាក់តែងនោះ មាននាមបញ្ញត្តិថា បិដកចុឡាភយថេរនៅស្រុកមជ្ឈិមប្រទេស គឺស្រុកឥណ្ឌាសព្វថ្ងៃនេះ លោកមានប្រាថ្នានឹងកំចាត់បង់នូវសេចក្តីសង្កាក្នុងធម៌វិន័យក្នុងពុទ្ធសាសនា មិនអោយមានសង្ស័យតទៅទើបលោកចាប់យករឿងនិទានជាអតីតវត្ថុ របស់ព្រះនាគសេនថេរ ដែលបានវិសជ្ជនាដោះប្រស្នាព្រះបាទមិលិន្ទរាជមកតាំងទុកជាគោលដើម ហើយទើបលោកជ្រើសរើសសេចក្តីក្នុងធម៌វិន័យដែលជាពាក្យស្នួកស្នាញ សឹកសៀតចង្អៀតអ្នកទាំងពួងនឹងចូលចិត្តបាន នោះមកអធិប្បាយតាមការចេះដឹងរបស់លោកដើម្បីជាប្រយោជន៍ដល់សាមញ្ញជនជាខាងក្រោយអោយយល់ធម៌វិន័យនោះច្បាស់លាស់ឡើង ។

ម្យ៉ាងទៀតឯរបៀបរៀបរៀងសេចក្តីក្នុងសៀវភៅនេះ នោះមានរបៀបបែបបំព្រួញពីរយ៉ាង គឺបំព្រួញសេចក្តីនិងបំព្រួញឈ្មោះ ឯបំព្រួញសេចក្តីនោះ បើសេចក្តីត្រង់ណា

www.budinst.gov.kh www.elibraryofcambodia.org

ដែលសៅដដែល ៗ ប្រហែលគ្នាដូចពាក្យដែលព្រះបាទមិលិន្ទ សួរពីអាការ ៣២ ជាដើម បានយកមកសំដែងតែ ៤.៥ បទ ហើយប្រាប់ថាដូចគ្នាមិនបាច់សំដែងគ្រប់ឡើយ ។ ឯបំព្រួញ ឈ្មោះនោះបើឈ្មោះណាដដែល ៗ ប្រហែលគ្នាដូចជាឈ្មោះ ថា មិលិន្ទរាជ និង ឈ្មោះថាព្រះនាគសេនថេរ មិនបានយកបា ឡីពេញឈ្មោះមកដាក់គ្រប់ពាក្យដែលសួរ និងពាក្យឆ្លើយទាំង អស់គ្រប់អន្លើទេ បានយកមកដាក់តែត្រង់បទសួរ និងឆ្លើយ ខាងដើមនៃប្រស្នានិមួយ ៗ គ្រប់ប្រស្នាទាំងអស់ ឯពាក្យសួរ ជាលំដាប់គ្នាទៅនោះ មិនបានដាក់ឈ្មោះពេញ គឺដាក់ឈ្មោះ បំព្រួញដូចឈ្មោះថា មិលិន្ទដាក់តែម.ប៉ុណ្ណោះ ឈ្មោះថានាគ សេនដាក់តែន.ប៉ុណ្ណោះ ម.គឺមិលិន្ទ ន.គឺនាគសេន គ្រាន់ជាទី សម្គាល់ដើម្បីជាប្រយោជន៍ដល់អ្នកមើល អោយឆាប់បាន សេចក្តីច្រើន ហើយកុំអោយនឿយថាដដែល ៗ ផង ។

ព្រះគ្រូវិមលបញ្ញា អ៊ុំ_ស៊ូរ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org



## មិលិន្ទបញ្ហោ

បណាមគាថា

ចរិយាសព្វលោកស្ស ហិតាយស្សមហេសិនោ
វរចិន្តុប្បានុភាវិបិ វន្ទេលោកគ្គនាយកំ
វិជ្ជាចរណសម្បន្នោ យេននីយន្តិលោកតោ
វន្ទេតម្ពុត្តមំធម្មំ សម្មាសម្ពុទ្ធបូជិតំ
សីលាទិគុណសម្បន្នោ ឋិតោមគ្គផលេសុយោ
វន្ទេអរិយសំឃន្តំ បុញ្ញក្ខេត្តមនុត្តរំ
វន្ទនាជនិតំបុញ្ញំ ឥតិយំរតនត្តយំ
ហតន្ត(១) រាយោសព្វេ ហុត្វាហន្តស្សតេជសា
យំមិលិន្ទបករណំ បុច្ឆព្យាករណសដ្ឋិតំ
សុណោថនិបុណោបញ្ហោ តំសុខាយេភវិស្សតីតិ

ប្រែសេចក្តីក្នុងប្រយោគគាថា

ចរិយាសព្វលោកស្ស ហិតាយស្សមហេសិនោ

---

(១)_ក្បាប់ខ្លះថានបស្សមេរៀនបស្សហានោបុញ្ញាភិសង្ខារបុបំររលេច្ឆំពស្សានុភា

www.budinst.gov.kh www.elibraryofcambodia.org

អចិន្តយានុភាវិបិ វន្ទេ លោកគ្គនាយកំ

វិរានុភាពនៃហេតុជាទីបំផុត គំនិតនៃព្រះបរមលោកនាថអង្គណាដែលជាអ្នកដឹកនាំនូវវេនេយ្យសត្វអោយចូលទៅកាន់សិវស្ថាន គឺព្រះនិព្វាន ជាអ្នកស្វែងរកនូវគុណមានសីលគុណជាដើម ដើម្បីប្រព្រឹត្តអោយជាផលជាប្រយោជន៍ ដល់សកលលោកទាំងអស់ ខ្ញុំសូមប្រណម្យករថ្វាយបង្គំនូវព្រះបរមលោកនាថអង្គនោះ ព្រោះជាអ្នកនាំផ្លូវយ៉ាងខ្ពង់ខ្ពស់បំផុត ។

វិជ្ជាចរណសម្បន្នោ យេននីយន្តិលោកតោ

វន្ទេតមុត្តមំធម្មំ សម្មាសម្ពុទ្ធពូជិតំ

ព្រះបរមលោកនាថដែលជាកំពូលនៃសត្វ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និង ចរណឬថាព្រះអង្គ ប្រកបដោយចំណេះចេះដឹងនឹងសេចក្តីប្រព្រឹត្តត្រឹមត្រូវយ៉ាងវិសេស ទ្រង់នាំសត្វវេនេយ្យនិករអោយឆ្លងចាកត្រៃលោក ទៅកាន់ទីឧត្តមស្ថានគឺព្រះនិព្វាន ដោយព្រះនព្វលោកុត្តរធម៌នឹងព្រះបរិយត្តិធម៌ឯណា ខ្ញុំសូមនមស្សការចំពោះនូវព្រះធម៌ទាំងនោះ ដែលព្រះសម្មាសម្ពុទ្ធបរមបពិត្រទ្រង់ធ្វើសក្ការបូជាគ្រប់ ៗ ព្រះអង្គពុទ្ធមក ។

www.budinst.gov.kh www.elibraryofcambodia.org

សីលាទិគុណសម្បន្នោ ឋិតោមគ្គផលេសុយោ

វន្ទេ អរិយសំឃន្តំ បុញ្ញក្ខេត្តមនុត្តរំ

ព្រះអរិយសំឃអង្គណា ប្រកបដោយគុណមានសីលគុណេជាដើមស្ថិតនៅក្នុងមគ្គនឹងផលទាំងឡាយ ខ្ញុំសូមប្រណេបនូវព្រះអរិយសំឃអង្គនោះ ដ៏ជាស្រែបុណ្យវិសេស រកស្រែដទៃស្មើគ្មាន

វន្ទនាជនិតំបុញ្ញំ ឥតិយំរតនត្តយំ

ហាតន្តរាយោសព្វេ ហុត្វាហន្តស្សតេជោសា

បុញ្ញរាសីរបស់ខ្ញុំ ដែលកើតឡើងអំពីកិរិយាថ្វាយបង្គំចំពោះព្រះរត្នត្រ័យឯណា សេចក្តីអន្តរាយទាំងអស់ចូលវិនាសសាបសូន្យទៅដោយតេជានុភាព នៃព្រះរត្នត្រ័យនោះកុំបីអោយខានឡើយ

យំមិលិន្ទុបករណំ បុព្ពព្យាករណសជ្ឈិតំ

សុណាថនិបុណោបព្ហោ តំសុខាយភវិស្សតិ

www.budinst.gov.kh www.elibraryofcambodia.org

រីគម្ពីរមិលិន្ទបញ្ហាឯណា ដែលព្រះគន្ថរចនាចារ្យបានតាក់តែងពាក្យបុច្ឆានិងពាក្យវិសជ្ជនារបស់ស្តេចមិលិន្ទ្រាធិបតីនឹងព្រះនាគសេនថេរ អ្នកទាំងឡាយចូលប្រុងស្តាប់នូវពាក្យចោទន៍នឹងពាក្យឆ្លើយក្នុងគម្ពីរមិលិន្ទបញ្ហានេះ ដោយបរិបូណ៌ចុះ និង នាំមកនូវសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការ ទៅហោង ។

## ពាហិរកថា

កាលព្រះគន្ថរចនាចារ្យ ដែលមាននាមថា ពិបិដកចុឡាភយថេរបានធ្វើសេចក្តីនមស្សការយ៉ាងនេះហើយទើបលោកតាំងផ្តើមសេចក្តីជាបាលីមកតាំងទុកជាខាងដើមថា តេនខោ បនសមយេនភគវា បរិនិព្វានសមយេ កុសិនារាយំ-គន្ត្វាមហតាភិក្ខុសំឃេនសទ្ធឹ ។

សេចក្តីថាក្នុងសម័យ ១នោះ ព្រះសម្មាសម្ពុទ្ធដ៏ទ្រង់ព្រះភាគកាលដែលព្រះអង្គនឹងចូលបរិនិព្វាននោះ ក៏ទ្រង់គមនាការទៅកាន់ក្រុងកុសិនារាបុរី ១ អន្លើ ដោយភិក្ខុសំឃច្រើនរូប លុះដល់ទៅទីនោះហើយ ទើបទ្រង់ចូលទៅអាស្រ័យនូវព្រះរាជឧទ្យាន នៃស្តេចមល្លរាជទាំងឡាយ ដែលនៅក្នុងក្រុងកុសិនារារាជធានីនោះ ក្នុងវេលានោះព្រះដ៏មានបុណ្យទ្រង់ធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីសំវេគអោយកើតឡើងដល់សត្វទាំងឡាយ ដោយធម៌មានអនិច្ចាទិលក្ខណជាដើម ហើយទ្រង់សំដែងនូវអាការនៃព្រះនិព្វាន ដោយនិព្វានធាតុដ៏វិសេសសល់នៃកិលេសតិចតួចមិនមាន ទ្រង់ផ្ទំលើក្រឡាព្រះបន្ទំជាទីបរិនិព្វាន ទ្រង់បែរព្រះសិរសិទៅទិសខាងជើង ក្រោមលង្វែករវាំងទាំងគូនៅទៀបមាត់ស្ទឹងនៃស្ដេចមល្លរាជទាំងឡាយ ដែលសោយរាជនៅក្រុងកុសិនារារាជបុរី តែថាសម្ដេចព្រះមហាករុណាស្ដេចទ្រង់ប្រកបដោយពុទ្ធអធ្យាស្រ័យជាយ៉ាងច្រើន ព្រោះថាព្រះអង្គទ្រង់នឹងដំរង់ចូលទៅផ្ទំ លើទីបញ្ចូសនរបស់ស្ដេចមល្លរាជពេលម្ដងនោះក៏ទេ គឺព្រះអង្គបានត្រាសប្រើព្រះអានន្ទអោយចូលទៅថ្វាយព្រះពរដល់ស្ដេចមល្លរាជជាមុន ហើយទើបស្ដេចទាំងនោះមកក្រាបបង្គំទូលអារាធនា សូមអោយព្រះអង្គទ្រង់ធ្វើនូវសេយ្យាសននៅទីនោះ លុះព្រះអង្គទទួលបានទីនោះហើយ ទើបទ្រង់មានពុទ្ធភាសិតត្រាស់ចំពោះទៅនឹងភិក្ខុសំឃទាំងពួងថា អាមន្តយាមិវោភិក្ខវេបដិវេទយាមិវោភិក្ខវេ សព្វសំខារាខយវយធម្មា អប្បមាទេនសម្បាទេថ ។

សេចក្ដីថាម្នាលភិក្ខុទាំងឡាយ តថាគតនឹងផ្ដាំនូវអ្នកទាំងឡាយថា នៃអ្នកទាំងឡាយ តថាគតនឹងរំឭកអ្នកទាំងឡាយអោយដឹងរាល់គ្នាថា សំខារធម៌ទាំងឡាយ គឺបុញ្ញាភិសំខារ

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកខាងកុសលធម៌ដែលតាក់តែងរូបរាងចិត្តចេតនារបស់មនុស្ស និងទេវតាអោយកើតក្នុងសុគតិភព គឺស្ថានសួគ៌ទាំង៦ជាន់ ហើយនិងជាមនុស្សដែលបរិបូណ៌ដោយរូបឆោម មិនរីកលរីការក្តីអបុញ្ញាភិសំខារចំណែកខាងអកុសលធម៌ដែលតាក់តែងរាងកាយនឹងចិត្តចេតសិកររបស់សត្វ អោយកើតក្នុងអបាយភូមិក្តីអនេញ្ជាភិសំខារ ចំណែកខាងរូបាវចរកុសល និងអរូបាវចរកុសលតាក់តែងជាតិកំណើតរបស់សត្វ ដែលបានរូបឈាន និងអរូបឈានអោយកើតក្នុងរូបព្រហ្មនិងអរូបព្រហ្មក្តី បណ្តាធម៌ទាំងឡាយនោះក៏មានតែកើតឡើងហើយនឹងវិនាសទៅជាធម៌នៀមធម្មតា រកទៀង រកប្រាកដគ្មានឡើយ តែងប្រែប្រួលទៅតាមពេលវេលាជាអនិច្ចំ ទុក្ខំ អនត្តា ហេតុយ៉ាងនេះហើយត្រូវអ្នកទាំងឡាយរាល់គ្នាចូលញុំាងអប្បមាទធម៌ គឺសេចក្តីមិនធ្វេសប្រហែស មិនភ្លេចស្មារតីនោះ អោយបរិបូណ៌ក្នុងសន្តានចិត្តគ្រប់រូបរាល់គ្នាត្រូវឧស្សាហ៍ខំដុសខាត់ចិត្តអោយបានផូរផង់ជ្រះថ្លា ចំរើនមេត្តាភាវនា កុំប្រមាទឡើយ កាលសម្តេចព្រះទសពលញាណ ទ្រង់ត្រាស់ប្រកាសផ្តែផ្តាំប្រៀនប្រដៅភិក្ខុសំឃ អោយតាំងសតិបញ្ញាជាធម្មសំវេគដូចនេះហើយ ភិក្ខុសំឃដែលមានចិត្តជាលោកិយនៅឡើយនោះក៏នឹងរាពទទួលនូវសេចក្តីសោកវាល័យចំពោះអង្គព្រះ

www.budinst.gov.kh www.elibraryofcambodia.org

បរមសាស្តានោះពុំបានឡើយ តែភ្នកនឹកដល់ឱវាទព្រះបរមគ្រូវេលាណាហើយ ក៏កើតសេចក្តីក្តួលក្តៅរន្ធត់ក្នុងឱរាហ្ងរហៀរទាំងទឹកភ្នែកស្រែកទ្រហោយំតាមធម្មតានៃខ្លួនជាបុថុជ្ជន តែរាល់ៗគ្នា ទើបសម្តេចព្រះវិជិតមារក៏ទ្រង់ត្រាស់ទេសនា រំលឹកដះទៀនសតិបញ្ញាថា នៃភិក្ខុសំឃទាំងឡាយ ប្រហែលជាអ្នករាល់គ្នាគិតស្មានថា កាលណាបើតថាគតបរិនិព្វានទៅហើយសមនឹងរកគ្រូអាចារ្យប្រៀនប្រដៅគ្មាន មិនមែនដូចនោះទេអ្នកតុម្ហាកំនវង្គជិនសាសនានិមយាបញ្ញត្តានិ(ល) សោមមច្ចយេនវោសត្ថា ។ ជិនសាសនាមានអង្គ ៩ ប្រការ ដែលតថាគតបានបញ្ញត្តិទុកហើយក្តី បាដិមោក្ខទាំង ២ប្រការ គឺភិក្ខុបាដិមោក្ខ និង ភិក្ខុនីបាដិមោក្ខ ដែលតថាគតបានប្រញប្តិទុកដល់អ្នកទាំងឡាយក្នុងគម្ពីរឱភតោវិភង្គនោះក្តី ហេតុដែលមានទោស និង ហេតុដែលឥតទោស ដែលតថាគតបានប្រកាសប្រាប់អ្នកទាំងឡាយក្តី សាវកបារមីញាណ ដែលតថាគតបានពោលហើយក្តី ញាណដែលដល់ព្រម គឺបច្ចេកពោធិបារមីនឹងសម្មាសម្ពោធិបារមី ដែលតថាគតបានសរសើរហើយក្តីសម្មប្បធាន ៤ ប្រការ អរិយសច្ច ៤ ប្រការ ពោជ្ឈង្គ ៧ប្រការបដិច្ចសមុប្បាទមានអង្គ ១២ ប្រការ សតិបដ្ឋាន ៤ ប្រការ មគ្គប្រកបដោយអង្គ ៨ ប្រការ ដ៏ប្រសើរផល ៧ ប្រការ

www.budinst.gov.kh · www.elibraryofcambodia.org

សមាបត្តិ ៨ ប្រការសមាបត្តិ ៩ ប្រការ ដែលតថាគតបាន សំដែងទុកហើយក្តីម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណាដែលជាអ្នក មានប្រតិពលយល់ភ្លាសក្នុងគុណធមិទាំងនោះ ភិក្ខុនោះ ហើយបានឈ្មោះថាសាវគនៃតថាគត ជាអ្នកឆ្លៀវឆ្លាសវាង វៃមានធមិមាំមួន ម្យ៉ាងទៀតធមិឯណាក្តី វិន័យឯណាក្តី ដែលតថាគតបានទេសនាហើយ បានព្រញប្តិហើយ ធមិ និង វិន័យទាំងនោះហើយ និងជាសាស្តា ជាគ្រូ នៃអ្នកទាំងឡាយ ក្នុងកាលដែលអំណើសផុតពីតថាគតទៅ ហេតុដូចនោះចូល អ្នកទាំងឡាយកុំបីឱ្យកខ្សូលអួលអន់ អាលោះអាល័យផល់ តថាគតពេកឡើយ ។

១ ទៀត កាលបើតថាគតបរិនិព្វានទៅបន្តិចហើយ អរិ យកស្សប នឹងរំឭកនូវពាក្យអាក្រក់របស់ភិក្ខុម្នាក់បួសខាង ឯ ចាស់ឈ្មោះថាសុភទ្ទហើយនឹងធ្វើនូវបឋមសង្គាយនាគីផ្សៀង ផ្ទាត់នូវធមិនឹងវិន័យជាដំបូងអោយត្រូវគ្នាជាបែប ១ ជំរះ សំអាតនូវពុទ្ធភាសិតទាំងអស់ របស់តថាគតអោយបានស្អាតភ្លឺ រុងរឿងឡើង ។ ខាងមុខអំពីឆ្នាំដែលអរិយកស្សប ធ្វើបឋម សង្គាយនានោះ ពុទ្ធសាសនកាលកន្លងទៅបាន ១០០ ឆ្នាំទៀត មានថេរអង្គមួយឈ្មោះថា យស្សកាកណ្ឌបុត្រ បានញាំញីនូវ ពាក្យនៃវជ្ជិបុត្តកភិក្ខុទាំងឡាយហើយធ្វើទុតិយសង្គាយនា ពី

www.budinst.gov.kh www.elibraryofcambodia.org

ផ្សៀងផ្ទាត់ពុទ្ធវចន គឺព្រះត្រ័យបិដកជាគំរប់ពីរអោយត្រឹមត្រូវ ដូចកាលធ្វើបឋមសង្គាយនានោះវិញ ។ តពីបឋមសង្គាយនានោះមក ពុទ្ធសាសនកាលកន្លងទៅបាន ២១៨ឆ្នាំ មានថេរអង្គ ១ ទៀត មាននាមបញ្ញត្តិថាមោគ្គលិបុត្តតិស្ស បានទំលាយនូវវាទ គឺពាក្យពោលនៃតិរ្ថិកដ៏ទៃ ហើយបានធ្វើតតិយសង្គាយនា គឺកិរិយាជំរះសំអាតនូវព្រះត្រ័យបិដកជាគំរប់បីគ្រា អោយបានត្រឹមត្រូវដូចកាលធ្វើបឋមសង្គាយនានោះឯង ។ លុះកន្លងកាលបន្តិចអំពីធ្វើតតិយសង្គាយនានោះ មានភិក្ខុអង្គ ១ ឈ្មោះថា មហាមហិន្ទបានទៅប្រតិស្ឋានព្រះពុទ្ធសាសនារបស់ពងាគតក្នុងតាម្ពបណ្ណិទ្វីប គឺកោះលង្កា ។ តពីនោះទៅពុទ្ធសាសនកាលបាន ៥០០ ឆ្នាំ រាប់អំពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធបរិនិព្វាននោះ មានមហាក្សត្រអង្គ ១ នាមថា មិលិន្ទរាជមានអភិនិហារ បានសាងសន្សំច្រើនមកហើយ ក៏ញុំាងសុខុមបញ្ហា គឺប្រស្នាដ៏ល្អិតអោយកើតឡើងដោយកំលាំងនៃបញ្ញារបស់ខ្លួន ហើយញុំាញីនូវពួកសមណនឹងព្រាហ្មណ៍ ក្នុងជម្ពូទ្វីបទាំងមូលនេះដោយសុខុមបញ្ហានោះ ។

ក្នុងគ្រានោះឯង មានភិក្ខុអង្គ១ ឈ្មោះថានាគសេន បានកំចាយទំលាយនូវវាទរបស់ស្តេចនោះ ហើយធ្វើមហាក្សត្រអង្គនោះ អោយរីករាយដោយពាក្យឧបមានុបមេយ្យយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ច្រើន ហើយធ្វើនូវសាសនាពថាគតមិនអោយមានទោសសៅហ្មងឡើយ បានទាំងប្រតិស្ឋានព្រះពុទ្ធសាសនាអោយតាំងនៅមាំមួនគ្រប់ទាំង ៥០០០ វស្សា ។

ឯស្ដេចមិលិន្ទ និង ព្រះនាគសេននេះ មានពុទ្ធទំនាយទាយទុកមកក្នុងមហាបរិនិព្វានសូត្រថាយ៉ាងនេះ ហេតុដូចនោះឯងបានជាព្រះសង្គីតិកាចារ្យពោលថា ជនឯណាបានកើតក្នុងត្រកូលក្សត្រ ក្នុងកាលដែលពុទ្ធសាសនាកន្លងបាន ៥០០ ឆ្នាំ អំពីឆ្នាំដែលបរិនិព្វាននៃព្រះភាគនោះជននោះហើយដែលហៅថាស្ដេចមិលិន្ទនោះឯង ហើយបានទាំងពោលនូវព្រះគាថាមានដើមថាយ៉ាងនេះ ។

មិលិន្ទោនាមសោរាជា សាគលាយំបុរុត្តមេ

ឧ ប គ ញ្ឆិ នា គ សេ នំ គ ង្គា វ យ ថ សា គ រំ

សេចក្ដីក្នុងព្រះគាថានេះថា ព្រះសង្គីតិកាចារ្យកាលរើងសំដែងរឿងរ៉ាវព្រះនាគសេន និង ស្ដេចមិលិន្ទ អោយបានពិស្ដារទៅនោះ គឺបានសរសើរព្រះកេរ្ដិ៍យសទុកជាខាងដើមថាគ្រានោះមានបរមក្សត្រាធិរាជ ១ ព្រះអង្គ ទ្រង់ព្រះនាមថាព្រះបាទមិលិន្ទជាបុរសដ៏ឧត្ដម ក្នុងសាគលរាជធានីនគរទ្រង់ចូលទៅទៀបព្រះនាគសេនថេរ ហើយសួរនូវប្រស្នាចំពោះនាគសេនថេរនោះ ឯប្រស្នានោះមានឧបមាដូចខ្សែទឹកក្នុង

www.budinst.gov.kh www.elibraryofcambodia.org

គង្គាទាំង ៥ ដែលហូរចូលទៅកាន់សមុទ្រសាគរដធំ នឹងមាន ឯាករវេរបែរទៅកាន់ទីដទៃក៏ទេ ទឹកក្នុងគង្គាប្រៀបដូចប្រាជ្ញា ញាណរបស់ព្រះបាទមិលិន្ទ ឯមហាសមុទ្រនោះប្រៀបដូច ញាណបទីបរបស់ព្រះនាគសេនថេរដ៏ជ្រាលជ្រៅមិនចេះរលស់ មិនចេះផុត ដូចមហាសមុទ្រដធំនោះឯងចំណែកស្តេចមិលិន្ទ បើនឹងសួរនូវប្រស្នាយ៉ាងណា។ ក៏មិនដឹងទើសទាល់ឡើយ ឯ ប៉ែកខាងប្រស្នានោះទៀត ទើបទុកជាជ្រាលជ្រៅល្អិតយ៉ាង ណា ៗ ព្រះនាគសេន ក៏គង់ដោះស្រាយអោយថែងច្បាស់ស្រ ឡះអស់សង្ស័យ ដោយសេចក្តីឧបមានុបមេយ្យ អោយបាន ស្វាងរុងរឿងសតិបញ្ញា ដល់ជនានុជន ដែលបានស្តាប់មាន ឧបមាដូចពន្លឺភ្លើងគោមយ៉ាងធំ ដែលភ្លឺយល់ច្បាស់នូវរូបារម្ភ ក្នុងទីដែលងងឹតអាប់អន្ធការក្នុងពេលរាត្រី ដែលឥត មានពន្លឺរស្មីព្រះច័ន្ទតិចតួចឡើយ ឯសេចក្តីបុច្ឆានឹងវិសជ្ជនា នៃលោកទាំងពីរ ក៏ជ្រៅដោយន័យនឹងអត្ថដែលមានក្នុងព្រះ អភិធម្មបិដក លោកបានលើកយកមកជាតួបញ្ហាសួរទៅវិញ ទៅមកគួរជាទីពេញចិត្តគាប់ចិត្ត នឹងជាទីស្រណុកសប្បាយ ដល់ត្រចៀកហើយជាទីអស្ចារ្យឱឡារិក អោយកើតព្រឺសក់ ព្រឺរោមដល់អ្នកដែលបានស្តាប់ទាំងប៉ុន្មាន ក្នុងកាលនោះឯង។

ប្រការមួយទៀត ជនទាំងពួងបានឮមកថា ស្រុកសាគលនគររាជធានី ដែលព្រះបាទមិលិន្ទស្តេចនៅគ្រប់គ្រងនោះ មានស្ទឹង និងភ្នំព័ទ្ធជុំវិញ មានចំណែកនៃប្រទេសគួរជាទីរីករាយសប្បាយដ៏បរិបូណ៌ដោយឧទ្យាន និងស្ទឹងស្រះបោក្ខរណី និងព្រៃច្បារទាំងឡាយ ម្យ៉ាងទៀតស្ទឹងភ្នំទាំងនោះមាននិមិត្រដ៏ល្អគួរត្រេអរក្រៃពេក មានទាំងពពួកសត្វបក្សីមានពណ៌ប្លែកៗគ្នាហើរទៅហើរមក ពាសពេញនៅក្នុងវនារាម នោះ ម្យ៉ាងទៀត ឯក្រុងសាគលរាជធានីនោះរកសេចក្តីអន្តរាយអំពីបច្ចាមិត្រសត្រូវមកបៀតបៀនគ្មានឡើយ ព្រោះនគរនោះប្រកបទៅដោយខ្លោងទ្វារដ៏ខ្ពស់ធំមាំមួន មានប្រការផ្សេង ៗ យ៉ាងវិចិត្រប្រសព្វដ៏ចំឡែក មានទាំងគូស្នាមភ្លស់ព័ទ្ធពីក្រៅហើយខាងក្នុងប្រដាប់ដោយកំពែងព័ទ្ធជុំវិញយ៉ាងមាំ មនុស្សម្នាមហាជនទាំងឡាយ សម្រាប់ចូលគាល់ជាច្រើនណាស់ណាន់ តាន់តាប់បំរើរក្សាមហាក្សត្រដោយយ៉ាងល្អ ម្យ៉ាងទៀតក្នុងព្រះរាជធានីនោះ ប្រកបទៅដោយវិថីថ្នល់ សម្រាប់មនុស្សប្រុសស្រីដើរទៅដើរមកបត់បែរវិលវង់គេចផ្ទុះគេចរឿង ខ្វាត់ខ្វែងជាក្រឡាចត្រង់ មិនងាយនឹងដើរស្ពាត់កាត់រកគ្នាឃើញឡើយ ឯផ្ទៃផ្លូវនោះសោត ក៏ក្រាលពាសពេញសុទ្ធសឹងថ្មសិលា ឯ

www.budinst.gov.kh www.elibraryofcambodia.org

ខាងមគាំនោះសោត ក៏ប្រកបដោយរានផ្សារដ៏រៀបរៀងទៅតាមចិញ្ចើមថ្នល់ ម្យ៉ាងទៀតបរិបូណ៌ទៅដោយពាហាណៈ ដំរីសេះរថ រទេះ ពលទាហ៊ាន មានព្រម មានទាំងនរជាតិនារីរត្នកំឡោះក្រមុំព្រហ្មចារី ប្រកបដោយត្រកូលទាំងឡាយ មានត្រកូលសេដ្ឋីជាដើម ក្រុងរបស់បរមក្សត្រាធិរាជនេះ ក៏សែនហៅមហាសប្បាយទូលាយជាអស្ចារ្យ ឯក្នុងព្រះរាជស្ថានក៏មានពន្លឺភ្លឺឱភាស ទៅដោយមហាប្រាសាទរាជនិវេសនស្ថានរាយរៀងរៀបផ្ទាជាររបៀបជាទីបំផុត នៃពាក្យពណ៌នាបានឡើយ ។

១ ទៀត ក្រុងព្រះរាជធានីនេះបរិបូណ៌ដោយសម្ពត់កាសិកពត្រឧទុម្ពរពត្រ និងកោសេយ្យវត្រ ហើយមានទាំងប្លាំងមាស ប្លាំងប្រាក់កែវមណី ជាទីប្រាថ្នាអ្នកឈ្នួញទាំងឡាយតែងទៅតែងមកឥតមានចន្លោះពេលឡើយ ហើយបរិបូណ៌ទៅដោយមច្ឆាជាតិទាំងឡាយច្រើន ឯទីក្រុងសាគលរាជធានីក៏ហាក់ដូចជាស្រុកឧត្តរកូរុទ្វីប បើមិនដូចនោះសោតក៏ប្រៀបដូចជាទេវបុរីឈ្មោះអាលកមណ្ឌាឧទ្យាន ដែលស្ថិតនៅក្នុងស្ថានទេវលោកក្នុងកាលគ្រានោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងមិលិន្ទបញ្ហានេះមាន ៦ កណ្ឌគឺ

១ សំដែងអំពីបុព្វយោគ

២ សំដែងអំពីមិលិន្ទបញ្ហា

៣ សំដែងអំពីមេណ្ឌកបញ្ហា

៤ សំដែងអំពីអនុមានបញ្ហា

៥ សំដែងអំពីលក្ខណបញ្ហា

៦ សំដែងអំពីឧបមាកថា

ឯក្នុងមិលិន្ទបញ្ហានោះ ចែកចេញទៅជា ២ ប្រការ គឺវិមតិច្ឆេទនបញ្ហា ១ លក្ខណបញ្ហា ១ ។

ក្នុងមេណ្ឌកបញ្ហានោះ ក៏មាន ២ ប្រការដែរ គឺមហាវគ្គបញ្ហា ១ យោគិកថាបញ្ហា ១ ។

ឯបញ្ហា ៥ប្រការ តាំងពីមិលិន្ទបញ្ហារហូតដល់ឧបមាកថាបញ្ហានេះ និងវិសជ្ជនាជាឯកទេស គឺប្រែតាមបាលីក្នុងមិលិន្ទបញ្ហាដែលព្រះបាទមិលិន្ទទ្រង់សួរនូវបញ្ហាចំពោះ នឹងព្រះនាគសេនថេរពៃម្យ៉ាង សេចក្តីដែលសួរយ៉ាងនឹងឈ្មោះថាមិលិន្ទបញ្ហា ។

ឯបញ្ហាដែលមានលក្ខណៈ ២ប្រការ គឺលក្ខណបញ្ហា គឺចោទសួរដោយលក្ខណៈ ដូចពាក្យសួរថា ផស្សចេតសិក មាន

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណយ៉ាងណាសួរយ៉ាងនេះ ហៅថាលក្ខណបញ្ហា ១ នេះចាត់បញ្ចូលក្នុងមិលិន្ទបញ្ហា ១ និងសួរដើម្បីកាត់ នូវសេចក្ដីសង្ស័យមិនអោយមាន ក៏ឈ្មោះថាវិមតិច្ឆេទនបញ្ហា១ នេះ ក៏រាប់ចូលក្នុងមិលិន្ទបញ្ហា ១ ។

ឯមេណ្ឌកបញ្ហានោះមានលក្ខណ ២ ប្រការ គឺមហាវគ្គកថា ពោលដោយវគ្គច្រើន ក៏ហៅថាមេណ្ឌកបញ្ហា ១ ឯយោពីបញ្ហានោះ ពោលដោយព្រះយោគាវចរប្រតិបត្តិតាមបែបយ៉ាងមានប្រតិបត្តិដូចសត្វលាជាដើម ១ ហៅថាមេណ្ឌកបញ្ហា ។

ឯអនុមានបញ្ហានោះ ដូចសេចក្ដីថា ព្រះនាគសេនថេរសំដែងនូវធម្មនគរ និងធម្មបព្វតអោយប្រាកដច្បាស់ ហើយគេបានដឹងថា សម្ដេចព្រះសព្វញ្ញូព្រះអង្គបានត្រាសដោយអនុមានបញ្ហា ជនទាំងឡាយបានឃើញធម្មនគរ ដែលព្រះអង្គសាងទុក ឯបញ្ហាយ៉ាងនេះ ហៅថាអនុមានបញ្ហា ។

ឯឧបមាកថាបញ្ហានោះ គឺសំដែងដោយសេចក្ដីប្រៀបធៀបអោយឃើញជាក់ច្បាស់ ហៅថាឧបមាកថាបញ្ហា ។

វេធិប្បាយមកក្នុងលក្ខណបញ្ហាទាំង ៥ ស្ថាននេះ ជានិទ្ទេសប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## បុព្វយោគកថា

សព្ទដែលថាបុព្វយោគនោះ សេចក្តីថារំពីកុសលកម្ម របស់អ្នកទាំងពីរ គឺព្រះបាទមិលិន្ទរាជ និង ព្រះនាគសេនថេរ ដែលបានកសាងសន្សំទុកមករំពីជាតិមុនពៃរាល់គ្នា ក្នុងកាល ដែលកន្លងទៅហើយដូចពោលនាការព្រះបាឡីថាអតីតេកស្សបស្ស ភគវតោ សាសនេវត្តមានេ វិជិតាវីនាមរាជា សាគលនគរេរជ្ជំ ការេន្តោ ។បេ។ ចតូហិបច្ចយេហិសម្មាឧបដ្ឋហិ ។ យ៉ាងនេះជា ដើមសេចក្តីថា ក្នុងកាលដែលកន្លងទៅហើយមានមហាក្សត្រ ១អង្គ ទ្រង់ព្រះនាមថា វិជិតាវី ព្រះអង្គសោយរាជ្យសម្បត្តិក្នុង សាគលនគរ ហើយទ្រង់ព្រះអំរុកបំរុងនូវជនានុជនដ៏ច្រើន ដោយសង្គហវត្ថុទាំងឡាយ ៤ប្រការ ព្រះអង្គកសាងវិហារវាល វត្ត ១ តាំងនៅជៀបខាងកំពែង ស្រេចហើយក៏បានវេរ ថ្វាយនូវវិហារនោះ ដល់ព្រះថេរទាំងឡាយ ដែលជាអ្នកចេះចាំនូវ វិជ្ជាទាំងឡាយមានចេះដឹងនូវព្រះត្រៃបិដកជាដើម ហើយបាន ទាំងថែរក្សានូវព្រះសង្ឃទាំងនោះ ដោយបច្ច័យទាំងឡាយ ៤ គឺចីវរ[១] បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជក្នុងសាសនកាល

---

(១) ត្រៃចីវរ ភោជនាហារ ទីដេកទីអង្គុយ ថ្នាំសម្រាប់រក្សាជម្ងឺ ។

www.budinst.gov.kh www.elibraryofcambodia.org

នៃព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា កស្សបសម្មាសម្ពុទ្ធ ជាម្ចាស់នោះដ៏រាបដល់អស់ព្រះជន្មាយុ ទ្រង់ក៏បានឡើងទៅកើតក្នុងពិភពតាវតឹង្ស ជាស្តេចនៃទេវតា ហៅថាសម្តេចនរិន្ទឥន្ទកោសី ស្ថិតនៅក្នុងសុរាល័យប្រទេស ។ ឯក្នុងអារាមវត្តដែលមហាក្សត្រស្តេចបានកសាងហើយនោះ មានភិក្ខុសង្ឃច្រើនតែងអាស្រ័យនៅមិនមានដាច់ឡើយ បណ្តាភិក្ខុទាំងឡាយនោះ មានភិក្ខុខ្លះដែលបរិបូណ៌ដោយវត្តប្រតិបត្តិ និងសីលបរិសុទ្ធល្អ លោកតែងក្រោកឡើងពីព្រលឹមកាន់យកនូវអម្បោសហើយពិចារណានូវគុណនៃព្រះដ៏មានព្រះភាគ រួចហើយទើបបោសច្រាសនូវទីព្រះលាននៃព្រះចេតិយស្ថាន ហើយប្រមូលធ្វើជាគំនរសម្រាម លុះធ្វើរួចហើយទើបមានភិក្ខុ ១អង្គ ដ៏បរិបូណ៌ដោយសីលសម្បត្តិ បានហៅនូវសាមណេរម្នាក់អោយចូលមកនិងបង្គាប់ថា (នែសាមណេរចូលអ្នកកើបនូវសម្រាមនេះយកទៅចោល)ចំណែកឯសាមណេរនោះក៏នៅស្ងៀមធ្វើហាក់ដូចជាមិនឮលោកភិក្ខុនោះខំហៅសាមណេរនោះដល់ពីបីដងសាមណេរក៏មិនធ្វើជាឮឡើយ លំដាប់នោះលោកក៏ពោលថា យីអើសាមណេរនេះអាក្រក់ណាស់តើ ជាបុគ្គល គឺបុគ្គលប្រដៅបានដោយកម្រក្រៃពេក ហើយក៏ប្រហារនូវសាម

www.budinst.gov.kh www.elibraryofcambodia.org

ណោរនោះដោយផងអម្ញោសនោះឯង ចំណែកឯសាមណេរនោះ លុះត្រូវនឹងផងអម្ញោសហើយ ក៏ស្រែកទ្រហោយំស្ទះមៅកើរបេកសម្រាមនោះ ទៅចាក់ចោលមួយរំពេចដោយសេចក្ដីភិតភ័យនោះឯង លុះចោលសម្រាមរួចហើយក៏តាំងដឹកល់ទូវសេចក្ដីប្រាថ្នាជាដំបូងថា ( ឱបុញ្ញកម្ម ដែលខ្ញុំបានចោលសម្រាមនេះ បើមិនទាន់អោយខ្ញុំបានដល់ព្រះនិព្វានទៅឡើយទេ ទោះបីបើខ្ញុំនឹងចូលទៅកើតក្នុងទីស្ថានណាដែលខ្លួនខ្ញុំកើតហើយដទៃអំពីភពនេះ ក៏សូមអោយមានសក្តិយសក្តង់ខ្ពស់ជាចម្បងជាងជនទាំងពួង ប្រៀបដូចជាសក្តានុភាពនៃព្រះសុរិយទេវបុត្រ ដែលស្ថិតនៅចំពាក់កណ្ដាលអាកាសនោះឯង ) កាលបើបានធ្វើកិច្ចចោលនូវសម្រាមនោះសម្រេចហើយសាមណេរនោះក៏ចុះទៅកាន់កំពង់ទឹក ដើម្បីងូតជំរះកាយអោយអស់សៅហ្មង លុះមុចដើបងូតស្រេចវេលាណាហើយមានចិត្ត ក៏សប្បាយ កាយក៏ត្រជាក់ ទើបក្រឡេកមើលទៅឃើញលលកទឹកបោកបក់កង្ហាញ់មកឥតមានដាច់ ក៏មានបីតិសោមនស្សកើតឡើងទៀត គឺតថា ( ព្រះថេរដែលលោកប្រើអញអោយកើបសម្រាមយកទៅចោលនោះ នឹងថាជាការងាររបស់លោកក៏ទេ ឬនឹងថាជាប្រយោជន៍ដល់អាចារ្យ និង

www.budinst.gov.kh www.elibraryofcambodia.org

ឧបជ្ឈាយ៍របស់លោកក៏ទេ បើនិងថាដោយពិតទៅគឺលោកសង្គ្រោះចំពោះខ្លួនរវៀននេះឯង ) គឺពយល់យ៉ាងនិងហើយទើបសាមណេរនោះ តាំងចិត្តដំកល់នូវសេចក្តីប្រាថ្នាម្តងទៀតថា (បើខ្ញុំនឹងទៅកើតក្នុងជាតិណា១ មុនដែលបានសម្រេចនូវព្រះនិព្វាននោះ សូមអោយមានប្រាជ្ញាច្រើន រាប់កុំអោយចេះអស់ឡើយ ដូចជាអង្កាញ់នៃលលកទឹកក្នុងគង្គានេះឯង ) ចំណែកភិក្ខុនោះលុះបោសច្រាសរួចហើយ ក៏យកនូវអម្បោសទៅទុកក្នុងសាលារោងសម្រាប់ទុកនោះ ហើយក៏ចុះទៅកាន់កំពង់ទឹក ដើម្បីងូតជំរះមន្ទិលញើសក្អែល ដែលជិតប្រឡាក់ដោយសរីរាងកាយ ក៏បានឮនូវសេចក្តីប្រាថ្នារបស់សាមណេរនោះហើយ តាំងពិចារណាថា សេចក្តីប្រាថ្នារបស់សាមណេរនេះធំខ្លាំងណាស់តើ មុននឹងបានសម្រេចមិនខាន ព្រោះអាស្រ័យនូវពុទ្ធគុណនោះឯង ព្រះថេរគិតឃើញយ៉ាងនេះហើយទើបញញឹមនឹកតែក្នុងចិត្តថា ( យីអើសាមណេរនេះប្រកបនូវសេចក្តីប្រាថ្នានេះចំពោះដល់អញហើយតើ បានជាតាំងប្រាថ្នាយ៉ាងនេះឯងសេចក្តីបំណងយ៉ាងនឹងនិងខានសម្រេចឯណាក៏បាន ) ហើយលោកក៏តាំងពិចារណាពុទ្ធគុណប្រៀបផ្ទឹមផ្ទួងឡើងនូវសេចក្តីប្រាថ្នារបស់លោកជាដំបូងថា ( វេលាដែលខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org

នឹងបានទៅកើតទៀតក្នុងជាតិនោះ ១ ដងទៀត ពីជាតិនេះទៅ កាលបើមិនទាន់បានសម្រេចព្រះនិព្វានក្នុងវេលានោះ ខ្ញុំសូមអោយបានប្រាជ្ញាច្រើនជាងគេក្នុងលោក រកកុំអោយចេះអស់ឡើយ ប្រៀបដូចតំណក់ទឹកនៃរលកក្នុងគង្គានេះ ហើយខ្ញុំសូមអោយបានប្រាជ្ញាឆ្លៀតវាងវៃ អាចដោះស្រាយ នឹងពំ-ពុះទំលាយនូវបញ្ហាគ្រប់យ៉ាង ដែលសាមណេរនេះសួរហើយ ប្រៀបដូចជាបុរសមានប្រាជ្ញាវៃឆ្លាត អាចដោះស្រាយនូវអម្បោះ ឬ សូត្ររបស់ជាងតម្បាញ ដែលរកាក់ហើយជំពាក់គ្នាវិកវក្នុងរកដើមពុំឃើញ បុរសនោះអាចនឹងកំណាត់ចោះការនេះចុង ការនេះចប់ហើយតព្វាបានយ៉ាងនេះឯង ដោយសារនិ-ស្ស័យដែលខ្ញុំបានបោសព្រាលនោះផង និង អានិសង្សដែលខ្ញុំបានប្រើនូវសាមណេរនេះ អោយនាំយកកព្រាមទៅចាក់ចោលនោះផង ។

អ្នកទាំងពីរ គឺភិក្ខុ នឹងសាមណេរនោះ លុះចំលាយខន្ធទៅកាលណា ក៏បានទៅកើតក្នុងជាតិជាមនុស្ស នឹង ទេវតាអស់ពុទ្ធន្តរ ១ ហើយក៏ល្មមដល់មកពុទ្ធុប្បាទនេះ ក៏កាលសម្តេចព្រះបរមលោកនាថជាគ្រូយើងនេះកាលរៀបនឹងចូលបរិនិព្វាននោះព្រះអង្គបានទ្រង់ព្យាករណ៍ទំនាយទុកថា កាលតថាគតនិព្វានកន្លងទៅបាន ៥០០ ឆ្នាំ នឹងកើតភិក្ខុអង្គ ១ បាន

www.budinst.gov.kh www.elibraryofcambodia.org

អាចរល្បោះថា នាគសេន នឹងអាចមកដោះបញ្ហារបស់ស្តេចមិលិន្ទនឹងអធិប្បាយប្រៀបធៀបនូវធម៌និងវិន័យ ក្នុងព្រះត្រៃបិដក ដែលតថាគតទេសនាទុក ដោយសេចក្តីជ្រាលជ្រៅសុខុមអ្នកអាចរោះរោយជាសេចក្តីរាក់ឡើងបាន ធ្វើសាសនាពថាគត អោយរុងរឿងថែងច្បាស់ តាំងនៅបានគ្រប់ទាំង ៥ ០០០ វស្សា ។

កាលបើពុទ្ធសាសនាកន្លងទៅ ត្រូវតាមពុទ្ធបំនាយនោះហើយចំណែកខាងសាគរណោរ ក៏បានមកជាមហាក្សត្រទ្រង់អាចបញ្ញត្តិឈ្មោះថា ព្រះបាទមិលិន្ទាធិបតី ព្រះចៅក្រុងសាគលរាជធានីបណ្ឌិតោ ទ្រង់ប្រព្រឹត្តទៅដោយញាណគតិវិយត្តោ មានប្រាជ្ញាដ៏ភ្លៀវឆ្លាសវាងវៃ មេធាវីបរិបូណ៌ដោយប្រាជ្ញាជាអ្នកប្រាជ្ញធំ បណ្ឌិតោ ទ្រង់អង់អាចដែលនឹងពិចារណានូវហេតុដែលជាអតីត នឹង អនាគត នឹងបច្ចុប្បន្ន ហើយជឹងក្នុងពិធីដែលនឹងប្រកបការទាំងពួងនឹងដឹងនូវសិល្បសាស្ត្រ ១៨ ប្រការ ហើយទ្រង់ជ្រាបនូវពុទ្ធវចនផងជា ១៩ ប្រការ ។

ឯសិល្បសាស្ត្រ១៨ប្រការនោះ គឺស្វពិសេចក្តីដឹងច្បាស់នូវសំឡេងរបស់សត្វទាំងឡាយ មានសំឡេងស្រែកជាដើមថា សំឡេងយ៉ាងនេះល្អ យ៉ាងនេះមិនល្អប្រការ ១ សម្មតិដឹង

www.budinst.gov.kh www.elibraryofcambodia.org

ច្បាស់នូវកំណើតភ្នំ និងដើមពេលជាដើម ប្រការ១ សំខ្យាដឹង នូវគម្ពីរលេខប្រការ ១ យោគា ដឹងការដែលជាងការត្រូវប្រកបប្រការ ១ និត្តិ ដឹងនូវសិល្បសាស្ត្រ របស់ត្រេចប្រការ ១ វិសេសិកា ដឹងគម្ពីរ និងសេចក្តីចិញ្ចឹមពួកជនអោយមានសិរីមង្គល ប្រការ ១ គណិកាដឹងរាប់នក្ខត្តឫក្ស និង ដឹងជព្រោផ្កាយប្រការ១ គន្ធព្វដឹងច្បាប់របៀបភ្លេងប្រការ១ ពិកិច្ឆាដឹងគម្ពីរពេទ្យប្រការ ១ ធនុព្វេទា ដឹងសិល្បសាស្ត្របាញ់ធ្នូ ប្រការ ១ បុរាណា ដឹងច្បាស់ថា ទីនេះជាទីស្រុកចាស់ដើមរើចាស់ប្រការ ១ ឥតិហាសា ដឹងច្បាស់ថាស៊ីបាយបែមុខទៅទិសនោះជាមង្គលជាដើមប្រការ១ ជោតិកាដឹងច្បាស់នូវគម្ពីរព្យាករណ៍ពីដឹងទាយថា មនុស្សកើតឆ្នាំនេះ ខែនេះ ថា ឆ្នាំនេះល្អ ឬ អាក្រក់ប្រការ ១ មាយា ដឹងថាវត្ថុយ៉ាងនេះជាកែវមណីនេះ មិនមែនកែវមណីប្រការ ១ ហេតុដឹងច្បាស់នូវហេតុដែលផ្តើមឡើងនឹងផលដែលចំរើនឡើងពីហេតុនោះប្រការ ១ វន្តជាដឹងច្បាស់នូវទីដែលនឹងចិញ្ចឹមគោក្របី ដឹងទីដែលនឹងដាំពូជផុះក្នុងស្រែចំការអោយចំរើនផលប្រការ១ យុទ្ធកា ដឹងនូវគម្ពីរពិជ័យសង្គ្រាមប្រការ ១ ជាសេប្លា ដឹងនូវគម្ពីរលោកវោហារប្រការ ១ ឆន្ទសា ដឹងច្បាស់នូវគម្ពីរ និងចំនួនរៀបរយកាពិកានិងពាក្យពោល ប្រការ ១ សិរីវាចាសិល្បសាស្ត្រទាំងរបស់នេះ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវ ១៨ ប្រការដូចនេះ បញ្ចូលពុទ្ធវចនមកផងជា១៩ ប្រការ។ វាចិទ្ធវាសទ្ធោ ម៉្យាងទៀតព្រះបាទសម្តេចមិលិន្ទរាជនេះ ព្រះអង្គមានព្រះវាចាសន្ទនាដ៏ពិរោះល្អពេកណាស់ តែងល្បីឮប្រាកដទូទៅក្នុងជនបទ ប្រទេសផ្សេងៗ ទុប្បសហោ នឹងរកអ្នកឯណាអាចទប់ទាស់ព្រះរាជវាចាព្រះអង្គនោះគ្មានឡើយ ព្រះអង្គប្រាកដជាបុគ្គលធំជាងពួកតិរ្ថិយគ្រណ្ឋទាំងពួងដែលនៅក្នុងជម្ពូទ្វីបទាំងអស់ រកបុគ្គលណាអោយស្មើនឹងព្រះអង្គ ដោយកំឡាំងកាយនិងកំឡាំងបញ្ញា នឹងសេចក្តីក្លៀវក្លា និងការសួរនូវប្រស្នានោះពុំមានឡើយ ។

ម៉្យាងទៀតព្រះរអង្គប្រកបដោយអង្គ ៣ ប្រការ គឺប្រកបដោយកំឡាំងវពល ពាហណ យោធា ទាហ៊ាននោះ យ៉ាងច្រើនប្រការ ១ ប្រកបដោយព្រះប្រាជ្ញាញាណ ដ៏ច្រើនប្រការ ១ ប្រកបដោយភោគសម្បត្តិដ៏ច្រើនប្រការ ១ ។

ក៏ក្នុងសម័យ ១ នោះ ព្រះបាទមិលិន្ទ ស្តេចមានចតុរង្គសេនា យោធា ទាហ៊ានហែរអមព្រះអង្គឆ្វេងស្តាំ ទ្រង់លីលាចេញចាកព្រះរាជនិវេសនស្ថានទៅខាងក្រៅព្រះនគរដើម្បីនិងក្រសាលេលប្បាយព្រះហឫទ័យរោយក្បេមក្សាន្ត ហើយទ្រង់បង្គាប់រោរោរញ្ញេបពួកពលនិករនៅក្នុងថ្ងៃ ១ នោះ ស្រេចក៏ទ្រង់ព្រះរាជដំណើរទៅក្នុងទីកន្លែង ដែលជាទីសប្បាយរើរើករ

www.budinst.gov.kh www.elibraryofcambodia.org

ក៏បើកព្រះនេត្រទៅឯផ្ទៃអាកាស ក៏ទតឃើញរស្មីព្រះអាទិត្យដ៏ផូរផង់ ទើបទ្រង់មានព្រះរាជឱង្ការត្រាស់ហៅអាមាត្យអោយចូលមកក្នុងទីចំពោះព្រះភក្ត្រ ហើយទ្រង់ត្រាស់ថា នែអាមាត្យ យើងមិនទាន់បានយាត្រាចូលទៅកាន់បរមរាជវាំងទេ យើងនឹងលះបង់សម្បត្តិព្រោះនេះ ទោះបុត្រជាទីស្រឡាញ់បន្តិចតិច អើអ្នកទាំងឡាយចូរអ្នកត្រិះរិះពិចារណាមើល មើលព្រោះបុត្រនេះនឹងកើតជាបរមក្សត្រ ឬព្រាហ្មណ៍ ដែលបានប្រសើត ចេះដឹងធម៌វិជ្ជា ម៉្យាងទៀតអ្នកដែលបានញ្ញាណខ្លួនថា ជាអ្នកប្រាជ្ញ ឬ ជាព្រះពុទ្ធបាទនឹងកាត់សេចក្ដីសង្ស័យរបស់យើងបានក្នុងពេលឥឡូវនេះ ។

កាលបើព្រះបរមក្សត្រ ស្ដេចមានព្រះរាជឱង្ការយ៉ាងនេះហើយ រស់អ្នកយោធាកជាខ្ញុំរាជការទាំង ៥០០ ក៏ពិតទូលថា បពិត្រព្រះសម្មតិទេព ឯអ្នកប្រាជ្ញទាំងឡាយមាននៅក្នុងដែននេះ មិនមានអ្នកឯណាអោយជាជាងគ្រូទាំង ៦ គឺបូរណកស្សប ១ មក្ខលិគោសាល ១ និគណ្ឋនាដបុត្រ ១ សញ្ជយវេលដ្ឋបុត្រ ១ អជិតកេសកម្ពល ១ បកុធកច្ចាយន ១ ផ្សំគ្នាត្រូវជា ៦ គ្រូទាំង ៦ នោះ មិនមែនជាមនុស្សអាក្រក់ឡើយ សុទ្ធតែជាមនុស្សល្អណាស់ ជាគ្រូអាចារ្យគេរាប់អានបរិបូណ៌ ដោយប្រាជ្ញាញាណនិងបរិវារយស ហើយជាទីសក្ការបូជា

www.budinst.gov.kh www.elibraryofcambodia.org

នៃមហាជនទាំងឡាយ មនុស្សទាំងឡាយតែងរាប់អានកាន់ពាម យើងរាល់គ្នាឃើញថា និងអាចដោះស្រាយកែខៃនូវអាថ៌ប្រស្នារបស់ព្រះអង្គបានមិនខានឡើយ សូមអញ្ជើញស្ដេចទៅកាន់សំណាក់គ្រូទាំងនោះចុះ ។

គ្រានោះព្រះមហាក្សត្រស្ដេចប្រោនទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ទើបទ្រង់ក្រោកឡើងគង់លើព្រះរាជរថភ្លាម មានអ្នករាជការទាំង ៥០០ និងរេពលទាំងពួងចោមរោមស្ដេចទៅកាន់សំណាក់គ្រូឈ្មោះបុរណកាស្សបបំរុងចោទសួរនូវប្រស្នាដោយសុន្ទរកថា ថាគួរជាទីសោមនស្សត្រេកអរ លុះដល់ហើយទើបទ្រង់សួរថា ភន្ដេកស្សបបពិត្រកស្សបដ៏ចំរើនសភាវអ្វីដែលជាទីចិញ្ចឹមរក្សានូវសត្វលោក ។ បុរណកាស្សបឆ្លើយថា បពិត្រសម្ដេចមហារាជបថវីលោកុំបាលេតិផែនប្រថពីនេះឯង ជាទីថែរក្សាទ្រទ្រង់នូវសត្វលោក សូមទ្រង់ជ្រាប ។

មហាក្សត្រស្ដេចត្រាស់ថាអើលោកម្ចាស់បើមហាប្រថពីជាអ្នកថែរក្សាទ្រទ្រង់នូវសត្វលោក ចុះហេតុអ្វីក៏អោយសត្វទាំងឡាយធ្លាក់ទៅកាន់ស្ថាននរកអវិចីបាន មិនទ្រទ្រង់ទទួលទុកផង ចំណែកគ្រូឈ្មោះបុរណកាស្សបក៏ទាល់គំនិត ទាល់

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដី មិនដឹងបើនឹងដោះស្រាយថាដូចម្ដេចបានឡើយ ក៏អង្គុយស្ងៀមនៅ ១ ប៊ីនោះឯង ។

ព្រះបាទមិលិន្ទរាជ ស្ដេចទ្រង់ព្រះដំរិះថា ឱ ជម្ពូទ្វីបនេះអើយស្ងាត់ស្ងៀមទទេទទេតើ ហើយទ្រង់ត្រាស់ថា នែគ្នាយើងដ៏ចំរើន ជម្ពូទ្វីបនេះគ្មានអ្នកប្រាជ្ញទេទោះសមណក្ដីព្រាហ្មណ៍ក្ដីក៏ដោយ ក៏គ្មានដល់ថ្នាក់ជាព្រះអរហន្តវិសេសឡើយ នឹងរកអ្នកឯណាមួយអាចចរចា ១ អន្លើ ដោយយើងគ្មានឡើយ ហើយទើបស្ដេចទ្រង់សួរទៅមក្ខលិគោសាលថា នែលោកម្ចាស់កម្មជាកុសលជាអកុសល មាន ឬគ្មានផលនៃកម្ម ដែលបុគ្គលធ្វើអាក្រក់ ឬធ្វើល្អនោះ តើមាន ឬគ្មាន ។

ឆត្តិមហារាជ បពិត្រសម្ដេចមហារាជ កម្មជាកុសល ឬអកុសល និងផលនៃកម្មដែលបុគ្គលធ្វើអាក្រក់ ឬ ធ្វើល្អនោះគ្មានសោះឡើយ បពិត្រមហារាជអ្នកឯណាកើតមកក្នុងលោកនេះហើយ បានជាស្ដេចវលោតស្លាប់ទៅ ១ កាន់លោកខាងមុខទៀត ក៏នឹងបានជាស្ដេចដ៏ដែលវិញ នឹងមានផលបុណ្យផលបាបអ្វីមកពាក់ពែងនោះគ្មានឡើយ ម៉្យាងទៀតជនឯណាដែលកើតមកក្នុងលោកនេះជាព្រាហ្មណ៍ក្ដី ជាអ្នកល្អញក្ដី ជាអ្នកស្រែចំការធម្មតាក្ដី ជាអ្នកចណ្ឌាលអាក្រក់ក្ដី ជាអ្នកកំសត់ទុគ៌តអនាថាក្ដី វលោតស្លាប់ចាកខន្ធនេះទៅហើយ តែងទៅ

www.budinst.gov.kh www.elibraryofcambodia.org

កាន់បរលោកនាយ ក៏នឹងកើតជាព្រាហ្មណ៍ ជាអ្នកឈ្មួញ ជាអ្នកស្រែចំការ ជាមនុស្សចណ្ឌាល ជាអ្នកកំសត់ទុគ៌តអនាថាដ៏ដែលវិញឥតមានផលបុណ្យផលបាបអ្វីនីមួយជួយទំនុកបំរុងអោយសុខអោយទុក្ខនោះឡើយ ។

មហាក្សត្រស្តេចត្រាស់ថាអើលោកម្ចាស់បើផលបុណ្យផលបាបមិនមាន ហើយអ្នកឯណាដែលធ្លាប់ជាសេដ្ឋី គហបតីនិងភេទផ្សេង ៗ នោះ លុះស្លាប់ទៅហើយកើតមកថ្មីទៀតអ្នកនោះឯងក៏តែងតាំងនៅតាមភេទចាស់របស់ខ្លួន ឥតមានប្រែប្រួលឡើយ ចុះបើអ្នកនោះជាមនុស្សទោសដែលគេកាត់ដៃកាត់ជើងក្នុងលោកនេះ វេលាដែលស្លាប់ទៅមិនទៅកើតជាមនុស្សទោសដ៏ដែល ត្រូវគេកាត់ដៃកាត់ជើងទៀតហើយលោកម្ចាស់ ។

មក្ខលីគោសាលឆ្លើយថា ថ្វាយព្រះពរយ៉ាងនិងមហារាជមនុស្សឯណាដែលគេកាត់ដៃកាត់ជើងក្នុងជាតិនេះ វេលាទៅកើតជាតិខាងមុខទៀត ក៏ត្រូវគេធ្វើយ៉ាងនេះឯង ឥតមានផុតវេរានោះឡើយសូមទ្រង់ជ្រាប ។

ព្រះបាទមិលិន្ទទ្រង់ត្រាស់ថា នលន្ទហាម យើងមិនជឿលោកទេ ពាក្យលោកយ៉ាងនិងមិនត្រូវសោះឡើយ កាលបើមហាក្សត្រស្តេចត្រាស់យ៉ាងដូចនោះហើយ ឯមក្ខលីគោ

www.budinst.gov.kh www.elibraryofcambodia.org

សាលក៏ទាល់សំដី ចិរដឹងបើនឹងឧបហោះបុប្បមេឃ្យ ដូចម្ដេច
តទៅទៀតបាន ក៏អង្គុយស្ងៀមនៅ ១ ទីនោះ ឯមហាក្សត្រ
ស្ដេចក៏មានព្រះរាជឱង្ការផ្ដេញផ្ដាញ់ ទៅបក្ខលិគោសាលទៀត
ថានៃបក្ខលីគោសាលខ្ញុំសួរលោកថាកម្មជាកុសលនិងអកុសល
នោះមាន ឬគ្មានយ៉ាងនេះ ចំណែកលោកជាមនុស្សពាលទៅ
ជានិយាយថា គ្មានកម្មគ្មានផលទេវិញ ។ កាលបើបរមក្សត្រ
ស្ដេចទ្រង់សួរនូវមក្ខលីគោសាលរួចហើយ ព្រះអង្គក៏ត្រឡប់
ចូលទៅកាន់បរមរាជវាំងវិញ។ លុះវេលារាត្រី ១ ទៀតនោះ
ទ្រង់ព្រះរាជវិតក្កក្នុងព្រះរាជចិន្ដាថា ឱ ហ្ន៎ ពេលរាត្រីថ្ងៃនេះ
មានពន្លឺព្រះច័ន្ទភ្លឺពាសពេញទាំងផ្ទៃអាកាស អាត្មានេះនឹង
ចូលទៅសួរនូវអត្ថបញ្ហា ចំពោះនឹងសមណ ឬ ព្រាហ្មណ៍ពួក
សង្ឃ និងគណ ឬគណាចារ្យ។ម្យ៉ាងវិញទៀតអ្នកឯណាដែល
បានប្ដេជ្ញាខ្លួនថា ជាព្រះអរហន្ត ឬ ព្រះពុទ្ធនោះ នឹងរកអ្នក
ទាំងនោះអាចដើម្បីនឹងចរចាបន្ទោបង់នូវសេចក្ដីសង្ស័យមួយ
អន្លើដោយអាត្មាអញនេះមិនមានសោះឡើយ ព្រះអង្គទ្រង់
ព្រះរាជវិតក្កដូចនេះហើយ ទើបមានព្រះរាជឱង្ការសួរទៅសេ-
វកាមាត្យ អ្នកយោនកទាំងឡាយ ដែលអង្គុយគាល់នៅទ្រៀប
ព្រាខាងឆ្វេងអាងស្ដាំព្រះអង្គនោះ ដូចសេចក្ដីដែលទ្រង់ព្រះ
ដំរិះនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

សេវកាមាត្យរាជយោនកទាំងពួង និងបានក្រាបទូលស្នងព្រះរាជឱង្ការថា សមណព្រាហ្មណ៍ទាំងឡាយ មានក្នុងទីនា ៗទៀតក៏គ្មានឡើយ ក៏បបួលគ្នាអង្គុយស្ងៀម នៅត្រាន់តែក្រឡេកមើលទៅព្រះភក្ត្រមហាក្សត្រប៉ុណ្ណោះ និងបានមានអ្នកឯណាមួយអាចទូលពិព្រឹត្តដូចម្ដេចទៀតគ្មានសោះឡើយ ។

ចាប់ដើមអំពីសម័យនោះមក ក្រុងសាគលនគរ ក៏ស្ងាត់ស្ងៀម មិនមានសមណព្រាហ្មណាចារ្យណាទៅមកក្នុងទីនោះទៀតឡើយ ប្រមាណជាង ១២ ឆ្នាំ ព្រោះហេតុថា ព្រះបាទមិលិន្ទ្រាធិរាជ តែស្ដេចបានជ្រាបថាទីណាមានសមណព្រាហ្មណាចារ្យជាអ្នកប្រាជ្ញហើយ ក៏ស្ដេចនឹងទៅសួរអត្ថបញ្ហាចំពោះសមណព្រាហ្មណ៍នោះមិនខានឡើយ ម្លោះហើយសមណព្រាហ្មណ៍ទាំងឡាយ ដែលមានប្រាជ្ញាតិច មិនអាចឆ្លើយបាន ក៏គេចវេះចាកសាគលនគរនោះ ចេញទៅកាន់ទីឯទៀត ឯសាគលនគរនេះ ក៏ស្ងាត់ស្ងៀម មិនមានសមណព្រាហ្មណ៍ដល់១ ឡើយ ព្រោះលោកទាំងនោះតែងរត់ទៅកាន់ទិសទីទៃស្រុកដទៃ ក៏មានរត់ទៅជ្រកពួនក្នុងភ្នំហិមពាន្តក៏មានដោយច្រើន ។

ក៏ក្នុងសម័យនោះ មានព្រះអរហន្តទាំងឡាយច្រើនប្រមាណ ១០០ កោដិ លោកតែងអាស្រ័យនូវក្នុងព្រៃហិមពាន្ត

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងរក្ខិតលេណគ្រានោះ មានព្រះមហាថេរ ១ អង្គ ជាប្រធានក្នុងពួកភិក្ខុសង្ឃទាំងនោះមាននាមថា ព្រះអស្សគុត្តថេរជាព្រះអរហន្តចាស់ជាងគេ លោកក៏បានដឹងនូវហេតុដែលព្រះបាទមិលិន្ទ្រាធិរាជធ្វើយ៉ាងនេះ លោកក៏យល់ថា ព្រះពុទ្ធសាសនានិងសៅហ្មងសាបសូន្យមិនខានឡើយ បើយអង្គលោកបានប្រកាសប្រាប់ព្រះអរហន្តទាំងឡាយ អោយមកប្រជុំព្រមគ្នាលើកំពូលភ្នំយុគន្ធរ លុះប្រជុំគ្នាស្រេចហើយ ព្រះអស្សគុត្តថេរ លោកតាំងប្រកាសថា ព្រះអរហន្តអង្គឯណា ១ នឹងអាចទៅដោះអាថិប្រស្នាព្រះបាទមិលិន្ទ្រាធិរាជបាន ហើយអាចធ្វើអោយមហាក្សត្រនោះ មានសេចក្តីជ្រះថ្លាដោយសតិបញ្ញារបស់ខ្លួនផង ដើម្បីជាការជ្រោមជ្រែងព្រះពុទ្ធសាសនាទុកអោយឋិតនៅ ពីព្រោះមានព្រះអរហន្តអង្គណាអាចទទួលការយករាសាទនេះបាន ព្រះអស្សគុត្តថេរពោលយ៉ាងនេះដល់ ២ - ៣ ដងដូចនោះហើយ ព្រះអរហន្តទាំងឡាយក៏គង់នៅស្ងៀម មិនមានលោកណា ១ អាចទទួលធុរនោះបាន ។

គ្រានោះព្រះអស្សគុត្តថេរ បានពោលចំពោះទៅនឹងពួកភិក្ខុសង្ឃទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ក្នុងពិភពស្ថានតាវតឹង្សឯនោះ មានទេវបុត្រ ១ ព្រះអង្គ ឈ្មោះថាមហាសេន នៅក្នុងវិមានឈ្មោះ កេតុមតីជា ខាងកើតនៃវេជយន្ត

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទនៃទេវរាជឈ្មោះសក្កៈ ឯមហាសេនទេវបុត្រនោះជាអ្នកឆ្លៀវឆ្លាស់ប្រឌិពល អាចចរចាជជែកជាមួយនឹងស្តេចមិលិន្ទបាន ហើយនិងបន្ទោបង់នូវសេចក្តីសង្ស័យរបស់ស្តេចនោះផង ។

ព្រះអស្សគុត្តថេរ បានអធិប្បាយពន្យល់រឿងនេះស្រេច ព្រះអរហន្តទាំងឡាយទាំង ១០០ កោដិបានទទួលស្តាប់នូវថេរវាចារនេះហើយ ក៏បាត់អំពីទីភ្នំហិមពាន្តនោះហោះ ឡើងទៅកាន់ស្ថានព្រះឥន្ទ្រាធិរាជឯទេវលោកឯនោះ គ្រានោះទេវរាជក៏បានឃើញនូវពពួកភិក្ខុសង្ឃទាំងឡាយមកអំពីចម្ងាយហើយ ស្តេចក៏ចូលទៅថ្វាយបង្គំចំពោះព្រះអស្សគុត្តថេរ ទើបពិតសួរព្រះអស្សគុត្តថេរថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ប្រមូលពពួនភិក្ខុសង្ឃមកច្រើនដល់អ្លេះ តើមានហេតុភេទអ្វីលោកម្ចាស់ ។

ព្រះអស្សគុត្តថេរថ្វាយព្រះពរថា បពិត្រមហារាជ ក្នុងជម្ពូទ្វីបឯនោះមានស្តេច ១ព្រះអង្គ មានបុណ្យឈ្មោះថា មិលិន្ទរាជ ស្តេចបានរៀននូវវិជ្ជាសិល្បសាស្ត្រទាំងឡាយច្រើន ហើយឆ្លៀវឆ្លាសក្នុងទីសន្ទនាវាទី តែងល្បងទូទិរនឹងរកអ្នកឯណា ១ អាចទប់ទាស់ពុំបានឡើយ តែងសួរនូវប្រស្នាចំពោះ

ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ដោយពិត្តិយវាទបៀតបៀនភិក្ខុសង្ឃមិនអោយបានសេចក្តីសប្បាយ ។

សម្តេចអម្រិន្ទ្រាធិរាជស្តេចសួរថា ស្តេចមិលិន្ទដែលច្យុតិពីទេវលោកនេះទៅឬអ្វី លោកម្ចាស់ ។

ព្រះអស្សគុត្តថេរថ្វាយព្រះពរថា អឹងហើយមហាបពិត្រទេវរាជស្តេចក៏ពិតថេរវាចាទៅវិញថា លោកម្ចាស់បើយ៉ាងនឹងព្រោមឃើញតែមហាសេនទេវបុត្រ ដែលនៅក្នុងកេតុមតីវិមាននោះទើបមានប្រាជ្ញាឆ្លៀវឆ្លាស់ អាចចរចាជជែកកាត់សេចក្តីកង្ខារបស់ស្តេចនោះបាន ខ្ញុំនឹងទៅជួយអារាធនាអញ្ជើញមហាសេនទេវបុត្រនោះ អោយច្យុតិបាកវិមានរបស់ខ្លួនចុះទៅកើតក្នុងមនុស្សលោកនាយ ស្តេចត្រាស់ដូចនោះហើយក៏ទ្រង់លិលាទៅក្នុងអាកាសប្រទេស នាំមុខភិក្ខុសង្ឃទាំងពួងចូលទៅដល់កេតុមតីវិមាន ហើយក៏ស្តេចចូលទៅអោបក្រសោបនូវមហាសេនទេវបុត្រ ដោយសេចក្តីរាប់អានយ៉ាងខ្ពស់ហើយទ្រង់ត្រាស់ថានែអ្នកនិរទុក្ខអើយឥឡូវនេះភិក្ខុសង្ឃឡើងមកពីជម្ពូទ្វីបច្រើនណាស់ ដើម្បីនឹងបកអញ្ជើញអ្នកអោយចុះទៅកើតឯមនុស្សលោកនាយ ចូលអ្នកអាណិតអាសូរទទួលសេចក្តីអារាធនា ដើម្បីនឹងចុះទៅកើតក្នុងមនុស្សលោកឥឡូវនេះកុំខាន ។

www.budinst.gov.kh www.elibraryofcambodia.org

មហាសេនទេវបុត្របានទទួលស្តាប់នូវទេវវាចាដូចនោះ ហើយទើបទូលទាស់មកវិញថា បពិត្រសម្តេចព្រះបរមទេវរាជដ៏ប្រសើរអើយ ខ្ញុំល្អងធូលីព្រះបាទនេះគ្មានប្រាថ្នាត្រូវការអ្វីសោះឡើយ ព្រងចុះទៅកើតក្នុងមនុស្សនាយនោះ ព្រោះមនុស្សលោកនោះ ប្រកបដោយការចិញ្ចឹមជីវិតច្រើនប្រការណាស់ហើយជាការពេញដោយសេចក្តីទុច្ចរិតផង ឯខ្លួនខ្ញុំព្រះករុណាពិសេសនេះមានសេចក្តីនើយណាយណាស់ហើយក្នុងការស្លាប់កើតនោះ សព្វថ្ងៃមានប្រាថ្នាតែនឹងឡើងទៅកើតក្នុងទេវលោកខាងលើ ។ ហើយនឹងទៅបរិនិព្វានក្នុងស្ថានអកនិដ្ឋកាមហាព្រហ្មនោះឯង ។

ព្រះអស្សគុត្តថេរបានស្តាប់ហើយទើបអង្វរទៅថាបពិត្រអ្នកពតមានសេចក្តីទុក្ខ មានតែសេចក្តីសុខម្យ៉ាងអើយអាត្មាភាពរាល់គ្នានេះពិចារណារកមើលអ្នកប្រាជ្ញដែលប្រកបដោយប្រាជ្ញាញាណរាទូទៅក្នុងមនុស្សលោកក្តី ទេវលោកក្តី មិនឃើញមានអ្នកឯណាដែលជាអ្នកឈ្លៀវឆ្លាស់ អាចនឹងឃិតយោងព្រះពុទ្ធសាសនាអោយអំណើតឡើងបាន ហើយអាចញាំញីនូវពាក្យនៃស្តេចមិលិន្ទទូន្នានស្តេចនោះ អោយជ្រះថ្លាបានឡើយបពិត្រមហាសេនទេវបុត្រអើយអាត្មាភាពឃើញតែអង្គលោកនេះឯង ទើបអាចជួយជ្រោមជ្រែងពុទ្ធសាសនានេះ

www.budinst.gov.kh www.elibraryofcambodia.org

បាន សូមអ្នកដ៏មានបុណ្យទទួលនូវពាក្យបដិញ្ញារបស់យើង និងសូមចុះទៅកើតក្នុងមនុស្សលោកនាយកុំខាន ។

កាលបើភិក្ខុសង្ឃ និង ស្តេចអមរិន្ទ្រាធិរាជ ពោលអង្វរ ២-៣ ដងយ៉ាងនេះហើយ ក៏មហាសេនទេវបុត្រមិនអាចនឹងទទឹងទាស់បានឡើយ ហើយក៏ទទួលបដិញ្ញាពោលថា ( គបិ-សក្យាហំ-ភន្តេ ឧត្តរលោកកំពេថអេវវាទិ) បពិត្រព្រះករុណាម្ចាស់ត្រូវចំរើនល្អ ខ្ញុំករុណានឹងទៅកាន់មនុស្សលោកជាប្រាកដមិនខានឡើយកុំព្រួយ តែសូមលោកម្ចាស់ទាំងឡាយទរាយពេលនេះខ្ញុំព្រះករុណាថា បើខ្ញុំព្រះករុណាបានសំណាងអាចនិងរៀបរៀងនូវពាក្យដែលស្តេចបិតាថ្លែងនោះបានហើយនឹងទំនុកបំរុងនូវព្រះពុទ្ធសាសនាផង ។

ព្រះអរហន្តទាំងឡាយ ក៏ត្រេកអរពេញពារសេចក្តីដែលទេវបុត្រនោះ សូមទទួលដំណែកនោះឯងមហាសេនទេវបុត្រនោះ ក៏មានចិត្តត្រេកអរយ៉ាងខ្ពស់ហើយក៏ទទួលបដិញ្ញាថាខ្ញុំព្រះករុណានឹងចុះទៅកើតក្នុងមនុស្សលោកនាយជាប្រាកដមិនខាន ឯភិក្ខុសង្ឃទាំងនោះ លុះបានយកសេចក្តីបដិញ្ញានោះហើយក៏បាត់អំពីស្ថានតាវតិង្សទេវលោកនោះមក ក៏មកប្រាកដក្នុងរក្ខិតលេណក្នុងព្រៃហិមពាន្តនោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះវស្សគុត្តថេរសួរទៅភិក្ខុសង្ឃទាំងពួងថា បណ្ដាភិក្ខុសង្ឃទាំងអស់នេះ មានភិក្ខុណា ១ ដែលមិនបានមកកាន់ទីប្រជុំនេះដែរមានភិក្ខុ ១ អង្គជាអ្នកដឹងក៏ពិតមកវិញថាបពិត្រព្រះថេរដ៏ចំរើន ព្រះរោហនថេរលោកទៅកាន់ភ្នំហិមពាន្តចូលកាន់ឈានសមាបត្តិអស់ ៧ ថ្ងៃ ហើយមិនបានមកកាន់ទីប្រជុំនេះឡើយ យើងខ្ញុំនឹងឲ្យសមណទូតទៅហៅលោកមកឥឡូវនេះ ។

គ្រានោះព្រះរោហនថេរ ក៏ចេញចាកនិរោធសមាបត្តិក្នុងខណៈនោះហើយ ទើបដឹងនូវសេចក្ដីបរិវិតក្ករបស់ព្រះអរហន្តទាំងឡាយទាំង ១០០ កោដិ ថា ព្រះសង្ឃមានកិច្ចត្រូវការ និងហៅរកខ្លួន ដូចនោះហើយក៏អន្តរធានបាត់ចាកភ្នំហិមពាន្តនោះហើយមកប្រាកដក្នុងរក្ខិតលេណក្នុងទីចំពោះមុខព្រះសង្ឃទាំងនោះឯង។ ឯព្រះអរហន្តទាំងឡាយក៏សួរថា នែអាវុសោរោហន ហេតុអ្វីក៏អ្នកមិនមានយកចិត្តទុកដាក់ក្នុងសាសនា ដែលព្រះឆានេះសោះ ព្រះរោហនក៏ទទួលសេចក្ដីផ្ដាំផ្ដែងនោះ និង ព្រះសង្ឃឥតមានប្រកែកឡើយ ។

គ្រានោះព្រះអរហន្តទាំងនោះ ក៏ដាក់ព្រហ្មទណ្ឌកម្មដល់ព្រះរោហន ព្រោះព្រះរោហនមិនយកចិត្តទុកដាក់និងពុទ្ធសាសនានោះឯង តែព្រះរោហនសួរទៅវិញថា បពិត្រព្រះសង្ឃដ៏ចំរើន ព្រះករុណាវាល់អង្គដាក់ព្រហ្មទណ្ឌដល់ខ្ញុំនោះ

www.budinst.gov.kh www.elibraryofcambodia.org

តើត្រូវរវាយធ្វើដូចម្ដេចដើម្បីសង្គ្រោះព្រះវិនៃរោបនេត្យិតបាន ព្រាហ្មណ៍ម្នាក់ឈ្មោះសោមទត្ត នៅក្នុងស្រុក១ ឈ្មោះកជង្គលេ នៅជើងខាងភ្នំហិមពាន្តព្រាហ្មណ៍នោះឯង និងមានកូន ១ ឈ្មោះផា នាគសេនកុមារកើតមកដែលចេះដើរលេងរាល់គ្នា ត្រូវដាក់ព្រហ្មទណ្ឌដល់អ្នកនោះ គឺរោហណត្ថេរទៅបិណ្ឌបាតចង្ហាន់ក្នុងផ្ទះព្រាហ្មណ៍នោះរោហណត្ថេររាល់ៗថ្ងៃនៃឆ្នាំ គឺថាទៅបិណ្ឌបាតនោះ ៧ ឆ្នាំ និង៧០ ថ្ងៃ ហើយក្រោយពីការនាំនាគសេនកុមារនោះរវាយចេញទៅកាន់វត្តវត្តនិយ មកបំបួសរួចស្រេចក្នុងការពណ៌នាអត្ថក៏បានរួចពីការរាជ្យានគរព្រាហ្មណ៍ ក្នុងការនោះ ៦៦ ឯព្រះរោហណត្ថេរ ក៏បានរួចពីបាបរាជ្ជាសង្ឃនោះពុំបានប្រកែកឡើយ ។

ចំណែកការយោគសេនកុមារទេវបុត្រ ក៏ច្យុតិចាកពិភពទេវ-លោកចុះកើតយកបដិសន្ធិក្នុងផ្ទៃ នៃភរិយាសោមទត្តព្រាហ្មណ៍ នៅនៅក្នុងស្រុកកជង្គលព្រាបនោះ ក្នុងវេលានោះឯង ការអស្ចារ្យ៣ប្រការកើតឡើង គឺគ្រឿងសស្ត្រាវុធបណ្ដាលរោចក្រុងរៀងគ្នា ១ ភ្លៀងធ្លាក់ចុះមកក្នុងសកល ឧសរជូវ ១ អាកាសកណ្ដាលឡើងនូវសម្លេងពីកកងរំពងទៅមក ១ ក្នុងការនេះនាគសេនទេវបុត្រចុះកើតយកបដិសន្ធិ ក្នុងគភ៌

របស់មាតានោះក៏រលោរឿងទាំងនេះ ព្រោះដោយបារមីរបស់បបរាសេនទេវបុត្រដែលលោកមកកើតនេះនិងបានទំនុកបំរុងព្រះពុទ្ធសាសនាអោយរុងរឿងគ្រប់ទាំង ៥០០០ វស្សា ។

ចំណែកឯព្រះរោហនថេរ លោកធ្វើនូវគមនាការទៅមកបិណ្ឌបាតក្នុងស្រុកនោះ ចំពោះត្រកូលនោះគ្រប់ ៧ ថ្ងៃ អស់ ៧ ឆ្នាំនិង ១០ ខែ ដោយចំនងនេះមិនដែលខានថ្ងៃណាមួយឡើយ ហើយនិងដែលបាននូវអភិវាទនកម្ម ឬអញ្ជលិកម្ម និងសាមិចិកម្ម ដែលព្រាហ្មណ៍នោះធ្វើគំនាប់គួរសមអ្វីដល់អ្នងនោះគ្មានសោះឡើយ ឃើញបានពៃពាក្យគ្រោតគ្រាតមានពាក្យជេប្រទេចជាដើម ព្រះរោហនថេរតាំងពីចូលទៅបិណ្ឌបាតទៀបផ្ទះព្រាហ្មណ៍នោះប្រមាណ ៧ វស្សា នឹងដែលបានចង្ហាន់អ្វីមាត្រាតែ ១ វែក ក៏គ្មានសោះឡើយ ឬនិងដែលបានយាគូបបរស្ងូម្បីតែ១ត្រឡោកក៏ទេសោះឯសោនុត្តរព្រាហ្មណ៍នោះសោតនឹងដែលចរចាប្រាស្រ័យពាក្យពេចអ្វីដល់ ១ មាត់នោះក៏គ្មាន ។

សត្តន្និវស្សានិអច្ចយេនឯកទិវសំ អពិច្ចថភន្តេពិវាក្យមត្តម្បិលភតិ លុះកន្លងកាលទៅអស់ ៧ ឆ្នាំ ព្រះថេរអ្នកបានពាក្យពោល ១ មាត់ ក្នុងថ្ងៃ ១ នោះបពិត្រលោកម្ចាស់ដ៏ចំរើនសូមលោកម្ចាស់និមន្តទៅប្រោសសត្វឯមុខទៀតចុះ ផ្ទះនេះពេ

www.budinst.gov.kh www.elibraryofcambodia.org

មិនត្រូវការលោកទេ ចំណែកឯព្រះថេរបានឮពាក្យនោះច្បាស់ដូចនោះហើយ លោកងាកត្រឡប់ចាកទីនោះទៅកាន់ទីដទៃទៀតក្នុងថ្ងៃនឹងឯងជួនជាសោនុត្តរព្រាហ្មណ៍ ចេញទៅធ្វើការងារខាងក្រៅភូមិ លុះឃើញព្រះថេរដើរមកក៏សួរថា នែបព្វជិតលោកចូលទៅកាន់ផ្ទះយើងបាននូវវត្ថុអ្វីតិចតួចខ្លះដែរឬទេ ព្រះថេរប្រាប់ថា អើព្រាហ្មណ៍បានខ្លះដែរ ឯព្រាហ្មណ៍នោះបានឮហើយក៏កើតចិត្តទោមនស្ស មិនសប្បាយប្រញាប់ប្រញាល់ទៅឯផ្ទះៗរំពេច ដល់ហើយក៏សួរទៅមនុស្សដែលនៅៗផ្ទះនោះថា នែអ្នកទាំងឡាយ ថ្ងៃនេះឯងរាល់គ្នាបានយកវត្ថុអ្វីដាក់បាត្រអោយអ្នកបួសនោះខ្លះដែរឬ ។ មនុស្សទាំងឡាយឆ្លើយប្រាប់មកវិញថា ទេលោកម្ចាស់យើងរាល់គ្នាគ្មានបានអោយវត្ថុអ្វីតិចតួចទៅអ្នកបួសនោះទេ ឯសោនុត្តរព្រាហ្មណ៍បានឮដូចនោះហើយក៏គិតថា អញនឹងអង្គុយមើលអ្នកបួសនោះ កាលណាបើមកកាន់ផ្ទះអញ ៗ នឹងពោលសង្កត់សង្កិនផ្ចាញ់ផ្ចាល់បព្វជិតនោះ ព្រោះពាក្យមុសាវាទអោយរាងចាលម្តងមើល ។

លុះថ្ងៃស្អែកទៀត ព្រះថេរក៏លិលាចូលទៅកាន់ស្រុកកដង្គុលព្រាមដល់ហើយ ក៏ទៅឈរនៅទៀបបហាត់ទ្វារផ្ទះនៃសោនុត្តរព្រាហ្មណ៍ ៗ នូវវេលាដែលបានឃើញហើយក៏ពាំង

www.budinst.gov.kh www.elibraryofcambodia.org

សួរទៅព្រះថេរនោះភ្លាមថា នែអ្នកបួសកាលពីថ្ងៃម្សិលមិញ គេគ្មានបានអោយវត្ថុអ្វីដល់លោកសោះទេចុះហេតុអ្វីក៏លោកប្រាប់ខ្ញុំថា បានវត្ថុតិចតួចដែរ ព្រះថេរក៏ឆ្លើយប្រាប់ថា នែព្រាហ្មណ៍អើយ អាត្មាភាពចូលមកបិណ្ឌបាតទៀបទ្វារផ្ទះអ្នកនេះយូរយាណាស់ហើយ ប្រមាណជា ៧ ឆ្នាំមកហើយ មិនដែលបានបាយ ១ វែកឬបបរ១ បោយឡើយ ក៏ក្នុងថ្ងៃ១ នោះអាត្មាបានឮពាក្យ ១ មាត់ថា ( អតិច្ឆថ ) ថា លោកម្ចាស់សូមលោកនិមន្តប្រោសសត្វទៅខាងមុខទៀតចុះ ចំណែកអាត្មាបានឮពាក្យនេះហើយក៏មានចិត្តត្រេកអរពេកណាស់ ព្រោះអ្នកផ្ទះនេះគេមិនដែលនិយាយពាក្យ ១ មាត់មករកទេ បានជាអាត្មាប្រាប់ព្រាហ្មណ៍ឯងថា បាននូវវត្ថុតិចតួចដែរគឺបានពាក្យនេះឯង បើយ៉ាងនិងថាអាត្មានិយាយមុសាវាទឯណាក៏បាន ។

ព្រាហ្មណ៍នោះបានឮដូចនោះហើយ ក៏មានសេចក្តីសំវេគ ហើយក៏បែរទៅជាសោមនស្សត្រេកអរពេក ដោយយល់ថាសមណនេះ គ្រាន់តែបានពាក្យគេនិយាយប្រាស្រ័យទៅមួយមាត់ប៉ុណ្ណោះទេក៏ត្រេកអរដែរ ហើយជាពាក្យបដិសេធន៍ឃាត់មិនអោយឈរឈប់នៅផង អួតប្រាប់គេប្រាប់ឯងថាខ្លួនបានរបស់បន្តិចបន្តួចដែរ នេះប្រសិនបើបាននៅបាយត្រីសាច់ឬភោជនាហារអ្វីដែលល្អ១ នោះ ប្រហែលជានឹងត្រេកអរ

ច្រើនជាងនេះទៀតដឹង ព្រាហ្មណ៍គិតដូចនោះហើយ ក៏ហៅទៅប្រពន្ធ អោយយកចង្ហាន់បកដាក់បាត្រព្រះថេរនោះហើយមានសេចក្ដីត្រេកអរក្នុងឥរិយាបថ និងការសង្រួមឥន្ទ្រិយរបស់ព្រះថេរនោះជាយ៉ាងច្រើន ហើយក៏និមន្តព្រះថេរថា លោកម្ចាស់ខ្ញុំមានចិត្តសទ្ធាជ្រះថ្លានឹងលោក សូមនិមន្តលោកមកឆាន់ក្នុងផ្ទះខ្ញុំនេះរាល់ថ្ងៃកុំខាន ។ ព្រះថេរក៏ទទួលនិមន្តដោយតុណ្ហីភាព លុះឆាន់រួចហើយលោកសូត្រទ្រព្យានុមោទន ១ បទ អោយព្រាហ្មណ៍ត្រាប់ពាក្យតាមគួរ ដល់វេលាគួរហើយ ក៏ចំរើនពរអោយព្រាហ្មណ៍នោះ ចុះចាកផ្ទះទៅកាន់អារាមរបស់ខ្លួនក្នុងកាលនោះ ។

ពីនេះទៅនឹងសំដែងពីនាគសេនកុមារ កាលចុះមកបដិសន្ធិជាដំបូងថា កាលមហាសេនទេវបុត្រច្យុតិចាកស្ថានសួគ៌មកកើតក្នុងផ្ទៃនៃភរិយាព្រាហ្មណ៍នោះ ឯភរិយានោះក៏ត្រូវជាញាតិនឹងព្រាហ្មណ៍នោះផង លុះនាងនោះមានគភ៌បាន ១០ ខែ ហើយក៏សម្រាលបុត្រចេញមក មាតាបិតាក៏អោយឈ្មោះបុត្រថានាគសេនកុមារ លុះកុមារនោះចំរើនធំឡើងបាន ៧ ឆ្នាំ ទើបមាតាបិតាប្រាប់កូននោះ អោយរៀនសិល្បសាស្ត្រសម្រាប់ត្រកូលព្រាហ្មណ៍ កូននោះសួរថា ដែលមាតាបិតាអោយខ្ញុំរៀនសិល្បសាស្ត្រៗ នោះ តើមានប៉ុន្មានប្រការ បិតា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាប់ថាមាន ៣ ប្រការ គឺត្រៃទេវនោះឯង ហើយនិងវិជ្ជា ដែលអាចារ្យប្រាប់ក្រៅពីត្រៃវេទនោះទៀត វិជ្ជាទាំងនេះជា គុណសម្រាប់ត្រកូលរបស់ព្រាហ្មណ៍ ឯនាគសេនកុមារក៏ ទទួលប្តេជ្ញាថាមុខជានឹងរៀនមិនខាន ឯសោនុត្តរជាបិតាក៏ អោយអញ្ជើញព្រាហ្មណ៍ម្នាក់ជាអាចារ្យមកបង្រៀន អោយ ទ្រព្យ ១ ពាន់កហាបណ ជារង្វាន់ថ្លៃបង្រៀននោះហើយទើប រៀបចំកន្លែងព្របទាំងតុះពាំង ហើយក្រាលនូវកំរាលយ៉ាងល្អ ក្នុងផ្ទះនោះ រួចហើយអញ្ជើញអាចារ្យនោះអោយឡើងអង្គុយ លើអាសនៈអោយបង្រៀនស្វាធ្យាយត្រៃវេទ អោយនាគសេន កុមារនោះស្តាប់ ឯព្រាហ្មណាចារ្យនោះក៏តាំងស្វាធ្យាយមន្ត ពាថា ឯសេនកុមារបានស្តាប់តែម្តង ក៏ចាំបានគ្រប់ប្រការ ដោយបញ្ញាចក្ខុឃើញជាក់ច្បះ ទៅក្នុងត្រៃវេទទាំង ៣ គ្មាន សល់សោះឡើយ ឯត្រៃវេទទាំង ៣ នោះ មានលក្ខណៈផ្សេង គ្នាដោយសិល្បសាស្ត្រ មានចំណេះសម្រាប់ដឹងនូវដើមឈើ ជាដើមនឹងផ្សេងគ្នាដោយអក្ខរ ដែលជាខ្លឹមសារសម្រាប់ត្រ-កូលរបស់ព្រាហ្មណ៍រាប់អាន ។

ម៉្យាងទៀតនាគសេនកុមារ មានបញ្ញាឆ្លងទៅក្នុងគម្ពីរ ទាំង ៤ គឺគម្ពីរបទក១ គម្ពីរវេយ្យាករណ៍១ គម្ពីរលោកាយត១ គម្ពីរមហាសុបិនលក្ខណ ១ នាគសេនកុមារ មានបញ្ញាចក្ខុ-

www.budinst.gov.kh www.elibraryofcambodia.org

ឃើញព្រោះព្រាតរហូតទៅក្នុងសិល្បសាស្ត្រទាំងអស់ ឯគម្ពីរទាំង ៤ ដែលរាប់មកនេះ មានគម្ពីរឥតិហាសជាគំរប់៥ ក៏គម្ពីរបទកនោះ និយាយដោយបទដែលនឹងសូត្រពិធីជាដើមឈ្មោះថា (បទក) គម្ពីរវេយ្យាករណោនោះ គីនិយាយពីមើលឫក្សនឹងទំនាយឫក្សឆ្នាំខែថ្ងៃយប់ គម្ពីរលោកាយតនោះ និយាយពីលោកនេះថា ព្រះឥសូរ និងបបាព្រហ្មតែងតាំងទុកមករោយកើតជាភ្នំ នឹងដើមឈើ នឹង ទឹកសមុទ្ររោយសម ដោយហេតុនោះ ។ ទើបសន្មតិឈ្មោះថា លោកាយតឯគម្ពីរមហាសុបិនលក្ខណនោះ និយាយពីទំនាយសុបិន (យប់) គម្ពីរឥតិ-ហាសនោះនិយាយពីកិច្ចទាំងឡាយ មានលប់មុខ ងូតទឹក បរិភោគអាហារ នឹងបន្ទោបង់នូវឧច្ចារបស្សាវជាដើម ហៅថាឥតិហាស ។

ក៏ឯគម្ពីរត្រៃវេទគ្គីសិល្បសាស្ត្រដទៃទៀតក្តីដែលព្រាហ្មណាចារ្យរោយស្តាប់នោះ នាគសេនកុមារបានស្តាប់តែម្តងក៏ចាំបានរហូតដោយបញ្ញាចក្ខុ គ្រានោះនាគសេនកុមារក៏សួរចំពោះទៅមាតាបិតាថា បពិត្រអ្នកម្តាយអ្នកឪពុកសិល្បសាស្ត្រទាំងឡាយ សម្រាប់ត្រកូលព្រាហ្មណ៍យើងនេះ អស់ប៉ុណ្ណេះហើយឬ ? នៅមានតទៅទៀត បិតាប្រាប់ថា អើកូនសិល្បសាស្ត្រទាំងឡាយ ដែលសម្រាប់ត្រកូលព្រាហ្មណ៍នោះ អស់

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ BUDDHIST INSTITUTE LIBRARY

ប៉ុណ្ណឹងហើយ ឯនាគសេនកុមារបានស្តាប់ហើយក៏ជូននូវប្រាក់ជារង្វាន់ដែលបង្រៀនវិជ្ជានោះដល់អាចារ្យ ហើយបានទទួលយកក្បួនសាស្ត្រា ដែលអាចារ្យកត់ត្រាសរសេររាយនោះមកហើយ ក៏លាអាចារ្យចុះចាកប្រាសាទចេញទៅលុះដល់ក្នុងទីស្ងាត់ប្លាតចេញពីអារម្មណ៍ផ្សេង ៗ ក៏វាសនាដែលខ្លួនបានសន្សំទុកមកក្នុងកាលមុននោះមកដាស់តឿន ហើយក៏ស្តីពនូវទៀបទ្វារនៃរោងអស់ ៧ ថ្ងៃ ខំពិចារណានូវសិល្បសាស្ត្រដែលខ្លួនរៀនហើយនោះតាំងអំពីដើមរហូតដល់កណ្តាលដល់ទីបំផុតក៏មិនបានឃើញនូវគុណប្រយោជន៍ខ្លឹមសារអ្វីសោះ ក៏កើតវិប្បដិសារីក្តៅក្រហាយស្តាយក្រោយ នឹងអាចទប់មាត់ពុំបានក៏លាន់វាចាថា ឱសិល្បសាស្ត្រដែលអញរៀនមកនេះអើយសូន្យទៅទទេទេ រកប្រយោជន៍អ្វីគ្មានសោះឡើយ ដូចជាសម្រាមស្លឹកឈើទេតើ ។

លំដាប់នោះព្រះរោហនថេរគង់នៅក្នុងទីសេនាសនស្ថានគួរជាទីប្រព្រឹត្តទៅ លោកក៏ដឹងនូវសេចក្តីបរិវិតក្កក្នុងចិត្តនៃនាគសេនកុមារដូចនោះហើយ ក៏តាំងស្លៀកស្បង់គ្រងចីវរកាន់យកនូវបាត្រ ហើយភៀសខ្លួនបាត់ចេញអំពីទីសេនាសនស្ថាននោះទៅ ៗ ឃើញប្រាកដក្នុងទីចំពោះមុខ នៃព្រះ-នាគសេនកុមារក្នុងស្រុកកជង្គលព្រាមង់ណោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះព្រះនាគសេនកុមារ ស្ថិតនៅទៀបមាត់ទ្វាររស់ ៧ ថ្ងៃ ហើយក៏បានឃើញនូវព្រះរោហនលោកអំពីទីចម្ងាយ ក៏មានចិត្តត្រេកអររីករាយយ៉ាងខ្លាំង ព្រោះទាំងបីតិសោមនស្ស កើតឡើងហើយក៏គិតថាដូចនេះ អ្នកបួសនេះមុខជានឹងដឹងនូវវិជ្ជាដែលមានខ្លឹមមានប្រយោជន៍មិនខានឡើយ លុះគិតដូចនេះហើយ ក៏ចូលទៅសួរនូវព្រះរោហនថេរនោះថា មារិស ម្នាលអ្នករកទុក្ខគ្មានហេតុអ្វី ក៏អ្នកស្លៀកដណ្តប់នូវសម្ពត់ដែលគេជ្រលក់ដោយទឹកចត់នេះ ព្រះរោហនប្រាប់ថា ម្នាលកុមារតូចដែលបេអាត្មាធ្វើដូចនេះគេហៅថា អ្នកបព្វជិត ។ ទើបនាគសេនសួរទៀតថា អ្នកបព្វជិតនេះ ប្រែថាដូចម្តេច ព្រះថេរប្រាប់ថា ដែលហៅថាបព្វជិតនេះ ព្រោះអ្នកវៀរចាកបាបនិងវៀរចាកទោសទាំងពួង ។ នាគសេនសួរថា ចុះលោកនឹងបានដឹងនូវសិល្បសាស្ត្រអ្វីខ្លះដែរឬ ។ ព្រះរោហនប្រាប់ថា អាត្មាដឹងនូវសិល្បសាស្ត្រដទៃ ៗ ក្នុងលោកនេះដែរ ។ នាគសេនកុមារសួរទៅទៀតថា ចុះលោកម្ចាស់អាចនឹងប្រាប់ដល់ខ្ញុំបានឬទេ ខ្ញុំនឹងសួរប្រស្នា ១ ចំពោះលោកម្ចាស់ ។ ព្រះថេរឆ្លើយថាប្រាប់បាន កុមារឥតមានទាស់អ្វីទេ។ នាគសេនសួរថា អើលោកម្ចាស់ចុះហេតុអ្វីសក់ទាំងឡាយក្តី ពុកមាត់ពុកចង្កាទាំងឡាយក្តីរបស់លោក ក៏មិនដូចគេរាប់គ្នា លោកម្ចាស់យល់

www.budinst.gov.kh . www.elibraryofcambodia.org

បើឃើញគុណប្រយោជន៍ដូចក្មេង ក៏បានជាកោរសក់ កោរពុកមាត់កោរពុកចង្កាចោល ។ ព្រះថេរប្រាប់ថាម្នាលក្មេងតូច ឯអ្នកបួសទាំងឡាយ បានជាកោរសក់ កោរពុកមាត់ពុកចង្កាចោលចេញនោះ ព្រោះឃើញនៅសេចក្ដីកង្វល់រវល់ទាំងឡាយ ១៦ ប្រការ គឺ ។

១ - អាភរណាភរណបលិពោធ សេចក្ដីកង្វល់ដោយគ្រឿងស្លៀកដណ្ដប់ ។

២ - អាលង្ការបលិពោធ ការកង្វល់ដោយគ្រឿងប្រដាប់កាយ ។

៣ - កម្មារបលិពោធ ការកង្វល់ដោយគ្រឿងដំណើរទៅប្រកបការងារពោល អោយធ្វើរបស់សម្រាប់តែងខ្លួន ។

៤ - បជ្ជនបលិពោធ កិរិយាកង្វល់ដោយកិច្ចដុសខាត់រាងកាយ ។

៥ - និក្ខិបនបលិពោធ សេចក្ដីរវល់ដោយកិច្ចរក្សាដាក់ទុកនូវរបស់ទាំងពួង ។

៦ - ធោវនបលិពោធ សេចក្ដីរវល់ដោយកិរិយាគក់លាងនូវវត្ថុទាំងពួង ។

៧ - មាលាបលិពោធ សេចក្ដីចំពាក់ដោយកិរិយាស្វែងរកផ្កាកម្រង ប្រដាប់ផ្សេង ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

៨ - គន្ធបលិពោធ សេចក្តីរំពល់ដោយកិរិយាស្វែងរកនូវក្លិនក្រអូបមករក្សា ។

៩ - វាសនបលិពោធ សេចក្តីរំពល់ដោយកិរិយាស្វែងរកនូវគ្រឿងរបស់ទាំងពួង ។

១០ - ហរិតកបលិពោធ សេចក្តីកង្វល់ដោយផ្លែស្រ-ល្អរ[1]

១១ - អាមលកបលិពោធ សេចក្តីកង្វល់ដោយផ្លែកន្ទួត[2]

១២ - បត្តិកបលិពោធ សេចក្តីកង្វល់ដោយដី[3] ។

១៣ - សុចិកបលិពោធ សេចក្តីកង្វល់ដោយឈើស្នៀតសក់ ។

១៤ - ពន្ធកបលិពោធ ការរវល់ដោយកិច្ចក្រងសក់ឬចង។

១៥ - កោច្ឆបលិពោធ កិច្ចរំពល់ដោយរលិតសក់ ។

១៦ - កប្បក្ខាបកបលិពោធ សេចក្តីរវល់ដោយរកដាំង កាត់សក់ និងកាត់ខោងសក់រួញ ត្រូវជាបលិពោធ ១៦ ប្រការដូចនេះ ។

ម្យ៉ាងទៀតពួកជង្គងទាំងឡាយ តែងអាស្រ័យនូវរបៀប

---

១.២.៣. កន្ទួត នឹងដីកាំង ៣ ប្រការ នេះជាថ្នាំប្រស់រុក្ខសក់ ។

ឬសសក់ ហើយទំពារស៊ីនូវឬសសក់ទាំងនោះ ធ្វើសក់ទាំងឡាយនោះអោយតែប្រែពណ៌ទៅជាស មនុស្សទាំងឡាយបានឃើញនូវសក់ទាំងនោះមានពណ៌អាក្រក់ដូចនោះហើយ ក៏កើតសេចក្តីក្រៀមក្រំលំបាកចិត្តផ្អិតផ្ទៀងកន្ទក់កន្ទេញ ព្រោះតែសក់អាត្មានេះឯង ម្នាលកុមារតូចសិល្បសាស្ត្រទាំងអស់ជាគុណដ៏ឧត្តមរបស់ជនទាំងឡាយ ដែលជាអ្នកប្រកបក្នុងបលិពោធទាំងនោះ តែងវិនាសសាបសូន្យទៅមិនខាន ។

នាគសេនកុមារបានស្តាប់ពាក្យនោះហើយក៏កើតអស្ចារ្យក្នុងចិត្ត ទើបសួរព្រះថេរថា បពិត្រលោកម្ចាស់ថាចុះសម្ពត់ស្លៀក សម្ពត់ដណ្តប់របស់លោកម្ចាស់នេះ ហេតុអ្វីក៏មិនដូចគេរាល់គ្នា ។ ព្រះថេរប្រាប់ថា ម្នាលកុមារសម្ពត់ស្លៀករបស់អាត្មាប្លែកពីសម្ពត់អ្នកស្រុក ដែលគេបរិភោគនូវកាមគុណឯសម្ពត់អ្នកស្រុកនោះ ក៏ជាទីចំណាំរបស់គ្រហស្ថដែលប្រកបដោយភ័យអន្តរាយទាំងឡាយ ហេតុនេះហើយបានជាសម្ពត់របស់អាត្មាមិនដូចគេរាល់គ្នា ។ នាគសេនកុមារសួរថា បពិត្រអ្នកមិនមានទុក្ខព្រួយ លោកម្ចាស់អាចញ៉ាំងខ្ញុំអោយសិក្សានូវសិល្បសាស្ត្ររបស់លោកនោះបានឬទេ ។ ព្រះថេរប្រាប់ថាអាចបង្រៀនបាន ។ នាគសេនថា បើដូចនោះសូមលោកម្ចាស់ប្រាប់មកឥឡូវនេះ ។ ព្រះថេរថាម្នាលកុមារ អ្នក

www.budinst.gov.kh www.elibraryofcambodia.org

អោយអាត្មាប្រាប់ឥឡូវនេះមិនបានទេ អាត្មានឹងចូលទៅ
ក្នុងបង្អៀកស្រុក ដើម្បីបិណ្ឌបាតព្រលឹម ព្រះនោះនាគសេន
កុមារទទួលយកនូវបាត្រពីព្រះថេរ ហើយនិមន្តព្រះថេរ
អោយចូលទៅកាន់ផ្ទះរបស់ខ្លួន ហើយប្រគេនចង្ហាន់យ៉ាង
ឧត្តមដោយដៃខ្លួនឯង លុះព្រះថេរឆាន់រួចហើយ នាគ
សេនកុមារក៏ពិតព្រះថេរថា លោកម្ចាស់អាចប្រាប់នូវសិល្ប
វិជ្ជាដល់ខ្ញុំបានឬទេ ព្រះថេរឆ្លើយថា អាត្មាអាចនឹងប្រាប់កុមារ
បាន តែថាលុះតែកុមារលះបង់នូវបលិពោធ ១៦ ហើយមាតា
បិតាអ្នក ក៏អនុញ្ញាតបើកអោយទៅនៅជាមួយនឹងអាត្មាផង
នឹងធ្វើនូវភេទជាអ្នកបួសដូចអាត្មាកាន់យកនូវអាការអោយ
សមគួរប្រហែលអាត្មាក្នុងកាលណា អាត្មានឹងប្រាប់នូវវិជ្ជា
ចំណេះដល់អ្នកក្នុងកាលនោះមិនខាន ។

ព្រះនោះនាគសេនកុមារ បានស្តាប់នូវពាក្យនៃព្រះពោ
ហនដែលពោលដូចនោះហើយ ក៏មានសេចក្តីព្រួយទើបឈប់
បរិភោគនូវអាហារហើយក៏បែទៅហៅមាតាបិតា សូមអោយ
អនុញ្ញាតនឹងចូលទៅបួស ។

ឯមាតាបិតានោះ ក៏ព្រមអនុញ្ញាតផ្តល់អោយ ព្រោះគិត
ថាកូនយើងតែរៀនមន្តវិសេសបានហើយកាលណា នឹងត្រ-
ឡប់មកវិញមិនខាន នាគសេនកុមារក៏ពិតព្រះថេរថាមាតាបិតា

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំព្រះករុណាបួសហើយ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំនឹងកាន់តែកន្ទុំរើភេទតាមលោកម្ចាស់ សូមលោកម្ចាស់ប្រាប់នូវសិល្បសាស្ត្រដល់ខ្ញុំកុំខានឡើយ ។

ព្រះរោហនថេរ ក៏ទទួលនាំយកនាគសេនកុមារនោះទៅកាន់ទីសេនាសនស្ថានឈ្មោះវត្តនិយ នឹងវិជម្ពវត្ថុបាននៅក្នុងវិជម្ពវត្ថុនោះ ១ រាត្រី ហើយក៏ចូលទៅកាន់រក្ខិតលេណរោយឃើញប្រាកដនៅមុខព្រះអរហន្តទាំង ១០០ កោដិ គ្រានោះ ព្រះអរហន្តទាំងឡាយក៏ទទួលបំបួសនាគសេនកុមារក្នុងរក្ខិតលេណវិហារនោះឯង វេលានោះ នាគសេនសាមណេរពិតទៅព្រះរោហនថា បពិត្រលោកម្ចាស់ដ៏ចំរើន ផ្នួស ឬភេទរបស់លោកនោះ ខ្ញុំបានទទួលកាន់មកហើយ សូមលោកម្ចាស់ប្រាប់នូវសិល្បសាស្ត្រនោះដល់ខ្ញុំក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះរោហនថេរ ក៏តាំងគិតរំពឹងថា នាគសេនសាមណេរនេះជាតិជាបណ្ឌិតមានប្រាជ្ញាគួរអាត្មានឹងបង្រៀនបិដកណាជាមុន វិន័យ ឬព្រះសូត្រ ឬព្រះអភិធម្មទើបយល់ថាគួរបង្ហាញនូវព្រះអភិធម្មបិដកជាមុនចុះ ហើយក៏ប្រាប់ទៅនាគសេនសាមណេរថា នែសាមណេរចូលអ្នករៀនយកនូវសិល្បសាស្ត្រនេះចុះ ព្រះថេរក៏តាំងសំដែងនូវព្រះអភិធម្ម ៧ គម្ពីរគឺធម្មសង្គណី ១ វិភង្គ ១ ធាតុកថា ១ បុគ្គលបញ្ញត្តិ ១

www.budinst.gov.kh www.elibraryofcambodia.org

កថាវត្ថុ ១ យមក ១ បដ្ឋានមហាបករណ៍ ១ រួមគ្នាត្រូវជា ៧ គម្ពីរ។ ឯព្រះរេវតាចារ្យនោះ បានបញ្ចេញក្តីក្រឹតឡើងភ្លឺ ព្រោងព្រាយដល់ព្រាហ្មណ៍សង្ស័យ ព្រាហ្មណ៍ស្តាប់តែម្តងក្នុងសត្ត-ប្បករណាភិធម្មទាំង ៧ គម្ពីរនោះ ក៏វាចយល់បានដូចសេចក្តីថា កាលសម្តេចព្រះជិនស្រីហ៍ទ្រង់ត្រាស់ទេសនា ក្នុងគម្ពីរអភិធម្មសង្គណីមានដើមថា កុសលាធម្មា អកុសលាធម្មា អព្យាកតាធម្មា ដូចនេះ គម្ពីរនេះប្រដាប់ដោយតិកមាតិកានិងទុកមាតិកាយ៉ាងនេះ ។ ក្នុងគម្ពីរវិភង្គនោះ ប្រដាប់ដោយចំណែក ១៨ យ៉ាង មានចំណែកនៃខន្ធ ៥ ជាដើម។ ក្នុងគម្ពីរធាតុកថានោះ មានសេចក្តីចែកដោយបទ ១៤ យ៉ាងមានដើមថា សង្គហោ អសង្គហោ ដូចនេះជាដើម ។ ក្នុងគម្ពីរបុគ្គលបញ្ញត្តិមានចំណែកដោយបញ្ញត្តិ ៦ យ៉ាង មានខន្ធបញ្ញត្តិ និងអាយតនបញ្ញត្តិជាដើម ។ ក្នុងគម្ពីរកថាវត្ថុនោះ មានសូត្រ ១០០០ សូត្រ ជាសកវាទី ៥០០ សូត្រ បរវាទី ៥០០ សូត្រ ។ ក្នុងគម្ពីរយមកនោះចែកជា ១០ បទ មានមូលយមក និង ខន្ធយមកជាដើម។ ក្នុងគម្ពីរមហាបដ្ឋាននោះ ចែកដោយបច្ច័យ ២៤ មានហេតុបច្ច័យ និង អារម្មណបច្ច័យជាដើម រួមគ្នាទាំងអស់ត្រូវ ៧ គម្ពីរ ។

ឯព្រាហ្មណ៍ពោធិឃោសនោះ ក៏បានរៀនមន្តព្រះអភិធម្មទាំង ៧ គម្ពីរ តែ ១ ខែ ក៏ចាំស្ទាត់គ្រប់បទទាំងអស់

www.budinst.gov.kh www.elibraryofcambodia.org

ហើយទើបអង្វរឃាត់ទៅព្រះរោហនថេរ ជាព្រះឧបជ្ឈាយ៍វិញ ថាសូមព្រះករុណាមេត្តាប្រាប់តែប៉ុណ្ណឹងសិនចុះ កុំអាលពោលតទៅទៀតឡើយ ខ្ញុំព្រះករុណានឹងរៀនទន្ទិញនូវអត្ថប៉ុណ្ណេះអោយរព់មាត់ជាមុនសិន ហើយក៏នាគសេនសាមណេរចូលទៅក្នុងរោងសំរាប់ប្រជុំ ទើបពិចារណានូវព្រះអភិធម្មថា ឱហ្ន ដូចអាត្មាគិតទៅក្នុងបទដែលថា កុសលាធម្មា អកុសលាធម្មា និងអព្យាកតាធម្មានេះដូចម្តេច នាគសេនចំរើនពិចារណានូវបាឡី ព្រមទាំងអត្ថកថា អស់វារម្តងហើយក៏ឃើញសេចក្តីថា កុសលាធម្មានេះ មានអត្ថាធិប្បាយថាយ៉ាងនេះ អកុសលាធម្មាមានអត្ថាធិប្បាយថាយ៉ាងនេះ អព្យាកតាធម្មាមានអត្ថាធិប្បាយថាយ៉ាងនេះ លុះឃើញសេចក្តីដូចនោះហើយក៏ចូលទៅកាន់សំណាក់ព្រះអរហន្តទាំង ៧០០ កោដិ ហើយពិត្រព្រះអរហន្តទាំងនោះថា បពិត្រព្រះករុណាព្រះអាំងព្យាយដ៏ចំរើន ខ្ញុំព្រះករុណានឹងសំដែងនូវព្រះសត្តបករណាភិធម្ម ដោយសេចក្តីពិស្តារប្រគេនព្រះករុណាគ្រប់អង្គស្តាប់ ក្នុងកាលឥឡូវនេះ ព្រះអរហន្តទាំងឡាយឆ្លើយថា នាគសេនយើងរាល់គ្នាពេញចិត្តព្រោះអរពេកណាស់ចូលអ្នកសំដែងមក ។

ព្រោះនោះនាគសេនសាមណេរដ៏មានអាយុ ក៏តាំងសំដែង

www.budinst.gov.kh www.elibraryofcambodia.org

នូវព្រះសរីរធាតុទាំង ៧ គាវុត ដោយការតោងឈើពិដាររាស់ ៧ ជាន់
ហើយចប់ ឯផែនដីក៏ញាប់ញ័រឡើងទៅ ទេវតាទាំងឡាយក៏ហោ៖
សោបសក្សិរីពកាល សក្ការបូជាដោយសម្ពុទ្ធការ ដោយសេរី-
ភាពបារមី នៃតាបសនោះ កាលព្រះអង្គអាះដៃសរសើរគុណ
គុណព្រះពុទ្ធគុណព្រះធម៌តាបសនោះ ឯក្មេងពេលនោះវិញ ក៏ត្រូវ
ទោសរបស់ត្រូវបញ្ជា ចំណែកតាបសទាំងនោះ ១០០ កោដិ
ក៏ត្រូវស្ងួតកាត់កាលដល់តាបសនោះយ៉ាងអត់ ព្រះនាគសេន
តាបសនោះក៏ត្រូវគ្រប់ ២០ វស្សា រួចហើយ ព្រះ-
ពុទ្ធទាំងឡាយ លោកក៏ត្រូវឧបសម្បទជាភិក្ខុភាវ
ឡើងក្នុងសាលឧបោសថក្នុងវត្តលេណ ព្រះព្រះនាគសេន
បានឧបសម្បទហើយ កន្លងរាត្រី ១ ទៅ ក៏ទៀបភ្លឺផ្សេងស្លៀក
ស្បង់ ការយកបាត្រ និងចីវរ ចូលទៅបិណ្ឌបាត្រក្នុង
ក្រុងក្នុងសម័យព្រឹកព្រលឹមជាមួយព្រះឧបជ្ឈាយ៍ទៅ ព្រះនាគ
សេនក៏បានបរិវិតក្កកើតឡើងក្នុងចិត្តថា ឱ ព្រះឧប-
ជ្ឈាយ៍របស់អញនេះខ្លៅណាស់តើ ចេះដឹងតែព្រះពុទ្ធវចន
អភិធម្មប៉ុណ្ណោះទេ និងបានដឹងដល់គាថាបាលីជាពុទ្ធវចន
ដទៃ ៗ ទៀតនោះមិនមានឡើយ ។

ព្រោះនោះព្រះរោហណថេរឧបជ្ឈាយ៍ បានដឹងនូវសេច-

www.budinst.gov.kh www.elibraryofcambodia.org

ព្រឹតក្ករពត់អោតតោរដូចនោះហើយ ទើបហៅព្រះនាគសេនមកហើយប្រាប់ថា នែនាគសេនសេចក្ដីត្រិះរិះរបស់អ្នកឯងយ៉ាងនឹងមិនគួរដល់អ្នកផងមិនគួរដល់ខ្ញុំផងឯព្រះនាគសេនបានស្ដាប់ដូចនោះ ហើយក៏អស្ចារ្យក្នុងចិត្តថា ព្រះឧបជ្ឈាយ៍របស់អាត្មានេះ មិនមែនជាបុគ្គលល្ងង់ឡើយ គឺជាបណ្ឌិតពិត ព្រោះលោកអាចដឹងនូវគំនិតនៃអញ បើយ៉ាងនេះគួរអាត្មាអញនឹងគួរទៅសូមខមាទោស អោយលោកអត់ទោសព្រោះពិតដូចនោះហើយ ក៏ចូលទៅថ្វាយបង្គំសូមខមាទោសថា បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនសូមព្រះគុណអត់នូវទោសនោះដល់ខ្ញុំព្រះករុណា ១ នឹងលែងគិតយ៉ាងនឹងទៀតនឹងលែងធ្វើយ៉ាងនឹងហើយ ។

ព្រះរោបានថេរប្រាប់មកវិញថា នែនាគសេន ខ្ញុំនឹងមិនអត់នូវទោសនេះអោយអ្នកឯងទេ នៃ នាគសេនមានមហាក្សត្រ ១ព្រះអង្គ ទ្រង់ព្រះនាមថាមិលិន្ទរាជសោយរាជ្យសម្បត្តិក្នុងបូរីឈ្មោះសាគលរាជធានី បើអ្នកឯងអាចនឹងទៅទូន្មានស្ដេចនោះអោយជ្រះថ្លាក្នុងពុទ្ធសាសនាបាន ទើបយើងនឹងអត់ទោសអោយអ្នកបាន ។

បពិត្រព្រះករុណាដ៏ចំរើន ចុះក្នុងវស្សាទាំង ៣ ខែ នេះ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវរោយខ្ញុំព្រះកុមារនេះទៅចាំវស្សា ក្នុងសំណាក់លោកម្ចាស់នោះ ព្រះរោហណប្រាប់ថា ម្នែ នាគសេនឯងមានព្រះថេរ ១ អង្គឈ្មោះថា អស្សគុត្តថេរលោកគង់នៅក្នុងទីសេនាសនស្ថានឈ្មោះវត្តនីយ អ្នកឯងចូលទៅថ្វាយបង្គំព្រះថេរនោះ ហើយពិតលោកថាបពិត្រលោកម្ចាស់ដ៏ចំរើន ឧបជ្ឈាយ៍នៃខ្ញុំ លោកសួរមកព្រះករុណាម្ចាស់ថា លោកម្ចាស់មានកំលាំងរហ័សរហួនមិនមានអាពាធ មិនមានរោគអ្វីទេឬ ហើយអ្នកឯងចូរនៅចាំវស្សាក្នុងសំណាក់នៃព្រះថេរអង្គនោះចុះ ។

ព្រះនាគសេនថេរបានស្តាប់ពាក្យព្រះឧបជ្ឈាយ៍ហើយធ្វើបទក្សិណានូវព្រះឧបជ្ឈាយ៍ ៣ ដង ហើយក៏ចេញទៅចុះដល់ហើយថ្វាយបង្គំនូវព្រះអស្សគុត្តថេរ ហើយអង្គុយនៅក្នុងទីសមគួរមួយ ទើបពោលតាមពាក្យព្រះឧបជ្ឈាយ៍ដែលផ្តាំមកនោះ ។

គ្រានោះព្រះអស្សគុត្តថេរក៏សួរទៅព្រះនាគសេនថា អ្នកឯងឈ្មោះអ្វី ព្រះនាគសេនពិតទៅវិញថា ខ្ញុំឈ្មោះនាគសេន ព្រះអស្សគុត្តថេរសួរទៀតថា ចុះអ្នកខ្ញុំនេះឯងឈ្មោះអ្វី ព្រះនាគសេនពិតថា បពិត្រព្រះករុណាដ៏ចំរើន ព្រះឧបជ្ឈាយ៍ខ្ញុំស្តាប់ឈ្មោះលោកម្ចាស់ច្បាស់ ព្រះអស្សគុត្តសួរទៀតថា ចុះ

www.budinst.gov.kh www.elibraryofcambodia.org

ឧបជ្ឈាយ៍របស់អ្នកឯងឈ្មោះអ្វី ព្រះនាគសេនឆ្លើយថាឈ្មោះព្រះឧបជ្ឈាយ៍ខ្ញុំគឺព្រះករុណាម្ចាស់ស្គាល់ច្បាស់ហើយ ។

ព្រះអស្សគុត្តថេរក៏ទទួលថាត្រូវហើយនាគសេន ហើយលោកគិតថាឯនាគសេននេះ មានប្រាជ្ញាច្រើនពេកណាស់ជាអ្នកប្រាជ្ញ ហើយមានប្រាថ្នានឹងមកនៅរៀនព្រះត្រៃបិដកអំពីសំណាក់អាត្មា(១) នេះ ដូចនេះអញនឹងបន្ទាបបន្ថោះនូវនាគសេននេះដោយមិននិយាយផង ធ្វើហាក់ដូចជាដាក់នូវទោសព្រហ្មទណ្ឌ ។

ចាប់ដើមតាំងអំពីថ្ងៃនោះទៅ ព្រះអស្សគុត្តក៏ឈប់និយាយនឹងព្រះនាគសេនអស់ត្រៃមាស ( ៣ ខែ ) ឯព្រះនាគសេន ក៏ចេះតែធ្វើវត្តប្រតិបត្តិបោសសំអាតនូវទីបរិវេណ នឹងតាំងដិកលំនូវទឹកលុបលាងស្រប់ព្រះភក្ត្រ ដើម្បីព្រះមហាថេរនោះឥតមានអោយខ្វះខាតឡើយ ក្នុងរវាង ៣ខែ ។ ចំណែកឯព្រះអស្សគុត្តថេរទីកន្លែងបរិវេណឯណា ដែលព្រះនាគសេនបោសច្រាសហើយ លោកក៏ទៅបោសច្រាសលើទីនោះទៀត

---

១ ) ក្នុងសេចក្ដីប្រែរយថាព្រះអស្សគុត្តគិតថា ដូចនេះព្រះត្រៃបិដកនេះ អាត្មាអញចេះពុំបានចប់សព្វគ្រប់ទេ ពិតមែនតែខ្លួនបានសំរេចមគ្គ នឹងផល តែថាចំណែកព្រះត្រៃបិដកចេះដឹងយ៉ាងកន្ទួលបទេ មិនអាចប្រាប់ចប់សព្វគ្រប់បានឡើយ បើដូចនោះ អាត្មានឹងធ្វើជាស្ងៀមពុំស្ដីនឹងភិក្ខុនេះឡើយ។

www.budinst.gov.kh www.elibraryofcambodia.org

ទឹកឯណាដែលព្រះនាគសេនដាក់ទុកហើយនោះ លោកក៏ចាក់ចោលទៅ ហើយយកទឹកឯទៀតមកដាក់ពេញត្រឡប់មកវិញ ។

ក្នុងសម័យមួយនោះ នាងឧបាសិកាម្នាក់ជាអ្នកឧបដ្ឋាកបំរើព្រះអស្សគុត្តថេរនោះប្រមាណ ៣០វស្សាមកហើយ ព្រឹកមួយនោះ ក៏ចូលទៅរកព្រះអស្សគុត្តថេរ ហើយពោលថា លោកម្ចាស់ក្នុងសំណាក់របស់លោកនេះ មានភិក្ខុដទៃជាអាគន្តុកមកចាំវស្សានៅ ១ ទីនេះដែរឬ ព្រះអស្សគុត្តថេរប្រាប់ថាមានភិក្ខុ ១ អង្គឈ្មោះថា នាគសេននោះ ឧបាសិកាពោលថា បើដូច្នោះសូមនិមន្តលោកម្ចាស់ ហើយនឹងព្រះនាគសេនភិក្ខុនោះ ទៅឆាន់ផ្ទះខ្ញុំព្រះករុណាឯនោះ ក្នុងវេលាព្រឹកស្អែកនេះកុំខាន ។

ព្រះអស្សគុត្តថេរក៏ព្រមទទួលនិមន្តដោយតុណ្ហីភាព លុះដល់វេលាព្រឹកឡើង ព្រះអស្សគុត្តថេរ នឹង ព្រះនាគសេនក៏កាន់យកនូវបាត្រនឹងចីវរ ហើយចូលទៅកាន់ផ្ទះនៃនាងឧបាសិកានោះតាមសេចក្ដីនិមន្ត ។

ឯនាងឧបាសិកា ក៏បានចាត់ចែងនូវបណីតភោជនាហារប្រគេនដល់ព្រះថេរទាំងពីរអង្គនោះដោយដៃខ្លួនឯង លោកក៏បានឆាន់ឆ្អែតបរិបូណ៌ លុះឆាន់រួចហើយ ព្រះអស្សគុត្តក៏

www.budinst.gov.kh www.elibraryofcambodia.org

ង្គាប់ទៅព្រះនាគសេនថា នៃនាគសេន ចូលអ្នកសំដែងធម៌
ទសនាអនុមោទនាភត្រដល់នាងឧបាសិកានេះ លុះបង្គាប់
ហើយលោកក្រោកឡើងចាកទីនោះ ត្រឡប់ទៅទីលំនៅវិញ
នាងឧបាសិកានោះក៏ និយាយពិតថេរវាចាព្រះនាគសេនថា
លោកម្ចាស់ខ្ញុំនេះជាស្រីចាស់ជរាហើយ ចូលចិត្តចង់ស្តាប់
ពធម៌ដែលជ្រាលជ្រៅជាគម្ពីរភាពបន្តិច ដើម្បីនឹងបាន
ំរើនសតិបញ្ញា ចំណែកព្រះនាគសេនលុះបានស្តាប់ហើយក៏
សំដែងអនុមោទនកថាដោយគាថាជាគម្ពីរភាព អោយនាងឧបា
សិកានោះស្តាប់ ឯនាងឧបាសិកានោះលុះបានស្តាប់ហើយក៏
បានធម្មចក្ខុកើតឡើងហើយប្រាសចាកធូលី គឺរាគពណ្ណារក
មន្ទិលមិនមាន គឺឃើញច្បាស់ទៅក្នុងខ្សែធម៌ដែលព្រះថេរ
សំដែងថា យំកិញ្ចិសមុទយធម្មំ សព្វន្តំនិរោធធម្មំ សេចក្តី
ថា ធម្មជាតិឯណាមួយ មានសភាវជាដែនប្រជុំកើតឡើងព្រម
ហើយ ធម្មជាតិទាំងពួងនោះ ជានិរោធធម៌គឺថាជាសភាវរលត់
បាត់ទៅ។ កាលដែលនាងឧបាសិកាបានស្តាប់ធម៌ទេសនារបស់
ព្រះនាគសេនថេរហើយ បានចប់ធម៌ទេសនាវេលាណាក៏នាង
នោះបានត្រាស់ដឹងនូវសោតាបត្តិផលក្នុងវេលានោះឯង ។

គ្រានោះព្រះអស្សគុត្តថេរ លោកគង់នៅក្នុងរោងជាទី

www.budinst.gov.kh www.elibraryofcambodia.org

ប្រជុំ បានដឹងនូវសេចក្ដីវិតក្កនៃព្រះនាគសេនថេរ ដោយព្រះនេត្រជាទិព្វ ហើយញុំាងសាធុការអោយប្រព្រឹត្តទៅថា សាធុ សាធុនាគសេន ឱហ្ន៎នាគសេននេះហានសាពិបញ្ហា ជាអ្នកញុំាងប្រយោជន៍អោយសម្រេច ។ ក៏ឯប្រជុំជនទាំងពីរចំណែក គឺ មនុស្ស នឹង ទេវតា ព្រះនាគសេនអាចធ្វើអោយបរិពារប្រាសចាកសេចក្ដីសង្ស័យទៅ បានដោយបាញ់ទៅនូវព្រួញតែ ១គ្រា ពោលគឺសំដែងធម៌ទេសនាតែម្ដង អោយអ្នកឧបាសិកានោះស្ដាប់ នាងក៏អាចបំលាយនូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសទៅបាន ទេវតាទាំងឡាយច្រើនជាងពាន់ ក៏មានចិត្តរីករាយរះដែលសរសើរបញ្ញាបារមីជាអព្ភរិយឱឡារិកថា ឃើរើព្រះនាគសេនថេរមានអាយុ លោកសំដែងអនុមោទនាធម៌បិណ្ឌពប្បើព្រោះអរណោស់ដោយគម្ពីរគាថាដ៏ជ្រាលជ្រៅ យ៉ាងមៀតងលើវិចិត្រនៃធម្មន៍ដ៏ជាទិព្វ ក៏រោយរាយព្រុំពុធុះឃកជាសក្ការបូជាក្នុងកាលដែរចប់ធម៌ទេសនានោះឯង ។

ព្រះនាគសេនថេរ បានធ្វើនូវអនុមោទនាដោយគម្ពីរគាថាចប់ហើយ ក៏ចំរើនពរលានាងឧបាសិកានោះក្រោកចាកអាសនចូលទៅកាន់សំណាក់ព្រះអស្សគុត្តថេរ លុះដល់ហើយក៏ក្រាបថ្វាយបង្គំចរង្គុយនៅក្នុងទីដ៏សមគួរហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះព្រះអស្សគុត្តថេរ លោកនិយាយនឹងព្រះនាគសេនថា នែនាគសេនភិក្ខុ អ្នកមកនៅក្នុងទីនេះក៏យូរក្រៃលហើយ ចូលអ្នកទៅកាន់ក្រុងបាតលិបុត្រចុះ ព្បិទមានព្រះថេរ ១ អង្គ នាមថា ធម្មរក្ខិតលោកតាំងនៅក្នុងវត្ត១ ឈ្មោះថាអសោការាម ស្ថិតនៅក្នុងទិសខាងជើង នៃក្រុងបាតលិបុត្រនោះ ហើយអ្នកចូលរៀនយកនូវពុទ្ធវចន គឺព្រះត្រៃបិដកអំពីសំណាក់នៃព្រះធម្មរក្ខិតថេរនោះចុះ ។ ព្រះនាគសេនក៏ពិតថាបពិត្រព្រះករុណាដ៏ចំរើន ពីបីនេះទៅនគរបាតលិបុត្រចម្ងាយប៉ុន្មាន ។ ព្រះអស្សគុត្តថេរក៏ប្រាប់ថា ពីទីនេះទៅដល់នគរបាតលិបុត្រនោះចម្ងាយ ១០០ យោជន៍ នាគសេន ទើបព្រះនាគសេនពិតទៀតថា បើផ្លូវឆ្ងាយម្ល៉េះ ក្រែងពីបាកដោយចង្ហាន់បិណ្ឌបាតណាស់ដឹង ក្នុងកណ្ដាលផ្លូវនោះព្រះករុណា ។ ព្រះអស្សគុត្តថេរប្រាប់ថា មិនអីទេនាគសេន អ្នកចូលទៅចុះអ្នកនឹងបាននូវអាហារបិណ្ឌបាតព្រមទាំងម្ហូបចំណើយ៉ាងច្រើនមិនខានឡើយកុំព្រួយ ព្រះនាគសេនបានទទួលស្ដាប់នូវពុទ្ធដិកានៃព្រះអស្សគុត្តថេរហើយក៏ថ្វាយបង្គំជៀសចេញទៅ ។

គ្រានោះមានសេដ្ឋីម្នាក់ជាអ្នកនៅទៀបក្រុងបាតលិបុត្រ សេដ្ឋីនោះចេញទៅជួញក្នុងជនបទទាំងឡាយ លុះលក់ដូរួចហើយក៏ប្រមូលរបស់ធំតូច ផ្ទុកក្នុងរទេះទាំង ៥០០ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ត្រឡប់ចូលទៅកាន់នគរបាដលីបុត្រវិញ សេដ្ឋីនោះក៏បានឃើញ ព្រះនាគសេនត្ថេរវិលត្រឡប់មកហើយ ទើបទៅរាំងបញ្ឈប់រទេះ ទាំងនោះ ហើយបានពោលសួរទៅកាន់ព្រះនាគសេនថេរថា ព្រះករុណាម្ចាស់និមន្តទៅកាន់ទីណា ។

បពិត្រមហាសេដ្ឋីគហបតី អាត្មាភាពនោះប្រាថ្នានឹងទៅឯក្រុងបាដលីបុត្រនោះ ។ ឱបើលោកម្ចាស់និមន្តទៅក្រុងបាដលីបុត្រនោះសូមនិមន្តទៅជាមួយនឹងខ្ញុំព្រះករុណាឯណោះទើបសប្បាយ ។ ឱចំរើនពរអ្នកគហបតី ពាក្យអ្នកពោលនេះពីរោះពិរោះទេ អាត្មាភាពនឹងសូមទៅជាមួយផង ។ លំដាប់នោះ នាយពាណិជ្ជគហបតីបានពិនិត្យមើលគ្រឿងប្រក្រតីភោជន ដែលព្រះនាគសេនត្ថេរក៏ដឹងចិត្តថាត្រឹមហើយ ក៏ទាល់ចិត្តនឹងនិមន្ត ភោជនាហារប្រណីតឆ្ងាញ់ ដោយចិត្តជ្រះថ្លាឯងប្រគេនទៅព្រះថេរនោះ លោកទទួលឆាន់ហើយ ទើបសេដ្ឋីថាបពិត្រព្រះករុណាម្ចាស់ បើព្រះករុណាត្រូវការដោយវត្ថុអ្វី សូមលោកម្ចាស់ប្រាប់ដល់ខ្ញុំព្រះករុណាកុំអាង ។

កាលបើនាគសេនត្ថេរ បានធ្វើភត្តកិច្ចរួចស្រេចហើយ គ្រានោះ ឯមហាសេដ្ឋីក៏អង្គុយនៅលើអាសនៈទាប ១ នៅទៀបខាង លុះអង្គុយនៅហើយ ក៏ថ្វាយបង្គំសួរទៅព្រះថេរថា

www.budinst.gov.kh www.elibraryofcambodia.org

បពិត្រព្រះករុណាម្ចាស់ លោកម្ចាស់មាននាមឈ្មោះដូចម្ដេចខ្ញុំចង់ស្គាល់ ។ អាត្មាភាពឈ្មោះថានាគសេន ។ ចុះព្រះករុណាម្ចាស់បានចេះចាំពុទ្ធវចនខ្លះដែរឬទេ។អាត្មាភាពបានរៀនសូត្រចេះដឹងតែព្រះអភិធម្មបិដកទេអ្នក ឯមហាសេដ្ឋីក៏លាន់មាត់ថាអើបើដូចនោះ យើងទាំង ២ អ្នក ក៏ជាអ្នកមានលាភល្អពេកណាស់ចំណែកខ្ញុំព្រះករុណាក៏បានរៀនតែព្រះអភិធម្មនេះដែរលោកម្ចាស់ទៀតក៏បានដឹងតែព្រះអភិធម្មនេះដូចគ្នា យើងនឹងសិក្សាស្វាធ្យាយនូវព្រះអភិធម្មដោយកាលដ៏សមគួរ សូមអារាធនាលោកម្ចាស់ សំដែងនូវបទព្រះអភិធម្មទេសនាបន្តិចទៅមើល គ្រានោះព្រះនាគសេនថេរក៏តាំងផ្ដើមសំដែងឡើងនូវព្រះអភិធម្មទេសនា អោយមហាសេដ្ឋីនោះស្ដាប់ ឯមហាសេដ្ឋីលុះបានស្ដាប់ហើយ ក៏មានចិត្តត្រេកអរយ៉ាងខ្ពស់នឹងមានសោមនស្សជាពដ៏រីករាយឥតឧបមា បានទាំងធម្មចក្ខុពីបញ្ញាចក្ខុកើតឡើង អាចហាមឃាត់នូវធុលីជាមន្ទិលបានហើយឃើញជាក់ច្បាស់នូវធម្មជាតិនិមួយដែលជាទីប្រជុំកើតព្រមឡើងថា ធម្មជាតិទាំងនោះតែងតែរលត់បាត់បង់ទៅជាធម្មតា លុះចប់ធម្មទេសនាហើយមហាសេដ្ឋីក៏បង្គាប់ទាសកម្មកររបស់ខ្លួនអោយទឹមរទេះទាំង ៥០០ បរបណ្ដោយចេញទៅតាមផ្លូវឆ្ងាយជាមួយនឹងព្រះនាគសេន លុះបានជិតដល់ទៅ

www.budinst.gov.kh www.elibraryofcambodia.org

ក្រុងបាតលិបុត្រហើយ មហាសេដ្ឋីក៏ពោលទៅព្រះថេរថា លោកម្ចាស់ផ្លូវនេះជាផ្លូវចូលទៅកាន់វត្តអសោការាម លោកម្ចាស់ចូលនិមន្តទៅតាមផ្លូវនេះចុះ តែមុនដែលនឹងនិមន្តទៅនោះ សូមព្រះករុណាឲ្យទាននូវពរដល់ខ្ញុំព្រះករុណាសិន ទើបព្រះនាគសេនសួរទៅវិញថា បពិត្រមហាសេដ្ឋីគហបតី ពរនោះជាអ្នកបួសជាភិក្ខុ នឹងត្រូវឲ្យពរដូចម្ដេចដល់អ្នក មហាសេដ្ឋីពោលទៅវិញថា លោកម្ចាស់ ពរឯណាដែលជារបស់គួរនឹងលោកម្ចាស់ឲ្យបាន សូមលោកម្ចាស់ប្រទាននូវពរនោះដល់ខ្ញុំព្រះករុណា ទើបព្រះនាគសេនពោលថា បើដូច្នោះចូរអ្នកទទួលនូវពរគឺកុសលនោះចុះ អ្នកចូរកុំធ្វេសប្រហែសភ្លេចខ្លួនក្នុងការកុសលនោះឡើយ លុះនោះទើបមហាសេដ្ឋីបានសេចក្ដីជ្រះថ្លា ហើយបើកយកសំពត់កម្ពលក្រហមមួយផ្ទត់បណ្ដោយប្រមាណ ១៦ ហត្ថ ទទឹង ៨ ហត្ថ ចូលទៅប្រគេនដល់ព្រះនាគសេនៗ ក៏បានទទួលយកនូវសំពត់កម្ពលនោះដោយសេចក្ដីអនុគ្រោះរួចហើយ ក៏មហាសេដ្ឋីបានបីតិសោមនស្សយ៉ាងខ្លាំង រួចទទួលយកនូវសេចក្ដីប្រាថ្នានឹងព្រះនាគសេនថេរ ហើយធ្វើនូវប្រទក្សិណក្រាបថ្វាយបង្គំលាទៅកាន់ក្រុងបាតលិបុត្រក្នុងគ្រានោះឯង ។ ឯព្រះនាគសេនថេរក៏ចូលទៅកាន់វត្តអសោការាម ដែលជាទីនៅនៃធម្មរក្ខិតថេរ

www.budinst.gov.kh www.elibraryofcambodia.org

នេះ លុះដល់ហើយ ក៏ថ្វាយបង្គំសូមពិតព្រះថេរនេះថាបពិត្រ លោកម្ចាស់ដ៏ចំរើន សូមព្រះករុណាមេត្តាប្រោសប្រាប់នូវពុទ្ធ វចនដល់ខ្ញុំព្រះករុណាដោយសេចក្តីអនុគ្រោះ ។ ក្នុងវេលា នោះជួនជាជួបនិងព្រះថេរ ១អង្គ ឈ្មោះពិស្សទត្ត នៅឯស្រុក ពាឡបណរិទ្វីប ពីកោះលង្កា បានរៀនពុទ្ធវចនជាសីហឡភា សាក្នុងលង្កាទ្វីបនោះចប់សព្វគ្រប់ហើយ តែប្រាថ្នានឹងមក រៀននូវពុទ្ធវចនជាមគធភាសា ហើយក៏ដោយសាសំពៅគេ ឆ្លងបកកាន់ជម្ពូទ្វីបនេះ ចូលទៅកាន់សំណាក់ព្រះធម្មរក្ខិត ធ្វើ អេរត្យការ ហើយទើបអង្គុយនៅក្នុងទីនោះ ក៏បានឮសំដីព្រះ នាគសេនពិតសូមរៀនពុទវចនដូចនោះដែរ ទើបព្រះពិស្សទត្ត ក៏ទូលពិតទៅព្រះធម្មរក្ខិតថេរថា បពិត្រព្រះករុណាម្ចាស់ដ៏ចំ- រើន ខ្លួនខ្ញុំនេះរេករពីស្រុកឆ្ងាយពេកណាស់ ប្រាថ្នានឹងរៀន ពុទឡវចនដែរ សូមព្រះករុណាមេត្តាប្រោសប្រាប់នូវពុទ្ធវចន នោះដល់ខ្ញុំកុំខាន ឯព្រះធម្មរក្ខិតថេរ ក៏បែរទៅនិយាយនឹងព្រះ នាគសេនថា នៃនាគសេន អ្នកចូលរៀននូវពុទ្ធវចនជាមួយគ្នា និងពិស្សទត្តនេះចុះ ត្រូវស្វាធ្យាយទន្ទេញអោយព្រមគ្នាតែ ម្តងទៅ កុំមានសេចក្តីអផ្សុកធុញទ្រាន់នឹងគ្នាឡើយ ទើបព្រះ នាគសេនពិតទៅវិញថា ខ្ញុំព្រះករុណា មិនអាចរៀនពុទ្ធវចន ព្រមគ្នា ដោយអ្នកពោលនូវពាក្យជាសីហឡភាសានោះទេ

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះព្រះពិស្សទត្តនេះ តែងចរចានូវពីរភេទភាសាជាប្រក្រតី ដូចនេះ ។

ពំពិស្សហេតុ មានពាក្យសួរថា ចុះហេតុដូចម្ដេចបានជា ព្រះនាគសេន មិនព្រមរៀនពុទ្ធវចនជាមួយនឹងព្រះពិស្សទត្ត នោះ ។

ពាក្យឆ្លើយថា ព្រោះព្រះនាគសេនយល់ចិត្តថា បុគ្គលមិនគប្បីធ្វើសមាគមមួយអរញ្ញើ ដោយហេតុបុគ្គលល្ងង់ជាមិលក្ខជាតិ នោះឡើយ ចំណង់បើនឹងទៅរៀនត្រូវត្រូវពុទ្ធវចនជាមួយគ្នា នោះដូចម្ដេចបានម៉្យាងទៀតប្រហែលជាព្រះនាគសេនលោក នឹកសំគាល់ថា ព្រះធម្មរក្ខិតជាអាចារ្យ នឹងប្រាប់ពុទ្ធវចនជា សីហឡភាសា ២ នេះ អ្នកស្រុកសាគលនគរទាំងអស់តែងមិន យល់ចិត្តរាប់អានឡើយ ឯព្រះនាគសេននោះបានតាំងចិត្តថា នឹងរៀនពុទ្ធវចនជាមគធភាសា ដើម្បីជ្រះថ្លាដល់អ្នកស្រុក សាគលរាជធានីនោះឯង ហេតុដូចនោះបានជាព្រះនាគសេន ប្រកែកអង្វរនឹងអាចារ្យថា មិនព្រមរៀនជាមួយគ្នានឹងអ្នកសី- ហឡជាតិនោះទេ ទើបព្រះធម្មរក្ខិតជាអាចារ្យ លោកក៏ពោល បង្ខំទៅព្រះនាគសេនដល់ពីរបីដងថា នែនាគសេន អ្នកចូររៀន នូវពុទ្ធវចនជាមួយនឹងពិស្សទត្តនេះទៅ កុំថាអ្វីឡើយ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ពិស្សទត្តនេះ មិនមែនជាមនុស្សល្ងង់ទេ ប្រាកដជាបណ្ឌិត ជាអ្នកប្រាជ្ញល្អណាស់ ឯព្រះនាគសេនមកចូលចិត្តជាក្រោយវិញថា ព្រះពិស្សទត្តនេះជាបណ្ឌិតចេះដឹងមែន ហើយអាចារ្យលោកក៏មិនមែនប្រាប់ពុទ្ធវចនជាសីហឡភាសាទេ គឺលោកនឹងបង្រៀនជាមគធភាសាប្រាកដ ទើបព្រះនាគសេនមកគិតថា ឱគំនិតដែលអាញគិតមុននេះមិនគួរសោះឡើយ កម្មដែលអាញធ្វើនេះជាភារិយកម្ម បើដូចនេះគួរអាញនឹងចូលទៅសូមខមាទោសនឹងព្រះពិស្សទត្តថេរ អោយលោកអត់ទោសអោយ គិតដូចនោះហើយក៏ក្រោកឡើងចាកអាសនាចូលទៅកាន់ទីចំពោះមុខព្រះថេរនោះ ហើយផ្គងឡើងនូវអញ្ជលីកម្មថ្វាយបង្គំប្រកបដោយអង្គ ៥ ប្រការ ហើយពោលថា បពិត្រព្រះករុណាម្ចាស់ សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំព្រះករុណា និង មិនពោលនូវពាក្យមានសុភាពយ៉ាងនេះតទៅទៀតទេ ឯព្រះពិស្សទត្តក៏ទទួលអត់ទោសនោះថា សាធុៗដូចនេះ ។

លំដាប់ពីនោះមក ព្រះនាគសេន នឹងព្រះពិស្សទត្តក៏បានរៀននូវពុទ្ធវចនព្រមជាមួយគ្នា ក្នុងសំណាក់នៃធម្មរក្ខិតថេរជាអាចារ្យ ចាប់រៀនតាំងពីគម្ពីរទីឃនិកាយដោយនិទ្ទេសស្មើ

www.budinst.gov.kh www.elibraryofcambodia.org

ញ្ញា ក៏ព្រះថេរទាំងពីរ គឺព្រះនាគសេនថេរនឹងព្រះពិស្សបត្តថេរ នេះចាប់រៀនបន្ទេញពុទ្ធវចនពីបិដកទាំង ៣ ធ្វើទុកក្នុងចិត្ត ដោយព្យញ្ជនៈប្រមាណ ៣ខែ ក៏បានចប់ហើយទើបតាំងរៀនបន្ទេញនូវពុទ្ធវចនពីបិដកទាំង ៣ ដោយជាអដ្ឋកថាប្រមាណ៣ ខែទៀត ទើបបានចប់របៀបបន្ទេញនោះត្រូវជា ៦ ខែ គត់ ទើបចប់ព្រះត្រៃបិដកទាំងព្យញ្ជននឹងអដ្ឋកថា ឯព្រះធម្មរក្ខិតថេរជាអាចារ្យបានដឹងថា ព្រះនាគសេននេះនៅជាបុថុជ្ជននៅឡើយ ហើយទើបពោលការថេរគាថាចំពោះនៅនឹងព្រះនាគសេនជាផ្លូវនឹងគោបាលដែលគេត្រូវរក្សាគោ ឯគោគេនោះ ធម្មតានាយគោបាល ដែលនាំក្របីចិញ្ចឹមរក្សាគោនៃគេមិនអាចដឹងនូវរសនៃទឹកដោះគោនោះឡើយ ចំណែកម្ចាស់គោនោះគេអាចនឹងបរិភោគនូវរសនៃទឹកដោះគោនោះបានតែគេទាំងនេះហ្នឹងឧបមាយ៉ាងណាមិញថា ធម្មតាបុគ្គលជាបុថុជ្ជនប្រាសដោយការឈានមិនសេចក្ដីសុខ ជាបានប្រទ្រង់នូវព្រះត្រៃបិដកដែលជាគុណភាពនៃគេគេក៏គង់មិនអាចដឹងនូវរសនៃសាមញ្ញភាគគឺមគ្គនឹងផលដែលជាចំណែកគួរមានដល់សមណៈ ដូចជានាយគោបាលនោះឯង ។

ព្រះនាគសេនពិចារណាវិញថាហេតុនេះ ឯត្តពិរតុពាលិដាំ

www.budinst.gov.kh www.elibraryofcambodia.org

រពិព្រព្រះករុណាម្ចាស់ដ៏ចំរើន ព្រះពុទ្ធវចនដែលព្រះករុណាបានប្រាប់បង្រៀនដល់ខ្ញុំៗ បានរៀនរួចហើយៗ ក៏សូមដម្កល់រុកសិនចុះ ខ្ញុំករុណានឹងពិចារណាមើលនូវរស់នៃសាមញ្ញកាតីតទៅទៀត នាគសេនថាតែប៉ុណ្ណោះហើយក៏ថ្វាយបង្គំលាព្រះអាចារ្យទៅកាន់ទីរបស់ខ្លួន ទើបលើកសតិបញ្ញាឡើងរាំងពិចារណានូវវិបស្សនាកម្មដ្ឋានបញ្ញាញាណ ក៏ភ្លឺឆ្លុសយល់ច្បាស់នូវព្រះអរិយសច្ច ប្រាកដបានដល់នូវព្រះអរហត្តផលព្រមទាំងបដិសម្ភិទាញាណផង ដោយចំណែកនៃរាត្រីថ្ងៃនោះឯង ក្នុងខណនោះក៏កើតជាអស្ចារ្យចំលែក ចំណែកឯផែនដីក៏កំរើកញាប់ញ័របន្លឺនូវសព្ទសំឡេងដ៏គឹកកងរំពងខ្ទរខ្ទា ហេតុដូចនោះហើយ ទើបព្រះអដ្ឋកថាពោលនូវគាថានេះថា ។

រ វ តិ ច ល តិ ប ថ វី ឧ ច្ច យ ន្តំ វ ប ី ឡិ តំ
ពេលយន្តំយថាចក្កំ ឯវិកម្បតិមេទនី
សំខុត្តិ(១) សុសមុទ្ទោច គិរិន្នោតត្តឱនមិ
ឱនមិតេសិនេរុម្ហិ ហីហីសទ្ទោបវត្តតីតិ

(១) ច្បាប់ខ្លះថា សំខុត្តិសោសបុព្វោច តែងបានពិនិត្យមើលទៅឃើញថា សំខុត្តិគួរបើបព្រៀវល្អ ។

សេចក្តីថា ត្បាលវិលោ ពេលការក្តួរគោតាប បានឮសព្ទ សង្វៀតគ្នា យ៉ាងពេរាះពិរោះ ផែនដីក៏កំរើកពីពកង មានឧប មេយ្យដូចនោះឯងយន្តគ្រឿងពេលការក្តួលបង្វិលទៅដោយកង់ ចក្រយ៉ាងណាមិញ ផែនដីក៏កំរើករំជួលដូចក្នុងនោះដែរ ឯសា គរសមុទ្រក៏មានរលកបោកបក់ជាជលោសិន្ទុឡើង ទាំង ត្បូចភ្នំឈ្មោះមេរុសោតក៏រោរកំភួបេហោរ៉ វិរានទៅការ់ ទីនោះ កាលបើសិនេរុរាជរោរកំភួលររាររៅដូចនោះហើយ សព្ទសំឡេងគ្រហឹមនៃត្បូងភ្នំនោះទាំង២ ដូចនោះ ក៏ប្រ-ព្រឹត្តទៅឥតបានរាក់ឡើយ ។

ឯពួកសុរាង្គនិករអមរទេវាទាំងឡាយ ក៏មានបីតិសោម នស្សត្មោះសរ ព្រោករររីករាយពេរាពេកត្នា ចំណែកខាងមហា ព្រហ្មនៅក្នុងជាន់សោឡសពោធ ក៏កោះពេញ្ចើយផ្គុកផ្អើល ហើយទះព្រះហត្ថា សរសើរថ្វាយពីរមហាគុណព្រះក្រុណាស្រស្តារព្រះ មហាថេរហើយបណ្តាលជាវស្សារ្យ ទាំងទាំងលំអិតចន្ទន៍ ចុណ្ណា និងមណ្ឌារវបុប្ផាជាតិក្នុងផ្ទៃអាកាសក៏បង្អោចុះមកបូជា ហាក់ដូចជាមានវិញ្ញាណ ក្នុងខណកាលព្រះថេរជាម្ចាស់ បាន លុះព្រះអរហត្តាភិសេកជាឯកអរហន្តក្នុងគ្រានោះ ។

តែនខោបនលបយោនកោដិលពាររបង្គោ ក៏ក្នុងសម័យ

www.budinst.gov.kh www.elibraryofcambodia.org

នោះសោត ព្រះអរហន្តទាំងឡាយ ១០០ កោដិ ដែលប្រជុំគ្នា នៅក្នុងរក្ខិតលេណក្នុងភ្នំហិមពាន្តនោះ ក៏បានជ្រាបដំណឹងថា ព្រះនាគសេនបានសម្រេចកិច្ចាភិនិហារហើយ ទើបចាត់ប្រើ ព្រះអរហន្តជាខីណាសវទូត អោយទៅកាន់សំណាក់ព្រះ នាគសេនថេរ ដោយសេចក្ដីបង្គាប់ថា ព្រះនាគសេនចូរចូល មកកុំខាន ព្រោះយើងរាល់គ្នាមានប្រាថ្នាចង់ឃើញខ្លួនអ្នក ពេកណាស់ គ្រានោះព្រះនាគសេនបានស្ដាប់ពាក្យទូត ដូច នោះហើយ ក៏ស្រោប់តែបាត់ចាកទីកន្លែងនោះ មកឃើញ ប្រាកដក្នុងទីចំពោះមុខនៃព្រះអរហន្តទាំង ១០០ កោដិ ដែល នៅគង់ក្នុងភ្នំហិមពាន្តនោះឯង ហើយព្រះនាគសេនក៏ចូលទៅ ថ្វាយបង្គំនូវព្រះថេរទាំងឡាយសួរថា ព្រះករុណាគ្រប់អង្គ ចាត់បំរើអោយទៅហៅខ្ញុំព្រះករុណានេះមក ព្រោះមានហេតុ អ្វី ។

ចំណែកព្រះអរហន្តទាំងឡាយ ក៏មានថេរវាចាប្រាប់ទៅ វិញថា នៃនាគសេន សព្វថ្ងៃនេះមានព្រះមហាក្សត្រ ១ព្រះអង្គ ទ្រង់ព្រះនាមថា មិលិន្ទ្រាធិរាជ មានអំណាចនិងពោលពាក្យ បៀតបៀននូវយើងទាំងឡាយគ្រប់គ្នាក្រៃពេកណាស់ ដោយ ចោទសួរនូវប្រស្នាផ្សេង ៗ ហើយយើងទាំងនេះនឹងរកអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ឯណាមួយ ហើយមានប្រាជ្ញាភ្លាសវាងវៃ អាចឆ្លើយដោះសា ព្យាករណ៍នូវប្រស្នាថ្វាយមហាក្សត្រនោះ ពុំមានឡើយហេតុ នេះហើយយើងរាល់គ្នា សូមអារាធនាព្រះគុណអ្នក ហើយទៅ ទូន្មានព្រះបាទមិលិន្ទនោះ ហើយបានលុះក្នុងផ្លូវល្អផងកុំខាន ពិជ្ជតុភន្តេឯកោមិលិន្ទោរាជា ទើបព្រះនាគសេនពិតទៅព្រះ អរហន្តទាំងអស់នោះថា ព្រះករុណាម្ចាស់គ្រប់ព្រះអង្គកុំព្រួយ កុំថាឡើយតែស្តេចមិលិន្ទ ១ ព្រះអង្គនេះ ទុកជាស្តេចនៅក្នុង កំឡុងជម្ពូទ្វីបទាំងមូលនេះក្តី សូម្បីតែមានបញ្ញានុភាពស្មើៗ គ្នា នឹងស្តេចមិលិន្ទនេះ ហើយមកគង់នៅពេញពីដែរជាសព្វ សិរសាគ្នាក្នុងដីជម្ពូទ្វីបនេះ ហើយសួរនូវប្រស្នាយ៉ាងណាក៏ ខ្ញុំព្រះករុណានឹងអាចឆ្លើយព្រះរាជបុច្ឆាទាំងនោះ ហើយ ព្រោះអរដោយកិរិយាពោលដោះនូវអាថ៌ប្រស្នារបស់ស្តេចទាំង ឡាយនោះមិនខានឡើយ សូមនិមន្តព្រះករុណាម្ចាស់គ្រប់ អង្គទៅកាន់សំណាក់ស្តេចមិលិន្ទ ឯក្រុងសាគលរាជធានី ឯណោះ ហើយកុំបានព្រះហឫទ័យភិតភ័យអារម្មណ៍ឡើយ ចូរប្រមក់និមន្តទៅជាមួយនឹងខ្ញុំព្រះករុណា ក្នុងកាលឥឡូវនេះ គ្រានោះព្រះមហាថេរទាំងឡាយ ធ្វើនូវការសារបដោពពី ពាក់ពៃងកាយដោយសម្ពត់អ្រពត់ហើយក៏តបអាការទៅជាមួយ

www.budinst.gov.kh www.elibraryofcambodia.org

នឹងព្រះនាគសេនថេរក្នុងពេលនោះឯង ឯព្រះអរហន្តដែលចោមរោមព្រះនាគសេនក្នុងគ្រានោះចំនួន ៨០ ០០០ អង្គ ។

ពេនខោបនសបយោន អាយុបាលោនាមថេរោ បញ្ចកាយិកោ ក្នុងសម័យនោះ មានព្រះមហាថេរ១អង្គ មាននាមថាអាយុបាលជាអ្នកស្ទាត់ជំនាញក្នុងនិកាយទាំង ៥ លោកតែងអាស្រ័យនៅក្នុងសំ(១) ខេយ្យបរិវេណ វេលានោះព្រះបាទមិលិន្ទ បរមក្សត្រាធិរាជទ្រង់ព្រះរាជដំរិះក្នុងព្រះចិន្តាថា វេលារាត្រីថ្ងៃនេះ ជារាត្រីល្អរុងរឿង ដោយរស្មីព្រះចន្ទ្រថែងចាំងច្បាស់ ប្រាសចាកមន្ទិលទោស គួរអាត្មាអញនឹងចូលទៅកាន់សំណាក់សមណ ឬព្រាហ្មណ៍ដែលជាមេក្រុមមេគណ ជាគណាចារ្យឬអ្នកឯណា ១ ដែលប្ដេជ្ញាខ្លួនថាជាព្រះអរហន្ត ឬជាព្រះពុទ្ធក្ដីដែលជាអ្នកចេះដឹងនូវពុទ្ធវចន ក៏អ្នកទាំងឡាយអម្បាលនោះនឹងអាចនិយាយចរចាជាមួយនឹងអាត្មាអញបាន ឬ អាចបន្ទោបង់នូវសេចក្ដីសង្ស័យរបស់អញបានហ្ន៎ លុះទ្រង់ព្រះដំរិះយ៉ាងនេះហើយ ទើបសួរទៅសេវកយោនកាមាត្យទាំង ៥០០ តាមសេចក្ដីដែលទ្រង់ត្រិះរិះនោះ ទើបពួកសេវកាមាត្យទាំងនោះ ក៏ទូលតបទៅវិញថា សូមទ្រង់ព្រះមេត្តាប្រោសមាន

(១) ក្នុងសេចក្ដីប្រែរបស់អក្សរសៀមថា អសំខេយ្យបរិវេណ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមហាថេរ ១ អង្គ មានព្រះនាមថា អាយុបាលថេរ ជាអ្នកទ្រទ្រង់នូវព្រះត្រៃបិដក ជាពហុស្សុត ហើយជាអ្នកបានសំដីថ្វីមាត់យ៉ាងវិចិត្រអាចចេះចាំស្ទាត់នូវនិកាយទាំង៥ លោកអង្គនោះឯងតែងគង់នៅក្នុងសង្ខេយ្យបរិវេណ សេចក្តីនេះសូមព្រះមហារាជស្តេចព្រះរាជដំណើរទៅសួរនូវប្រស្នាចំពោះនឹងព្រះថេរអង្គនោះចុះ ។

ទើបព្រះបរមក្សត្រស្តេចបង្គាប់ទៅអាមាត្យនោះវិញថា ចូរអ្នកឯងទៅពិតលោកម្ចាស់អង្គនោះ អោយលោកជ្រាបជាមុនថា យើងនឹងមកជួបនឹងលោកពិតមែន ឯមហាមាត្យនោះក៏បានប្រើបំរើម្នាក់ អោយទៅកាន់សំណាក់ព្រះអាយុបាលថេរនោះ ពិតពោលតាមព្រះរាជបង្គាប់ ។ ព្រះអាយុបាលថេរលោកក៏បន្លូលសេចក្តីនោះដោយថេរវាចាថា សូមអោយព្រះបរមក្សត្រស្តេចទ្រង់ព្រះរាជដំណើរមកចុះ ឯអាមាត្យនោះក៏ត្រឡប់ទៅវិញយកសេចក្តីក្រាបបង្គំទូលតាមដំណើរ។ ព្រះមហាក្សត្រស្តេចក៏មានព្រះតម្រាស់គ្រប់គ្រាន់ ក៏តាំងចាត់ចែងរៀបព្រះអង្គឡើងគង់លើរាជរថ ហែរហមសេវកយោធាអាមាត្យទាំង ៥០០ ជាសេនាយោធា ហែរហមព្រះអង្គចូលទៅកាន់សំណាក់ព្រះអាយុបាលថេរ ឯសង្ខេយ្យបរិវេណ

www.budinst.gov.kh www.elibraryofcambodia.org

អាវាមឯណោះ ហើយស្តេចក៏ធ្វើនមស្សការបដិសណ្ឋារ ទ្រង់ព្រាស់ប្រាស្រ័យទៅវិញទៅមក ដោយសេចក្តីរាក់ទាក់ ហើយទ្រង់គង់នៅក្នុងទី ១ ដ៏សមគួរ លុះគង់ស្រួលហើយទើបទ្រង់បានព្រះរាជឱង្ការសួរចំពោះទៅព្រះអាយុបាលថេរថា កិបត្តិយាភន្តេអាយុបាល បពិត្រព្រះអាយុបាលថេរម្ចាស់ដ៏ចំរើនបព្វជាផ្នួសរបស់លោកម្ចាស់នេះ មានប្រយោជន៍ដូចម្តេចបានសេចក្តីដ៏ឧត្តមរុងរឿងដូចម្តេចខ្លះ ។

ព្រះថេរឆ្លើយទៅវិញថា ធម្មចរិយាយ សមចរិយត្ថាយមោបហារាជ បពិត្រសម្តេចមហារាជ បព្វជានេះមានប្រយោជន៍ ២ យ៉ាង គឺប្រយោជន៍នឹងបានប្រព្រឹត្តក្នុងធម៌ដ៏ល្អហើយជាធម្មចារិម៉្យាងនឹងបានប្រព្រឹត្តក្នុងធម៌ដ៏ស្មើ ហៅថាសមចារិនោះម៉្យាង ដើម្បីគុណប្រយោជន៍យ៉ាងឧត្តមដល់ពពួកទេវតា នឹងមនុស្សទាំងឡាយ ។

ព្រះមហាក្សត្រព្រោសថា អត្ថិភន្តេកោចិ គិហិធម្មចារីសមចារី លោកម្ចាស់ចុះគ្រហស្ថ នឹងអាចប្រព្រឹត្តក្នុងធម៌ដ៏ល្អនឹងប្រព្រឹត្តក្នុងធម៌ដ៏ស្មើនោះបានឬទេ ។

អាមមហារាជ បពិត្រសម្តេចមហារាជ យរាវាសនឹងប្រកបការជាធម្មចារី សមចារីនោះ បានឥតមានទាស់អ្វីទេ គឺ

www.budinst.gov.kh www.elibraryofcambodia.org

ថាគ្រហស្ថអាចនឹងធ្វើចិត្តរីករាយជ្រះថ្លា ក្នុងគុណព្រះរត្នត្រ័យ អាចសមាទានរក្សានូវនិច្ចសីល ឬ បោសថសីល នឹងធ្វើទាន ចំរើនភាវនា ស្តាប់ធម៌ទេសនា ចាត់ថាធម្មចារី សមចារីបាន បពិត្រមហារាជដូចកាលសម្តេចព្រះភគវន្តមុនី កាលដែលទ្រង់ធរមាននៅ ព្រះអង្គបានទៅគង់ក្នុងព្រៃ ឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ទ្រង់សំដែងនូវ ព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុលុះបានចប់សូត្រនោះហើយ ព្រហ្មទាំង ១៨កោដិ ក៏បានសម្រេចមគ្គនឹងផលជាព្រះអរិយបុគ្គលដ៏ឧត្តម ក្នុងលោក ឯព្រហ្មទាំងឡាយនោះក៏សុទ្ធសឹងជាគ្រហស្ថទាំងអស់នឹងបានជាអ្នកបួសជាឧបសម្បទាដល់ម្នាក់ក៏ទេ ម៉្យាងទៀត កាលព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសប្រទាន ធម្មទេសនា មហាវេស្សន្តរបរិយាយ នឹង ខទិរង្គារបរិយាយ នឹង រាហុលោវាទបរិយាយនៅទៀបមាត់ទ្វារនគរសំកស្ស ក៏បរិសទ្យទាំង ២០ កោដិ ដែលបានស្តាប់ធម៌ទេសនានោះក៏បានសម្រេចមគ្គនឹងផលទាំងអស់ឥតមានសល់ដល់ម្នាក់ឡើយ ឯបរិសទ្យទាំងអស់នោះសោតក៏សុទ្ធតែជាគ្រហស្ថទាំងអស់ដែរ ឥតមានជាបព្វជិតដល់ម្នាក់ឡើយ ។

អថខោ ពិម្ពិសារោ រាជា ព្រោះនោះព្រះបាទពិម្ពិសាររាជទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជសណ្តាប់ពាក្យព្រះថេរដូចនោះ ទើបស្តេចមានព្រះ
រាជឱង្ការចំពោះទៅនឹងព្រះអាយុបាលថេរនោះថា លោកម្ចាស់
បើដូចនោះពួកគ្រហស្ថទាំងប៉ុន្មាននោះ ក៏ដូចគ្នាស្មើគ្នានឹងបព្វ
ជ្ជាភេទនេះដែរ មិនមែនសម្រេចត្រង់តែបួសទេ គឺស្រេច
ត្រង់ប្រតិបត្តិល្អ ប្រតិបត្តិត្រូវនោះឯង បើយ៉ាងនោះអ្នកបួស
ជាសមណសាក្យបុត្រ ពុទ្ធជំនោរសដែលបានកាន់បានរក្សានូវ
ធុតង្គផ្សេង ៗ នោះចំពោះជាអ្នកបួសទាំងនោះបានសាងសន្សំ
នូវអំពើអាក្រក់អំពីជាតិមុនមក បានជាផលកម្មដលាមកនោះ
ហូរជូនមិនដាច់ដល់មកក្នុងជាតិនេះ ផលបាបនោះឯងនាំចិត្ត
អោយកាន់យកនូវធុតង្គឈ្មោះ ឯកាសនិកឆាន់ចង្ហាន់តែម្តង
ព្រោះកាលជាតិអំពីមុនពួកអ្នកបួសទាំងនោះ បានធ្វើនូវអំពើ
ចោរកម្មលួចប្លន់ យកភោជនាហារ របស់អ្នកដទៃ បង្អត់
អាហារគេ លុះមកដល់ជាតិនេះផលកម្មនោះឯងដឹកនាំចិត្ត
អោយចង់ឆាន់ចង្ហាន់តែម្តង មិនអាចនឹងបរិភោគរាល់ពេល
ទៅបាន អើបើយ៉ាងនេះហើយបព្វជ្ជាភេទនេះនឹងមានផល
ប្រយោជន៍អ្វីអ្នកបួសទាំងនោះនឹងរក្សាសីលក្តីចំរើនតបឈាន
ក្តី ប្រព្រឹត្តព្រហ្មចរិយធម៌ក្តី ក៏មិនមានផលប្រយោជន៍ដូចគ្នា
ទាំងអស់ ។ ម្យ៉ាងទៀតលោកម្ចាស់អ្នកបួសទាំងឡាយកាន់នូវ
ធុតង្គហៅថា អរញ្ញកោសិក គឺមិននៅក្នុងទីសេនានដែលមាន

ប្លន់ឡើយតែងទៅនៅក្នុងទីវាលឥតហានប្លប់បិទបាំង ក៏អំពើ
ដែលធ្វើដូចនេះនេះមិនគិតវេរាអ្វីទេ គឺវេរាដែលអ្នកទាំងនោះ
កាលពីជាតិមុនបានប្រព្រឹត្តធ្វើនូវអំពើចោរកម្ម ទៅលួច
ប្លន់អ្នកស្រុក វាតទីបំលាយផ្ទះ ធ្វើអោយអ្នកស្រុកទាំងនោះ
វិនាសបាត់ទីកន្លែង រកទីពឹងពួនពំនាក់ពុំបាន ហេតុយ៉ាងនេះ
ហើយបានជាផលនៃអកុសលកម្មនោះ មកដឹកនាំចិត្តអោយ
កាន់យកធុតង្គវត្តឈ្មោះថា អព្ភោកាសិកដែលជាធុតង្គអ្នកទី
ដេកទីវាលក្នុងប្លប់គ្មាន សីលរបស់អ្នកបួសទាំងឡាយនោះ
ក្តី តបក្តី វត្តក្តី ព្រហ្មចរិយធម៌ក្តី ក៏មិនកើតដល់អ្នកបួសទាំង
នោះឡើយ ប្រការ ១ទៀត ដែលអ្នកបួសទាំងឡាយកាន់យក
នូវធុតង្គវត្តឈ្មោះថា នេសជ្ជិក គឺសេចក្តីតាំងចិត្តអធិដ្ឋានតែ
អង្គុយមិនព្រមដេកនោះ កាលអំពីជាតិមុនពួកអ្នកបួសទាំង
ឡាយនេះ ធ្វើជាចោរកំណាចចាំស្ទាក់ផ្លូវលួចប្លន់អ្នកដំណើរ
ទាំងឡាយ តែងចាប់ចងនូវអ្នកទាំងឡាយ ដែលជាអ្នកដំណើរ
នោះចងរឹតពួតពាន់ដៃទៅខាងក្រោយ គឺចងសេកមិនអោយ
ដេកបាន អោយតែអង្គុយនៅ ហេតុនេះហើយបានជាផលនៃ
អកុសលនោះមកដឹកនាំអោយចិត្តកាន់យកនេសជ្ជិកធុតង្គ គឺធុ
តង្គមិនព្រមដេកនោះឯងសីលរបស់អ្នកបួសទាំងឡាយនោះក៏
មិនបានឈាន ក៏មិនមានព្រហ្មចរិយធម៌ ក៏មិនមានទាំងអស់

www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់ ។

កាលបើមហាក្សត្រស្តេចមានព្រះរាជឱង្ការ សម្រេចយ៉ាងនេះហើយ ព្រះអាយុបាលថេរលោកស្ងៀមនៅមិនអាចនឹងពោលជជែក ប្រកែកតទៅនឹងបហាក្សត្រទៀតឡើយ សម័យនោះ យោនកាមាត្យទាំង ៥០០ ក៏ក្រាបបង្គំទូលព្រះបហាក្សត្រថា បពិត្រសម្តេចមហារាជ សូមព្រះករុណាស្តេចទ្រង់ព្រះចេញាស្ថិតនៅដោយសង្គហវត្ថុការសិនចុះ ព្រោះព្រះថេររង្គនេះ លោកជាបណ្ឌិតជាពហុស្សូត្រ ជាអ្នកចាំស្ទាត់ក្នុងនិកាយទាំង ៥ ឥឡូវនេះបែរទៅជាមិនក្លៀវក្លា មិនអាចនឹងពបេពព្រះរាជបុច្ឆាបានវិញ ។ ក្នុងវេលានោះ ព្រះបាទមិលិន្ទរាជស្តេចមិនបានអើពើពាក្យរាជអាមាត្យទាំងនោះឡើយ ទ្រង់បេះព្រះនេត្រចំពោះទៅត្រង់ព្រះថេរ ឃើញព្រះថេរនោះគង់ស្ងៀមនៅដូចនោះហើយ ក៏ទះព្រះហស្តត្រាស់ថា ពុទ្ធោវតភោជម្ពូឧទីបោនត្តិនៃយោនកាមាត្យទាំងឡាយ ខ្ញុំឯងយល់ឃើញថា ជម្ពូទ្វីបទាំងមូលនេះសូន្យស្ងាត់ទទេ រកអ្នកចេះដឹងគ្មានទេ ទោះបីសមណក្តី ព្រាហ្មណ៍ក្តី ពួកសង្ឃក្តី គណក្តី ឬគណាចារ្យក្តី ម្យ៉ាងទៀតអ្នកឯណា ១ ដែលជាអ្នកប្តេជ្ញាខ្លួនថាជាព្រះអរហន្ត ឬ ជាព្រះសម្មាសម្ពុទ្ធក្តី មិនអាចដើម្បីនឹង

www.budinst.gov.kh www.elibraryofcambodia.org

ពោលជជែកជាមួយនឹងយើងបានឬនឹងកាត់នូវសេចក្តីសង្ស័យ របស់យើងបានឡើយ ចំណែកឯព្រះអាយុបាលថេរ លោកបានឃើញអាការកិរិយារបស់ស្តេចនោះ ដូចនោះហើយលោកក៏គិតថា ធម្មតាសមណទាំងឡាយមិនគួរនឹងនិយាយជជែកដោយហេតុប្រកៀវប្រកាន់ ឬ ដោយការជំលោះប្រកែកនោះឡើយ ឯកិច្ចដែលអាត្មាអញមិនបានឆ្លើយដោះសារនូវអាថ៌ប្រស្នានៃមហាក្សត្រនេះ ក៏មិនបែរជាការនឹងអោយសាសនាវិនាសសាបសូន្យឡើយ លុះគិតដូចនេះស្រេចហើយលោកក្រោកឡើងរលាស់នូវចម្ពក្ខន្ធហើយនិមន្តចេញទៅ ។ ឯព្រះមហាក្សត្រឃើញព្រះថេរក្រោកទៅយ៉ាងនោះ ហើយស្តេចក៏តាំងគិតម្តងទៀតថា ឱមែនហើយពើ បើដូចនេះនឹងនៅមានអ្នកដ៏ទៃណា១ ជាអ្នកបរិបូណ៌ដោយប្រាជ្ញាអាចនឹងចរចាឆ្លើយអន្លើដោយអាត្មាអញអោយរស់សង្ស័យបានឬហ្ន៎លុះទ្រង់ព្រះដំរិះដូចនេះហើយទើបទ្រង់ត្រាស់សួរទៅនេមិត្តិយអាមាត្យថា នៃនេមិត្តិយក្នុងនគរយើងនេះ នឹងមានអ្នកណា ១ ជាបណ្ឌិតអាច នឹងពោលជជែកជាមួយគ្នានឹងយើងបានឬទេ ។ ក៏ក្នុងសម័យនោះ ជួនជានេមិត្តអាមាត្យបានដឹងដំណឹងច្បាស់ថាមានព្រះថេរ១ អង្គមាននាមថាព្រះនាគសេនដ៏មានអា

www.budinst.gov.kh www.elibraryofcambodia.org

យុមានពពួកនៃសមណៈចោមរោមជាយសបរិវារ បានទ្រទ្រង់នូវព្រះត្រៃបិដកព្រមទាំងត្រៃភេទវិសេសផងជាបុគ្គលមានប្រាជ្ញាភ្លឺឆ្លសព្រោងព្រាយអាចចេះចាំស្ទាត់ក្នុងនិកាយទាំង៥ប្រការមានទីឃនិកាយជាដើម អាចទ្រទ្រង់នូវព្រះបរិយត្តិធម៌ក្នុងសាសនាសម្ដេចព្រះជិនសព្ទាដែលប្រកបដោយអង្គ ៩ ប្រការមានសព្ទថា សុត្តនិងគេយ្យជាដើម មានបារមីទុំបរិបូណ៌ជាបុគ្គលមានចិត្តតាំងនូវនឹងមាំមួន ប្រៀបដូចជាស្ដេចភ្នំមិនបានកំរើកញាប់ញ័រប្រាកដជាបណ្ឌិតពិតយ៉ាងល្អ អាចញាំញីនូវពាក្យបរប្បវាទជាអ្នកឆ្លៀវឆ្លាស់ក្នុងអត្ថនឹងធម៌ដ៏វិចិត្រ ដោយព្យញ្ជនកម្របុគ្គលដទៃជ្រៀតជ្រែក ឬ រាំងឃាត់ ដោយគលឧបាយណាមួយបានឡើយ ជាអ្នកឈ្នះនូវសង្គ្រាមៈ មានរស្មីប្រាជ្ញាភ្លឺព្រោងព្រាយ អាចបន្ទោបង់នូវសេចក្ដីងងឹតងឿងឆ្ងល់របស់បុគ្គលដទៃបាន មានវាចាយ៉ាងពីរោះស្រស់ស្រាយហើយអាចឈ្វេងយល់ដឹងច្បាស់ នូវហេតុនឹងផលនឹងភាសាដទៃនិងកំណើតព្យញ្ជនផង ជាបុគ្គលបានដល់នូវត្រើយ គឺព្រះនិព្វានមានប្រាជ្ញាច្រើន ប្រៀបដូចទឹកក្នុងមហាសមុទ្រសាគរព្រះថេរនោះឯង ជាបណ្ឌិតដ៏ឧត្ដមជាងធីរាធីរជាតិទាំងពួងជាអ្នកឆ្លៀវឆ្លាស់ ដោយពាក្យពោលក្នុងទីប្រជុំធំមិនអោយឆ្គាំឆ្គងឡើយ ជាបុគ្គលអាចនឹងញាំញីនូវពួកតិរ្ថីទាំងពួងបានជា

www.budinst.gov.kh www.elibraryofcambodia.org

អ្នកវៀងវៃវង្គរាចគេះប្រាជ្ញានអ្នកដទៃ ហើយការរីកប្រើ ដោយសេចក្ដីសុខកាយសុខចិត្តឥតបោះសៅព្រេងជាភិក្ខុជិតស្រ្ឋ លង្ឃជារង្គឯកអសេក្ខបុគ្គល ជាព្រះអរហន្តដ៏ប្រសើរជា អ្នកដល់ហើយនូវសេចក្ដីរុងរឿងដោយភោគសម្បត្តិ និង រុង រឿងដោយយសបរិវារជាបុគ្គលគួរជាទីគោរពរាប់អានដល់ បរិ សទ្យទាំង៤ពួក ។ ម្យ៉ាងទៀតកាលបើរឹងប្រាជ្ញាឬអ្នកផ្កា ក៏គួរជាម៉ជ្រះថ្លាដល់ស្រោពប្រសារ នៃបរក្តិតជាតិទាំងឡាយ ដែលជាអ្នកមានប្រាជ្ញា កាលបើរឹងប្រកាសនូវពាក្យប្រៀន ប្រដៅរបស់ព្រះជិនពាក្យា ដែរប្រកបដោយអង្គ ៨ ប្រការ ដល់ប្រជាជនទៀត ក៏រោយឃើញជាក់ច្បាស់ ហើយជាអ្នក ចាត់ចែងនូវគ្រឿងបូជា គឺព្រះធម៌លើកឡើងនូវបហាប្រា សាទ គឺព្រះត្រៃបិដកដំឡើងនូវទង់ជ័យ គឺព្រះពុទ្ធវចនផ្លុមនូវ ស័ង្ខ គឺព្រះសទ្ធម្មគោះឬ ទូងនូវស្គរធំ ពោលគឺព្រះអរិយសច្ច កំដៅនូវមេឃ គឺធម៌ឆ្មៀលឆ្វាត់ដោយផ្លេកបន្ទោល គឺប្រាជ្ញា ញាណ ហើយព្រះថេរអង្គនោះ មានទាំងពួកភិក្ខុសង្ឃចោម រោមឆ្វេងស្ដាំ ចរចេញទៅកាន់ចារិក នៃស្រុកនិងនិគមជនបទ ខេត្តដែននគររាជធានី បានអនុគ្រោះនូវមហាក្សត្រទាំងឡាយ និងពពួកជនទាំងឡាយច្រើនដោយធម្មទេសនា ហើយឥឡូវ នេះលោកក៏បានដល់មកកាន់ក្រុងសាគលរាជធានី ដែលជាទី

www.budinst.gov.kh www.elibraryofcambodia.org

លើរអៅនៃព្រះបាទមិលិន្ទ្រាធិរាជ ឯព្រះថេរនោះព្រមទាំងសបណាបរិវារទាំងអស់ ក៏ចូលទៅអាស្រ័យនៅ ៧ សំខេយ្យបរិវេណកដែលជាទីនៅនៃព្រះអាយុបាលថេរ ក្នុងកាលគ្រានោះ ។ ហេតុនេះហើយ បានជាអ្នកប្រាជ្ញទាំងឡាយលោកពោលសរសើរព្រះនាគសេនថេរនោះជាបទគាថានេះថា ។

ពហុស្សុតោចិត្តកថី និបុណោចវិសារទោ
សាមយិកោចកុសលោ បដិភាណោចកោវិទោ
តេបិដកេហិបរិវុតោ បញ្ចនិកាយិកេហិច
ចតុនិកាយិកាភិក្ខុ នាគសេនំបុរក្ខិសុំ
តេហិភិក្ខុហិបរិវុតោ និបុណោសព្វបាលិភិ
ចរន្តោគាមនិគមំ សាគលំឧបសង្កមិ
សំខេយ្យំបរិវេណម្ហិ នាគសេនោវសីតទា
សមតុលេហិបរិវុតោ បវនេកេសរីយថា
គម្ភីរបញ្ញោមេធាវី មគ្គាមគ្គស្សកោវិទោ
ឧត្តមត្ថំបកាសេន្តោ នាគសេនោវិសារទោ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីថា ព្រះនាគសេននេះ លោកជាពហុស្សូតជាអ្នកមានសំដីវៀងវៃដ៏វិចិត្រជាបុគ្គលបរិបូណ៌ ដោយសេចក្ដីរង់រាចជាអ្នកប្រាជ្ញឆ្លៀវឆ្លាស់ក្នុងបីប្រជុំ និង ប៉ុនប្រសប់ក្នុងកិរិយាពោលចរចា ហើយមានទាំងសបណោបរិវារដែលជាអ្នកចេះចាំស្ទាត់នូវនិកាយទាំង ៥ និងបិដកទាំង ៣ ប្រការមកចោមរោមជាបរិវារផង ម្យ៉ាងទៀតភិក្ខុទាំងឡាយដែលជាអ្នករៀននូវនិកាយទាំង ៤ ប្រការនោះ ក៏លើកតំកល់នូវព្រះនាគសេនថេរទុកជាប្រធាន ហើយភិក្ខុទាំងនោះសុទ្ធតែជាអ្នកចេះចាំស្ទាត់នូវបាលីទាំងអស់ ឯព្រះនាគសេនគោត លោកក៏ត្រាច់ទៅកាន់ស្រុក និង និគមជនបទមកដល់កាន់ក្រុងសាគលរាជធានីនេះមកគង់នៅនៅវត្តឈ្មោះសំខេយ្យបរិវេណ លោកជាអ្នកប្រាជ្ញ បានប្រាជ្ញាដ៏ជ្រាលជ្រៅជាគម្ពីរភាពត្រាស់ដឹងនូវមគ្គនិងផល ហើយតែងប្រកាសនូវប្រយោជន៍យ៉ាងឧត្តមប្រាប់គេរាល់គ្នាជាបណ្ឌិតដ៏ក្លៀវក្លា ប្រៀបដូចកេសរសីហរាជនោះឯង ។

ពំសេវ្តំសុត្វាទេវមន្តិយោ មិលិន្ទំរាជានំឯតទវោច ទេវមន្តិយអាមាត្យ បានឮនូវកិត្តិនាមនិងគុណសម្បត្តិរបស់ព្រះ-ថេរដូចសេចក្ដីខាងដើមនេះហើយ បានជាក្រាបបង្គំទូលព្រះ

www.budinst.gov.kh www.elibraryofcambodia.org

មហាក្សត្រនោះថា បពិត្រសម្តេចមហារាជ រឿងនេះសូមទ្រង់រង់ការសិនចុះ ព្រោះឥឡូវនេះមានភិក្ខុ ១អង្គ ព្រះនាមថា ព្រះនាគសេន សែនហៅចេះជាមហាបណ្ឌិត ពិតជាអ្នកប្រាជ្ញ ជាអ្នកក្លៀវក្លាអង្គអាច ជាធម្មកថិកយ៉ាងឆ្នើម លោកនោះជាពហុស្សុត ជាអ្នកវៀងវៃដោយសំដីពោលពីរោះ ជាវិចិត្រកថា អាចចេះដឹងនូវបាឡី និង អដ្ឋកថានឹងភាសាផ្សេងៗ បានបារមីពុំបរិបូណ៌ ម្យ៉ាងទៀតជាអ្នកធ្លាប់ប្រសប់តែងនិយាយជជែកចរចាជាមួយនឹងលោកបាលទាំងឡាយ គឺឥន្ទទេវរាជ និងតុរោបបទេវរាជ នឹង ស្តេចវរុណ កុវេរ វេស្សវណ្ណបានឥតមានញញើតកោតខ្លាចឡើយ នឹងបាច់ចាំពោលទៅថ្វីដល់មនុស្សលោកយើងនេះ ។

គ្រានោះព្រះបាទមិលិន្ទរាជ ស្តេចបានឮឈ្មោះថា ព្រះនាគសេនៗ មួយរំពេចដូចនេះហើយ ទ្រង់ក៏មានព្រះហឫទ័យញាប់ញ័ររន្ធត់ស្លុតព្រឺរោម ទើបទ្រង់មានព្រះរាជឱង្ការចំពោះទៅនឹងទេវមន្ទិយ អាមាត្រថា នែទេវមន្តិយ ចុះឥឡូវនេះព្រះនាគសេនថេរម្ចាស់នោះ លោកគង់នៅក្នុងទីណាចូលអ្នកប្រាប់យើងអោយច្បាស់ ព្រោះយើងមានប្រាថ្នាចង់ជួបនឹងព្រះថេរអង្គនោះក្រៃពេកណាស់។ឯទេវមន្តិយក៏ក្រាបបង្គំទូល

www.budinst.gov.kh www.elibraryofcambodia.org

ថា បពិត្រព្រះរាជកុមារ ព្រះនាគសេនថេរមានភិក្ខុទាំង ៨០.០០០ អង្គ ជាបរិវារ សព្វថ្ងៃនេះលោកគង់នៅក្នុងសង្ខេយ្យបរិវេណទៀបក្រុងសាគលរាជធានីនេះ សូមទ្រង់ជ្រាប ។ ទើប ស្តេចទ្រង់បង្គាប់ទៅដល់ទេវមន្ត្រីយ ឲ្យនេះរាជបំរើនាំបទៅ និមន្តលោកម្ចាស់នោះនិមន្តនោះមកក្រុងថា ហើយការ ព្រះរាជាទ្រង់ជួបនឹងលោកផង ឯទេវមន្ត្រីបានបង្គំព្រះរាជឱង្ការនោះហើយ ក៏ដែងទៅងាយរាជទូតឲ្យទៅនិមន្តនាយទៅពិត ព្រះថេរនោះថា ( ព្រះមហាក្សត្រ ស្តេចការព្រះរាជបំណងប្រាថ្នា ទ្រង់ជួបនឹងលោកម្ចាស់ ) ឯរាជទូតក៏បាននាំពីព្រះនាគ សេនថេរតាមព្រះរាជឱង្ការត្រាស់នោះ ពីដំណើរព្រះថេរលោក បានស្តាប់នូវពាក្យរាជទូតនោះហើយ ទើបប្រាប់ទៅទូតនោះ វិញថា ដែព្រះរាជបំរើ សូមនិមន្តអញ្ជើញព្រះមហាក្សត្រស្តេចយាង មកចុះតាមព្រះបាទប័ណ្ណាថ្នា ។ ឯរាជបំរើនោះត្រឡប់មក វិញ ហើយយកសេចក្តីក្រាបបង្គំទូលតាមពាក្យព្រះថេរនោះ ព្រះមហាក្សត្រទ្រង់បានព្រះសណ្តាប់ហើយ ទើបទ្រង់អោយ រៀបរាជរថយ៉ាងវិសេស រួចព្រះអង្គក៏ស្តេចឡើងគង់លើព្រះ រាជយាននោះ ហើយពួកយោនកាមាត្រជាបរិវារហែព្រះអង្គ ទៅប្តូយរង្វើ ដោយពលនិកាយដ៏ច្រើនធំពោះនឹងទៅជួបនឹង ព្រះនាគសេនថេរឯសំខេយ្យបរិវេណ គ្រានោះព្រះនាគ

www.budinst.gov.kh www.elibraryofcambodia.org

សេនថេរលោកកំពុងតែគង់នៅក្នុងសាលាទីប្រជុំធំ ជាមួយនឹងភិក្ខុសង្ឃទាំង ៨០.០០០ អង្គ ឯព្រះមហាក្សត្រស្តេចក៏ទតទៅឃើញសង្ឃជាបរិសទ្យ នៃនាគសេនច្រើនយ៉ាងនោះ ហើយទើបទ្រង់សួរទៅទេវមន្ត្រីយជារាជអាមាត្យថា នែទេវមន្ត្រីយ ចុះបរិសទ្យ អ្នកណាក៏ច្រើនមីដេរដាស ដល់ម្លេះទេវមន្ត្រីយ ក៏ទូលថា ឯបរិសទ្យទាំងអស់នោះ ជាពួករបស់ព្រះនាគសេនថេរ ហើយទូលព្រះករុណាស្តេចទ្រង់ជ្រាប ។

ព្រះបាទមិលិន្ទ្រាធិរាជ លុះស្តេចបានជ្រាបប្រាកដនូវបរិសទ្យទាំងអស់នោះថា ជាប័ក្ខពួករបស់ព្រះនាគសេនដូចនោះហើយ ទ្រង់ក៏បានព្រះហឫទ័យព្រួយព្រឺរោមពក់ស្លុតរន្ធត់ញាប់ញ័រប្រៀបដូចសត្វដំរី ដែលជាប់នៅក្នុងចំណោមសត្វរមាសចោមព័ទ្ធជុំវិញ ឬដូចពស់ ដែលនៅក្នុងចំណោមបក្សីគ្រុឌ ពុំនោះសោតប្រៀបដូចឆ្កែចចកដែលពស់ថ្លាន់ព័ទ្ធជាប់ហើយ ឬដូចខ្លាឃ្មុំដែលក្របីចោមរោមហើយ ឬ ដូចសត្វកង្កែបដែលនាគព័ទ្ធចាប់បានហើយ ឬ ដូចសត្វម្រឹគដែលជាប់ជំពាក់ដោយអន្ទាក់ឬអង្គប់ បើមិនដូចនោះសោតស្តេចមិលិន្ទរាជនោះ ដែលមានព្រះហឫទ័យតក់ស្លុតខ្លាចព្រះនាគសេនថេរប្រៀបដូចសត្វពស់ហាម័ញ ដែលនៅក្នុងអំណាចនៃហ្មរពស់

www.budinst.gov.kh www.elibraryofcambodia.org

ឬដូចសត្វកណ្ដុរ ដែលនៅក្នុងអំណាចឆ្មា ឬ ដូចភូតបិសាច ខ្មោចព្រាយ ដែលជាប់នៅក្នុងកណ្ដាប់ដៃរបស់គ្រូពេទ្យ ឬ ដូចព្រះចន្ទនៅក្នុងមាត់នៃរាហូអសុរិន្ទ ឬ ដូចសត្វពស់សាម័ញដែលជាប់នៅក្នុងកំប្រោង ឬដូចសត្វស្លាបដែលជាប់នៅក្នុងទ្រុង ឬដូចសត្វត្រី ដែលជាប់នៅក្នុងជាល ឬដូចបុរសដែលចូលទៅរស់ខ្លួនទៅក្នុងអំណាចនៃសត្វព្រៃពាឡ បើមិនដូច្នោះទេ មហា-មាដូចយក្សទាំងពួង ដែលបានទោសព្រោះនឹងស្ដេចវេស្សវណ្ណ ឬ ដូចទេវបុត្រដែលទៀបច្យុតិចាកស្ថានទិព្វនោះឯង ទ្រង់មានព្រះហឫទ័យតក់ស្លុត រាន់រាំងជាទីបំផុត តែទ្រង់អំពាំងទំជម្រង់ព្រះស្មារតីថា ព្រះថេរអង្គនេះមិនអាចនឹងធ្វើអ្វីរញបានឡើយ ហើយស្ដេចបានព្រះរាជឱង្ការប្រាប់ទៅទេវមន្ទិយរាមាត្យថា នៃទេវមន្ទិយ អ្នកឯងកុំបាច់ចាំបង្ហាញព្រះនាគសេននោះដល់យើងឡើយ យើងគង់ស្គាល់មិនខាន ទេវមន្ទិយអាមាត្យឆ្លើយថា សូមព្រះករុណាស្ដេចជ្រាបចុះ។ បណ្ដាភិក្ខុសង្ឃដែលជាបរិវារទាំង ៨០.០០០អង្គ ក្នុងវេលានោះ ព្រះនាគសេនថេរមានវស្សា ខ្ចីជាងភិក្ខុទាំងឡាយ ៤០.០០០ អង្គ ដែលគង់នៅខាងចុងនោះ ហើយមានវស្សាចាស់ជាងភិក្ខុទាំងឡាយ ៤០.០០០ អង្គ ដែលគង់នៅខាងក្រោយអង្គលោកនោះ គឺអង្គព្រះនាគសេនឯងគង់នៅជា

www.budinst.gov.kh www.elibraryofcambodia.org

កណ្ដាលនៃភិក្ខុសង្ឃទាំងនោះ ទើបព្រះមហាក្សត្រទ្រង់ទត ព្រះនេត្រពិនិត្យមើលសព្វគ្រប់តាំងពីដើមអាសន រហូតដល់ចុងអាសន ក៏បានឃើញនូវព្រះនាគសេនគង់នៅលើទីអាសនជាកណ្ដាលនៃភិក្ខុសង្ឃទាំងពួង. ទ្រង់ក៏ជ្រាបច្បាស់ថាលោកនេះហើយជាព្រះនាគសេនពិតឥតមានសង្ស័យ ព្រោះទ្រង់ស្គាល់ឫក្សអាការជាអ្នកក្លៀវក្លាអង់អាច ឥតមានស្ញើបខ្លាចព្រឺព្រួយអ្វីឡើយ ប្រៀបដូចជាកេសរសីហរាជដែលស្ថិតនៅក្នុងកណ្ដាលហ្វូងនៃសីហទាំងពួងនោះឯង ហើយទ្រង់ត្រាស់ប្រាប់ទៅទេវមន្ត្រីយអាមាត្យថា ឯសោខោអាយុស្មានាគសេនោ នៃទេវមន្ត្រីយព្រះនាគសេន មិនពីអង្គណាទេ គឺព្រះថេរនោះហ្នរ យើងស្គាល់ដោយច្បាស់ រាជអាមាត្យក៏ទូលតបទៅវិញថា ព្រះករុណាស្ដេចទ្រង់ជ្រាបនោះមែនប្រាកដហើយ ឯមហាក្សត្រស្ដេចបានឃើញនូវព្រះនាគសេនហើយ ទ្រង់ក៏មានព្រះហឫទ័យភ័យស្ញើបជាប់ជានិច្ច នៅក្នុងព្រះសន្ដានហេតុនោះហើយទើបបានជាបោរាណាចារ្យទាំងឡាយលោកពោលនូវគាថានេះថា ។

ចរណេនចសម្បន្នំ សុទន្តំឧត្តមេទមេ
ទិស្វារាជនាគសេនំ ឥទំវចនមព្រវិ

www.budinst.gov.kh www.elibraryofcambodia.org

កថិកាបរោពរោទិដ្ឋា ពាកក្ខាឪតដ្ឋោពរោ

នពាទិសំវាយំហោតិ វជ្ជពាសោយថាបម

ធិស្សសយំបវាជយោ បបវជវាវិព្យតិ

ជយោចនាគសេនស្ស យថាចិត្តុំសេបរៀតំ

សេចក្តីថា ព្រះបបាកក្សត្រពេត្រចបានឃើញនូវព្រះនាគសេនថេរ ដែលជាអ្នកបរិបូណ៌ ដោយសេចក្តីប្រព្រឹត្តនិងការប្ឫនាងអ្នកយ៉ាងឧត្តមដូចនោះហើយទើបទ្រង់ពោលជាឧទានវាចាថា ឯពាក្យពេចជាគ្រឿងពោលដែលរវាត្មារញបានរប់នោះក៏មានច្រើនប្រការពេកណាស់ សេចក្តីពាកព្យួរចោទឆ្លើយនោះសោត ក៏អ្នករញធ្លាប់ឆ្លើយជាច្រើនគ្រានោះស់បើនដែលមានស្អួនការដលើអ្នងឡើយ ទើបនឹងថ្ងៃនេះ សេចក្តីពាក់ព្ពូតក៏បាក់ដូចជានឹងមានដល់រញប្រាកដហើយ ឱការបរាជ័យចាញ់គេ ប្រុបជានឹងមានបកដល់រញក្នុងថ្ងៃនេះរកសង្ស័យគ្មានឡើយ ឯជ័យជំនះមុខជានឹងបានខាងព្រះនាគសេនថេរក្នុងថ្ងៃនេះមិនខាន រាត្មារញមិនដឹងបើនឹងដាក់លប់ចិត្តយ៉ាងណាទេ ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីដែលសំដែងមកនេះជាពាហិរកថាសំដែងដោយព្រះបាទមិលិន្ទស្ដេចបានសួរអាចារ្យទាំងពួងមានបុរណកស្សបនឹងព្រះរាបបុបាលថេរជាដើម ក៏ចប់បរិបូណ៌តែប៉ុណ្ណោះហោង ។

មិលិន្ទបញ្ហា

បឋមវគ្គ មានប្រស្នា១៥

នាមបញ្ហា១ ទី១

សេចក្ដីបុច្ឆា នឹង វិសជ្ជនារបស់ព្រះបាទមិលិន្ទ និង ព្រះនាគសេនថេរ ។

អថខោមិលិន្ទោរាជា យេនាយស្មានាគសេនោ តេនុបសង្កមិឧបសង្កមិត្វា អាយស្មតានាគសេនសទ្ធឹសមោទិ ។

សេចក្ដីថា គ្រាមួយនោះ ព្រះបាទសម្ដេចមិលិន្ទរាជបានចូលទៅកាន់សំណាក់ព្រះនាគសេនថេរ ហើយក៏ទ្រង់ធ្វើនូវសេចក្ដីព្រេកអរសោទរ ជាមួយគ្នា រួចហើយមហាក្សត្រស្ដេច ក៏គង់នៅក្នុងទីមួយដ៏សមគួរ ។

ឯព្រះនាគសេនបានធ្វើសេចក្ដីសម្រួលព្រះហឫទ័យនៃព្រះបាទមិលិន្ទ អោយស្ដេចរីករាយសប្បាយក្នុងពេលនោះដោយសេចក្ដីគ្មោះសរ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទមិលិន្ទ ត្រាស់សួរព្រះឱង្ការទៅនឹងព្រះនាគសេន ថេរថាបពិត្រលោកម្ចាស់ដ៏ចំរើន អ្វីហ្នះប្រាជ្ញាដើរឡើងនឹងចរចា ត្រូវនូវប្រស្នាជាដំបូងនឹងលោកម្ចាស់បាន ឬពុំបាន ។

ព្រះនាគសេនក៏ថ្វាយព្រះពរថា សូមបរមបពិត្រត្រាស់ ហោះព្រះរាជឱង្ការពេកចុះ អាត្មាភាពនឹងស្តាប់ ។

ម - បពិត្រលោកម្ចាស់ដ៏ចំរើន អ្វីត្រូវហើយលោកម្ចាស់ ចូរពោលចុះ ។

ន - បពិត្របរមរាជ អាត្មាភាពពោលហើយ ចូរព្រះអង្គ ទ្រង់ចាំចុះ ។

ម - បុច្ឆាមិ ភន្តេ បពិត្រព្រះថេរដ៏ចំរើន យើងសួររួចហើយ ។

ន - វិសជ្ជិតំ មហារាជ បពិត្រមហារាជ អាត្មាភាពឆ្លើយរួចហើយ ។

ម - កិំវិសជ្ជិតោ លោកម្ចាស់ឆ្លើយថាដូចម្តេច ។

ន - កិំបុច្ឆិតោ បរមបពិត្រត្រាស់ថាដូចម្តេច ។

កាលបើព្រះបាទមិលិន្ទ នឹង ព្រះនាគសេនថេរបានបុច្ឆា វិសជ្ជនាយ៉ាងនេះហើយ ពួកយោនកាមាត្យទាំង ៥០០ នាក់ ក៏

អោយសព្ទសាធុការដល់ព្រះនាគសេនថេរហើយ ទើបក្រាបបង្គំទូលព្រះបាទមិលិន្ទថាសូមអញ្ជើញព្រះអង្គសួរនូវអត្ថបញ្ហានឹងព្រះនាគសេនថេរតទៅទៀត ក្នុងកាលឥឡូវនេះ គ្រានោះមហាក្សត្រាធិរាជ ស្ដេចទ្រង់ចោទឡូនូវប្រស្នាតទៅទៀតថាលោកម្ចាស់ធម្មតាបុគ្គលដែលនឹងសន្ទនាគ្នា បើមិនដឹងនាមនឹងគោត្រនៃគ្នានឹងគ្នាហើយ ក៏របៀបពាក្យនៃជនទាំងពីរនោះមិនបានជាការមាំមួនឡើយ ហេតុដូចនេះ យើងទាំងពីរនាក់ត្រូវដឹងឈ្មោះគ្នាទេវិញទៅមកជាមុនសិន ស្ដេចទ្រង់ត្រាស់ដូចនេះហើយទើបសួរថា កិនាមោសិ លោកម្ចាស់ព្រះនាមឈ្មោះអ្វី។

ន - នាគសេនោនាម បពិត្រមហារាជ ឯឈ្មោះអាត្មាភាពនោះ ពួកព្រាហ្មណាចារ្យទាំងឡាយគេតែងហៅថានាគសេនៗដូចនេះទាំងមាតាបិតារបស់អាត្មាភាពសោត លោកអោយឈ្មោះអាត្មាភាពច្រើនយ៉ាងទៀត ជួនកាលលោកហៅថានាគសេនខ្លះ ជួនហៅថាវិរសេនខ្លះ សូរសេនខ្លះ សីហសេនខ្លះ ឯសព្ទថានាគនោះ ព្រោះសេចក្ដីថា អ្នកឯណាមិនធ្វើនូវកម្មជាលាមក អ្នកនោះឯងឈ្មោះថានាគ។

ឯនាមថា សេននោះព្រោះសេចក្ដីថាជាទីពឹងពំនាក់ ជាបី

www.budinst.gov.kh www.elibraryofcambodia.org

ឱនក្រាបនៃបុគ្គល ដែលប្រេជ្ញាខ្លួនជាសិស្សសិក្សារៀនសូត្រ ដែលថារីវនោះដោយអត្ថថាមានសេចក្ដីព្យាយាមមិនបានរុញរា ដែលថា សូរនោះដោយអត្ថថាញៀវក្លាររង្គរាចប្រាសចាកភ័យ មិនមានកោតខ្លាច ក្នុងកណ្ដាលបរិសទ្យ ដែលថា សីហនោះ ដោយអត្ថថាជាទីកោតក្រែងដល់អ្នកប្រាជ្ញទាំងឡាយដ៏ទៃ ដូច កេសរសីហជាទីកោតខ្លាច ដល់ពួកម្រឹគជាតិទាំងពួង ឯសេន សព្ទនោះមានសេចក្ដីដូចបានអធិប្បាយមកហើយក្នុងខាងដើម ឯពាក្យពោលកំណត់ ដែលលោកទាំងពួងបញ្ញត្តិទុក នឹងបាន សត្វមានបុគ្គលជាទីតាំង នៃមានទិដ្ឋិកាន់យកចាំថាអបាំមចំក្នុង ពេញ្ញាះទាំងពួងនោះ ដោយបរមត្ថរោបារក៏ទេមហាបពិត្រ សូមទ្រង់ជ្រាប ។

ព្រះបាទមិលិន្ទ មានព្រះឱង្ការទៅនឹងពួកយោនកទាំង ៥០០ នឹងព្រះភិក្ខុសង្ឃទាំង ៨០០០០រង្គថា រស់អ្នករស់លោក ទាំងឡាយចូលស្ដាប់នូវពាក្យព្រះនាគសេនថេរចុះ លោកថា ពួកព្រហ្មចារិយ៍របស់លោកហៅខ្លួនលោកថា នាគសេន ៗ នោះ នឹងមានសត្វមានបុគ្គលក្នុងពេញ្ញាះនោះ ដោយបរមត្ថរោ បារក៏ទេ បពិត្រព្រះនាគសេនដ៏ចំរើន បើសត្វនឹងបុគ្គលមិន បានក្នុងពេញ្ញាះនេះ ដូចពាក្យដែលលោកពោលពោលហើយ

www.budinst.gov.kh www.elibraryofcambodia.org

ហើយ ចុះជនទាំងឡាយឯណា ដែលគេបានអោយនូវបាត្រ នឹងចីវរ និងអាហារបិណ្ឌបាត នឹងគ្រឿងសេនាសន នឹងគិលានបច្ច័យ និងភេសជ្ជបរិក្ខាទាំងពួងដល់លោកម្ចាស់នោះ ផលកុសលរបស់ជនទាំងឡាយនោះ ក៏មិនមានដែរឬ អ្នកណានឹងសម្លាប់នូវលោកម្ចាស់ក្តីផលនៃបាណាតិបាតកម្មនោះ ប្រហែលជាមិនមានដល់អ្នកនោះដែរឬ បពិត្រព្រះនាគសេនដ៏ចំរើន បើលោកម្ចាស់ថាមិនមានសត្វ មិនមានបុគ្គលទេ ចុះអ្នកណាអោយចីវរបិណ្ឌបាត សេនាសន គិលានបច្ច័យ នឹងភេសជ្ជបរិក្ខារដល់លោកម្ចាស់ អ្នកណាបរិភោគនូវចតុបច្ច័យទាំងនោះ អ្នកណារក្សាសីល អ្នកណាប្រកបរឿយ ៗ នូវការភាវនា អ្នកណាធ្វើអោយជាក់ច្បាស់នូវមគ្គ និងផល នឹងព្រះនិព្វាន ចំណែកខាងបាបទៀត អ្នកណាសម្លាប់សត្វលួចទ្រព្យគេប្រព្រឹត្តអាក្រក់ក្នុងកាមទាំងឡាយ ពោលនូវពាក្យកុហកផឹកនូវម៉េកស្រវឹង អ្នកណាធ្វើនូវបញ្ចានន្តរិយកម្ម បើនឹងមិនមានសត្វមិនមានបុគ្គលទេ ទាំងកុសលក៏មិនមានអកុសល ក៏មិនមានដែរឬ អ្នកណាធ្វើនូវកុសលកម្ម ឬអកុសលកម្មដោយខ្លួនឯងឬ ឬប្រើគេអោយធ្វើក៏មិនមានផលវិបាកនៃអំពើអាក្រក់ និងអំពើល្អដែលបុគ្គលធ្វើហើយនោះឯង ព្រោះមិនមានសត្វមិនមានបុគ្គលទាំងអស់បពិត្រព្រះថេរដ៏ចំរើន បើយ៉ាងនឹង

www.budinst.gov.kh www.elibraryofcambodia.org

ន - ថ្វាយព្រះពរ មិនមែនទេ ។

ប - សញ្ញា គឺធម្មជាតិសម្រាប់ស្គាល់ ឬ អ្វី ជាព្រះអាគតេរះ ។

ន - ថ្វាយព្រះពរ មិនមែនទេ ។

ប - សង្ខារ គឺសភាវតាក្រាប់តាក់តែង ឬ អ្វី ជាព្រះអាគតេរះ ។

ន - ថ្វាយព្រះពរ មិនមែនទេ ។

ប - វិញ្ញាណ គឺធម្មជាតិតាក្រាប់ដឹងផ្សេងៗ ឬអ្វីជាព្រះអាគតេរះ ។

ន - ថ្វាយព្រះពរ មិនមែនទេ ។

ប - ចក្ខុធាតុ គឺធម្មជាតិ ដែលត្រូវប្រស្រស់ផ្លូវព្រលោកអើងអែ ផ្លូវ ពីចក្ខុប្រសាទ ឬ អ្វីជាព្រះអាគតេរះ ។

ន - ថ្វាយព្រះពរ មិនមែនទេ ។

ប - រូបធាតុ គឺធម្មជាតិ ដែលត្រូវប្រស្រស់ផ្លូវព្រលោកអើងអែ ផ្លូវ ពីរូបារម្មណ៍ ឬអ្វីជាអាគតេរះ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - ថ្វាយព្រះពរមិនមែនទេ ។

ម - សោតធាតុ ធាតុ ពីសោតប្រសាទសទ្ទធាតុ ធាតុពីសទ្ទារម្មណ៍ ឃានធាតុ ធាតុពីឃានប្រសាទ គន្ធធាតុ ធាតុពីគន្ធារម្មណ៍ ជិវ្ហាធាតុ ធាតុពីជិវ្ហាប្រសាទ រសធាតុ ធាតុ ពីរសារម្មណ៍កាយធាតុ ធាតុ ពីកាយប្រសាទ ផោដ្ឋព្វធាតុ ធាតុពីផោដ្ឋព្វារម្មណ៍មនោធាតុ ធាតុពីមនោប្រសាទ ធម្មធាតុ ធាតុពីធម្មារម្មណ៍ ធម្មជាតិ ទាំងនេះ ឬអ្វី ដែលជាព្រះនាគសេន ពោកឡោត ។

ន - សូមថ្វាយព្រះពរ មិនមែនទេ ។

ម - រូបក្ខន្ធ វេទនា សញ្ញា សំខារ វិញ្ញាណក្ខន្ធធម្មជាតិទាំង ៥ នេះ ឬ អ្វី ជាព្រះនាគសេន ។

ន - ថ្វាយព្រះពរមិនមែនទេ ។

ម - ជំនុំខន្ធទាំងឡាយ ៥ នេះ ខន្ធឯណានិមួយ ឬអ្វីជានាគសេន ។

ន - ថ្វាយព្រះពរមិនមែនទេ ។

ម - បពិត្រព្រះថេរដ៏ចំរើន ខ្ញុំបានសួរលោកម្ចាស់ពី

www.budinst.gov.kh www.elibraryofcambodia.org

អាការ ៣២ នឹងខន្ធទាំង ៥ នឹងធាតុទាំងឡាយថា ជានាគ
សេនឬអ្វី លោកម្ចាស់ឆ្លើយបដិសេធចេញទាំងអស់ថា មិន
មែនជានាគសេនឡើយ បើយ៉ាងនឹងខ្ញុំពិចារណាមើលទៅមិន
យល់មិនឃើញមានអ្វីត្រង់ណាថា ព្រះនាគសេននោះសោះ
ចុះកាលពីដើមលោកម្ចាស់បានប្រាប់ខ្ញុំថា លោកឈ្មោះព្រះ
នាគសេន ដល់ខ្ញុំរកនាគសេនក្នុងអាការទាំងអស់នៅ
លោកថាមិនមែនទាំងអស់ ហើយដូច្នោះលោកម្ចាស់ពោល
ពាក្យទាំងប៉ុន្មាននោះ ជាពាក្យកុហកបញ្ឆោតទេ ។ លោកពិត
ជាគ្មានទេ ពួកយោនកទាំង ៥០០ នឹងព្រះភិក្ខុសង្ឃទាំង ៨០
០០០អង្គ ដែលជាទីរាប់អានគួរប្រជុំនៅនេះ ចូរអស់លោក
ទាំងឡាយស្ដាប់ចុះ យ៉ាងនឹងការហើយលោកគ្រប់គ្រាន់ស្ដេចបាន
ព្រះរាជឱង្ការត្រាស់ពោះពោះបោកពេះជឿរ ជាបរិការួរ ដល់
ព្រះនាគសេនថេរជាព្រះអរហន្តយ៉ាងនេះហើយ ចំណែក
ព្រះថេរដែលជាព្រះអរហន្តដល់ហើយ នូវបដិសម្ភិទាញាណ
៤ ប្រការ គឺធម្មបដិសម្ភិទាប្រាជ្ញាត្រាស់ដឹងច្បាស់នូវហេតុដឹង
ច្បាស់នូវបាលីក្នុងព្រះត្រៃបិដក នឹងបដិវេធធម៌ គឺមគ្គនឹងផល
នឹងព្រះនិព្វាន អត្ថបដិសម្ភិទាប្រាជ្ញា ត្រាស់ដឹងច្បាស់នូវផល
នឹងដឹងច្បាស់នូវអដ្ឋកថា ។ និរុត្តិបដិសម្ភិទា ប្រាជ្ញាត្រាស់ដឹង

www.budinst.gov.kh www.elibraryofcambodia.org

ច្បាស់នូវឋានអក្ខរនិងអក្ខរប្រភេទ មិនហានវៀងឆ្ងល់ឡើយ ១ បដិភាណបដិសម្ភិទាប្រាជ្ញាឆ្លាស់ព្រាស់ដឹងច្បាស់ក្នុងកិរិយាអានឮព្រមអោយត្រូវ តាមគរុលហុសិថិលធនិតជាដើម ជាឆន្ទានុរក្សនិងសំដែងធម៌ក៏ក្បៀវក្លាពិរោះពីរោះក្បាយ បានគ្រប់ប្រការហោកជាជំពូកនៃបុរសយ៉ាងនេះ កាលបើបានឮព្រះរាជឱង្ការបរុសវាក្យព្រពោលព្រពោះយ៉ាងនោះហើយ ក៏មិនតានព្រះហឫទ័យញាប់ញ័ររាក់រន់ឡើយ មានឧបមាយ៉ាងណាថាហោនឧបមេយ្យដូចកំពូលនៃបរពតរាជ ដែលជាស្តេចនៃភ្នំទាំងពួង មិនបានរំភើបញ័រទៅដោយកំលាំងខ្យល់កាលវេរម្ភាវាតបក់ផាត់នោះឡើយ ព្រះមហាថេរមិនមានព្រះហឫទ័យក្រេវក្រោធតបតពោរនឹងស្តេចមិលិន្ទ ដែលពោលនូវពាក្យផរុសវាចានោះឡើយ ព្រះថេរជាអ្នកចំរើននូវមេត្តាព្រហ្មវិហារ ពោរព្រះទ័យមេត្តាករុណាដល់មហាក្សត្រជាទីបំផុតប្រៀបដូចមាតា នឹងកូនតូច ១ នោះយ៉ាងណាមិញព្រះនាគសេនតាំងព្រះហឫទ័យល្អ អោយប្រព្រឹត្តទៅក្នុងស្តេចមិលិន្ទដែលជាបុថុជ្ជននោះដូចនោះឯង ព្រះថេរតាំងព្រះហឫទ័យមិនអោយមានសេចក្តីក្រោធ ព្រោះប្រាថ្នានឹងប្រោសសម្តេចមិលិន្ទអោយបានមគ្គនឹងផល សោយនូវព្រះអម្រឹតធារាគឺព្រះនិព្វានក្នុងបច្ចុប្បន្នជាតិនោះ ដោយព្រះប្រាជ្ញារបស់លោក

www.budinst.gov.kh www.elibraryofcambodia.org

ព្រះទេវដឹងនូវចិត្តវាសវក្សត្រហើយ ក្រែងក្រោធខ្ញុំនេះហើយ ក៏ធ្វើពាក់ដូចជារង្គលោកមិនដោះឆ្លើយមិនរួចហើយ ក៏គង់នៅស្ងៀមដោយទុក្ខព្រួយភាពក្រោមព្រោយប្លែកក្រត់ ក្នុងពេលនោះ ។

ព្រះរាជតេជះគង់នៅស្ងៀមបន្តិចហើយ ទើបថ្វាយព្រះពរថា ពិត្រព្រះនរោត្តមរាជកុមារ ព្រះវង្សាជាខត្តិយព្រុំនិវឹង ដោយគេសេចក្តីក្តុមអើតេតេជោបក្តិយត្តុកុមាហើយ កាលទ្រង់ស្តេចចេញចាករាជស្ថាន មកកាន់វាលាវតំបន់ព្រៃហិមវណនេះ ក៏រាវីញលំបាក ព្រះវង្សតោវញ្ញូងគរហើតក្សត្រិពកមោគវ ប៉ុន្តែអៀតស្តេចក៏ត្រូវកំដៅព្រះវាមិត្តប៉ោងឡើងក្នុងវេលារស្មីរៀកតរហើយ នាំព្រះបញ្ចប័ទ្មនោះនៅក្រោយមកពីរតាក្បាលត្រើងហើយក៏ទ្រង់ព្រះរាជដំណើរមកកាន់តំណាក់វាត្មាភាពនេះទៀតក៏មកដោយព្រះបាទទទេ ក្រវិលនេជាមឹងផល់ចំពប់ព្រះបាទ ដោយដុំគ្រួសជុំថ្មនោរាបួយមិនអាចដឹងបានជាព្រះបញ្ចប័យផ្ទាំងផ្ទាក់សៅប្លង់ ទោះព្រះអង្គាវឡាំង ២ព្រោតព្រាតមកកាន់រាជ្ញាវគពេ២ ត្រូវបន្ទូរបាបពិត្រ ២ ស្តេចមកនេះ តើដោយព្រះបាទទទេ ឬ ទើបរាជពោនរាជពាបានឯណោះមួយ ត្រូវមហាបពិត្រស្តេចប្រោសប្រទានប្រាប់រាជ្ញា

www.budinst.gov.kh www.elibraryofcambodia.org

ភាពរោយបានដឹងហេតុនេះផង។

ប.បពិត្រព្រះថេរដ៏ចំរើនកាលដែលខ្ញុំមកកាន់សំខេយ្យបរិវេណនេះ ពីមកដោយរាជរថលុះចូលមកកាន់សំណាក់លោកម្ចាស់នេះទើបមកដោយជើងទទេ ។

ន . ព្រះនាគសេន ទើបតាំងប្រកាសសេចក្ដីទៅនឹងរាជរាពាក្យថា នែរាជសេវកាមាត្យទាំង៥០០ ចូរលោកស្ដាប់នូវព្រះរាជឱង្ការចុះ ព្រះមហាក្សត្រស្ដេចទ្រង់ត្រាស់ថា កាលស្ដេចព្រះរាជដំណើរពីរាជស្ថានមក គឺស្ដេចមកដោយរាជរថលុះមកកាន់សំណាក់អាត្មាភាពនេះ ទើបស្ដេចមកដោយព្រះបាទទទេ នែរួកទាំងអស់គ្នានឹងភិក្ខុសង្ឃ ទាំង៨០ ពាន់ ចូរស្ដាប់ចុះ ហើយអស់លោកចូរចាំទុកជាបន្ទាល់សាក្សីរបស់អាត្មាផង រួចព្រះថេរថ្វាយព្រះពរមហាបពិត្រទ្រង់ត្រាស់ថា ស្ដេចព្រះរាជដំណើរមកដោយរថនោះជាទ្រង់ត្រាស់ថា មែន អែន ឬដូចម្ដេច ។

រ . ករុណាខ្ញុំថាមែនប្រាកដ ។

ន . បើទ្រង់ស្ដេចមកដោយរាជរថនោះ ចុះត្រង់ណាហៅថារថ ពីត្រង់ចន្ទោលនោះ ឬ អ្វី ។

www.budinst.gov.kh www.elibraryofcambodia.org

ម - ទេលោកម្ចាស់ ចន្លោលនោះមិនមែនរថទេ ។

ន - ចុះត្រង់ភ្លៅ ឬខាងក្នុងភ្លៅនោះដែលហៅថារថ ។

ម - ទេរបស់ទាំងនោះ ក៏មិនមែនរថដែរ ។

ន - ថ្វាយព្រះពរ ចុះត្រង់កង់ ឬខាងក្នុងកង់នោះ ដែលហៅថារថ ។

ម - របស់ទាំងនោះក៏មិនមែនរថដែរ ។

ន - បពិត្រព្រះរាជសម្ភារ ចុះត្រង់ចង្កូតនោះ ឬអ្វី ដែលហៅថារថ ។

ម - មិនមែនទេព្រះករុណា ។

ន - ចុះត្រង់ផ្ទះរទេះនោះ ឬអ្វី ដែលហៅថារថ ។

ម - មិនមែនទេលោកម្ចាស់ ។

ន - ចុះខ្សែចន្លោងនោះឬ ដែលហៅថារថ ។

ម - ទេខ្សែចន្លោងនោះ មិនមែនហៅថារថទេ ។

ន - ជន្លួញនោះ ឬអ្វី ដែលហៅថារថ ។

ម - មិនមែនទេព្រះតេជគុណ ។

www.budinst.gov.kh www.elibraryofcambodia.org

ន . ចុះនឹមឬអ្វីដែលហៅថារថ ។

ប . នឹមក៏មិនមែន ។

បពិត្រមហារាជដ៏ប្រសើរ អាត្មាភាពបានយកគ្រឿងប្រុងរបស់រថច្រើនមុខមកថ្វាយព្រះពរសួរមហាបពិត្រៗ ស្ដេចឆ្លើយបដិសេធន៍ដាច់ថាមិនមែនរថទាំងអស់ អាត្មាភាពរកពុំឃើញវត្ថុអ្វីដែលហៅថារថនោះសោះ ចុះកាលដែលទ្រង់ត្រាស់ព្រះឱង្ការអំពីដើមថា កាលស្ដេចចេញចាករាជដ្ឋានមកនោះពីមកដោយរថ លុះអាត្មាភាពសួរព្រះរថជាវត្ថុនោះ ៗ ឬអ្វីដែលហៅថារថនោះ មហាបពិត្រទ្រង់ឆ្លើយហាត់ថាមិនមែនរថទាំងអស់ សេចក្ដីនេះគួរអោយសង្ស័យពេកណាស់ ព្រះអង្គជាក្សត្ររាជជាស្ដេចរុងរឿងជាទីបំផុត ជាម្ចាស់ផែនដី មិនគួរសោះឡើយនឹងមកពោលពាក្យមុសាវាទទេ ៗ រកគួរស្ដាប់មិនបាន នៃសេវកាមាត្យទាំង ៥០០ និងភិក្ខុសង្ឃទាំង ៨០ ពាន់ ដែលយើងបានសូមពាំងអស់លោកជាបន្ទាល់សាក្សីនោះ ចូរលោកស្ដាប់ចុះតើអស់អ្នកអស់លោកទាំងអស់យល់ដូចម្ដេច ។

ពេលនោះពួកមន្ត្រីទាំងអស់បានអោយសព្ទសាធុការថ្វាយព្រះនាគសេនថេរនោះផ្សេង ៗ គ្នា មន្ត្រីខ្លះ ដែលជាគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ក្រោកស្រុះហើយនោះ ក៏អារម្មណ៍តាំងនៅសម្តីគួរគោរពស្រឡាញ់ព្រះ ហេតុអ្វីត្រូវ វាយនៅស្ដេចពីតដែលធ្វើការបានដោះតែចក្ខុ ចំពោះក្នុងការគ្រោះនោះដោយការរួតរាន់ ។

ចំណែកមហាក្សត្រ ស្ដេចក៏បានព្រះរាជឱង្ការឆ្លើយតប ទៅនឹងព្រះថេរថា បពិត្រ ព្រះករុណាម្ចាស់ ប្រិយនឹងបានឆន់ហោយ រុក្ខជាតិនេះ ពីពោធិ៍ដោយពិត ងាយស្រួលបញ្ចុះរបស់វានោះ វាត្រូវការ នូវគ្រឿងដំណាំដំបូងក្នុងការរស់ពិតប្រាកដ និង ភ្លើងនឹង ការ នឹងធូបនេះ នឹងទៀនផ្លែ នឹង និងជាដើមទៀតបាន ឈ្មោះថា វត្ថុបរិក្ខារគ្រប់គ្រាន់ ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារប័ណ្ណ ត្រឡប់ ដែលវាល្អាកាលពោះថ្វាយព្រះធម៌ពីក្រុងជីវ្យាកក ជាឈ្មោះនាគសេននោះ ក៏វាត្រូវការនូវគ្រាប់ពូជប្រការ ភាព តក់ ពាមជាដើម មានអ្នកក្នុងភូមិជាអ្នកថែទាំបានឈ្មោះ ថានាគសេន ក៏ដូចជាឈ្មោះថារថ ដែលវាត្រូវការនូវគ្រឿងផ្គុំ ទាំងរបស់ ទើបហៅថារថដូចគ្នា ការនឹងពាក្យនោះជាចារ ហើយបានពោលក្នុងវិថីចំពោះព្រះរាជ្យសម្ដេចព្រះនគរពល ដោយបទគាថានេះថា :

យថាបិរវង្គសរ្ការ[១] ហោតិសន្នោរថោផតិ

ឯវំខន្ធេសុ សន្តេសុ ហោតិសត្តោតិសម្មតិ

សេចក្ដីថា ពាក្យដែលគេហៅថារថ ១ នោះ ព្រោះអាស្រ័យនូវអវយវជាគ្រឿងប្រុង មានមកព្រមគ្រប់ប្រជាប់យ៉ាងណាមិញនាកាលខន្ធទាំងឡាយរបស់សត្វមាននៅហើយលោកក៏សន្មតិវោហារយពេញ្រោះថាសត្វ ឬ បុគ្គលដូចនោះឯង ។

វស្សាបញ្ហា ១ ទី.២

ព្រះបាទមិលិន្ទ្រាធិបតិ ទ្រង់សួរនូវព្រះនាគសេនតទៅទៀតក្នុងប្រស្នាទីពីរថា បពិត្រព្រះនាគសេនថេរចំរើន លោកម្ចាស់បួសបានប៉ុន្មានវស្សាហើយ ។

ព្រះនាគសេនថ្វាយព្រះពរថា អាត្មាភាពបួសបាន ៧ វស្សាហើយសូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រទ្រង់ត្រាស់ថា ចុះដែលលោកម្ចាស់ថាបាន ៧ វស្សានោះ តើតីរាប់ខ្លួនលោកម្ចាស់បញ្ចូលជាមួយនឹង

---

(១) ក្នុងសេចក្ដីប្រែរបេរបស់ប្ញារោហថារវង្គសព្ភារោហោតិសញ្ញោរថោផតិ។

វត្ថុនោះផងឬ ។ រាប់តែវត្ថុនេះទេនោះទេ ។ ក៏ក្នុងកាលពេលនោះព្រះមហាក្សត្រស្តេចទ្រង់ប្រដាប់គ្រឿងអាភរណ៍ទាំងពួង ការបិលន្ធិតមហាលតាអលង្ការជាដើម ហើយក៏ត្រូវបោះព្រះអង្គនោះធ្លាក់ចូលទៅក្នុងទឹកក្អមកែវ ដែលតាំងនៅទៀបព្រះអង្គ តែបានឃើញប្រាកដ ហើយព្រះរាជគ្រូនោះវេរពោកយកពោតនោះមកជាទីតាំង ហើយថ្វាយព្រះទេចំពោះព្រះភក្ត្រព្រះពិត្រព្រះបរមរាជា ស្រមោលដែលធ្លាក់ទៅក្នុងទឹកក្អមនោះជាមហាក្សត្រឬ ។ ធ្លាព្រះអង្គឯណេះជាបរមក្សត្រព្រះទ្រង់ព្រះវិសជ្ជនា ។

ប . នបរិភាគ បពិត្រព្រះរាជគ្រូនេះពីរ ស្រមោលនោះមិនមែនជាស្តេចទេ ពីព្រោះខ្ញុំនេះឯងហើយជាស្តេច ដោយពិត ឯស្រមោលនោះជាធម្មជាតិ គ្រាន់តែអាស្រ័យនឹងខ្ញុំនេះទេ ។

ន . ឯវិមបាភាជ បពិត្រមហារាជ ឯកិរិយារាប់នូវវត្ថុ ៧ នោះ ក៏ជាធម្មជាតិ គ្រាន់តែអាស្រ័យនូវញាណភាពនេះមិនមែនជាខ្លួនញាណភាពទៀតទេ គ្រាន់តែប្រៀបជាគ្រាបដែលអាស្រ័យនឹងព្រះអង្គនោះរាប់ព្រមទាំងគ្រាក ។

ម - អច្ឆរិយំភន្តេ បពិត្រព្រះករុណាម្ចាស់ ដ៏ចំរើន សេចក្តីប្រៀបធៀបក្នុងប្រស្នាដ៏វិចិត្រដែលលោកម្ចាស់វិសជ្ជនាមកនេះ ជាទីអស្ចារ្យចំឡែកពេកណាស់ ត្រូវព្រេងតាមទម្នង ប្រស្នាដែលខ្ញុំសួរនោះ ឥតមានទាស់អ្វីឡើយលោកម្ចាស់ ប្រាកដជាអ្នកប្រាជ្ញចេះដឹងមែនហើយ ។

ផេវស្សេពិភូបដិញ្ញាវេបញ្ហា ១ បិ ៣

ព្រះបាទមិលិន្ទរាជស្តេចទ្រង់បុច្ឆាទៅ ព្រះនាគសេនថេរ ក្នុងប្រស្នាទី ៣ថា មានប្រយោជន៍ដ៏ឧត្តមយ៉ាងណាហើយប្រព្រឹត្តទៅដើម្បីគុណអ្វីខ្លះលោកម្ចាស់ ។

ព្រះថេរថ្វាយព្រពរថា បពិត្រមហារាជបព្វជាភេទរបស់អាត្មាភាពនោះ មានប្រយោជន៍ដ៏ឧត្តមដើម្បីនឹងរំលត់ទុក្ខដែលមាននៅក្នុងសន្តាននេះហើយ នឹងមិនអោយទុក្ខដទៃកើតឡើងបាន ម្យ៉ាងទៀតបព្វជាភេទរបស់អាត្មាភាពនេះជាគុណសម្បត្តិយ៉ាងប្រសើរ ដើម្បីនឹងអោយកើតប្រយោជន៍ផងគុណនឹងសេចក្តីសុខដល់មនុស្សនីករ នឹងទេវនីករទាំងឡាយសព្វអន្លើរជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ប - ព្រះបាទមិលិន្ទ ស្តេចបានទ្រង់ព្រះសណ្តាប់ពាក្យព្រះនាគសេនសំដែងដូចនោះហើយ ស្តេចក៏មិនអាចនឹងរកផ្លូវសឹកសៀត ជ្រៀតជ្រែកសួរតទៅទៀតបានឡើយ ហើយទ្រង់មានព្រះរាជឱង្ការដំណើរវិញទៀតថា បពិត្រព្រះនាគសេនម្ចាស់ដ៏ចំរើន លោកម្ចាស់អាចនឹងចរចាជជែកគ្នាជាមួយនឹងខ្ញុំតទៅទៀតបានឬទេ ។

ន - ព្រះថេរឆ្លើយថា បពិត្រមហារាជ បើទ្រង់មានព្រះហឫទ័យបំរុងនឹងចោទឆ្លើយដោយបណ្ឌិតវាទនោះ អាត្មាភាពអាចនឹងវិសជ្ជនាថ្វាយបាន បើព្រះអង្គទ្រង់ចោទឆ្លើយដោយរាជវាទទេនោះ អាត្មាភាពមិនអាចនឹងវិសជ្ជនាបានឡើយ ។

ម - បពិត្រព្រះថេរដ៏ចំរើន បណ្ឌិតវាទនោះ គឺបណ្ឌិតលោកពោលដូចម្តេច ។

ន - បពិត្រមហារាជ ធម្មបណ្ឌិតទាំងឡាយកាលដែលលោកនិយាយទៅហើយ ៗ បើមានអ្នកដទៃណា ១ គេអាចនិយាយផ្គួញផ្គាប់សង្កត់សង្កិនចំពោះខ្លួនក្តីគេបង្ហុសថា អោយជៀសចេញទៅក្តី គេធ្វើអោយវិសេសជាងនេះទៅក្តី គេពោលបដិសេធហាមឃាត់មិនអោយនិយាយក្តី គេប្រុងនឹងចង និងស្រាយក្តី ក៏ពង់អ្នកប្រាជ្ញទាំងឡាយនោះ លោកមិនមានចិត្តថ្នាំងថ្នាក់អាក់អន់ឡើយ បពិត្រមហារាជក៏ការដែល

www.budinst.gov.kh www.elibraryofcambodia.org

ពោលជជែកយ៉ាងនេះឯងហើយហៅថា បណ្ឌិតវាទសូម ទ្រង់ជ្រាប ។

ម - ចុះរាជវាទនោះ ដូចម្ដេចទៅលោកម្ចាស់ ។

ន - បពិត្រព្រះបរមក្សត្រាធិរាជឯរាជវាទនោះថា ធម្មតា បហាក្សត្រទាំងឡាយលោកមានឫទ្ធិអំណាច អាចតាំងម្ដេ ថ្វាដោយវត្ថុតែម៉្យាង គឺថាបើទ្រង់បង្គាប់ ឬបញ្ញត្តិទៅយ៉ាង ណាត្រូវតែប្រតិបត្តិតាមបើមានអ្នកណា ១ មិនខ្លាច មិនព្រម ធ្វើតាមស្ដេចនឹងដាក់ទោសទណ្ឌកម្ម ទៅដល់អ្នកនោះមិន ខានឡើយ បពិត្រមហារាជសេចក្ដីដែលពណ៌នាមកនេះហៅ ថារាជវាទ សូមបរោបពិត្រស្ដេចទ្រង់ជ្រាប ។

ម - បពិត្រព្រះនាគសេនដ៏ចំរើន បើដូចនោះ ខ្ញុំនឹង ពោលដោយបណ្ឌិតវាទចុះ មិនពោលដោយរាជវាទទេលោក ម្ចាស់កុំព្រួយ សូមលោកម្ចាស់ពោលមកនឹងខ្ញុំនេះ អោយដូច ជាលោកម្ចាស់និយាយចំពោះទៅនឹងនាងភិក្ខុនី ឬ នឹងសាម ណេរ ឧបាសក ឧបាសិកា ឬដូចជាពោលនឹងក្មេងវត្ត ក៏បាន ឥតមានទោសមានទាស់អ្វីឡើយ ឯអំណាចខ្ញុំជាស្ដេចនោះ លះបង់លើកទុកសិន ហើយសូមលោកម្ចាស់កុំអារម្មណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - សុដ្ឋុមហារាជ បពិត្រព្រះបរមក្សត្រព្រះក្សត្រិយមហាសាល ទ្រង់មានព្រះឱង្ការពោះពិរោះត្រូវលោកពេកណាស់ បើយ៉ាងនឹង អាត្មាភាពអាចនឹងវិសជ្ជនាព្រះរាជប្រស្នាថ្វាយបានដោយងាយឥតពោរពិបាក ។

ម - បពិត្រព្រះនាគសេន បើដូច្នោះលោកម្ចាស់ប្រុងចាំស្តាប់ខ្ញុំនឹងសួរឥឡូវនេះ ។

ន - បុច្ឆមហារាជ បពិត្រមហារាជសូមព្រះករុណាត្រាស់បុច្ឆាមកចុះ ។

ម - បុច្ឆិតោភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ខ្ញុំសួររួចហើយ ។

ន - វិសជ្ជិតំមហារាជ បពិត្រព្រះមហាក្សត្រ អាត្មាភាពវិសជ្ជនាថ្វាយហើយ ។

ម - កឹបនភន្តេ លោកម្ចាស់ឆ្លើយហើយដូចម្តេច ។

ន - កឹបនមហារាជ មហារាជស្តេចសួរហើយដូចម្តេច ។

ព្រះបាទមិលិន្ទ្រាធិបតិ ស្តេចទ្រង់សួរប្រស្នាជាសំនួនចំលែងលងប្រាជ្ញាព្រះនាគសេនលមើល ព្រោះហោជា

www.budinst.gov.kh www.elibraryofcambodia.org

ភាន់ច្រឡំភ្លេច ព្រោះប្រស្នានេះស្តេចបានសួរម្តងហើយក្នុងរាងដើម ។

អដ្ឋកាមេបញ្ហា ១ បី ៤

អថខោមិលិន្ទស្សរញ្ញោឯតទហោសិ គ្រានោះព្រះបាទមិលិន្ទបរមក្សត្រាធិរាជ ទ្រង់ព្រះរាជដំរិះក្នុងព្រះរាជចិន្តាថា ដើរអើភិក្ខុនេះ មានប្រាជ្ញាឆ្លៀវឆ្លាស់ប្រតិពលឆាប់យល់ការណាស់ពើ លោកនេះអាចនឹងវិសជ្ជនាអាថ៌ប្រស្នារបស់អាត្មាអញបាន ហើយម្យ៉ាងទៀតហេតុដែលអាត្មាអញបំរុងនឹងសួរជាប្រស្នានោះមានច្រើនកន្លែងណាស់ តែមិនទាន់បានសួរនៅឡើយ ព្រោះព្រះអាទិត្យក៏ទៀបអស្តង្គតបាត់រស្មីទៅហើយ បើដូចនោះត្រូវបង្អង់ចាំថ្ងៃស្អែកសិនចុះ នឹងឲ្យវិសជ្ជនាគ្នាខាងក្នុង នៃព្រះបរមរាជវាំងវិញ លុះទ្រង់ព្រះរាជដំរិះដូចនេះហើយ ទើបទ្រង់មានព្រះដម្រាស់ចំពោះទៅលើទេវមន្តិយអាមាត្យ ថានែទេវមន្តិយ ត្រូវអ្នកឯងពិតព្រះនាគសេនឡាស់ថា ក្នុងវេលាព្រឹកស្អែកនេះនឹងមានសេចក្តីឲ្យវិសជ្ជនាជាមួយគ្នានាខាងក្នុងព្រះរាជបុរី លុះព្រះអង្គមានព្រះរាជឱង្ការដូចនេះហើយ ទើបទ្រង់ព្រះរាជឧដ្ឋាការក្រោកចាករាជាសន ទ្រង់ឡើងគង់លើសេះព្រះរាជទីនាំងជាអាជានិយជាតិ ហើយលាន់ព្រះឱស្ឋទន្តេញដែល ៗ ថា នាគសេន ៗ

www.budinst.gov.kh www.elibraryofcambodia.org

មិនបាត់សូរទ្រង់បែចំពោះព្រះភក្ត្រទៅកាន់ព្រះរាជស្ពាន ។ លំ
ដាប់នោះ ទេវមន្ទិយអាមាត្យក៏ចូលទៅជិត ហើយពិតថេរវា
ចាព្រះនាគសេនថា បពិត្រព្រះករុណាម្ចាស់ ក្នុងវេលាព្រឹក
ព្រឹកនេះ មានព្រះរាជដំណាស់ព្រាស់ មិនបានព្រះរាជបុត្រា
ចំពោះអង្គលោកម្ចាស់ រាំងក្នុងព្រះរាជនិវេសស្ពានឯណោះ
សេចក្តីនេះ សូមនិមន្តព្រះករុណាចូលទៅក្នុងព្រះបរមរាជវាំង
កុំខាន ឯព្រះថេរលោកក៏ទទួលព្រះរាជនិមន្តថា សាធុៗ ស្រួល
ហើយរាជអាមាត្យ។ លុះកន្លងផុតរាត្រីយប់ រស្មីព្រះអាទិត្យទិ-
វាករក៏ភ្លឺស្វាងឡើងច្បាស់ ចំណែករាជអាមាត្យទាំងឡាយ ៤នាក់
គឺនេមិត្តិយ ១ អនន្តកាយ ១ មង្គុរ ១ សព្វទិន្ន ១ ក៏នាំគ្នាចូល
ទៅក្រាបបង្គំគាល់ព្រះមហាក្សត្រ ហើយរាយរាប់សេចក្តីក្រាប
ទូលថាសូមព្រះរាជតេជះព្រះគុណព្រះបាទដ៏កល់លើត្បូងទ្រង់
ព្រះករុណាអោយនិមន្តព្រះនាគសេនចូលមកកាន់ព្រះរាជស្ពាន
ឬដូចម្តេច ។

ព្រះមហាក្សត្រស្តេចទ្រង់ត្រាស់ថា រីរាយលោកចូល
មកកុំខាន ។

អាមាត្យទាំងនោះទូលថា សូមទ្រង់ព្រះមេត្តាប្រោសព្រះ
ករុណាទ្រង់អនុញ្ញាតឱ្យព្រះនាគសេន ចូលមកជាមួយនឹងភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃប៉ុន្មានអង្គ ។

ស្ដេចទ្រង់ត្រាស់ថា តាមតែប៉ុន្មានអង្គចុះ ស្រេចនឹងព្រះថេរនោះ បើលោកពេញព្រះហឫទ័យនឹងយកភិក្ខុប៉ុន្មានអង្គក៏យកមកចុះឥតមានទាស់អ្វីទេ ។

សព្វមិន្ទអាមាត្យបានទូលថា សូមព្រះរាជទានទោស សូមឲ្យព្រះនាគសេនលោកនិមន្តជាមួយនឹងភិក្ខុ ត្រឹម ១០ អង្គ ហើយ កុំអោយលោកមកច្រើនពេក ។ ទើបស្ដេចបានព្រះរាជឱង្ការត្រាស់ថា ឱសព្វទិន្នអើយកុំឃាត់លោកឡើយ តាមព្រះទ័យលោកលោក ចង់មកប៉ុន្មានក៏មកចុះមិនអីទេ ។

សព្វទិន្នអាមាត្យខំទូលយ៉ាងនេះដល់ទៅ ២-៣ ដង ព្រះបរមរាជព្រះស្ដេចពុំព្រមតាមឡើយ ។

ព្រះមហាក្សត្រស្ដេចទ្រង់ត្រាស់ចំពោះទៅនឹងសព្វទិន្នអាមាត្យទៀត នៃសព្វទិន្នភោជនាហារ ដែលនៅក្នុងរាជស្ថាននេះមានច្រើនល្មម យើងនឹងប្រគេនដល់លោកទាំងអស់នោះឆាន់គ្រប់គ្រាន់បាន មិនខ្វះខាតទេ ។

កាលបើព្រះមហាក្សត្រស្ដេចត្រាស់ដូចនោះហើយ សព្វទិន្នអាមាត្យក៏ស្ងៀបនៅក្នុងវេលានោះ លំដាប់ពីនោះទៅ

www.budinst.gov.kh www.elibraryofcambodia.org

ទើបអាមាត្យទាំង ៤ គឺទេវមន្តិយអាមាត្យ - និងអនន្តកាយអា-
មាត្យ-មង្គុរអាមាត្យ និងសព្វទិន្នអាមាត្យ ក៏នាំគ្នាទៅកាន់សំ-
ណាក់ព្រះនាគសេនថេរដល់ហើយក៏ពោលនូវវាចាថា បពិត្រព្រះ
ករុណាម្ចាស់ដ៏ចំរើន ព្រះមហាក្សត្រទ្រង់ត្រាស់អារាធនានិមន្ត
លោកម្ចាស់ចូលទៅក្នុងព្រះរាជវាំង ជាមួយនឹងភិក្ខុសង្ឃ
ទាំងប៉ុន្មាន ដែលលោកម្ចាស់ត្រូវការនាំទៅផង ។

លុះអាមាត្យបណ្ឌា នាគសេនទទួលនិមន្តហើយ គ្រានោះព្រះ
នាគសេនថេរ ដ៏មានអាយុ លោកក៏តាំងទាត់តែងស្បង់ចីវរ
លោកស្លៀកស្រេចហើយទើបនិមន្តចូលទៅកាន់សាគលរាជធានី
ជាមួយនឹងភិក្ខុទាំងឡាយ ៨០ អង្គ ។

ក្នុងសម័យនោះអនន្តកាយអាមាត្យចូលទៅជិតព្រះនាគ
សេនថេរ ហើយសួរថាបពិត្រព្រះករុណាម្ចាស់ដ៏ចំរើនដែល
លោកម្ចាស់ពោលថា អង្គលោកឈ្មោះថានាគសេន ។ តើថា
ឈ្មោះនាគសេននេះ នឹងបានចាត់ថា សត្វមានជីវិត ថាបុគ្គល
ក៏ទេ សេចក្តីនេះខ្ញុំម្ចាស់នៅសង្ស័យពេកណាស់ ទើបព្រះនាគ
សេនលោកសួរទៅវិញថា ចុះអ្នកចូលចិត្តដូចម្តេចក្នុងឈ្មោះ
នាគសេននោះ ។

www.budinst.gov.kh www.elibraryofcambodia.org

អន្តកាយអាមាត្យពិតទោវិញថា ខ្ញុំព្រះករុណាចូលចិត្តថា ដង្ហើមចេញចូលក្នុងកាយនេះមាននៅដរាបណា ក៏ឈ្មោះថា មានជីវិតរស់នៅដរាបនោះ ដូចយ៉ាងលោកម្ចាស់នេះមាន ជីវិតរស់នៅ ក៏បានឈ្មោះថានាគសេនដូចនេះឯង ។

ព្រះថេរសួរទៅវិញថា នែអ្នករាជអាមាត្យ អាត្មានឹងសួរ អ្នកថា ចុះដង្ហើមចេញនោះ ចាកកាយទៅហើយមិនត្រឡប់ ចូលមកក្នុងកាយមនុស្សនោះវិញ តើមនុស្សនោះនឹងថាជា មនុស្សរស់ ឬស្លាប់ ។

អន្តកាយអាមាត្យពិតទោវិញថា លោកម្ចាស់បើខ្យល់ ចេញនោះចេញចាកកាយទៅហើយ មិនត្រឡប់ចូលមកវិញ ទេ មនុស្សនោះឯងបានឈ្មោះថាមនុស្សស្លាប់ដោយពិត ។

ព្រះនាគសេនថេរសួរថា ចុះមនុស្សដែលផ្លុំត្រែ ផ្លុំ សង្ខ ផ្លុំមាស ឬក៏ផ្លុំបប៉ីនោះ មានតែខ្យល់ចេញទេ មិនបាន ខ្យល់ចូលសោះ តើជាមនុស្សនោះរស់ ឬស្លាប់ ។

អន្តកាយអាមាត្យពិតទោវិញថា នាហាំបដិតលោះលោក ម្ចាស់ខ្ញុំព្រះករុណាមិនជាអ្នកឆ្លៀវឆ្លាសចេះដឹងទេមិនអាចដឹង

www.budinst.gov.kh www.elibraryofcambodia.org

ពោលតបតជាប្ដូរនឹងលោកម្ចាស់បានឡើយ សូមនិមន្តព្រះករុណាអធិប្បាយដោយខ្ញុំចូលចិត្តតាមបានផង ។

គ្រានោះព្រះនាគសេនថេរ លោកក៏បានប្រាប់ទៅអង្គការពោលពាក្យថាអ្នកអង្គការ ឯដង្ហើមចូលដង្ហើមចេញនោះ គឺខ្យល់អស្សាសបស្សាសនេះឯង គឺជាឈ្មោះរបស់កាយសំ-ខារទេតើ ។

អង្គការតបពាក្យពិតទៅវិញថា បពិត្រព្រះករុណាម្ចាស់ ចុះកាយសំខារនោះ តើស្ថិតនៅត្រង់ទីកន្លែងណា ។

ព្រះនាគសេនថេរ លោកក៏ប្រាប់ថា ឯកាយសំខារ(១) នោះតែងស្ថិតនៅក្នុងខន្ធទាំង ៥ ដោយរូបខន្ធជាដើមលុះលោកប្រាប់ប៉ុណ្ណោះហើយ ព្រះថេរក៏តាំងសំដែងធម្មទេសនា ដោយវាចាពាក្យនោះស្ដាប់ ជាប់ដល់ចូលចិត្តជឿបានហើយ អង្គការ ក៏មានចិត្តជ្រះថ្លានឹងចម្លើយរបស់ព្រះថេរអង្គនោះ

(១) កាយសំខារ គឺខ្យល់អស្សាសបស្សាស គឺដង្ហើមចូលដង្ហើមចេញនោះឯង ឯសត្វដែលកាលជីវិតរស់នៅនោះ មិនមែនរស់នៅ ព្រោះតែដង្ហើមចូលដង្ហើមចេញប៉ុណ្ណោះទេ ព្រោះពពួកសត្វខ្លះពុំមានដង្ហើមចូលនឹងដង្ហើមចេញដែរ តែវាក៏រស់នៅបានដូចទារក ដែលនៅក្នុងផ្ទៃមាតា និងមនុស្សមុជទឹក និងលោកដែលចូលនិរោធសមាបត្តិជាដើមទាំងរស់នេះ គឺពុំមែនមានដង្ហើមចូលដង្ហើមចេញឡើយ តែគង់មានជីវិតរស់នៅបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ទើបសំដែងសេចក្តីប្តេជ្ញាខ្លួនជាឧបាសកក្នុងព្រះពុទ្ធសាសនា ។

បព្វជ្ជាបញ្ហា ៧ បី៩

ម - ព្រះបាទមិលិន្ទ្រាធិរាជ ទ្រង់ត្រាស់សួរទៅព្រះថេរ ថាបពិត្រព្រះមហាថេរដ៏ចំរើន បព្វជ្ជារបស់លោកម្ចាស់នេះ ឧត្តមយ៉ាងណាមានប្រយោជន៍ដូចម្តេច ។

ន - ព្រះថេរឆ្លើយថាថ្វាយព្រះពរផ្នួស របស់អាត្មាភាព នេះមានប្រយោជន៍ដើម្បីនឹងរំលត់ទុក្ខ ៤ ប្រការ គឺសេចក្តី ព្រួយដែលកើតឡើងអំពីខន្ធ ៥ ប្រការ គឺជាតិទុក្ខ ១ ដែលេ កើតរំពីសេចក្តីត្រាំត្រាទ្រុឌទ្រោមទៅ នៃគំនរទាំង ៥ ប្រការ គឺជរាទុក្ខ ១ ដែលកើតអំពីការប្រេះឆាឈឺចាប់នៃខន្ធ ៥ប្រការ គឺព្យាធិទុក្ខ ១ ដែលកើតអំពីបែកធ្លាយសាបសូន្យទៅ នៃខន្ធ ៥ ប្រការ គឺមរណទុក្ខ ១ អោយបានរម្ងាប់និងមិនអោយទុក្ខ ព្រួយដទៃទៀតកើតឡើងបាន ម៉្យាងទៀតផ្នួសនេះ ដើម្បី អោយបានប្រយោជន៍ដ៏ឧត្តម គឺព្រះនិព្វានដែលជាស្ថានទំនេ ក្សេមក្សាន្តប្រាសចាកសេចក្តីស្រេកឃ្លានគ្រប់ចំពូក គឺអនុបា ទាននោះឯងសូមទ្រង់ជ្រាប ។

ម - បពិត្រព្រះនាគសេនដ៏ចំរើន ចុះលោកអ្នកបួសទាំង ឡាយនោះ តើលោកមានប្រាថ្នាពៃម៉្យាង ដូចលោកម្ចាស់នឹង

www.budinst.gov.kh www.elibraryofcambodia.org

ដែរឬ ១ ក៏ប្រាថ្នាផ្សេងគ្នា ។

ន - ថ្វាយព្រះពរ មិនដូចគ្នាទេ ផ្សេងគ្នា ដោយហេតុ ៧ យ៉ាង គឺអ្នកខ្លះនៅជាគ្រហស្ថមិនបាន ព្រោះមហាក្សត្រ បៀតបៀនប្រើញឹកញាប់ពេកណាស់ ហើយគេចរត់ចេញមកបួស ក៏មានអ្នកបួសពួកខ្លះ ដើម្បីសេចក្ដីស្និទ្ធស្នាល នឹងមហាក្សត្រ ព្រោះស្ដេចរាប់អានក៏មានខ្លះ ដើម្បីបានឥស្សរិយយសជាអ្នកធំក៏មាន ខ្លះដើម្បីបានភោជនាហារបរិភោគចិញ្ចឹមជីវិតដោយងាយក៏មាន ខ្លះខ្លាចចោរតាមប្លន់ ឬគ្រោះផ្សេងៗ បៀតបៀន ក៏មានខ្លះខ្លាចស្ដេចចាប់ចងធ្វើទោសខ្លះ គិតខ្លាចភ័យក្នុងវដ្ដសង្សារហើយចេញបួសប្រាថ្នាយកព្រះនិព្វានក៏មានដែរតាមប្រវង្សជ្រាប ។

ប - ចុះចំណែករដ្ឋបាលលោកម្ចាស់នេះបួសដើម្បីអ្វី ។

ផ - អាត្មាភាពកាលដែលបួសនោះ តាំងពីអាយុ ៧ ឆ្នាំ មិនទាន់ដឹងប្រាកដជាបួសប្រាថ្នា ដើម្បីប្រយោជន៍អ្វីដែរ តែដល់អាត្មាភាពចំរើនចំរុងចំរើនឡើង ព្រះសង្ឃជាសាក្យបុត្រ លោកជាគ្រូបាធ្យាយបង្ហាត់បង្រៀនអាត្មាភាពតាមពុទ្ធបញ្ញាត្ត និងពុទ្ធាធិប្បាយ [illegible] ឡើង ហើយកាលខ្ញុំនេះអាត្មាភាព [illegible] ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ម . សាធុលោកម្ចាស់ៗ នេះឆ្លាតមែន ហើយចេះឆ្លើយព្រួលពេលរាស់សង្ស័យ ។

បដិសន្ធិតមហាណបញ្ហា ។ ទី ៦

ព្រះបាទមិលិន្ទភូមិន្ទ្រាធិបតី ស្តេចមានព្រះរាជឱង្ការត្រាស់សួរទៅព្រះថេរថា លោកម្ចាស់មនុស្សទាំងអស់ដែលស្លាប់ទៅនោះ តែមកកើតទៀត ឬ អ្វី លោកម្ចាស់ ។

ព្រះថេរឆ្លើយថា ថ្វាយព្រះពរ បុគ្គលខ្លះស្លាប់ទៅហើយត្រឡប់កើតទៀត ខ្លះមិនកើតទៀតទេសូមទ្រង់ជ្រាប ។

ម . លោកម្ចាស់ជនប្រព្រឹត្តយ៉ាងណាដែលស្លាប់ហើយត្រូវកើតទៀតសត្វចំពួកណាដែលស្លាប់ហើយមិនកើតទៀត។

ន . បពិត្រមហារាជ អ្នកដែលនៅមានរាគាទិកិលេសនោះរលត់ខន្ធទៅហើយត្រឡប់ទៅកើតទៀត អ្នកដែលប្រាសចាកកិលេសពល្លានោះមិនកើតទៀតទេសូមទ្រង់ជ្រាប ។

ម . ចុះអង្គព្រះករុណាម្ចាស់ វេលាដល់រលត់ខន្ធទៅហើយ តើនឹងកើតទៀតដែរឬ ។ មិនកើតទៀតទេ ។

ន . ថ្វាយព្រះពរ បើអាត្មាភាពនេះប្រកបដោយរាគាទិ-កិលេសជាវត្ថុកចំពាក់ដោយឧបាទាននោះ វេលារលត់ខន្ធទៅ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវត្រឡប់កើតទៀត បើមិនប្រកបដោយបរាគារិកិលេសទេ នោះ មិនកើតទៀតឡើយសូមទ្រង់ជ្រាប ។

ម - ស្តេចទ្រង់សរសើរថា ព្រះករុណាម្ចាស់ឆ្លើយនេះ ពិរោះល្អគួរស្តាប់ពេកណាស់ ខ្ញុំអស់សេចក្តីសង្ស័យហើយ ។

មនសិការបញ្ហា ១ ទី ៧

ព្រះបាទមិលិន្ទបវរមហាក្សត្រ ទ្រង់សួរទៅព្រះនាគសេនថា លោកម្ចាស់ខ្ញុំនៅសង្ស័យថា បុគ្គលដែលមិនមានបដិសន្ធិគឺមិនកើតទៀតនោះ តើមិនកើតដោយហេតុអ្វី មិនកើតទៀតដោយយោនិសោមនសិការដូចម្តេច ។

ព្រះនាគសេនឆ្លើយថាសូមបពិត្រព្រះករុណា បុគ្គលដែលស្លាប់ទៅហើយមិនបដិសន្ធិទៀតនោះ ដោយហេតុធម៌ ៣ យ៉ាង គឺ យោនិសោមនសិការ ១ បញ្ញា ១ កុសលធម៌ដទៃដែលបានបំពេញទុកមកអំពីមុនបរិបូណ៌តាមកំណត់ហើយ រួចបានសម្រេចនូវព្រះនិព្វាន ១ បុគ្គលដែលប្រកបដោយគុណទាំង ៣ យ៉ាងនេះហើយទើបមិនបានកើតទៀតសូមទ្រង់ជ្រាប ។

ម - ចុះយោនិសោមនសិការនោះគឺអ្វី គឺបញ្ញានេះឯង ឬមិនមែនទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - ថ្វាយព្រះពរ យោនិសោមនសិការនោះដទៃមិនមែនបញ្ញាទេ បញ្ញានោះក៏ដទៃមិនមែនយោនិសោមនសិការទេ ឯយោនិសោមនសិការមានលក្ខណស្ថាន ១ បញ្ញាមានលក្ខណស្ថាន ១ ក៏ឯយោនិសោមនសិការចេតសិកនោះ តែងមានក្នុង សន្ដាននៃសត្វតិរច្ឆានទាំងឡាយ មានពពែ នឹងក្របី ពោឱដ្ឋលាជាដើម ចំណែកបញ្ញាចេតសិកនេះ មិនមានក្នុងសន្ដានចិត្តនៃសត្វតិរច្ឆានទាំងឡាយនោះឡើយ ។

បនសិការលក្ខណបញ្ញា ១ ពី ៨

ព្រះបាទមិលិន្ទមហាក្សត្រ ស្ដេចទ្រង់សួរថា បពិត្រលោកម្ចាស់ដ៏ចំរើន មនសិការនោះមានលក្ខណដូចម្ដេច បញ្ញានោះបានលក្ខណដូចម្ដេច ។

ព្រះថេរថ្វាយព្រះពរបពិត្រមហារាជ មនសិការនោះបានលក្ខណ ២ យ៉ាង គឺសេចក្ដីព្យាយាមថាជាលក្ខណ១ ហៅថា ឧស្សាហលក្ខណនិងកិរិយាកាន់យកជាលក្ខណ ១ ហៅថា គហណលក្ខណឯបញ្ញានោះ មានលក្ខណតែ ១ គឺកិរិយាកាត់ផ្ដាច់ជាលក្ខណហៅថាឆេទនលក្ខណ។

ម - បើដូចនោះលោកម្ចាស់ចូលប្រៀបឧបមាបន្តិចមកមើល លក្ខណរបស់យោនិសោមនសិការ និង លក្ខណបញ្ញា

www.budinst.gov.kh www.elibraryofcambodia.org

នោះផ្សេងគ្នាដូចម្តេច ខ្ញុំស្តាប់មិនទាន់ចូលចិត្តនូវឡើយ ។

ន - សូមថ្វាយព្រះពរសម្តេចមហារាជ ទ្រង់បានជ្រាបនូវកិរិយាអ្នកស្រែដែលគេច្រូតស្រូវនោះដែរឬ ។

ម - ករុណាខ្ញុំបានដឹងច្បាស់ហើយការនោះ ។

ន - ចុះអ្នកស្រែច្រូតស្រូវនោះធ្វើដូចម្តេចមហាបពិត្រ

ម - ឱអ្នកស្រែច្រូតស្រូវនោះ កាលបើនឹងកាត់ដើមស្រូវនោះ គឺគេយកជើងជាន់គុម្ពស្រូវទប់ទុក ហើយដៃឆ្វេងចាំបង្អូបចាប់ក្តាប់នូវបាច់ស្រូវដៃស្តាំ កាន់យកកណ្តៀវហើយកៀវប្រមូលមកនូវដើមស្រូវហើយទើបត្រឡប់យកកណ្តៀវកាត់នូវបាច់ស្រូវនោះឯង សូមលោកម្ចាស់ជ្រាប ។

ន - បពិត្រសម្តេចមហារាជ ដៃឆ្វេងដែលជាអ្នកចាប់កាន់នូវបាច់ស្រូវទុកនោះ ប្រៀបដូចជាយោនិសោមនសិការចេតសិកដែលថា មានលក្ខណកាន់យកដៃស្តាំ ដែលកាន់នូវកណ្តៀវហើយប្រមូលមកនូវដើមស្រូវធ្វើជាបាច់ ហើយកាត់នូវបាច់ស្រូវនោះ ឧបមាដូចបញ្ញាចេតសិក ដែលថាមានលក្ខណសម្រាប់កាត់ផ្តាច់នោះឯង សូមទ្រង់ជ្រាប ។

ម - សាធុ ៗ លោកម្ចាស់ ប្រៀបនេះគួរស្តាប់ពេកណាស់ ព្រោះលោកម្ចាស់ ក្នុងសេចក្តីឧបមានុបមេយ្យ

សេស ឮរតប្បីក្រលចិត្តថា អ្នកដែលមិនកើតទៀតនោះ គឺព្រះបិណោ ស្រេចដែលលោកបានព្រះនិព្វាននោះឯង ។

ព្រះបាទមិលិន្ទបរមក្សត្រាធិរាជ ទ្រង់មានព្រះរាជឱង្ការសួរថា លោកម្ចាស់ៗ បានពោលក្នុងជាន់មុននោះថា អ្នកដែលបានព្រះនិព្វាននោះដោយគុណធម៌បីយ៉ាង គឺយោនិសោមនសិការ ១ បញ្ញា ១ និងកុសលធម៌ដទៃនោះ១ ត្រង់យោនិសោមនសិការនិងបញ្ញានោះ ខ្ញុំមិនមានសង្ស័យទេ សូមសួរលោកម្ចាស់តែត្រង់គុណធម៌ទី ៣ ដែលឈ្មោះថា កុសលធម៌ដទៃៗនោះតើគឺអ្វីលោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯកុសលធម៌ដទៃមាន ៦ យ៉ាង គឺសីល១ សទ្ធា ១ វិរិយ ១ សតិ ១ សមាធិ ១ បញ្ញា ១ សូមទ្រង់ជ្រាប ។

ម - កិលក្ខណំសីលំ បពិត្រលោកម្ចាស់សីលនោះមានលក្ខណដូចម្តេច ។

ន - បតិដ្ឋានលក្ខណាសីលនោះ មានលក្ខណជាទីតាំងទីដំកល់នៃកុសលធម៌ទាំងពួង គឺឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឈាន ៤ វិមោក្ខ ៨ សមាធិ ៦ សមាបត្តិ ៨ បពិត្រមហារាជបុគ្គលឯណាដែលបាន

www.budinst.gov.kh www.elibraryofcambodia.org

តំកល់ខ្លួនក្នុងសីលហើយ កុសលធម៌ទាំងពួងនោះមិនបាន វិនាសចាកសន្តានបុគ្គលនោះឡើយ ។

ម - ឧបមំ ករោហិ លោកម្ចាស់ចូរធ្វើនូវសេចក្ដីប្រៀប ផ្ទឹមបន្តិចមកចុះអោយខ្ញុំស្ដាប់បើរ ។

ថ - យថា មហារាជ យេ កេចិ ពីជគាមភូតគាមា ពូជទាំង ឡាយឯណា ២ គឺពូជដែលកើតអំពីគ្រាប់ និងពូជដែលកើត អំពីមើមជាដើម ហើយរាលដាលទៅកាន់សេចក្ដីចំរើនធំ ឡើងបានពូជទាំងឡាយនោះ ក៏ព្រោះអាស្រ័យនូវផែនដី តំ-កល់នៅលើផែនដីទើបដុះឡើងបាន សេចក្ដីនេះមានឧបមា ដូចម្ដេចមិញ ។

ឯវមេវ ខោ មហារាជ បពិត្រសម្ដេចមហារាជ ព្រះយោគាវ-ចរ អាស្រ័យនូវសីលហើយតំកល់ខ្លួនក្នុងសីល ទើបចំរើននូវ ឥន្ទ្រិយទាំងឡាយ ៥ គឺសេចក្ដីជឿជាធំ ១ ( សទ្ធិន្ទ្រិយ ) សេចក្ដីព្យាយាមជាធំ ១ (វីរិយិន្ទ្រិយ) ធម្មជាតិសម្រាប់រឭកជា ធំ ១ (សតិន្ទ្រិយ) ធម្មជាតិសម្រាប់ញុំាងចិត្ត អោយតាំងនូវ មាំជាធំ ១ ( សមាធិន្ទ្រិយ ) ធម្មជាតិសម្រាប់ដឹងគ្រប់យ៉ាងជា ធំ១ (បញ្ញិន្ទ្រិយ)ក៏មានឧបមេយ្យដូចនោះឯងសូមទ្រង់ជ្រាប ។

ម - ភិយ្យោ ឧបមំ ករោហិ ត្រូវហើយលោកម្ចាស់ ពៃ សូមព្រះគុណម្ចាស់ឧបមាអោយច្រើនទៅទៀតចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

ន . យេកេចិករណីយា បពិត្រមហារាជមនុស្សទាំង ឡាយឯណា ១ ជាអ្នកស្រែធ្វើកសិកម្មគឺភ្ជួរក្តី ឬអ្នកល្បួញ ទេះក្តី តែងធ្វើការនោះលើទីទួល ឬ តាមផ្លូវគោកក៏មនុស្ស ទាំងឡាយនោះ តែងអាស្រ័យនូវផែនដីហើយទើបធ្វើការងារ សម្រេចបានសេចក្តីនេះ មានឧបមាយ៉ាងណាថា គណនា ពួកព្រះយោគាវចរ ដែលអាស្រ័យនូវសីលដ៏បរិសុទ្ធជាកល់ខ្លួន ក្នុងសីលហើយទើបអាចញ៉ាំងឥន្ទ្រិយទាំង៥ មានសទ្ធាជាដើម អោយចំរើនឡើងបានសូមទ្រង់ជ្រាប ។

ប.ករុណា ត្រូវហើយលោកម្ចាស់ សូមលោកម្ចាស់ ឧបមេទៀត មើល ។

ន . បពិត្រមហារាជ មនុស្សឯណា ១ ដែលជាអ្នកចេះ ចំណេះសិល្បសាស្ត្រ ខាងហាត់លោតលេងកំប្លែងច្រើន យ៉ាង ហើយអ្នកនោះមានប្រាថ្នាដើម្បីនឹងសម្តែងល្បែងនូវ សិល្បសាស្ត្រនោះ មើលដើមឡើយគេតែងញ៉ាំងមនុស្ស អោយធ្វើបីភូមិកន្លែងអោយស្អាតគឺចូកចាំងនូវផែនដីហើយនាំ ចេញនូវថ្ម និងគ្រួស រវាងនឹងអម្បែងចែះអម្បែងចាន អំពី ទីនោះ ២ ហើយទើបធ្វើនូវកន្លែងនោះអោយរាបស្មើ លុះទី នោះបានរាបស្មើហើយ ទើបចេញសម្តែងនូវសិល្បសាស្ត្រ នោះ អោយគេឃើញជាក់ស្តែងសេចក្តីនេះ ប្រៀបដូចម្តេច

www.budinst.gov.kh www.elibraryofcambodia.org

ពិញេបពិត្រ មហារាជព្រះយោគាវចរកុលបុត្រ បានសីលវេតុ្ភាព
បរិសុទ្ធហើយ ឋិតនៅក្នុងសីលនោះបាន ទើបគួរនឹងធ្វើនូវ
កុសលធម៌ទាំងឡាយ មានសេចក្តីជឿជាដើមរហូតចំរើនបាន
ដូចនោះឯង ។

ក - ឱពិរោះបើរៀបព្រះនគរ ស្រុកព្រះនគរនោះ ១ ទៀ
ទៅមើលខ្ញុំចង់ស្តាប់ហើយបានច្រើនយ៉ាងច្រើនបែប ។

ន - បពិត្រ ព្រះរាជសម្ភារនាយជាងដ៏ឈ្លាស ក្នុងកិ
កសាងនូវព្រះនគររាជធានីកាលដើមដំបូងនោះ នាយជាងព្រ

បង្គាប់ហើយគេជំរះនៅទីកន្លែង ដែលគេនឹងធ្វើនូវវាំងប្រា
សាទនោះ គឺហើយនាំចេញនូវគល់ឈើព្រៃ និងគម្រោងបន្ល
ហើយធ្វើទីនោះហើយរាបស្មើល្អ ទើបធ្វើនូវវាំងប្រាសាទនឹ
ទីទាំងឡាយមានផ្លូវប្រកបដោយព្រុំង ៤ និងផ្លូវព្រៀងព្រែ
ជាដើម វិធីនេះ មានឧបមាយ៉ាងណា បពិត្របរមរាជ ព្រះយោ
គាវចរភិក្ខុជាអ្នកអាស្រ័យនៅចតុបរិសុទ្ធសីល ឋិតនៅក្នុ
សីលនោះបាន ទើបត្រូវធ្វើនូវឥន្ទ្រិយទាំង ៥ គឺសទ្ធិន្ទ្រិ
វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ហើយបរិបូណ៌
បានក៏មានឧបមាដូចនេះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

ម - ស្រួលល្អស្ដាប់ហើយលោកម្ចាស់ សូមលោកម្ចាស់ប្រៀប ១ ទៀតទៅមើល ។

ន - បពិត្រមហារាជ សេចក្ដីឧបមាថាចតុរង្គសេនាដែលចូលទៅកាន់ទីពិជ័យសង្គ្រាមផ្ចាញ់ផ្ចាល់ឬសំលាប់នូវបច្ចាមិត្រដែលច្រើន ក៏តែងសែងរកទីជ័យភូមិ ដែលល្អ ហើយធ្វើនូវទីផែនដីត្រង់នោះ អោយរាបស្មើលុះពេលដែលសត្រូវច្រើនមកដល់ហើយ ក៏នឹងធ្វើនូវជ័យជំនះនោះអោយឈ្នះ បានសេចក្ដីនេះឧបមាយ៉ាងណាមិញ ព្រះយោគាវចរអាស្រ័យនូវសីលសំវរជាទីតាំង ហើយទើបនឹងញ៉ាំងកុសលទាំង ៥ គឺសេចក្ដីជឿពិត ១ កិរិយាប្រឹងប្រែង ១ ធម្មជាតិរឭកប្រពៃ ១ ការតាំងចិត្តមាំល្អ ១ ធម្មជាតិដឹងទូទៅ១ អោយកើត អោយចំរើនក្នុងសន្ដានបាន ក៏មានឧបមេយ្យដូចនោះឯង ម៉្យាងទៀតព្រះសាក្យមុនីជាសាស្ដា លោកទ្រង់ត្រាស់ទេសនាទុកមកថា ដូចនេះ ។

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដន្តិ ។
អយំ បតិដ្ឋា ធរណីវ បាណីនំ ឥទញ្ច មូលំ កុសលាភិវុឌ្ឍិយា

www.budinst.gov.kh www.elibraryofcambodia.org

មុខញ្ចិទំ សព្វជិនានសាសនេ សុសីលេភូតោ វរបាដិមោក្ខោតិ

ក្នុងសំណៅអត្ថរសនៃពុទ្ធភាសិត ដែលព្រះអង្គទ្រង់ត្រាស់ទុកមកនេះថា ពពួកជនឯណាដែលមានសទ្ធាជ្រះថ្លាប្រកបដោយត្រៃហេតុកបដិសន្ធិបញ្ញា បានដឹកនាំខ្លួនទុកក្នុងសីលដ៏បរិសុទ្ធហើយ គួរតប្រឹងញាំងសមាធិចិត្ត និងវិបស្សនាបញ្ញាអោយចំរើនបាន ពពួកជននោះឯង បានឈ្មោះថាភិក្ខុជាអ្នកមានប្រាជ្ញាចាស់ទៅ និង មានព្យាយាមប្រៀតប្រៀន ដុតកិលេសញាំងកិលេសអោយក្តៅ អាចនឹងកាប់ផ្តាក់ផ្តាច់បង់នូវបណ្តាញ់ គឺកិលេសឈ្មោះតណ្ហាក្នុងអារម្មណ៍អោយផុតចាកសន្តានទៅបាន ។ សីលនេះជាហេតុ ជាទីតាំងនៃឈ្មោះអោយផុតអោយផ្តើមឡើង នៃកុសលធម៌ទាំងឡាយ ប្រៀបដូចផែនប្រថពីធរណី ដែលជាទីតាំងនៃរុក្ខជាតិទាំងឡាយ និងជាទីទ្រទ្រង់នូវពពួកនិករ នាគ គ្រុឌ មនុស្ស និង ភូតបិសាចទាំងឡាយ បណ្តាវត្ថុទាំងអម្បាលមាណនេះ ក៏តែងអាស្រ័យនូវផែនធរណីនេះឯង សេចក្តីនេះមានឧបមាយ៉ាងណា សីលដែលបុគ្គលរក្សាល្អហើយនេះ តែងជាប្រធាននៃកុសលធម៌ទាំងឡាយ ក្នុងសាសនានៃព្រះជិនស្រីសព្វញ្ញូជាម្ចាស់ បានដល់សីលក្ខន្ធ គឺបាដិមោក្ខសំវរសីល ក៏ឈ្មោះថាប្រសើរយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

...នោះឯង ឥឡូវនេះពាក្យដែលទ្រង់មហាពពិតគឺហើយនិង ក៏ធ្វើហើយ
...ទូលថ្វាយព្រះពរ ។

ឋ - ករណ្ហោសិតភន្តេ បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនលោក
...ពោលល្អណាស់ ឆ្លើយមកនេះល្អណាស់ពេកសេចក្ដីដែល
...ព្រះករុណាវៀបរាប់តាមពុទ្ធភាសិតមកហើយ ក៏ល្មមសមគួរ
...តែងហើយ ។

ករណ៍ព្រះបញ្ចន្ទបរិច្ចៈ ១ ទី ១០

ទេវបាក្យព្រះស្តេចទ្រង់បុច្ឆាក្នុងលក្ខសទ្ធា ចំពោះនឹង
...ព្រះនាគសេនក៏ពាក្យណាភន្តេសទ្ធា បពិត្រព្រះនាគសេន ម្ចាស់
...សទ្ធាចេតសិកនោះ មានរបស់អ្វីជាកំណត់ជាលក្ខណៈ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ
...សទ្ធាចេតនានោះ មានលក្ខណៈ ២ យ៉ាង គឺសេចក្ដីវង្វេងជា
...លក្ខណៈ ១ (សម្បសាទនលក្ខណៈ) កិរិយាស្ទុះទៅជាលក្ខណៈ
១ ( សម្បក្ខន្ទនលក្ខណៈ ) សូមទ្រង់ជ្រាប ។

ឋ - សម្បសាទនលក្ខណៈសទ្ធានោះ មានប្រយោជន៍ដូច
...ម្តេច ។

ន - បពិត្រមហារាជសម្បសាទនលក្ខណៈសទ្ធានោះបើ

កើតឡើងក្នុងសន្តានៃបុគ្គលណោ រាគៈនឹងរារាំងនូវនីវរណធម៌ទាំង ៥ មានកាមច្ឆន្ទជាដើម ហើយធ្វើចិត្តនៃបុគ្គលនោះ ឱ្យរួចផុតចាកអំណាចនីវរណធម៌ តែងញ៉ាំងចិត្តឱ្យរីករាយឱ្យស្រស់ ឱ្យស្ងប់ផុតពីទោសទាំងពួងបាន ល្អប្រសើរប្រពៃ ។

ខ . និរាមិសភាព ល្អមែនពិតព្រោះមិនលាយឡំមកនឹង អាមិសឡើយ ។

គ . ប្រយោជន៍ចំពោះភាព ករុណាសម្បត្តិរបស់ព្រះភាគល្អប្រសើរ សេចក្តីថ្លាថ្លៃ ឈ្មោះព្រះធម្មបទគាថា ស្តេចអានន្ទព្រះអង្គ ជិតនៅវេលាគាប់ផ្លូវខ្ញុំ ២ ខ្សែ ដោយមានវត្ថុសំខាន់ហើយ ប្រសិនបើខ្លួនខ្ញុំនៅខ្លួនដែលគោរពទឹកតិច ព្រោះមានទឹកទាំងនោះក៏កក់ ក្តៅទឹកដោយធ្វើឈើ និងតោះ និងផ្ទះ និងពពកធ្វើឈើ (ផា ពីកដ ) ទាំងឡាយ ព្រះពុទ្ធក្រោមព្រៃសេចក្តីល្អរួចហើយ ប្រសិនក៏ បន្ទាប់មកទុកឲ្យរាយនៅផ្ទះទឹកនោះឯក . ដើម្បីគោរពក្នុង ពេលនោះជាបរិតប្រចាំកែវដែលប្រទះព្រៃទឹកក៏កោះនូវ១នោះ ផង តោះកាពោធិក៏បានជាបរិតប្រចាំនោះនៅហើយ ទើបការ នូវស្លូតរាបនិងភាគ់ពេញហើយបើបដាក់ត្រាំជាបនោះក្នុងទឹក ក្រៅនោះឯងក៏រកានុភាពនៃតប្រចាំនោះរាគធ្វើនូវទឹកពីរបក្តៅ

www.budinst.gov.kh www.elibraryofcambodia.org

កករនោះ រោយនៅជាខាងក្រៅ ហើយសម្រិតសម្រាំងស្រូប យកតែទឹកដែលថ្លាឆ្លុះរកកករគ្មាននោះ អោយចូលទៅខាងក្នុងបានទើបរអាមាត្យទាំងនោះ យកទឹកថ្លានោះទៅថ្វាយស្តេចអោយទ្រង់សោយ បពិត្រសម្តេចមហារាជទឹក ដែលល្អក់ហើយត្រឡប់ទៅជាថ្លាល្អវិញ ដោយរានុភាពនៃតម្រងនោះយ៉ាងណាមិញ ចិត្តនៃព្រះយោគាវចរដែលមានសទ្ធាចេត្តសិកបកប្រកបផង ហើយតែងធ្វើរោយជ្រះថ្លា រាចនិងបរិច្ចាគ អានរក្សាសីលចំរើនមេត្តាភាវនា ក៏មានឧបមេយ្យយ៉ាងនោះឯងសូមទ្រង់ជ្រាប ។

ម ‐ បពិត្រព្រះនាគសេនថេរ ចុះសម្បត្តិនៃលក្ខណៈសទ្ធាអោះដូចម្តេចទៅ សូមលោកម្ចាស់អធិប្បាយជាសេចក្តីពន្លិតមកមើល ។

ន ‐ សូមថ្វាយព្រះពរ ឯសម្បត្តិនៃលក្ខណសទ្ធានោះប្រែថា សទ្ធាមានលក្ខណស្ទុះទៅព្រម ឬ ស្ទុះទៅតាមគេបានអាងឯព្រះយោគាវចរ ដែលបានឃើញនូវចិត្ត នៃបុគ្គលដទៃដែលរួចចាកភាគាទិកិលេស បានដល់នៅក្នុងធម៌វិសេសពីសោតាបត្តិផល ឬសកិទាគាមិផល អនាគាមិផល អរហត្តផលហើយជាស់ទៀនចិត្តរបស់ខ្លួន ឱ្យស្ទុះទៅតែធំធ្វើនូវសេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

ព្យាយាម ដើម្បីដល់នូវមគ្គ និងផល ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវមគ្គនិងផល ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ដែលខ្លួនមិនទាន់ធ្វើ ឲ្យជាក់ច្បាស់ បពិត្រឧបាសកជាសប្បុរស ហេតុការណ៍ ទោះការព្យាយាមដូចនេះគួរត្រូវប្រាថ្នា ។

ប - ឧបមាការណ៍ គួរឲ្យយល់ហេតុក្ដាច់តម្រូវបរិយ-ការខាងក្នុងក្រោយ ។

គ - បពិត្រឧបាសកសេចក្ដីនេះ ត្រូវដូចឧបាសកឲ្យ ចំណុះស្ពានធ្លាក់ចុះលោកទៅក្នុងផ្ទុក ហើយទឹកទាំងនោះ បានហូរទៅកាន់ទីទាប បានជ្រោះ និងស្ទឹងជាដើម ហើយក៏ទំលាយនូវច្រាំងទាំង ២ ចូលទៅ ឧបមាដោយទោះជាមនុស្សដំណើរច្រើនមកកាន់ទីនោះ ហើយមិនអាចនឹងឆ្លងទៅបាន ព្រោះពុំដឹងនូវជំរៅទឹកនោះថាជ្រៅ ឬ រាក់ ហើយក៏ឈរនៅមាត់ច្រាំងជិតនឹងពិតឆ្លងទៅនោះ បានបុរសម្នាក់មកកាន់ទីនោះដែរ ជាមនុស្សមានរូបរាងមាំមួនកំលាំងច្រើនតាំងពាក្យថាស្ទាត់សម្ពន់យ៉ាងមាំ ហើយទើបគ្រាំចុះទៅកាន់ទឹកនោះ ហើយឆ្លងទៅ ក៏ឆ្លងបានដោយងាយស្រួល បានឃើញនូវបុរសនោះឆ្លងរួចហើយ ទើបប្រាប់គ្នាថាឲ្យឆ្លងតាមទៅ សេចក្ដីនេះ

www.budinst.gov.kh www.elibraryofcambodia.org

មានឧបមាដូចអ្នកចមិញថា សម្បត្តិនូនលក្ខណ សទ្ធានោះមាន ឧបមេយ្យដូចព្រះយោគាវចរ ដែលបានឃើញនូវចិត្តនៃព្រះអរិយសាវកដទៃ ដែលរួចផុតចាកអកុសលធម៌ទាំងពួង ហើយៗ បង្អុំចិត្តខ្លួនអោយស្ទុះទៅកាន់មគ្គ និងផលទាំងឡាយ អានតេពាពាកព្តិវត្តជាដើមអំធ្វើនូវសេចក្តីព្យាយាម ដើម្បីដល់នូវមគ្គផលដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវមគ្គ នឹងផលដែលខ្លួនមិនទាន់បាន ដើម្បីធ្វើអោយជាក់ច្បាស់នូវមគ្គ នឹងផលដែលមិនទាន់ធ្វើជាក់ច្បាស់ មានឧបមាមេយ្យដូចនោះឯងសេចក្តីនេះត្រូវគ្នានឹងពុទ្ធភាសិត ដែលទ្រង់ត្រាស់ថា ។

សទ្ធាយ តរតិ ឱឃំ  អប្បមាទេន អណ្ណវំ

វិរិយេន ទុក្ខមច្ចេតិ  បញ្ញាយ បរិសុជ្ឈតិ

សេចក្តីសេដែពុទ្ធភាសិតនេះថា ព្រះយោគាវចរដែលឆ្លងនូវអន្លង់ទាំង ៤ ប្រការ មានការមោឃជាដើមបាននោះដោយកំលាំងនៃសម្បត្តិនូនលក្ខណសទ្ធា នឹងឆ្លងនូវមហាសមុទ្រសាគរបាន ព្រោះសេចក្តីប្រុងប្រយ័ត្នមិនធ្វេសប្រហែសពី នឹងឆ្លងនូវសេចក្តីទុក្ខបាន ព្រោះសេចក្តីព្យាយាមមាំ នឹងបរិសុទ្ធស្អាតប្រាស់ចាកមន្ទិល គឺរាគាទិកិលេសបាន ព្រោះឆេទនលក្ខណបញ្ញា ពែងកាត់ផ្តាច់នូវកិលេសធម៌ទាំងពួង មិន

www.budinst.gov.kh www.elibraryofcambodia.org

ទោះបីគេតែងតែរស់នៅបានល្អហើយ សេចក្ដីព្រួយព្រោះភាពវិ-ប្បយោគនេះ សូមមហារាជជ្រាប ។

ប - កល្លោសិ លោកម្ចាស់វៀងវៃពេកណាស់ ចេះវិធិល្បាយក្រៀមពេក ខ្ញុំព្រះករុណាអស់សេចក្ដីសង្ស័យហើយ ក្នុងប្រស្នានេះ ។

វិសេសក្នុងបញ្ហា ១ ក ១១

ព្រះបាទមិលិន្ទ ទ្រង់ត្រាស់ទៅព្រះនាគសេនតទៅទៀតថា កិច្ចក្នុងការវីរិយៈ បពិត្រព្រះនាគសេនដ៏ចំរើន សេចក្ដីព្យាយាម ប្រឹងប្រែងនោះតើមានហេតុដូចម្ដេច ។

ន - ព្រះនាគសេនថេរថ្វាយព្រះពរថាបពិត្រសម្ដេចមហា រាជ ឯសេចក្ដីព្យាយាមនេះមានគុណជាទូកដាក់ក្នុងនោ ការពាំ ប្រមុកប្រវត្តិសេចក្ដីកំសូងនោះការបរិក្ខារ មិនទោះការវិនាស ពារបរមក្សានៅបានល្អើយត្រូវទ្រង់ជ្រាប ។

ម - ឧបមំ ករោហិ សូមលោកម្ចាស់ប្រៀបឧបមា ជា សេចក្ដីបង្អិចបកមើល ។

ន - យថា មហារាជ បពិត្រមហារាជ ទីកើតនៅមានផ្ទះជា ពីរកំពែងបែកពាំងនៅការមិនបានប្រុងប្រុងឥតនៅការនោះ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

អាស្រ័យនូវគ្រឿងគាំទ្រ មានចន្ទល់ នឹងឈើខ្វែងជាដើម សេចក្តីនេះមានឧបមាដូចម្តេចមិញថា វិរិយចេតសិកមានអានុភាពអាចជួយឧបត្ថម្ភគាំទ្រទុកនូវកុសលធម៌ទាំងឡាយ ក្នុងសន្តានកាយនៃបុគ្គល អោយតាំងនូវបាន មិនអោយសាបសូន្យទៅ ក៏មានឧបមេយ្យដូចនោះឯង សូមទ្រង់ជ្រាប ។

ម - ត្រូវហើយលោកម្ចាស់ តែសូមលោកម្ចាស់ឧបមា ១ ទៀតមកមើល ។

ន - បពិត្រមហារាជ សេចក្តីប្រៀបដូចបរមក្សត្រាធិរាជ ស្តេចចេញទៅបង្ក្រាបសត្រូវជាអរិន្ទរាជ ដោយសេនាអាពលនយ៉ាងច្រើន ក៏មិនអាចនឹងបង្ក្រាបបានឡើយ ព្រោះសត្រូវនោះវាដឹងខ្លួន ដោយឃើញពួកពលច្រើន ហើយក៏គេចវេះបាត់ទៅ ព្រោះថា វាងាយនឹងពួន លំដាប់នោះទើបមហាក្សត្រ ស្តេចមានព្រះឱង្ការបង្គាប់អោយសេនាយ៉ាងតិចលើកទៅជាលំដាប់ៗ គ្នា ហើយតាំងមេត្រួតត្រាតាមមុខក្រសួងជួយទំនុកបំរុងគ្នាតាមជាន់តាមថ្នាក់ ហើយក៏ចូលទៅចោមចាប់យកសត្រូវច្រើននោះបានដោយងាយ ព្រោះអាស្រ័យនូវពួកជំនួយនឹងពួកត្រួតត្រា សេចក្តីនេះមានឧបមាយ៉ាងណាមិញថា ហានឧបមាមេយ្យដូចវិរិយចេតសិក ដែលជាអ្នកគាំទ្រទុកនូវ

www.budinst.gov.kh www.elibraryofcambodia.org

កងកុសលធម៌ទាំងឡាយមិនរេរាយវិនាសទៅបាន សេចក្តី
នេះ ត្រូវតាមបើការពុទ្ធភាសិតដែលទ្រង់ត្រាស់ទុកមកថា ដូច
នេះ ។

វីរិយវាភិក្ខវេអរិយសាវកោ អកុសលំបជហតិ

កុសលំភាវេតិ សាវជ្ជំបជហតិ អនវជ្ជំភាវេតិ

សុទ្ធំអត្តានំបរិហរតិ ។

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកលោកតែង
បានសេចក្តីព្យាយាមគង្វាតជាក់លាក់ នោះលះបង់នូវអកុសល
ធម៌ទាំងឡាយ ហើយចម្រើនកុសលធម៌ដ៏ប្រសើរឡើង នោះលះបង់
នូវធម៌ដែលប្រកបដោយទោស ហើយការចម្រើនធម៌ដែលគ្មាន
គុណទោសការចម្រើនធ្វើឡើងជាកុសលធម៌ដែលគ្មានទោស ចាកព្រះតម្រ
ប្អូនឡើកនេះទាំង ជាភាសិតរបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់
ទុកដូចនេះតបថ្វាយព្រះអរ ។

ប ‑ ឱ ពិរោះណាស់ តើលោកឃ្លាតៗ សន្ទុះរោកនេះ
សមគួរប៉ុណ្ណឹងហើយ ។

គតិវេកក្ខមហេត្តា ១ ពី ១៧

បេយាក្យត្រីយ៍ ត្រូវទ្រង់ស្បូរទៅក្នុងព្រួលពេលពិលា កើ

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណាសតិ បពិត្រព្រះថេរដ៏ចំរើន សតិចេតសិកនោះមាន
លក្ខណាប៉ុន្មានយ៉ាង ។

ន - ព្រះថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯ
សតិចេតសិកនោះមានលក្ខណា២យ៉ាង គឺកិរិយាដាស់តឿនចិត្ត
ជាលក្ខណា ១ ( អបិលាបនលក្ខណា ) កិរិយាដឹកនាំចិត្ត ឬផ្គង
ចិត្តជាលក្ខណា ១ ( ឧបគ្គណ្ហលក្ខណា ) សូមទ្រង់ជ្រាប ។

ម - ចុះអបិលាបនលក្ខណាសតិនោះ មានសេចក្តីអធិ-
ប្បាយដូចម្តេចលោកម្ចាស់ ។

ន - បពិត្រមហារាជ ឯអបិលាបនលក្ខណានោះកាលបើ
កើតឡើងក្នុងសន្តានបុគ្គលក្នុងវេលាណា តែងនិងតឿនចិត្ត
អោយរឭកនូវធម៌ទាំងឡាយថា ធម៌ចំណែកនោះជាកុសល
ធម៌ចំណែកនោះជាអកុសល ចំណែកនោះប្រកបដោយទោស
ធម៌ចំណែកនោះ ប្រកបដោយគុណ ចំណែកនោះជារបស់ថោក
ទាប ចំណែកនោះជារបស់ឧត្តម ចំណែកនោះជាវត្ថុមានពណ៌
ស ចំណែកនោះជាវត្ថុមានពណ៌ខ្មៅ ធម៌ទាំងឡាយ ៤ មាន
កាយានុបស្សនាជាដើម ហៅថាសតិបដ្ឋាន ធម៌ទាំងឡាយ ៤
មានអនុប្បន្នានំ អកុសលានំ ជាដើម ហៅថាសម្មប្បធានធម៌

៤ ទៀត មានឥទ្ធិបាទជាដើម ហៅថាឥទ្ធិបាទ ធម៌ ៥ ពួកមានសទ្ធិន្ទ្រិយជាដើម ហៅថាឥន្ទ្រិយ ៥ ធម៌ ៥ ពួកមានពលជាដើម ហៅថាពល ៥ ធម៌ ៧ មានសតិសម្ពោជ្ឈង្គជាដើម ហៅថាពោជ្ឈង្គ ធម៌៨ មានសម្មាទិដ្ឋិជាដើម ហៅថាអរិយមគ្គ ធម៌ ៧ ពួក មានកសិណ ១០ ជាដើម ហៅថាសមថកម្មដ្ឋាន ធម៌ ៤ ពួកមានវិសុទ្ធិ ៧ជាដើម ហៅថាវិបស្សនាកម្មដ្ឋាន ធម៌ដែលជាគុណនាំរាប់អោយចេះដឹង ហៅថាវិជ្ជាធម៌ ដែលជាគុណនាំ-រាប់អោយរួចចាកភពាទិកិលេស ហៅថាវិមុត្តិ កាលបើព្រះយោគាវចរបានអបិលាបនលក្ខណសតិ រក្សាវត្ថុ និងចិត្ត ហើយក៏តែងដាស់តឿនចិត្តអោយរឭកនូវធម៌ ដូច្នេះហើយ នឹងរាប់អាននូវធម៌ដែលអ្នកប្រាជ្ញ គាត់រៀបរាប់អាន មិនរាប់អាននូវធម៌ ដែលអ្នកប្រាជ្ញ មិនគាត់រៀបរាប់អានស្មើគ្នានោះនូវធម៌ដែលអ្នកប្រាជ្ញគាប្បីសើពសាល មិនស្មើពសាលនូវធម៌ដែលអ្នកប្រាជ្ញមិនគាប្បីសើពសាល បពិត្រសម្ដេចមហារាជ ឯអបិលាបនលក្ខណសតិនោះ មានសេចក្ដីយ៉ាងនេះ សូមទ្រង់ជ្រាប ។

ម - ឧបមំករោហិ សូមលោកធ្វើឧបមា ក ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - យថាមហារាជ បពិត្រមហារាជសេចក្តីនេះប្រៀបដូចភណ្ឌាគារិកបុរស គឺនាយឃ្លាំងក៏ធម្មតា នាយឃ្លាំងតែងយកសេចក្តីក្រាបបង្គំទូលរំលឹកមហាក្សត្រ អោយស្តេចជ្រាបថា បពិត្រព្រះសម្មតិទេវ ឯរបស់ព្រះរាជទ្រព្យនោះ គឺដំរីមានប៉ុណ្ណោះ សេះប៉ុណ្ណោះ រាជរថប៉ុណ្ណោះ ពលថ្មើរជើងប៉ុណ្ណោះ ប្រាក់ប៉ុណ្ណោះ មាសប៉ុណ្ណោះជាដើម សូមព្រះអង្គជ្រាបសេចក្តីនេះ ឧបមាដូចម្តេចមិញថា ឧបមេយ្យដូចអបិលាបនលក្ខណាសតិដែលកើតឡើងជាមួយនឹងចិត្តតែងនាំញាំងចិត្តអោយរំលឹកនូវធម៌ជាកុសល ឬអកុសលជាគុណឬទោសជាឧត្តម ឬថោកទាបម្យ៉ាងទៀតអោយរំលឹកថាធម៌ទាំងឡាយនេះគឺសតិបដ្ឋាននេះ គឺសម្មប្បធានជាដើម បពិត្រមហារាជ ឯអបិលាបនលក្ខណាសតិនោះ ប្រៀបដូចនាយឃ្លាំងនោះឯង សូមជ្រាប ។

ម - កល្លោសិ ឱលោកម្ចាស់ឈ្លាសពេកណាស់ពើ ត្រូវហើយព្រះករុណាចុះឧបគ្គណ្ហលក្ខណាសតិនោះ តើមានអធិប្បាយដូចម្តេចទៀត ។

ដ - បពិត្រមហារាជ ឧបគ្គណ្ហលក្ខណាសតិនោះ កាលបើកើតឡើងក្នុងសន្តានតែងនឹងដឹកនាំចិត្ត អោយ[illegible]នូវ

www.budinst.gov.kh www.elibraryofcambodia.org

គតិនៃធម៌ដ៏ល្អ សេចក្តីថា ព្រះយោគាវចរ កាលបើឧបេក្ខញ្ញ លក្ខណាសព៌កើតឡើងក្នុងសន្តានចិត្តហើយ តែងនឹងធ្វើចិត្ត អោយពិចារណាដឹងថា ធម៌យ៉ាងនេះមានប្រយោជន៍ធម៌យ៉ាង នេះមិនមានប្រយោជន៍ ធម៌យ៉ាងនេះ ជាឧបការធម៌យ៉ាងនេះ មិនជាឧបការឡើយ កាលបើព្រះយោគាវចរដឹងយ៉ាងនេះ ហើយក៏អាចនឹងបណ្តេញចេញនូវធម៌ មិនមានប្រយោជន៍ ហើយនឹងទាញយកនូវធម៌ដែលប្រយោជន៍កុំចោលបង់ នូវធម៌ មិនមានឧបការ ហើយនឹងទំនុកបំរុងនូវធម៌ដែលមានឧប ការ បពិត្រមហារាជ ឧបត្ថញ្ញហេត្តពេលាគរពិនោះរេះបង់នូវវត្ថុ ដែលសរាក្រក់ កាន់យកនូវវត្ថុដ៏ល្អ ដូចសេចក្តីដែលអាត្មាលើក មកនេះ សូមមហារាជទ្រង់ជ្រាប ។

ប – ឧបរិកោបា បើដូច្នោះសូមលោកម្ចាស់ប្រៀប ជាសេចក្តីផ្ទៀតបកនឹងស្តាប់ហើយ ។

ថ – បពិត្រមហារាជ សេចក្តីនេះប្រៀបដូចនាយទ្វារនៃ បរមក្សត្រ ធម្មតានាយទ្វារតែងស្គាល់នូវជនទាំងឡាយ ដែល ជាអ្នកមានគុណមានប្រយោជន៍ដល់ព្រះក្សត្រ ឬជាជនដែល មិនមានឧបការដល់ស្តេច កាលបើពួកជនណាមកដែលស្គាល់ បានប្រាថ្នានឹងចូលទៅកាន់ទ្វារព្រះរាជវាំងនោះ ក៏ហាមឃាត់

មិនអោយចូលទៅឡើយ បើឃើញអ្នកឯណាដែលមានឧប-
ការដល់មហាក្សត្រ ពីជារាជវង្សានុវង្ស ឬមន្ត្រីទាំងពួង ទើប
បើកបណ្តោយអោយចូលទៅកាន់រាជស្ថានបាន ជនដែល
មិនមានប្រយោជន៍ ឬជាសត្រូវដល់មហាក្សត្រមិនអោយចូល
ទៅឡើយ នាយទ្វារដែលកំចាត់បង់នូវមនុស្ស មិនមានប្រ-
យោជន៍ ហើយបើកអោយអ្នកដែលមានប្រយោជន៍ចូលទៅ
គាល់ក្សត្រ នេះឧបមាយ៉ាងណា បពិត្រមហារាជឧបត្ថម្ភលក្ខ
ណាសតិ នោះកាលបើកើតឡើងក្នុងសន្តានហើយ តែងញ៉ាំង
ចិត្តអោយកាន់យកនូវធម៌ដែលមានប្រយោជន៍ មានគុណវៀរ
បង់នូវធម៌ដែលឥតប្រយោជន៍ មិនមានគុណដូចនាយទ្វារ
ដែលហាមឃាត់មនុស្សទុច្ចរិតមិនអោយចូលគាល់ហើយបើក
បណ្តោយអោយមនុស្សសុចរិត ចូលគាល់មហាក្សត្រនោះ
ឯង ឯព្រះយោគាវចរ បើបានឧបត្ថម្ភលក្ខណាសតិកើត
ឡើងហើយតែងនឹងលះបង់នូវធម៌ដែលជាទោស ហើយកាន់
យកធម៌ដែលជាគុណនោះ មានឧបមេយ្យដូចនោះឯង ដូច
ពុទ្ធភាសិតទ្រង់ត្រាស់ទេសនាទុកមកថាដូចនេះ ។

សតិញ្ចខោភិក្ខវេសព្វត្ថិកំវទាមិ

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតតែងសរសើរនូវ

www.budinst.gov.kh www.elibraryofcambodia.org

ល្អារពីនេះថា ជាគុណនាំសម្បត្តិទាំងពួងដែលរាបសំរេចនូវ ប្រយោជន៍គ្រប់ប្រការ នាំបំបាត់នូវទោសគ្រប់យ៉ាងបាន វគ្គសរបស់ពុទ្ធភាសិតយ៉ាងនេះ សូមថ្វាយព្រះពរបរមរាជ ត្រាស់ជ្រាប ។

ម - ត្រូវណាស់ហើយលោកម្ចាស់ សេចក្តីវិសជ្ជនា នេះសមគួរហើយ ។

សមាធិលក្ខណប្បញ្ហា ទី ១៣

បពិត្រ ស្តេចទ្រង់សួរព្រះនាគសេនទៀតថា ពីលក្ខណៈសមាធិបពិត្រព្រះនាគសេនដ៏ចំរើន សមាធិ កិរិយាតាំងចិត្តមាំ លក្ខណដូចម្តេច ។

ន - ព្រះថេរៈទូលថា បពិត្រមហារាជ សមាធិនេះមាន លក្ខណៈជាប្រធានៈនៃកុសលធម៌ទាំងពួង ព្រោះថាពួកកុសលធម៌ ទាំងឡាយ មានសមាធិនេះជាមុខបង្អស់ ( សមាធិប្បមុខា ) មានសមាធិជាកំពូល ( សមាធិនិន្នា ) មានសមាធិជាទីឱនទៅ ( សមាធិបោណា ) មានសមាធិជា ជម្រាល (សមាធិបព្ភារា) បពិត្រមហារាជ កុសលធម៌ទាំងពួងនេះ មានសមាធិធម៌នេះ ឯងជាប្រធានយ៉ាងនេះបើបថាសមាធិនេះ មានលក្ខណៈជាប្រធាន សូមទ្រង់ជ្រាប ។

ម - ឧបមាកំណោបា ពិរោះណាស់ហើយលោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

151 ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

សូមលោកម្ចាស់ធ្វើនូវសេចក្ដីឧបមាបន្តិចមកមើល ។

ន - យថាមហារាជ បពិត្រមហារាជសេចក្ដីនេះប្រៀប ដូចគ្រឿងទព្វសម្ភារនៃផ្ទះកំពូលទាំងពួង មានផ្ដោង និងបង្គង់ ជាដើម ក៏គ្រឿងទាំងនេះមានកំពូល ឬ មេដំបូលជាប្រធាន មានកំពូលជាទីជ្រៀលចុះ មានកំពូលជាទីឱនចុះ មានកំពូល ជាទីចោមរោម មានកំពូលជាទីញោចទៅ បពិត្រមហារាជ សេចក្ដីនេះ មានឧបមាដូចម្ដេចមិញថា មានឧបមេយ្យដូច កុសលធម៌ទាំងពួង តែងមានសមាធិជាប្រធាន ជាមុខមាន សមាធិជាកំពូល មានសមាធិជាទីឱនទៅ មានសមាធិជាទី ញោចទៅ ជាទីចោមរោមនៃកុសលធម៌នោះឯង សូមមហា រាជត្រេចទ្រង់ជ្រាប ។

ប - រ៉ែលោកម្ចាស់ ៗ ឆ្លើយមកនេះ គួរសមហើយតែ សូមអោយព្រះករុណាម្ចាស់ឧបមាន័យ ១ ទៀតមកមើល ខ្ញុំ ចង់ស្ដាប់តទៅទៀត ។

ន - បពិត្រព្រះមហារាជ សេចក្ដីនេះប្រៀបដូចជាបរម ក្សត្រអង្គណា ១ ទ្រង់ចូលទៅកាន់ទីសង្គ្រាមធំ ១អន្លើដោយ សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើង ក៏ចំណែកខាងពួកពលទាំងនោះ តែងមានព្រះ

www.budinst.gov.kh www.elibraryofcambodia.org

បពេក្យព្រះនោះជាធំជាងខ្លួនការពេក្យព្រះនោះជាកំពូលបេហាង
បពេក្យព្រះនោះឯងជាទីផ្ចិតនៅនៃប្រ្ញះ ការពេក្យព្រះនោះ
ជាប្រធាននៃខ្លួន បពិត្រមហារាជ សេចក្តីនេះមានឧបមា
យ៉ាងណាថា មានឧបមេយ្យដូចកុសលធម៌ទាំងឡាយនោះ
រំពឹងបានសមាធិនោះជាទីតាំង ដូចបានពុទ្ធភាសិតទ្រង់ត្រាស់
ទុកមកថា ។ សមាធឹភិក្ខវេភាវេថ សមាហិតោភិក្ខុ យថា ភូតំ
បជានាតិ ។

សេចក្តីថាម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលចំរើន
យាមចំរើននូវសមាធិនេះរឿយៗ ព្រោះភិក្ខុឯណា ១
ដែលបានសមាធិចិត្តកើតឡើងក្នុងសន្ដានហើយ ភិក្ខុនោះរមែង
រមែងត្រាស់ដឹងនូវហេតុ និងផល និងត្រៃបរិញ្ញាសច្ចាបត្តិ ដោយ
ពិតមិនខានឡើយ បពិត្រមហារាជ សេចក្តីដែលអាត្មាភា
សជ្ឈាយមកនេះ សូមទ្រង់ជ្រាប ។

ប.- កណ្តាលសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោក
ម្ចាស់ឆ្លាស់ពេកណាស់ពេះប្រៀបផ្ទឹមត្រូវស្រួល ។

បញ្ញាលក្ខណប្រស្នា វគ្គ ១ ទី ១៨

ហេតុព្រះ ស្ដេចទ្រង់សួរព្រះនាគសេនតទៅទៀតថា
កីលក្ខណាបញ្ញា បពិត្រមហាថេរដ៏ចំរើន បញ្ញាចេតសិកនោះ

www.budinst.gov.kh www.elibraryofcambodia.org

តើមានលក្ខណាដូចម្តេច ។

ន - បពិត្រសម្តេចមហារាជ ឯបញ្ញាចេតនានោះមានកិរិយាកាត់ផ្តាច់សរប្រេចសេចក្តីជាលក្ខណា ( ឆេទនលក្ខណា ) ឬថា សេចក្តីភ្លឺផ្លុះជាលក្ខណា ( **ឱភាសនលក្ខណា** ) តែថាត្រង់ឆេទនលក្ខណានោះ អាត្មាភាពបានវិសជ្ជនាថ្វាយរួចហើយពីគ្រាមុន សូមមហារាជស្តេចជ្រាប ។

ម -កថំភន្តេ ឱភាសនលក្ខណា បពិត្រព្រះករុណាម្ចាស់ដ៏ចំរើនខ្ញុំសូមសួរលោកម្ចាស់តែត្រង់ឱភាសនលក្ខណា ដែលលោកម្ចាស់សំដែងថា បញ្ញានោះមានកិរិយាភ្លឺផ្លុះជាលក្ខណា ១ នេះ តើមានសេចក្តីអធិប្បាយដូចម្តេច ។

ន - អវិជ្ជន្ធការវិធមេតិ វិជ្ជោភាសំជនេតិ បពិត្រសម្តេចមហារាជ ឯបញ្ញាចេតសិកនេះ កាលបើកើតឡើងក្នុងសន្តានចិត្តវេលាណាតែងកំចាត់បង់នូវសេចក្តីងងឹតងងល់ ឬ កិរិយាភាន់ច្រឡំ គឺសេចក្តីល្ងង់ គឺអវិជ្ជានោះឯង អោយវិនាសបាត់ទៅ ហើយអាចញ៉ាំងរស្មីពន្លឺដែលភ្លឺផ្លុះនឹងពន្លឺ គឺញាណ អោយកើតមានឡើងក្នុងសន្តាន ហើយអាចធ្វើនូវអរិយសច្ច អោយច្បាស់ប្រាកដបាន កាលបើឱភាសនលក្ខណាបញ្ញាកើតឡើងប្រកបព្រមនឹងចិត្តក្នុងវេលាណាហើយ ក៏ជាគុណនឹង

www.budinst.gov.kh www.elibraryofcambodia.org

អោយឃើញច្បាស់នូវត្រៃលក្ខណញាណកថាវរនិច្ចនិវាររនត្តា ពិភា សេចក្តីថាខន្ធទាំង ៥ ប្រការ មាននូវរូបជាដើមនេះ តែងប្រ-ព្រឹត្តទៅក្នុងអំណាចនៃសេចក្តីមិនទៀងផង សេចក្តីទុក្ខផង និងសេចក្តីវិនាសទៅផង ពាក្យដែលអាត្មាភាពថ្វាយព្រះពរមកនេះសូមមហារាជទ្រង់ជ្រាប ។

ម - ឧបមាំកោលិ សូមលោកម្ចាស់ប្រៀបជាសេចក្តីបំភ្លឺបន្តិចមកមើល ។

ន - យថាមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះប្រៀបដូចជាបុគ្គលកាន់ភ្លើងចង្កៀង ឬគោមដែលមានពន្លឺចូលទៅក្នុងផ្ទះក្នុងវេលាយប់ងងឹត ប្រទីបនោះអាចនឹងកំ-ចាត់បង់នូវសេចក្តីងងឹតនោះចេញបាន ហើយនឹងញ៉ាំងរស្មីពន្លឺអោយភ្លឺច្បាស់ស្រឡះឡើង អាចធ្វើអោយនូវរូបទាំងឡាយអោយប្រាកដដល់ភ្នែក បពិត្រមហារាជបញ្ញាចេតសិកនោះកាលបើកើតឡើងហើយ អាចនឹងកំចាត់បង់នូវសេចក្តីងងឹតល្ងង់ភាន់ច្រឡំ គឺអវិជ្ជានោះអោយបាត់បង់ទៅបានហើយអាចញ៉ាំងរស្មីភ្លឺផ្លុះ គឺវិជ្ជាអោយកើតឡើង និងធ្វើនូវអរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើមអោយប្រាកដឡើងបំ-ផាយនោះ កាលបើព្រះយោគាវចរៈនេះបញ្ញា ចេតសិកកើត

www.budinst.gov.kh www.elibraryofcambodia.org

ទៀងពោលមិនស្មុគស្មាញដោយគ្រាប់ដឹងពិត្ត ហើយអាចយល់ច្បាស់នូវព្រះត្រ័យបេក្ខភាពញាណពោលបញ្ញាដ៏ប្រពៃ ថារូបធម៌និងនាមធម៌ទាំង ២ នេះលុះក្នុងអំណាចសេចក្តីមិនទៀងផង

ក្នុងអំណាចសេចក្តីទុក្ខព្រួយផង ក្នុងសេចក្តីព្រាត់ព្រាកគ្នាផង បពិត្រមហារាជ ឯឱភាសនលក្ខណបញ្ហានោះ ប្រៀបដូចពន្លឺពោធនោះឯង សូមទ្រង់ជ្រាប ។

ម - កល្លោសិកាន្តេនាគសេន បពិត្រព្រះនាគសេនថេរដ៏ចំរើនលោកក្តោសនេះ ពេញបៅថាជាអ្នកប្រាជ្ញល្អោសលោក់ហើយលោកឆ្លើយមកពិរោះពេក ខ្ញុំពេញចិត្តហើយអស់សង្ស័យប៉ុណ្ណោះ ។

មាឯលកកិច្ចករណេបញ្ហា ១ ថ្ងៃ ១៥

ម - នានាសន្តា ឯកំអត្ថំ បពិត្រព្រះថេរដ៏ចំរើន កុសលធម៌ទាំងឡាយមានសន្តានផ្សេង ១ គ្នា តែអាចធ្វើអោយសម្រេចនូវប្រយោជន៍តែម្យ៉ាងនោះ តើដូចម្តេច ។

ន-កិលេសេហនន្តិ បពិត្រមហារាជកុសលធម៌ទាំងឡាយមានសន្តានផ្សេង ១ គ្នា តែអាចអោយសម្រេចនូវប្រយោជន៍

www.budinst.gov.kh www.elibraryofcambodia.org

តែម្យ៉ាងនោះ ពីព្រោះសម្លាប់បង់នូវកិលេសធម៌ទាំងនោះឯង ឈ្មោះប្រសើរជ្រាប ។

ឃ - ឧបមាពោហើ សូមព្រះថេររៀបសេចក្ដីនេះបន្តិចមើល ។

ង - មាតា បិតា ក្សត្រា ពីរព្រះរាជា សេចក្ដីនេះ ទ្រង់ប្រៀបធៀបនឹងប្រការដោយអង្គ ៤ គឺតណ្ហាផ្សេង ១ ពួក គឺតណ្ហាដែលជាដើមតែកើតកិច្ចតែម្យ៉ាង ត្រូវធ្វើការព្រោះ នូវតណ្ហានោះឯង ពីរព្រះរាជាសេចក្ដីនេះ ការណែនាំ ម៉្យាងទៀត បានប្រការប្រៀបធៀបនឹងសង្សារ ការណ៍ផ្សេង ១ ពួក តែធ្វើការប្រៀបនូវព្រះរាជាពីរតែ ១ ត្រូវ សម្លាប់នូវកិលេសធម៌ទាំងនោះស្ងប់បរាជ័យតែប្រសើរ ។

## ទុតិយវគ្គ ពាក្យប្រស្នា ៩

ធម្មបទដ្ឋកថា ១ ទំ ១

ព្រះបាទមិលិន្ទ្រាធិបតី កាលបើទ្រង់សួរបញ្ហាក្នុងវគ្គទី១ ចប់ហើយ ទើបទ្រង់ប្រារព្ធសួរព្រះនាគសេនថេរ ក្នុងទុតិយវគ្គតទៅទៀតថា បោះបង្គ្រប់តែព្រោះ ពិព្រះព្រះថេរដ៏ចំរើន អ្វីការតែសេចក្ដីតណ្ហាកើតឡើងជាមួយវិញ្ញាណ ដែលកើតក្នុងលោកនេះ ពួកយ៉ាងបុរសត្រូវសេចក្ដីក្តៅ បានដើម ២

ជើង ៤ ក្តី មានជើងច្រើនក្តី ឬឥតជើងក្តី គ្រាកាលដែលកើតមកជាយ៉ាងណា ក៏នៅជាយ៉ាងនោះ ឬប្រែក្លាយទៅផ្សេង ៗ បើបុរសក្លាយទៅជាបុរសដទៃ បើជាស្ត្រីក្លាយទៅជាស្ត្រីដទៃ បើជាសត្វមានជើងពីរក៏ជាសត្វមានជើងពីរដទៃ បើជាសត្វមានជើង ៤ ក៏ក្លាយទៅជាសត្វមានជើង ៤ ដទៃទៅ បើសត្វមានជើងច្រើន ក៏ក្លាយទៅជាសត្វមានជើងច្រើនដទៃទៅ បើជាសត្វឥតជើង ក៏ក្លាយទៅជាសត្វឥតជើងដទៃទៅ យ៉ាងនេះឬ ដូចម្តេចលោកម្ចាស់ ។

នាគសេនត្ថេរតបថា បពិត្រសម្តេចមហារាជ ជនដែលកើតឡើងក្នុងលោកនេះ នោះនឹងថាជាមនុស្សសត្វដដែល ក៏មិនមែន ឬនឹងថាក្លាយទៅជាមនុស្សសត្វដទៃទៀតក៏មិនមែន ព្រោះថាកាលដែលកើតឡើងជាក្មេងតូច ៗ នោះ មិនទៀងតែនៅជាក្មេងតូចទេ បន្តិចក៏ធំឡើងចាស់ទៅ ហេតុនោះបានជាថាមិនមែនសត្វដដែល តែនឹងថាជាសត្វដទៃ ក៏ថាមិនបាន ព្រោះថា កាលដែលកើតឡើងនោះ ជាបុរសក៏ច្រើននៅតែជាបុរស បើជាស្ត្រីក៏ច្រើននៅតែជាស្ត្រីដដែល មិនអាចប្រែប្រួលទៅជាសត្វដទៃឡើយ ពំពួកសត្វតិរច្ឆានទៀតក៏ដូចគ្នាដែរ មិនប្លែកគ្នា សេចក្តីដូចនេះ សូមថ្វាយព្រះពរ ។

www.budinst.gov.kh www.elibraryofcambodia.org

ថ ‑ បើដូច្នោះ សូមលោកប្រាប់ធ្វើនូវសេចក្ដីឧបមា
បន្តិចមកមើល ។

ន ‑ ពិតមែន បពិត្រមហារាជ ព្រះអង្គទ្រង់យល់ដូច
ម្ដេចទៅវិញ សេចក្ដីនេះថាមនុស្សម្នាក់ដុតប្រទីបក្នុងការ
ដែលបើកនឹងប្រទ្យូតពេញមួយរាត្រី ព្រះអង្គព្រះវររាជការណា
ពីព្រោះគេតែងបីបាច់ព្រះរាជឱរសតូច ឬក្មេងខ្ចី ឆាងពិសៀវដែល
អញ្ជើញព្រះអង្គដេកផ្ងារទ្រង់ផ្កាលើព្រះអង្គ ក្នុងកាល
នោះ ពេលព្រះអង្គក៏ចំរើនធំឡើងបានដល់ពេលនេះ តើត្រូវនេះ
ឬព្រះអង្គនេះ ឬដែលជាព្រះរាជឱរសតូច ដែលទ្រង់ផ្កាលើ
អង្គឯនោះ ឬជាអ្នកដទៃ ។

រ ‑ នបរិភត្តេ មិនដូច្នោះទេលោកម្ចាស់ ខ្ញុំកាលដែល
ជាឱរសតូចនោះយ៉ាង ព្រោះចំរើនធំឡើង ក៏យ៉ាងនឹងបាន
ព្រោះពេលផ្សា ឱរសតូចនោះ គឺខ្ញុំឯងនេះក៏ទេ ព្រះករុណាកាល
នៅតូចនោះផ្សេង ដល់ពេលចំរើនផ្សេង កាលនៅក្មេងតូច
នោះមានរូបនឹងឈ្មោះ ប៉ុន្តែគ្រាដល់ចំរើនធំឡើងមាននាម
នឹងរូបប៉ុន្តែមិនដូចគ្នាឡើយ សេចក្ដីយ៉ាងនេះ សូមលោក
ប្រាប់ប្រាប ។

[illegible]

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជឱង្ការមកយ៉ាងនេះហើយនោះ ទោះមាតាក្តី បិតាក្តី អាចារ្យក្តី ក៏នឹងមិនមែនបុគ្គលដែលមានសីលក្តី មានសិល្ប សាស្រ្តក្តី មានបញ្ញាក្តី ក៏នឹងមិនមែនទាំងអស់ ព្រោះព្រះរាជ ឱង្ការត្រាស់ថា កាលពីក្មេងតូចនោះផ្សេង ដល់ចំរើនធំឡើង ផ្សេង បពិត្រមហារាជ សេចក្តីនឹងត្រូវរោយរស់ហ៊ីយពេក បើ ប្រាកដជាយ៉ាងនឹងហើយ កាលបឋមវិញ្ញាណរាចកកាន់យក ផិសន្ធិជាដំបូងអាស្រ័យនូវកលលរូបក្នុងផ្ទៃនៃមាតានោះ ក៏ អានមាតាដ៏ទៃទៅលុះគ្រប់ ៧ ថ្ងៃ ហើយកលលរូបនោះ ប្រែ ទៅជាអព្វុទៈ ក៏បានមាតាដ៏ទៃទៀត លុះគ្រប់ ៧ ថ្ងៃ ហើយអ- ព្វុទរូបនោះប្រែទៅជា បេសិ គ្រប់ ៧ថ្ងៃ ហើយ បេសិនោះ ប្រែទៅជាឃនៈ ក៏បានមាតាផ្សេងទៀត លុះដល់ប្រសូតិចេញ មកកាលពីទារកតូចនៅឡើយនោះ ក៏មានមាតាផ្សេង លុះ ចំរើនធំឡើង ក៏បានមាតាផ្សេងទៀត ព្រោះចេះតែក្លាយ ទៅ ២ បពិត្រសម្តេចមហារាជ បើថាយ៉ាងនឹងហើយអ្នកដែល រៀនត្រូវសិល្បសាស្រ្តនោះផ្សេងទៅ អ្នកដែលចេះចាំប្រ ព្រឹត្តទុកនូវសិល្បសាស្រ្តនោះផ្សេងទៅ អ្នកដែលធ្វើអំពើ អាក្រក់នោះដ៏ទៃទៅ អ្នកដែលទទួលអំពើបាបត្រូវគេកាត់ដៃ កាត់ជើងនោះដ៏ទៃទៅ ព្រោះអ្នករៀននោះដ៏ទៃដល់ចេះ២ទៅ អ្នកដ៏ទៃវិញ អ្នកដែលធ្វើអាក្រក់នោះដ៏ទៃ ដល់បានបាបបាន

www.budinst.gov.kh www.elibraryofcambodia.org

ទៅអ្នកដទៃវិញនេះ បើតាមសេចក្ដីដែលទ្រង់បានព្រះរាជឱង្ការមកនោះយ៉ាងនឹង ពិតពុំគួរនឹងមហារាជទ្រង់ព្រះដំរិះច្រឡំយ៉ាងនេះសោះ សេចក្ដីនេះសូមមហាបពិត្រទ្រង់ព្រះដំរិះក្នុងទៀត ។

៥ - ទេវិកាទេ្ព មិនដូចគ្នានេះទេលោកម្ចាស់ ក្រូចក៏នៅជាលោកពោលត្រូវប្រាកដម្រឹមវិកយ៉ាងនឹងនេះវិញ បើដូចនេះសូមលោកម្ចាស់ប្រៀបធៀបទៅវិញឲ្យអាត្មាភាពឲ្យច្បាស់លាស់ទៅបើទេ ។

៦ - អាចារ្យ មហារាជ បពិត្រមហាបពិត្រមហារាជសេចក្ដីនេះ ប្រៀបដូចខ្លួនអាត្មាភាពនេះ កាលដែលនៅក្មេងតូចនោះក៏ជាអាត្មានេះឯង វេលាដល់ពេញវ័យធំឡើងហើយដល់ឥឡូវនេះក៏នៅជាអាត្មាភាពដដែល មិនមែនប្រែក្លាយទៅជាអ្នកដទៃឡើយ ព្រោះសង្ខារធម៌ទាំងឡាយទាំងអស់នេះ តែងតែអាស្រ័យរូបកាយរូបនេះ បើបុគ្គលព្រិត្តទៅទោះបីលោកពិរៀនះចូលជាអ្នកប្រាជ្ញ តែយ៉ាង មិនបានក្លាយទៅជាអ្នកដទៃឡើយ ទោះបើតាមមហាបពិត្រដែលទ្រង់ត្រាស់កាលដែលនៅក្មេងតូចនោះជាអ្នកនេះ ព្រោះដល់ពេញវ័យធំឡើងក្លាយទៅជាអ្នកនោះវិញ នោះមិនសមគួរឡើយសូមទ្រង់ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ច ‐ សេចក្តីនឹង ខ្ញុំព្រះករុណាសង្ស័យពេកណាស់ បើដូច្នេះ សូមលោកម្ចាស់ ឧបមានុមេយ្យ ជាការប្រៀបធៀបបន្តិចមកទៀតមើល ។

ន ‐ បទីបំ ទីបេយ្យ បពិត្រសម្តេចមហារាជសេចក្តីនេះប្រៀបដូចប្រទីបតែមួយ ដែលបុគ្គលបានវាល់ប្រេងដាក់ល្មមរុចបាន ១ យប់ ហើយដុតលល់ទុកតាំងពីពេលព្រលប់ រហូតដល់កណ្តាលរាត្រីព្រដល់ភ្លឺឡើង បពិត្រមហារាជចុះក្បាលពីពេលព្រលប់បឋមយាមនោះ ជាប្រទីបចង្កៀង ១ ដល់ពេលកណ្តាលរាត្រីមជ្ឈិមយាម ប្រែទៅជាចង្កៀង ១ ដ៏ទៃទៀត ឬដល់ទៅពេលព្រឹកបច្ឆិមយាម ជាចង្កៀងដ៏ទៃពីរចង្កៀងដែលដុតលល់ទុកពីពេលព្រលប់នោះទេ ឬ ដូចម្តេច ។

ប ‐ មិនមែនប្រទីបដ៏ទៃទេលោកម្ចាស់ គឺប្រទីបដែលដុតលល់ទុកក្នុងបឋមយាមនោះឯង ក៏តាំងប្រព្រឹត្តទៅរហូតដល់មជ្ឈិមយាម បច្ឆិមយាមនឹងបានប្រែក្លាយទៅជាប្រទីបដ៏ទៃ ក៏ទេ គឺប្រទីបតែ ១ នោះឯងអាចឆេះទៅអស់រាត្រី ១ ទាំងមូលនោះសូមលោកម្ចាស់ជ្រាប ។

ន ‐ កិន្នុខោមហារាជ្យ បពិត្រមហារាជ្យ ចុះអណ្តាតប្រ

www.budinst.gov.kh www.elibraryofcambodia.org

ទីបដែលឆេះពីពេលព្រលប់នោះ ឬអ្វីដែលមកជាអណ្តាតប្រ-ទីបក្នុងពេលកណ្តាលរាត្រនោះមហាបពិត្រ ។

ម - នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូចោ្នះទេ អណ្តាតដែលឆេះពីព្រលប់នោះវាតែងប្រព្រឹត្តកន្លងៗ ទៅ សូមលោកម្ចាស់ជ្រាប ។

ន - បញ្ឆិមេយាមេអគ្គិ ចុះអណ្តាតប្រទីប ក្នុងពេលកណ្តាលរាត្រនោះ ឬអ្វី ដែលមកជាអណ្តាតប្រទីបក្នុងពេលព្រឹកនោះមហាបពិត្រ ។

ម - នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូចនោះទេ ឯអណ្តាតប្រទីបពីពេលព្រលប់ក្តី នឹងពេលកណ្តាលរាត្រព្រក្តី ក៏មិនបានតាំងនៅប្រក្រតីទេ ។

ន - កិន្នុខោមហារាជ បពិត្រមហារាជ បើដូចនោះ ប្រ-ទីបកាលពីបឋមយាមនោះ ក៏ជាប្រទីបដ៏ទៃទៅឬដល់មជ្ឈិមយាមក៏ជាប្រទីបដ៏ទៃទៀត ដល់ទៅបច្ឆិមយាមក៏ជាប្រទីបដ៏ទៃដែរ នេះបើតាមព្រះរាជឱង្ការរបស់មហាបពិត្រឬដូចម្តេចវេរះ ។

ម - នហិភន្តេតំយេវ បពិតលោកម្ចាស់ដ៏ចំរើន មិន

www.budinst.gov.kh www.elibraryofcambodia.org

ថែនដូចនោះទេ អណ្តាតភ្លើងដែលរុងរឿង នៅអស់រាត្រី ១ ទាំងមូលនោះ ក៏ព្រោះតែអាស្រ័យនូវរូបចង្កៀង ១ នោះឯង សូមលោកម្ចាស់ជ្រាប ។

ន - ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ ក៏ប្រទីប ១ ដែលគេដុតកល់ទុកមានអណ្តាតភ្លើងរុងរឿង នៅអស់រាត្រី ១ មិនបានក្លាយទៅជាប្រទីបដទៃទេនោះ មានសេចក្តីប្រៀបយ៉ាងណា ក៏ធម្មសន្តតិគឺគ្រឿងតនៃរូបធម៌និងនាមធម៌របស់សត្វដែលកើតមកនេះ សឹងមានដំណរនៃរូបធម៌ និងអរូបធម៌តែងតន្តាតែ ១ ដូចគ្នាកាលដើម ដែលមិនទាន់បដិសន្ធិនៅឡើយនោះ កាលនឹងកើតនឹងរលត់ក្តី ឬធម៌ដទៃ នឹងកើតក្តីធម៌ដទៃនឹងរលត់ក្តី ក៏ប្រព្រឹត្តទៅបានតាមទំនើងរបស់ខ្លួន ពេលគ្រាដែលបដិសន្ធិចិត្តកើតឡើងហើយ រូបធម៌ នឹងនាមធម៌នេះក៏កើតឡើងព្រមគ្នា មិនមុនមិនក្រោយឡើយ សត្វទាំងពួង ដែលកើតមកដោយបដិសន្ធិចិត្តណា វេលាដែលចំរើនធំឡើងហើយ ដល់ជរាចាស់ទៅក្តី ក៏អាស្រ័យនូវចិត្តដែលបដិសន្ធិនោះឯង នឹងបានជាចិត្តដទៃរូបដទៃក៏ទេ គឺបច្ឆិមវិញ្ញាណនោះឯង ចិត្តដែលបដិសន្ធិកើតឡើងជាដំបូងនោះ នឹងបានជាសត្វដទៃ ចិត្តដទៃក៏ទេ គឺចិត្តតែ ១ នោះពិត កាល

www.budinst.gov.kh www.elibraryofcambodia.org

ដែលបដិសន្ធិកើតឡើងនោះ ប្រៀបដូចជាប្រទីបទី២ ដែលគេអុជដុតទុកតាំងពីបឋមយាម ឆេះទៅរហូតដល់បច្ឆិមយាមនោះ សូមថ្វាយព្រះពរ ។

ខ - ភិយ្យោភន្តេ សូមលោកម្ចាស់ប្រៀបឧបមាឡើងទៀតឲ្យជាភិយ្យោភាពទៅទៀត ព្រោះខ្ញុំព្រះករុណាដូចជានៅមានសង្ស័យមិនទាន់ចូលចិត្តនៅឡើយ ។

គ - យថាមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះប្រៀបដូចទឹកដោះគោ ដែលគេច្របាច់ហើយដាក់ទុកក្នុងភាជន៍ លុះកាលក្រោយនៅទៀត ទឹកដោះគោនោះក៏ប្រែជាទធិ។ នៅយូរទៀតទៅក៏ក្លាយទៅជា នវនីត។ នោះ ក៏ប្រែទៅជាឃេ ចំណែកមនុស្សទាំងឡាយ ដែលហៅវត្ថុទាំងនោះថា ដូចម្តេចគឺនឹងហៅថា ឃេ នោះ មិនមែន នវនីត។ នោះ មិនមែនជា ទធិ។ នោះមិនមែនជា ខីរ។ នោះ មិនមែនជា ឃេ ដូចនេះ ឬដូចម្តេច ។

ឃ - នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មនុស្សទាំងឡាយ គេមិនហៅថាដូចនោះទេព្រះករុណា គឺគេហៅទឹកដោះគោស្រស់ ខីរ ទឹកដោះជូរ ទធិ ទឹកដោះខាប់ នវនីត ទឹកដោះ

www.budinst.gov.kh www.elibraryofcambodia.org

ថ្លា យេដ ព្រោះលោណៈទាំងនោះ តែងអាស្រ័យនូវទឹកដោះតែ ប៉ុណ្ណោះ សូមលោកម្ចាស់ជ្រាប ។

ន - ឯវមេវខោមហារាជ បពិត្រមហារាជ ឯទឹកដោះ ដែលប្រព្រឹត្តក្លាយទៅជា ទធិ ជា នវ និត ជា ឃដ នោះយ៉ាង

ណា ធម្មសន្តតិ ដំណៅនៃរូបធម៌ នឹងនាមធម៌ពណ្ណាតាំងអំពីកើត ឡើងជារូបជាចិត្តហើយចំរើនធំឡើង ដរាបដល់ជរាចាស់ទៅ ដោយប្រការយ៉ាងណាក្តី តែនឹងបានហៅថា ចិត្តដែលកើត នោះជាចិត្តដ៏ទៃចិត្តដែលរលត់នោះ ជាចិត្តដ៏ទៃក៏ទេ គឺចិត្តតែ មួយដែលបដិសន្ធិកើតឡើងព្រមគ្នានោះឯង វេលាដល់រលត់ ក៏រលត់ព្រមគ្នា មិនមុនមិនក្រោយ ព្រោះហេតុនោះព្រះសម្មា សម្ពុទ្ធជាម្ចាស់នឹងបានត្រាស់ថា កាលកើតនោះជាចិត្តដ៏ទៃ កាលរលត់នោះជាចិត្តដ៏ទៃក៏ទេ ព្រះអង្គត្រាស់ថា គឺបច្ឆិម វិញ្ញាណនោះឯង មានឧបមេយ្យដូចជាទឹកដោះគោ ដែលប្រ ព្រឹត្តក្លាយទៅតាមពេលវេលានោះហោង សូមមហារាជស្តេច ជ្រាប ។

ម -កល្លោសិភន្តេ លោកម្ចាស់ឈ្លាសមែន ចេះសំដែង ជាឧបមានុបមេយ្យ គួរអោយចូលចិត្តណាស់អស់សង្ស័យ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទមិលិន្ទ្រាធិបតិ ទ្រង់ត្រាស់សួរទៅព្រះនាគសេនថេរថា បពិត្រលោកម្ចាស់ដ៏ចំរើន អ្នកឯណាដែលមិនបដិសន្ធិពីបិនកើតទៀតនោះ អ្នកនោះឯងអាចនឹងដឹងខ្លួនថា អាត្មានឹងមិនកើតទៀតដូច្នេះ ឬដូចម្តេច ។

ព្រះនាគសេនថេរថ្វាយព្រះពរថា យ៉ាងនឹងហើយព្រះអង្គ អ្នកណាដែលមិនកើតទៀតអ្នកនោះឯង តែងដឹងថាអញនឹងមិនកើតទៀតជាប្រាកដសូមទ្រង់ជ្រាប ។

ព - ពពិភទ្ទេលោកម្ចាស់ អ្នកនោះឯងដឹងដោយហេតុអ្វី ។

ន - យោហេតុ-យោបច្ចយោ បពិត្របរាភជ អ្នកដែលមិនទៅកើតក្នុងភពថ្មីទៀតនោះ គេដឹងថា ធម៌ឯណាជាហេតុធម៌ឯណាជាបច្ច័យនៃកិរិយាកាន់យកនូវបដិសន្ធិ ពីកើតទៀតនោះ ធម៌នោះឯងបាត់អស់ទៅហើយ ហេតុនេះបានជាដឹងថា អាត្មាមិនត្រូវកើតទៀតឡើយសូមថ្វាយព្រះពរ ។

ម - បើដូចនោះ សូមលោកម្ចាស់ប្រៀបឧបមាជាសេចក្តីបន្តិចមកនិងស្តាប់មើល។

www.budinst.gov.kh www.elibraryofcambodia.org

ន . យថាមហារាជ បពិត្រមហារាជ សេចក្តីនេះប្រៀប
ចគហបតី អ្នកស្រែដែលគេនឹងធ្វើស្រែនោះ គឺភ្ជួរស្រែប្រែ
នោះរួច គេព្រោះគេស្ទូង លុះដល់ស្រូវនោះមានផ្លែទុំវេលា
ហា គេក៏ច្រូតយកមកដាក់លានបញ្ជាន់ហើយកើបដាក់ជង្រុក
ទុកទៅ លុះចំណេរកាលមកខាងក្រោយ គហបតី អ្នកស្រែ
នោះមិនបានភ្ជួរមិនបានព្រោះទៀតឡើយ គ្រាន់តែបរិភោគ
ប្រើប្រាស់ចាយវាយតាមសមគួរដល់បច្ច័យនោះ បពិត្រមហា
រាជ ចុះអ្នកស្រែនោះនឹងអាចដឹងថា ស្រូវក្នុងជង្រុករបស់
អញស្រកស្រុតទៅមិនតាំងនៅបរិបូណ៌ឡើយ ដោយអំណាច
បរិភោគនោះ ឬដូចម្តេច ។

ម . អាមភន្តេ បពិត្រលោកម្ចាស់ អ្នកស្រែនោះអាច
ដឹងយ៉ាងនឹងថា ស្រូវក្នុងជង្រុករបស់អញអស់ទៅហើយ ។

ន . កថំជានេយ្យចុះហេតុដូចម្តេចក៏គេដឹង ។

ម . យោហេតុ-យោបច្ចយោ បពិត្រលោកម្ចាស់ សភា
វឯណា ដែលជាហេតុជាបច្ច័យនៃកិរិយាពេញបរិបូណ៌ នៃ
ស្រូវនោះ អ្នកស្រែនោះគេអាចដឹងដោយហេតុដោយបច្ច័យ
នោះថា ស្រូវក្នុងជង្រុករបស់អញនោះ វាស្រកស្រុតទៅមិន
តាំងនៅបរិបូណ៌ដូចប្រក្រតីឡើយ គឺអស់ទៅហើយបពិត្រ

www.budinst.gov.kh www.elibraryofcambodia.org

មហារាជ សេចក្ដីនេះមានឧបមាយ៉ាងណាមិញថា ពាលឧបមេយ្យដូចជាព្រះយោគាវចរកុលបុត្រ ដែលដឹងនូវធម៌ជាហេតុជាបច្ច័យនោះរលស់ហើយ ទើបចូលចិត្តថា រាគារវញ្ញនឹងមិនកើតទៀតឡើយសូមទ្រង់ជ្រាប ។

ន - កល្លោសិ លោកម្ចាស់ពោលក្នុងសេចក្ដីឧបមានុបមេយ្យគួរអោយចូលចិត្តហើយ ។

បញ្ញានិរុជ្ឈនបញ្ហា ១ ទី ៣

បរមក្សត្រាធិរាជ ស្ដេចទ្រង់សួរទៅព្រះនាគសេនថេរថាបពិត្រព្រះថេរដ៏ចំរើន ញាណគឺសេចក្ដីឃើញដល់កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថាមានបញ្ញាគឺសេចក្ដីដឹងទូទៅកើតហើយ ឬដូចម្ដេចលោកម្ចាស់ ។

ព្រះនាគសេនឆ្លើយថា ថ្វាយព្រះពរ បុគ្គលឯណាមានញាណបុគ្គលនោះហើយឈ្មោះថាមានប្រាជ្ញាសូមទ្រង់ជ្រាប។

ម - បើដូច្នោះពាក្យដែលហៅថាញាណ ១ នោះ មិនគឺបញ្ញានោះឯងឬ ។

ន - ថ្វាយព្រះពរ នឹងហើយញាណសព្ទនោះ គឺជាឈ្មោះរបស់បញ្ញានោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

ម - ឱបើដូច្នោះ ញាណសព្ទនោះ គឺបញ្ញានេះហើយ ចុះបើបុគ្គលឯណាមានបញ្ញាហើយ បុគ្គលនោះពើនៅវង្វេងភាន់ច្រឡំដែរឬ ។

ន - កត្ថចិបញ្ញាវា បុគ្គលដែលមានបញ្ញានោះ នៅមានមោហ ពីសេចក្ដីភ្លេចភ្លាំងខ្លះ មិនភ្លេចភ្លាំងខ្លះ សូមមហារាជជ្រាប ។

ម - កុហ៊ីភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចុះមានបញ្ញាហើយ ហេតុអ្វីក៏នៅមានមោហា គឺសេចក្ដីភាន់ច្រឡំនោះទៀត បើមានសេចក្ដីភាន់ច្រឡំ ពើភាន់ច្រឡំក្នុងបីដូចម្ដេច មិនភាន់ច្រឡំក្នុងបីដូចម្ដេច ។

ន - អកកពបុព្វេចបពិត្រមហារាជ ឯអ្នកដែលមានប្រាជ្ញានោះ នៅមានសេចក្ដីវិបរិតភ្លេចភ្លាំង ក្នុងចំណោះទាំងពួង គឺសិល្បសាស្ត្រឯណា ដែលខ្លួនមិនបានរៀនសូធ្យាយអោយស្ទាត់ ប្រាកដផងក្នុងនាម នឹងបញ្ញត្តិទាំងពួងដែលខ្លួនមិនស្ទាត់មិនធ្លាប់ស្ដាប់ ឬឮផង សូមមហារាជជ្រាប ។

ម - កុហ៊ីភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចុះអ្នកណាដែលមានញាណឬបញ្ញាហើយមិនមានមោហា ពីសេចក្ដីវង្វេង

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងទីដូចម្ដេច ។

ន - យំខោបន បពិត្រសម្ដេចមហារាជសេចក្ដីកំណត់ឯណា ដែលអ្នកមានប្រាជ្ញា បានធ្វើទុកក្នុងចិត្តដោយកិច្ចជាឧបាយនោះ ថារូបរបស់សត្វទាំងពួងមិនទៀង មិនពាំងនៅយូរផង (អនិច្ចំ) រូបនេះ តែងនាំមកនូវសេចក្ដីទុក្ខទោមនស្សផង ( ទុក្ខំ ) រូបនេះមិនមែនជាខ្លួនប្រាណរបស់សត្វផង សេចក្ដីកំណត់យ៉ាងនេះឯង គឺអ្នកមានប្រាជ្ញាមិនវង្វេងភ្លេចឡើយ សូមទ្រង់ជ្រាប ។

ម - មោហោបនស្សបនស្ស ចុះមោហោ គឺសេចក្ដីភាន់ច្រឡំ ដែលធ្លាប់មាននៅក្នុងសន្ដានអ្នកប្រាជ្ញនោះ តើរលាត់បាត់ទៅឯណាទៅ ។

ន - មោហោនោ សេចក្ដីល្ងង់វង្វេងនោះកាលបើប្រាជ្ញាកើតឡើងហើយក៏រលត់រលាយផ្សាយបាត់ទៅក្នុងទីនោះដោយអំណាចនៃប្រាជ្ញានោះគ្របសង្កត់បំបាត់ទៅ សូមទ្រង់ជ្រាប ។

ម - ឧបមំករោហិ បើដូច្នេះសូមលោកព្រោស់ប្រៀបប្រដូចមកមើល ។

ន - យថាមហារាជ បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចប្រទីបគោម ដែលបុរសកាន់ចូលទៅក្នុងទីអន្ធការងងឹត ។ នោះ ក៏ក្លាយរលាយរលត់បាត់អស់ទៅដោយអានុភាព នៃពន្លឺប្រទីប។ នោះ ក៏សំដែងនូវអំណាចរាជ្ញារបស់ខ្លួនអោយភ្លឺរុង

www.budinst.gov.kh www.elibraryofcambodia.org

រឿងប្រាកដឡើងក្នុងទីនោះ បពិត្រមហារាជ រឿងនេះមានឧបមាយ៉ាងណាមិញថា មានឧបមេយ្យ ដូចមោហចេតសិកនោះពេលដែលនឹងរលាយបាត់ទៅ ក៏ដោយតេជានុភាពនៃញាណប្រទីបនោះឯងសូមទ្រង់ជ្រាប ។

ម - បញ្ហាបន អើលោកម្ចាស់ថាមោហវិនាសទៅដោយកំលាំងបញ្ញាចេតសិក ចុះចំណែកខាងបញ្ញាចេតសិកនោះ តើទៅកាន់ទីណាហោកម្ចាស់ ។

ន - បញ្ហាបិនោ បពិត្រមហារាជបែកខាង បញ្ញានោះកាលដែលកើតឡើងហើយធ្វើកិច្ចរបស់ខ្លួនបានសម្រេច ក៏រលត់ទៅក្នុងទីនោះឯង ឯកិច្ចរបស់បញ្ញានោះ គឺអនិច្ចំ១ ទុក្ខំ១ អនត្តា ១ ដូច្នេះដែលបញ្ញាបានពិចារណាធ្វើហើយនោះ កិច្ចនោះឯង ក៏មិនបានរលត់បាត់ទៅឡើយ សូមព្រះអង្គជ្រាប ។

ម - យំបនេតំព្រួសិ បពិត្រលោកម្ចាស់ ៗ បានពោលពាក្យយ៉ាងនេះថា បញ្ញាកើតឡើងនូវកិច្ចរបស់ខ្លួនស្រេចហើយក៏រលត់ទៅ ឯកិច្ចដែលបញ្ញាកំណត់ថាអនិច្ចំ ទុក្ខំ អនត្តានោះក៏សល់នៅមិនបានរលត់ទៅទីណាឡើយ សេចក្ដីនឹងគួរអោយសង្ស័យពេកណាស់ ចំណែកខាងប្រាជ្ញាចេះថាកើតឡើងធ្វើកិច្ចហើយរលត់ទៅ ចុះព្រងកិច្ចរបស់បញ្ញា

www.budinst.gov.kh www.elibraryofcambodia.org

នោះ ហេតុអ្វីក៏សល់នៅ សេចក្តីនេះសូមលោកម្ចាស់ប្រៀប
បក្តូងទៀតបើយវោហាររបស់សង្ស័យ ។

ឆ - យេផាទេបាភាព បពិត្រសម្តេចមហាភាព សេចក្តីនេះ
ប្រៀបដូចបុរសម្នាក់យកសរសេរលេខបញ្ញើទុក នឹងក្តារ ឬ
ក្រដាស ហើយកោះប្រាក់ ដើម្បីបើលទ្ធនេះនោះក្នុងវេលា
រាត្រីយប់ បុរសនោះវក្តប្រមីពោធហើយហើយ ១ ហើយ
មើលតរសេរនេះឬសេចក្តីវ៉ីមិព្វយកទុកនឹងក្តារឬក្រដាសនោះ
ហើយក៏លត់ចង្កៀងដេកទៅ ចំណែកខាងចង្កៀងក៏រលត់
ទៅពីកងនេះឬរក្សាដែលសរសេរទុកនោះ ក៏គង់នៅ
ជាប់នឹងក្តារ ឬនឹងក្រដាស មិនបាត់វិនាសទៅណាឡើយ សេចក្តី
នេះគួរយល់យ៉ាងណា បពិត្រទេវមហារាជ វិញ្ញាណដែលកើត
ឡើងធ្វើរូវកិច្ចរបស់ខ្លួនហើយរលត់ទៅ ចំណែកខាងកិច្ចគឺ
វេទនា សញ្ញា វេទនា របស់វិញ្ញាណនោះសល់នៅ ក៏យោងគួរយ៉ាង
ដូចនោះឯង ។

ម - យំបនេតំព្រូសិ បពិត្រលោកម្ចាស់ដ៏ចំរើន លោក
ម្ចាស់វធិប្បាយថា បញ្ហាកើតឡើងធ្វើរូវកិច្ចរបស់ខ្លួន ហើយ
រលត់ទៅ សេចក្តីនេះតូបលោកម្ចាស់ឧបមា ១ ទៀត វោហារ
ជាភិយោគ្យភាពទៅមើល ។

www.budinst.gov.kh www.elibraryofcambodia.org

ន - យថាបន បពិត្រមហារាជ សេចក្តីនេះប្រៀបដូចមនុស្សទាំងឡាយក្នុងជនបទ ចំណែកទិសខាងកើតមានសេចក្តីខ្លាចរអំពីភ្លើងឆេះផ្ទះរបស់ខ្លួន ហើយបានយកក្អមដ៏ពេញទៅដោយទឹកទាំងឡាយ ៥ ក្អម មកដាក់ទុកទៀបទ្វាររបងផ្ទះ ដើម្បីបំរុងលត់នូវភ្លើងគ្រាដែលភ្លើងឆេះផ្ទះវេលាណា មនុស្សទាំងឡាយក៏យកទឹកក្នុងក្អមនោះបាចសាចលត់ភ្លើងក្នុងវេលានោះ ភ្លើងក៏រលត់រលស់ទៅ បពិត្រមហារាជ កាលបើភ្លើងរលត់រលស់ហើយយ៉ាងនេះ តើមនុស្សទាំងឡាយនឹងបានគំនិតគិតថាយើងនឹងធ្វើនូវកិច្ចដោយទឹកក្នុងក្អមទៀតដែរឬ មហាបពិត្រ ។

ម - នហិភន្តេ មិនមានត្រូវការអ្វីដោយទឹកក្អមនោះទៀតទេលោកម្ចាស់ ព្រោះភ្លើងរលត់រលស់ហើយ ប៉ុណ្ណឹងល្មមហើយ ។

ន - បពិត្រមហារាជ ក្អមទឹកទាំង ៥ នោះ ប្រៀបដូចឥន្ទ្រិយ៍ ៥ មានសិទ្ធិន្ទ្រិយជាដើម មនុស្សទាំងឡាយនោះប្រៀបដូចព្រះយោគាវចរកុលបុត្រ ដែលធ្វើព្យាយាមដើម្បីលត់នូវភ្លើងគឺរាគាទិកិលេសភ្លើង ដូចជាកិលេសទាំង១០ ប្រការមានរាគជាដើម គំនរភ្លើងដែលរលត់សូន្យទៅនោះដោយ

www.budinst.gov.kh www.elibraryofcambodia.org

រំលោចនៃទឹកក្តមទាំង ៥ នោះ យ៉ាងណា ចំណែកកិលេស ដែលនឹងទ្រុតទ្រោមសាបសូន្យទៅមិនកើតទៀតនោះ ដោយ រាឝុភាពនៃឥន្ទ្រិយ៍ ៥ ប្រការ យ៉ាងនេះឯង បពិត្រមហារាជ ឯបញ្ញាដែលកើតឡើងធ្វើនូវកិច្ចរបស់ខ្លួន ហើយរលត់ទៅ ឯ កិច្ចពី អនិច្ចំ ទុក្ខំ អនត្តា នោះ ក៏សល់នៅមិនបានរលត់ទៅឯ ណាឡើយ សូមទ្រង់ជ្រាប ។

ម - សូមលោកម្ចាស់ឧបមាម៉្យាងទៀត អោយប្លែកពី ឧបមាមុនៗ ទៅមើល ។

ន - យថាមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះ ប្រៀបដូចគ្រូពេទ្យ ដែលជាអ្នករក្សារោគក្នុងវេហោ ១ គ្រូ-ពេទ្យនោះកាន់យកនូវឫសឈើ ៥ យ៉ាងជាថ្នាំងសម្រាប់ពេទ្យ ហើយចូលទៅកាន់សំណាក់អ្នកជំងឺ ដល់ហើយមើបពាំង ចាត់ចែងកិនថ្នាំផុសថ្នាំស្រេចក៏បង្ហំអ្នកជំងឺអោយផឹក លុះ ផឹកទៅហើយ រោគាព្យាធិនោះក៏វិនាសចាកសន្តានកាយអ្នក ជំងឺនោះទៅ ដោយអានុភាពនៃមូលភេសជ្ជនោះឯង បពិត្រ មហារាជ រីសេចក្តីបរិតកររបស់ពេទ្យនោះ នឹងមានពិតថា អញនឹងផ្សំថ្នាំដោយឫសឈើទាំង ៥ យ៉ាងនេះ ប្តូងទៀតឬ ១ ដូចម្តេច ។

www.budinst.gov.kh www.elibraryofcambodia.org

ម ‑ នហិរភន្តេ ពំនិតពេទ្យនោះ មិនមានគិតដូច្នោះទេ លោកម្ចាស់ ព្រោះវិធីដែលបំផឹកថ្នាំនោះ ល្មមប៉ុណ្ណឹងហើយ ពាកធិនោះក៏ថយចាករូបកាយហើយ ។

ន ‑ បពិត្រមហារាជ ឯឫសឈើទាំង ៥ យ៉ាងនោះ ជាថ្នាំសម្រាប់ពេទ្យនោះ បណ្ឌិតគប្បីដឹងថា ដូចជាឥន្ទ្រិយ៍ទាំង៥ ប្រការមានសទ្ធិន្ទ្រិយជាដើមត្រូវពេទ្យនោះប្រៀបដូចព្រះយោគាវចរព្យាធិនោះដូចកិលេសធមិទាំងពួង អ្នកជំងឺនោះប្រៀបដូចមនុស្សបុថុជ្ជនទាំងឡាយទោសទាំងឡាយ គឺរោគាព្យាធិដែលនឹងសះស្បើយ ស្រាកស្រាន្តចាករូបកាយអ្នកជំងឺនោះបានក៏ដោយអំណាចនៃថ្នាំ ៥ យ៉ាង១ ណាមិញ កិលេសទាំងឡាយដែលនឹងរីងស្ងួតចាកខន្ធសន្តានទៅ មិនអាចនឹងកើតទៀតបាន ក៏ដោយគុណានុភាពនៃឥន្ទ្រិយ៍ទាំង ៥ ប្រការយ៉ាងនោះដែរ បពិត្រមហារាជ ឯបញ្ញាចេតសិកដែលកើតឡើងហើយធ្វើនូវកិច្ចរបស់ខ្លួនហើយរលត់ទៅ ចំណែកខាងកិច្ចដែលបញ្ញាបានធ្វើទុកក្នុងចិត្តថា អនិច្ចន្តិវា ទុក្ខន្តិវា អនត្តាតិវា នោះមិនបានរលត់រលាយក្លាយបាត់ទៅណាឡើយ សេចក្តីនេះមានឧបមាយ៉ាងណាមិញថា មានឧបមេយ្យដូចកំលាំងថ្នាំដែលធ្វើអោយរោគវិនាសទៅហើយ សល់នៅតែព្រង់

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីសុខកាយ គុះចិត្តព្រៀងពុំព្រោះឯង ។

ប - ភិយ្យោឧបចំករោហិ លោកក្លាស់ប្រៀបផ្ទឹម សេចក្ដីបែកនេះ ក៏ពិរោះហើយ ពែត្រូបលោកក្លាស់ធ្វើនូវ សេចក្ដីឧបមាដ៏ទៃ រោយរពិរោះជាងនេះទៅមើល ។

ន - សង្ខាហោវចរោបុរិសោ បពិត្រសម្ដេចបរមរាជ រឿង នេះប្រៀបដូចរបោរកោធា ដែលជាអ្នកធ្វើនូវសង្គ្រាមក្នុង វេលាព្រលប់នោះ យោធានោះឯងកាន់នូវព្រួញទាំង ៥ ព្រួញ ហើយចូលទៅកាន់ទីជ័យភូមិ ដើម្បីច្បាំងនូវសេនាអាយានដែន សត្រូវដ៏ទៃ ហើយក៏បាញ់ទៅនូវព្រួញទាំងឡាយ ៥ ព្រួញនោះ ឯព្រួញពេញទាបាននៃសត្រូវដ៏ទៃដែលជាសត្រូវនោះ ក៏បាក់បែរ ខ្ទេចខ្ទាំព្រួញនោះ ហើយក៏រត់ចេញទៅ បពិត្រមហារាជ ចុះឯ គំនិតរបស់យោធាដែលឈ្មោះសត្រូវនោះ តើគិតដូចម្ដេចនឹង គិតថាអញត្រូវបាញ់នូវព្រួញទៅត្រង់មិនខ្វះនោះទៀត ឬ ដូច ម្ដេចមហាបពិត្រ ។

ប - នបរាភន្តេ ព្រោះតែគិតថាប៉ុណ្ណឹងល្មមហើយ សេនា ទាហានពេលនោះ ក៏បាញ់ចោលទៅ ហើយប្រយោជន៍អ្វីនឹង បាញ់ព្រួញនោះទៀត បពិត្រមហារាជ កូនសរទាំង

www.budinst.gov.kh www.elibraryofcambodia.org

នោះ ប្រៀបដូចជាឥន្ទ្រិយ៍ទាំង ៥ ប្រការ គឺសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ឯយោធានោះ ប្រៀបដូចជាព្រះយោគាវចរសេនា នឹងពលថ្មើរជើងរបស់ស្តេចដ៏ទៃនោះ ប្រៀបដូចកិលេសធម៌ទាំងពួង សេនាទាហាននៃស្តេចដ៏ទៃ ដែលបាក់បបចាញ់ចាលទៅដោយអំណាច នៃពួកទាំង ៥នោះ យ៉ាងណាមិញធម៌ដែលសៅហ្មងទាំងឡាយ ដែលភិជ្ជនាការបាក់បែកទៅដោយអានុភាពនៃឥន្ទ្រិយ៍ទាំង ៥ ប្រការ ហើយមិនបានត្រឡប់កើតវិញឡើយ ក៏យ៉ាងនោះឯង បពិត្រមហារាជ ឯបញ្ញាចេតសិកដែលកើតឡើងហើយធ្វើនូវកិច្ចរបស់ខ្លួនរួចរលត់ទៅ ចំណែកឯកិច្ចដែលបញ្ញាបានធ្វើទុកក្នុងចិត្តថា អនិច្ចំ ទុក្ខំ អនត្តា នោះក៏សល់នៅជាធម្មតាមិនបានរលត់ទៅឡើយសូមទ្រង់ជ្រាប ។

ម . កល្លោសិ ភន្តេ លោកម្ចាស់វៀងវៃល្អណាស់ ឆ្លើយឥតមានទាស់ ។

បរិញ្ញូនបញ្ហាទី ៧ ទី ៤

ព្រះបាទមិលិន្ទ្រាធិរាជ ទ្រង់មានព្រះឱង្ការត្រាស់សួរទៅព្រះនាគសេនថេរថា បពិត្រព្រះថេរដ៏ចំរើន អ្នកណាដែលមិនកាន់យកបដិសន្ធិ គឺមិនកើតទៀត អ្នកនោះឯងនឹងត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ទទួលសោយទុក្ខវេទនាខ្លះដែរឬទេលោកម្ចាស់ ។

ព្រះនាគសេនឆ្លើយថា សូមថ្វាយព្រះពរ អ្នកដែលមិនត្រូវកើតទៀតនោះ បានសោយទុក្ខវេទនាខ្លះ មិនសោយខ្លះ សូមទ្រង់ជ្រាប ។

ម - បពិត្រលោកម្ចាស់ដ៏ចំរើន ដែលសោយទុក្ខខ្លះនោះដូចម្តេច ដែលមិនសោយទុក្ខខ្លះនោះដូចម្តេច ។

ន - កាយិកវេទនាបពិត្រមហារាជ លោកដែលសោយទុក្ខខ្លះនោះ គឺលោកសោយតែទុក្ខវេទនាឯណា ដែលប្រព្រឹត្តទៅក្នុងកាយ ឯព្រង់ទុក្ខវេទនាដែលប្រព្រឹត្តក្នុងចិត្តនោះលោកមិនបានសោយឡើយ ។

ម - កថិកាយិកវេទនា ហេតុអ្វីក៏លោកសោយតែទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងកាយព្រង់ទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងចិត្តនោះលោកមិនសោយ ។

ន - បពិត្រមហារាជ លោកដែលសោយនូវទុក្ខប្រព្រឹត្តទៅក្នុងកាយ ហើយមិនសោយនូវទុក្ខ ដែលសម្បយុត្តទៅដោយចិត្តនោះ ព្រោះលោកនោះឯង ជាព្រះខីណាស្រពធមិងណា ដែលជាហេតុផ្តើមឡើងជាបច្ច័យចំនុកបំរុងបណ្តាល

www.budinst.gov.kh www.elibraryofcambodia.org

អោយកើតឡើងនៃសេចក្តីទុក្ខលំបាក ប្រកបទៅក្នុងកាយធម៌ដែលជាហេតុជាបច្ច័យនោះ មានឧបាទានមិនទាន់រលត់ទៅនៅឡើយ ព្រោះហេតុនោះហើយបានព្រះខីណាស្រព នោះ លោកត្រូវសោយតែសេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងកាយនោះ ម៉្យាងទៀតធម៌ឯណា ដែលជាបច្ច័យបណ្តាលបណ្តុះអោយកើតឡើងនៃសេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្តធម៌ជាហេតុជាបច្ច័យនោះរលត់ចាករាគ ទោស មោហ តណ្ហាបិដ្ឋិអស់ហើយ ហេតុនេះហើយបានជាព្រះខីណាស្រពនោះលោកមិនសោយនូវទុក្ខលំបាក ដែលប្រព្រឹត្តទៅក្នុងចិត្តនោះឡើយ បពិត្រសម្តេចមហារាជ ពាក្យនេះហើយដែលជាភាសិតរបស់ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកមកថា សោឯកំវេទនំវេទិតិកាយិកំនចេតសិកំដូច្នេះ ។

ម . បពិត្រព្រះថេរម្ចាស់ បើព្រះខីណាស្រពនោះលោកមិនសោយនូវទុក្ខវេទនា ហើយចុះ ហេតុអ្វីក៏លោកមិនបរិនិព្វានទៅ ។

ន . នហិស្សមហារាជ បពិត្រមហារាជ សេចក្តីត្រេកអរឬរីករាយក្តីកិរិយាអាក់អន់ ឬតូចចិត្តក្តី ពិតជាមិនមានដល់ព្រះអរហន្តនោះឡើយ តែធម្មតាបណ្ឌិតជាតិទាំងឡាយ ដែល

www.budinst.gov.kh www.elibraryofcambodia.org

ជាព្រះអរហន្តនោះ លោករមែងនឹងមិនធ្វើនូវផល ដែលមិនទាន់ទុំនោះ អោយធ្លាក់ចុះខូចវិនាសឡើយ លោកតែងរង់ចាំពេលវេលាអោយសមគួរ ទើបបានចូលទៅកាន់អមតមហាៈនិព្វាន ដូចមានភាសិតរបស់ព្រះសារីបុត្តថេរ ជាអគ្គសាវកវិសេស លោកពោលទុកថា ។

នាភិនន្ទាមិមរណំ នាភិនន្ទាមិជីវិតំ
កាលញ្ចបដិកង្ខាមិ វេត្តនំភត្តិកោយថា
នាភិនន្ទាមិមរណំ នាភិនន្ទាមិនជីវិតំ
កាលញ្ចបដិកង្ខាមិ សម្បជានោបដិស្សតោ

សេចក្តីប្រែថា ខ្ញុំមិនត្រេកអរ ចំពោះត្រង់សេចក្តីស្លាប់ ខ្ញុំមិនពេញចិត្តត្រង់ការដែលរស់នៅ ខ្ញុំខំពិនិត្យរំពឹងតែត្រង់ពេលវេលាដែលសមគួរនឹងរស់ ឬនឹងស្លាប់ខ្លួន ខ្ញុំនេះប្រៀបដូចនាយពិសេស ជាអ្នកធ្វើនូវភោជនាហារ ពីព្រះស្ងោយសម្រាប់ថ្វាយស្តេច ពេលណាដែលមហាក្សត្រស្តេចមានប្រាថ្នានឹងសោយៈ ក៏លើកគ្រឿងក្រយាស្ងោយនោះទៅថ្វាយក្នុងវេលានោះតាមធម្មតា ម៉្យាងទៀតខ្លួនអាត្មានេះ មានតណ្ហាប្រាស់ចាកសុន្តាន ហើយជាអ្នកមានស្មារតីដឹងព្រម ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ទោះបីរាត្រីនេះនឹងដល់នូវមរណភាពទៅក្តី ក៏មិនទោមនស្សពូចចិត្ត ឬនឹងមានជីវិតរស់នៅក្តី ក៏មិនសោមនស្សត្រេកអរ អាត្មានេះមានប្រាថ្នាចាំពោះតែត្រង់ កាលវេលាដែលគួរ នឹងចូលទៅកាន់ព្រះនិព្វានប៉ុណ្ណោះ ប្រៀបដូចនាយវិសេស ដែលរង់ចាំពេលនឹងលើកដង្វាយ ទៅថ្វាយស្តេចនោះហោង ហេតុដូច្នោះ បពិត្រមហារាជលោកដែលមិនកើតទៀតនោះ កាលដែលលោករស់នៅ ៗ មានសេចក្តីទុក្ខ ប្រកបដោយកាយ តែម៉្យាងចំណែកទុក្ខដែលប្រព្រឹត្តទៅក្នុងចិត្ត មិនមានឡើយ លោករំពឹងគយគន់តែត្រង់កាលដែលគួរ នឹងបរិនិព្វានប៉ុណ្ណោះ សូមមហារាជស្តេចជ្រាប ។

ម - កល្លោសិរាន្តេ លោកម្ចាស់ពេញហៅឈ្លាសព្រេកណាស់ សំដែងមកនេះពិរោះហើយឥតមានសង្ស័យពិចពូចឡើយ ។

សុខវេទនាបញ្ហា ៗ ចិ ៥

ស្តេចមិលិន្ទសួរថា បពិត្រលោកម្ចាស់ដ៏ចំរើនជនដែលបានសោយនូវសេចក្តីសុខនោះ តើជាកុសល ឬជាអកុសល ឬជាអព្យាកត ។

ព្រះនាគសេនថេរឆ្លើយថា អ្នកដែលសោយនូវសុខវេទ

www.budinst.gov.kh www.elibraryofcambodia.org

នានោះ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតក៏មាន សូមទ្រង់ជ្រាប ។

ម . បើជាកុសលហើយ មិនមែនទុក្ខទេបើជាទុក្ខហើយ មិនជាកុសលទេ សេចក្ដីសុខជាកុសលកើតឡើង ហើយ ចំណែកខាងទុក្ខមិនអាចកើតឡើងបានទេលោកម្ចាស់ ។

ន . ពំគឺមញ្ញសិ . ម្ដេចក៏មហារាជទ្រង់យល់ដូច្នោះវិញ បើយ៉ាងនឹង អាត្មាភាពសូមសួរថា មានបុរសម្នាក់ ហើយអ្នកដ៏ទៃ ពេយកដុំដែកដែលក្ដៅមកដាក់លើបាតដៃម្ខាង យកដុំពពកដែលត្រជាក់ មកដាក់លើបាតដៃម្ខាងទៀត បពិត្រមហារាជ ឯដៃទាំងពីរនោះរោលរាលក្រហល់ក្រហាយ អំពីដុំទាំងពីរនោះដែរឬទេ មហាបពិត្រ ។

ម . ត្រូវរោលរាលក្រហល់ក្រហាយដូចគ្នាលោកម្ចាស់ ។

ន . ពីបន បពិត្រមហារាជ បើដូច្នោះដៃទាំងពីរដែលរោលរាលនោះ តើព្រោះក្ដៅឬអ្វី ។

ម . មិនមែនព្រោះតែក្ដៅទេលោកម្ចាស់ ។

ន .បើមិនមែនរោលរាលព្រោះតែក្ដៅ ចុះរោលរាលព្រោះត្រជាក់ឬអ្វី ។

www.budinst.gov.kh www.elibraryofcambodia.org

ម . នឹងក៏មិនមែនសុទ្ធតែត្រជាក់ម៉្យាងទេលោកម្ចាស់។

ន . បើយ៉ាងនឹងហើយ មហារាជនឹងសព្វព្រះហឫទ័យថា ស្ដេចម្ដេចទ្រង់នឹងយល់ថា បើក្ដៅដៃខាងឆ្វេងហើយ ដៃខាងស្ដាំ ក៏នឹងក្ដៅដូចគ្នាទាំងពីរ ក៏ថាមិនបាន បើត្រជាក់ដៃខាងស្ដាំហើយដៃខាងឆ្វេងនឹងត្រជាក់ដូចគ្នាទាំងពីរ ក៏ថាមិនកើត ឬនឹងនិយាយថាដៃទាំងពីរ សុទ្ធតែត្រជាក់ក៏ថាមិនត្រូវនឹងថាសុទ្ធតែក្ដៅក៏មិនបាន បើមិនដូច្នោះនឹងថាដៃម្ខាងត្រជាក់ដៃម្ខាងក្ដៅ ក៏ថាមិនកើត ព្រោះចិត្តដែលទទួលវេទនានោះ ពីចិត្តតែ ១ មិនអាចនឹងទទួលអារម្មណ៍ពីរបាន បើយ៉ាងនឹងតើមហាបពិត្រទ្រង់ជ្រាបដូចម្ដេច ។

ម . បពិត្រព្រះថេរម្ចាស់ សេចក្ដីប្រស្នានេះ ខ្ញុំមិនអាចនឹងឆ្លើយដោះសារបានឡើយ សូមលោកម្ចាស់អធិប្បាយពន្យល់ខ្ញុំអោយភ្លឺសេចក្ដីជាក់ច្បាស់មកមើល ។

ន . ព្រះមហាថេរលោកក៏ទទួលអធិប្បាយថ្វាយសេចក្ដីក្នុងព្រះអភិធម្មបិដកថា បពិត្រព្រះរាជសម្ភារ ឯវេទនានោះមិនមែនមានតែម៉្យាង ពីរយ៉ាងប៉ុណ្ណោះទេ វេទនានេះមានដល់ ១០៨ យ៉ាង គឺឆគេហនិស្សិតា សោមនស្សវេទនា ដែលអាស្រ័យនៅក្នុងអារម្មណ៍ទាំង ៦ នៃបុគ្គល ដែលត្រេកអរ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបញ្ចកាមគុណនោះ ចាត់ជាសោមនស្សវេទនា ៦, ឆនេក្ខម្មនិស្សិតា, សោមនស្សវេទនា ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ នៃបុគ្គលដែលបានវិបស្សនាបញ្ញានោះ ចាត់ជាសោមនស្សវេទនា ៦, ឆ គេហនិស្សិតាទោមនស្សវេទនា ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ នៃបុគ្គលដែលត្រេកអរ ក្នុងបញ្ចកាមគុណនោះ ចាត់ជាទោមនស្សវេទនា ៦ , ឆនេក្ខម្មនិស្សិតា ទោមនស្សវេទនា ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ នៃបុគ្គលដែលត្រេកអរក្នុងបញ្ចកាមគុណនោះ ចាត់ជាឧបេក្ខាវេទនា ៦, ឆនេក្ខម្មនិស្សិតា ឧបេក្ខាវេទនា ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ នៃបុគ្គល ដែលបានវិបស្សនាបញ្ញានោះ ចាត់ជាឧបេក្ខាវេទនា ៦ រួមវេទនា ៦ ៗ ផងត្រូវជា ៣៦ ទើបយកវេទនា ៣៦ នេះ ចាត់ជាអតីត ៣៦ ជាអនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ បូករួម ៣៦ បីដង ត្រូវជា ១០៨ វេទនា ប៉ុណ្ណេះ បពិត្រព្រះស្តេចមហារាជ ឯសុខវេទនានោះនឹងថាជាកុសលក៏ថាមិនបាន ថាជាអកុសលឬជាអព្យាក្រឹត ក៏ថាមិនត្រូវ សេចក្តីនេះប្រៀបដូចបុរសដែលកាន់ធុរដោយដៃទាំងពីរដៃឆ្វេងកាន់ដុំដែកដែលក្តៅ, ដៃស្តាំកាន់ដុំទឹកកក ដែលត្រជាក់ ប្រសិនណាបើមានគេសួរចំពោះបុរសនោះថា អ្នកឯងក្តៅ ឬត្រជាក់ បុរសនោះមិនអាចឆ្លើយប្រាប់គេបានឡើយ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីនេះក៏ដូចគ្នា សូមមហារាជទ្រង់ជ្រាប ។

ម - ស្ដាប់បានហើយលោកម្ចាស់ ៗ ឈ្លាសមែន ។

នាមរូបបដិសន្ធិបុច្ឆាបញ្ហា ១ ពិ ៦

ព្រះបាទមិលិន្ទ ស្ដេចទ្រង់សួរប្រស្នាដ៏ទៃទៅទៀតថា ពីបដិសន្ធិយតិ ធម្មជាតិដូចម្ដេចដែលនាំសត្វអោយកើតត ៗ រកលោកខាងមុខ ។

ព្រះនាគសេនឆ្លើយថា នាមរូបនេះឯង បពិត្រមហារាជ នាមនឹងរូបនោះឯង តែងនាំសត្វអោយកាន់យកនូវបដិសន្ធិ សូមទ្រង់ជ្រាប ។

រ - នាមរូបឯណា លោកម្ចាស់នាមរូបរបស់សត្វសព្វថ្ងៃនេះ ឬអ្វីដែលនាំអោយបដិសន្ធិនោះ ។

ន - សូមថ្វាយព្រះពរ មិនមែនទេបពិត្រមហារាជ ប្រុសស្រីដែលកើតមកក្នុងលោកនេះ បានធ្វើនូវកម្មជាកុសល ឬជាអកុសល គឺធ្វើបុណ្យធ្វើបាបដោយនាមរូបនោះ ចំណែកផលបុណ្យផលបាបដែលសត្វបានធ្វើហើយនោះឯង ជាតួខ្លួនសត្វទៅកើតទៀតជានាមនឹងរូបតទៅយ៉ាងនឹងហើយ ទើបថានាមនឹងរូបនោះអោយបដិសន្ធិទៀតសូមថ្វាយព្រះពរ ។

www.budinst.gov.kh www.elibraryofcambodia.org

ប . ឥឡូវនេះយើង បពិត្រលោកម្ចាស់ដ៏ចំរើនថាបើនាមរូបនេះមិនបានទៅកើតទៀតទេ តើផលបុណ្យនឹងផលបាប ឬកំលាំងបុណ្យនឹងកំលាំងបាប ដែលខ្លួនបានធ្វើទុកហើយក្នុងនាមរូបនេះរលាយកើតទៀតទេ ចុះអ្នកនោះនឹងបានរួចចាកបុណ្យកម្មឬបាបកម្មដែលខ្លួនបានធ្វើពីមុននោះដែរឬអ្វី ។

ន . បពិត្រមហារាជដ៏ប្រសើរថា បើសត្វនោះមិនកើតទៀតទើបរួចចាកបុណ្យនឹងបាប បើត្រូវជាកើតទៀតហើយក៏មិនអាចនឹងផុតចាកបុណ្យនឹងបាបបានឡើយ សូមទ្រង់ជ្រាប ។

ម.សូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមាបង្កិតមកមើល។

ន . សូមថ្វាយព្រះពរមហារាជ សេចក្តីនេះប្រៀបដូចបុរសម្នាក់ទៅលួចយកផ្លែស្វាយរបស់គេបានមក ឯម្ចាស់ស្វាយនោះ គេក៏ចាប់បុរសចោរនោះបានមកហើយយកខ្លួនទៅថ្វាយដល់បរមក្សត្រ ទើបទូលថា ចោរនេះជាចោរលួចផ្លែស្វាយរបស់ខ្ញុំព្រះអង្គថ្វាយព្រះបាទ ចំណែកចោរនោះក៏ទូលថា សូមព្រះរាជទានទោស ខ្លួនខ្ញុំព្រះអង្គទូលព្រះបាទ មិនបានលួចយកផ្លែស្វាយរបស់អ្នកនេះក៏ទេ ឯផ្លែស្វាយដែលគាត់ដាំនោះជាផ្លែដទៃ លុះដុះជាដើមធំធំរើនឡើងហើយមានផ្លែ

www.budinst.gov.kh www.elibraryofcambodia.org

ចេញមកជាប់នៅចុងនោះជាផ្លែដ៏ទៃ ខ្ញុំព្រះករុណាវិសេសបាន បេះយកតែផ្លែនូវចុងមែកនោះទេតើ ឯគ្រាប់ដែលពាត់ដាំ នោះមានបានយកឯណា បើយ៉ាងនឹងតើអោយខ្ញុំល្អងធូលី ព្រះបាទត្រូវទណ្ឌកម្មឯណាក៏បាន បុរសចោរនោះអភិប្រាយ រាប់សេចក្ដីជាពាក្យសំនួនយ៉ាងនេះ តើនឹងផុតចាកទោស ឬ ដូចម្ដេចមបពិត្រ ។

អ . បពិត្រលោកម្ចាស់ បុរសចោរដែលអធិប្បាយកែ ខ្លួនជាសំនួនយ៉ាងនឹងហើយ ក៏គង់តែត្រូវទោសមិនខានទេ លោកម្ចាស់ ។

ន . ពេលការពោល ហេតុអ្វីក៏នៅតែត្រូវទោស បើចោរ នោះបានឆ្លើយថាបេះតែផ្លែដ៏ទៃទេ ឯផ្លែដែលគេដាំនោះមិន បានយកទេ ។

ម .មិនមែនគ្រាប់ស្វាយដែលដាំនោះពិតហើយ ប៉ុន្តែផ្លែ ដ៏ទៃនោះ តើកើតពីណាមក មិនតែកើតពីគ្រាប់ដែលគេដាំនោះ ឯង ហើយចោរនោះបានទាំងឆ្លើយទទួលការថា បានបេះផ្លែ ស្វាយនោះមែន តែត្រង់ដែលលោកម្ចាស់គេដាំទុកមុននោះ មិនបានយកទេ យកតែផ្លែថ្មីដ៏ទៃដែលកើតមកពីដើមស្វាយ នោះទេ ឯផ្លែដែលគេដាំនោះជាផ្លែដ៏ទៃទៅ ផ្លែដែលខ្ញុំបេះ

www.budinst.gov.kh www.elibraryofcambodia.org

នេះជាផ្លែថ្មីទៀតទេ ពាក្យចោរដែលឆ្លើយរវាយដឹណរឹងយ៉ាង
នេះហើយ នឹងរួចចាកទោសឯណាក៏បានព្រោះផ្លែស្វាយដែល
ចោរលួចយកនោះ ក៏កើតពីផ្លែដែលម្ចាស់គេដាំមុននោះ
ឯង ហេតុយ៉ាងនឹងហើយ បានជាថាចោរនោះមិនអាចរួចចាក
ទុក្ខទោសទណ្ឌកម្មនោះឡើយសូមលោកម្ចាស់ជ្រាប ។

ង . បពិត្រមហារាជ រឿងនោះយ៉ាងណាមិញ បុរសស្ត្រី
ណាដែលបានធ្វើកុសលកម្ម ឬ បាបកម្ម ដោយនាមរូបក្នុង
បច្ចុប្បន្នជាតិនេះក្ដី កាលដែលធ្វើកាលកិរិយាទៅក្នុងបរលោក
ក៏កើតជារូបនាមដទៃ ពិតមែនតែគង់មិនរួចផុតចាកកុសល
កម្ម ឬ បាបកម្មនោះទេ ប្រៀបដូចចោរដែលលួចផ្លែស្វាយ
នោះឯង សូមទ្រង់ជ្រាប ។

ម . សេចក្ដីអធិប្បាយ របស់លោកម្ចាស់នេះត្រូវហើយ
តែសូមលោកម្ចាស់ប្រៀបឧបមារឿង ១ ទៀត រវាយថ្លែកពី
នេះទៅមើល ។

ន . យថាមហារាជ បពិត្រមហារាជ ប្រៀបដូចជាបុរស
ម្នាក់បង្កាត់ភ្លើងក្នុងទី១ ដើម្បីអាំងក្នុងហិមន្តរដូវភ្លើងនោះមិន
ទាន់រលត់ខ្លួនក៏ជៀសចេញពីទីនោះទៅ ចំណែកខាងភ្លើង
នោះក៏រាលទៅឆេះដល់ស្រូវក្នុងស្រែជនដទៃ ទើបជនទាំង

www.budinst.gov.kh www.elibraryofcambodia.org

ឡាយនោះគេចាប់ខ្លួនបុរសដែលដុតភ្លើងនោះ យកទៅថ្វាយស្តេចហើយគេទូលថាបពិត្រព្រះសម្មតិទេពបុរសនេះដុតភ្លើងអោយឆេះស្រូវក្នុងស្រែខ្ញុំ សូមទ្រង់ព្រះករុណាមេត្តាពិនិច្ឆ័យអោយទាន ឯបុរសអ្នកដុតភ្លើងនោះឆ្លើយឡើងថា សូមព្រះរាជទានទោស ភ្លើងដែលខ្ញុំព្រះករុណាវិសេសបានដុតនៅទីកន្លែងណា កន្លែងនោះរលត់បាត់ទៅហើយ ឯភ្លើងដែលឆេះស្រែរបស់អ្នកនេះ នោះគឺភ្លើងឯទៀតដែលឆេះពីភ្លើងនេះទៅទេ ខ្លួនទូលព្រះបង្គំជាខ្ញុំ មិនគួរដល់ទណ្ឌកម្មឡើយ បើអ្នកដុតភ្លើងគេទូលយ៉ាងនឹងហើយ តើនឹងត្រូវមានទោសដែរ ឬមិនត្រូវទេ មហាបពិត្រ ។

ម - ត្រូវមានទោសមិនខានទេលោកម្ចាស់ ។

ន - កេនការណោន ព្រោះហេតុអ្វីក៏មានទោស ។

ម - បានជាមានទោសនោះ ព្រោះហេតុថា បុរសនោះបានឆ្លើយទទួលជាពាក្យសំនួនថា ភ្លើងមុនដំបូងដែលខ្លួនដុតនោះរលត់បាត់ទៅហើយ ឯភ្លើងដែលឆេះស្រែនោះជាភ្លើងដ៏ទៃដែលរាលតទៅនោះទេ ហេតុនឹងហើយបានជាយើងត្រូវកាត់សេចក្តីថា អោយមានទោសដល់បុរសនោះខានមិនបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ន . ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជសេចក្តី ដែលព្រះអង្គទ្រង់បានពណ៌នាមកនេះយ៉ាងណា ក៏សត្វលោក ដែលកើតមកជាមនុស្សប្រុសស្រីជានាមធម៌ រូបធម៌ បានធ្វើ នូវសោភណកម្ម ឬអកុសលកម្មទុកក្នុងជាតិនេះវេលាដល់ទៅ កាន់បរលោកនាយ ក៏កើតឡើងជានាមរូបដទៃទៀតនឹងបាន ផុតចាកផលបុណ្យបាបដែលបានធ្វើទុកនោះក៏ទេ ប្រៀប ដូចជាបុរសដែលដុតភ្លើង រោលរាលដោយទៅឆេះស្រូវស្រែ គេនោះឯង ត្រូវទោសរាជទណ្ឌព្រោះ ។

ថ . ត្រូវហើយលោកម្ចាស់ ឧបមាដែលលោកលើកពីនេះទៅទៀត ពិរោះ ។

ន . បពិត្រសម្តេចមហារាជ រឿងនេះប្រៀបដូចបុរស ម្នាក់អុជនូវប្រទីបចង្កៀងដាក់ទុកក្នុងទី ១ ហើយចូលទៅបរិ- ភោគអាហារក្នុងរោងរបស់ខ្លួន លុះបរិភោគអាហាររួចហើយ ក៏ដើរចេញទៅ ចំណែកភ្លើងប្រទីបនោះក៏ឆេះឆាបនូវស្បូវ នឹងស្លឹកដ៏ស្ងួត ហើយរាលទៅឆេះដល់ផ្ទះតូចផ្ទះធំក្នុងស្រុក វិនាសសាបសូន្យអស់ទៅ ឯជនអ្នកស្រុកទាំងនោះក៏បបួល គ្នាមកចាប់យកនូវបុរសជាម្ចាស់ចង្កៀងនោះ ទៅថ្វាយសម្តេច តាមចំនៀមព្រះរាជអាជ្ញា ហើយទូលតាមដំណើរថា សូម

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ព្រះមេត្តាប្រោស បុរសនេះដុតភ្លើងអោយឆេះផ្ទះយើងខ្ញុំ ក្រោមល្អងធូលីព្រះបាទរាល់គ្នា អោយវិនាសអស់ ទើបបុរសនោះទូលទាស់ឡើងភ្លាមថា សូមព្រះករុណាពិសេសទ្រង់ព្រះរាជទានទោស ខ្ញុំល្អងធូលីព្រះបាទមិនបានដុតផ្ទះអ្នកទាំងនោះទេ ឯភ្លើងដែលឆេះផ្ទះពួកនោះ គឺភ្លើងដែលឆេះស្មៅនឹងស្លឹកនឹងកំពេកត់ហើយនោះទេតើ ចំណែកភ្លើងរបស់ខ្ញុំព្រះបាទនោះ គឺភ្លើងចង្កៀងទេ ការបើបុរសដើមរឿងនិយាយការប្រដងណៃរយ៉ាងនឹងហើយ តើនឹងត្រូវបានទោស ឬមិនបានទេព្រះអង្គ ។

ធ . ស្តេចបានព្រះរាជឱង្ការត្រាស់ថា បុរសដើមភ្លើងនោះត្រូវបានទោសមិនបានទេលោកម្ចាស់ ។

ន . សេចក្តីនេះយ៉ាងណា បពិត្រមហារាជ ធម្មតាបុរសស្ត្រីដែលកើតមកក្នុងលោកនេះជារូបធម៌នាមធម៌ ហើយបានធ្វើអំពើទុច្ចរិតឬសុចរិតទុកក្នុងជាតិនេះ លុះដល់ទំលាយនាមរូបនេះចោលទៅហើយកើតឡើងម្តងទៀត ជានាមធម៌ រូបធម៌ដទៃក៏គង់មិនរួចចាកផលទុច្ចរិត ឬផលសុចរិត ដែលខ្លួនបានធ្វើទុកក្នុងជាតិមុននោះឡើយ ប្រៀបដូចជាអ្នកម្ចាស់ចង្កៀងនោះឯង សូមទ្រង់ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ម - សេចក្ដីដែលលោកម្ចាស់តាំងដែងមកនេះ ខ្ញុំនៅមានសង្ស័យណាស់ សូមព្រះថេរឧបមា ១ ទៀត អោយប្លែកជាងនេះទៅមើល ។

ន - កោចិទេវបុរិសា បពិត្រសម្ដេចព្រះមហារាជរឿងនេះ ប្រៀបដូចបុរសម្នាក់ទៅដណ្ដឹងកូនក្រមុំគេ កាលបើកូននោះនៅតូចនៅឡើយ លុះមាតាបិតាគេព្រមព្រៀងហើយក៏បានជូនជំនូនទៅមាតាបិតារបស់កូនស្រីនោះ ទុកជាបង្គាប់ជាស្រេច ហើយក៏លាទៅកាន់ទិសឆ្ងាយទៅ ចំណែកខាងនាងទារិកានោះបានចំរើនធំឡើងតាមកាលវេលា លុះគ្រាខាងក្រោយមក ក៏មានបុរសឯទៀតគេទៅដណ្ដឹងបានជូនរង្វាន់នោះពេញចិត្ត មាតាបិតារបស់នាងនោះ ក៏លើកកូនស្រីនោះអោយទៅបុរសក្រោយនេះទៀតទៅ បានទាំងរៀបរាពហ៍ពិពាហ៍រួចស្រេចផង ឯបុរសប្ដីដើមនោះបានដឹងដំណើរនេះហើយ ក៏មកប្រញាប់រួសរាន់តវ៉ាថា នែបុរសនេះអ្នកឯងម្ដេចក៏នាំយកភរិយារបស់ខ្ញុំទៅ ទើបប្ដីក្រោយនោះឆ្លើយថា ខ្ញុំមិនបាននាំប្រពន្ធអ្នកឯងទេ គឺជាប្រពន្ធរបស់ខ្ញុំដោយពិត ឯនាងទារិកាប្រពន្ធអ្នកឯងនោះដទៃទេ កាលដែលអ្នកដណ្ដឹង គឺនាងទារិកាដែលនៅតូចមិនទាន់ចំរើននោះទេតើ ឯនាងនេះជានាង

www.budinst.gov.kh www.elibraryofcambodia.org

ទារិកាដែលចំរើនធំឡើងហើយនោះទេ ទើបខ្ញុំមកដណ្តឹងបានទាំងជូនជំនូនផងស្រេចជាប្រពន្ធខ្ញុំហើយ ចូលអ្នកកុំសង្ស័យឡើយ ជនទាំង ២ នាក់ នោះ កើតវិវាទជជែកគ្នាប្រសិនណាបើអ្នកទាំងនោះនាំគ្នាមកកាន់សំណាក់ព្រះអង្គ ៗ នឹងសម្រេចសេចក្តីនេះដូចម្តេច ទ្រង់នឹងអោយជ័យជំនះនោះទៅនាងអ្នកណា អោយទៅអ្នកមុន ឬអ្នកក្រោយ ។

អ . បុរិមកត្ស បពិត្រលោកម្ចាស់ដ៏ចំរើន បើដំណើរយ៉ាងនឹងត្រូវអោយឈ្នះនោះទៅអ្នកដែលដណ្តឹងមុន ឯស្វាមីក្រោយនោះត្រូវអោយបរាជ័យចាញ់គេ សូមលោកម្ចាស់ជ្រាប ។

ន . កិការណា ហេតុដូចម្តេចក៏ត្រូវអោយជ័យជំនះនេះទៅស្វាមីមុន បើស្វាមីក្រោយនេះគេបាននិយាយរៀបរាប់ថានាងទារិកាដែលអ្នកដណ្តឹងមុននោះ ជានាងទារិកាក្មេងតូចទេ ឯនាងដែលជាប្រពន្ធគេនោះ ជាស្ត្រីធំដទៃឯណោះទេ ចុះហេតុអ្វីក៏អោយអ្នកមុនឈ្នះ ។

ម .·កិញ្ចាបិ ពិតមែនហើយតែស្វាមីក្រោយនេះ បាននិយាយរៀបរាប់ថា នាងទារិកានោះកាលនៅក្មេងជាភរិយាអ្នកមុន វេលាដល់នាងទារិកានោះធំឡើងជាភរិយារបស់ខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

វិញ ពាក្យនេះជាពាក្យមិនពិត ពីជាពាក្យកែសំរួលមេលោកជាប្រមាណមិនបាន ។ ព្រោះថាស្វាមីមុនគេបានចូលមកដណ្ដឹងតាមច្បាប់សំរាប់ប្រវេណី មាតាបិតាក៏បានព្រមវេរឲ្យទៅគេជាស្រេច ហើយបានទាំងទទួលរបស់ទ្រព្យគេជាបន្ទាល់ផង ពិតមែនតែមិនទាន់បានរួមសំវាសជាមួយគ្នា តែច្បាប់សម្រាប់ផែនដីលោកសំដែងថា ជាកម្មសិទ្ធិគឺថាជាការស្រេចទៅហើយ ព្រោះមាតាបិតាបានលើកវេរឲ្យទៅគេមុនហើយ ឯស្វាមីថ្មីនោះមិនត្រូវបានទេ ម៉្យាងទៀតដែលស្វាមីថ្មីដឹកចិត្តថា នាងទារិកាតូចនោះពើជាភរិយាអ្នកមុន ដល់ចំរើនធំឡើងមកជាប្រពន្ធខ្លួនវិញនោះខុសទេ ភរិយាមនុស្សតែ ៦ ខែ តើ ព្រមតែពីដើមវានៅតូច យូរទៅវាធំឡើងប៉ុណ្ណោះឯង ហេតុនឹងហើយបានជាកាត់ថា ត្រូវវេរឲ្យឈ្នះទៅស្វាមីមុន សូមលោកម្ចាស់ជ្រាប ។

ន .ឯវមេវខោមហារាជ បពិត្រមហារាជ រឿងវិវាទនេះយ៉ាងណាក្ដី បុរសស្ត្រីដែលបានធ្វើបាបកម្ម ឬបុញ្ញកម្ម ដោយនាមរូបក្នុងបច្ចុប្បន្ននេះមែនពិតហើយ វេលាដល់ធ្វើមរណកាលរំលាយខន្ធទៅក៏កាន់យកបដិសន្ធិដោយនាមរូបដ៏ទៃទៀត តែគង់អាស្រ័យនូវផលបាប ឬ ផលបុណ្យ ដែលខ្លួនបានធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ហើយក្នុងនាមរូបមុននោះមិនខានឡើយ ព្រោះសត្វទាំងឡាយកាលដែលស្លាប់ទៅនោះមិនទាន់បានសម្រេចព្រះនិព្វន កាលណាត្រូវតែកើតទៀតជាធម្មតា ហេតុនោះបានជាថា ផលបាបផលបុណ្យ ក៏តង់ជាប់តាមទំនុកបំរុងសត្វទាំងនោះមិនខាន អានឧបមេយ្យដូចនាងកុមារីតូច វេលាដល់ចំរើនធំឡើងយ៉ាងណាក្តីនឹងបានឃ្លាតផុតស្វាមីដើមនោះក៏ទេ សេចក្តីដូច្នេះសូមមហារាជត្រាស់ជ្រាប ។

ម . ករុណាម្ចាស់ចូលចិត្តស្តាប់បានហើយ តែសូមលោកម្ចាស់ឧបមាអោយច្រើនតទៅទៀត ។

ន . បពិត្រមហារាជ សេចក្តីនេះប្រៀបដូចបុរសម្នាក់ទៅទិញទឹកដោះអំពីនាយគោបាលៗ ក៏ដងទឹកដោះស្រស់ (អំរ) លក់អោយទៅបុរសនោះ ៗ ក៏ទទួលយក ហើយផ្ញើទុកនឹងនាយគោបាលនោះសិន ខ្លួនក៏ចៀសចេញទៅធ្វើការងារដទៃ កន្លងរាត្រីៗ តាមប្រាថ្នាហើយ ទើបត្រឡប់មក ចំណែកខាងទឹកដោះនោះ លុះកន្លងវេលារាត្រីទៅហើយ ក៏ប្រែទៅជាទឹកដោះជូរ ព្រោះត្រូវកំដៅខ្យល់កំដៅថ្ងៃ ឯបុរសនោះក៏ចូលទៅជិតនាយគោបាលហើយនិយាយថា ខ្ញុំមកសូមយករបស់ដែលខ្ញុំបានផ្ញើទុកនឹងអ្នកពីថ្ងៃម្សិលនោះ ទើបនាយគោបាល

www.budinst.gov.kh www.elibraryofcambodia.org

ក៏ក្រោកឡើង ទៅយកទឹកដោះមកអោយបុរសនោះ ១ ក៏បរិភោគ ភ្លក់មើលទៅដឹងថាជូរហើយ និយាយថា នែអ្នកទឹកដោះដែល ខ្ញុំផ្ញើទុកនឹងអ្នកនោះ ជាទឹកដោះស្រស់ ហេតុអ្វីក៏អ្នកយកទឹក ដោះជូរមកអោយខ្ញុំ ទើបនាយគោបាលនោះនិយាយថា ទឹក ដោះនឹងហើយដែលអ្នកឯងទិញខ្ញុំ ហើយផ្ញើទុកនឹងខ្ញុំនោះ ប៉ុន្តែទុកយូរទៅវាប្រែជាទឹកដោះជូរនេះឯង កុំសង្ស័យនឹង ហើយឱអ្នកអើយ មិនអោយសង្ស័យឯណាក៏បាន បើកាលណា ដែលផ្ញើប្រាកដជារបស់នេះ វាលែងដល់យករោកខ្ញុំអោយវា ជារបស់នោះវិញ ហើយថាមិនអោយខ្ញុំសង្ស័យ ជនទាំង ២ នោះកើតវិវាទទាស់ទែងគ្នា បើប្រសិនណាអ្នកទាំង ២ នោះ ក្តីមកកាន់សំណាក់ព្រះអង្គ ១ នឹងទ្រង់សេចក្តីខាងអ្នក ណា ។

ម - ខ្ញុំម្ចាស់នឹងកាន់ខាងនាយគោបាលនោះឯង ។

ន - ហេតុដូចម្តេចក៏ទ្រង់កាន់ខាងនាយគោបាល ។

ម - បានជាខ្ញុំកាន់ខាងនាយគោបាល ព្រោះនាយគោ បាលនោះនិយាយថា ទឹកដោះដែលជូរនោះមិនមានអំពីណា គឺ ក្លាយពីទឹកដោះស្រស់នោះ ព្រោះរបស់ដែលផ្ញើនោះទុក អោយកន្លងរាត្រីយូរ សូមលោកម្ចាស់ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ន - បពិត្រសម្តេចមហារាជ ទឹកដោះស្រស់នោះដែលក្លាយទៅជាទឹកដោះជូរនោះមានប្រការ យ៉ាងណាមិញរូបធម៌នាមធម៌របស់សត្វ កាលដែលស្លាប់ ហើយក្លាយទៅជារូបធម៌នាមធម៌ដទៃ និងបានផុតចាកបាបកម្ម ឬ បុញ្ញកម្មដែលខ្លួនបានធ្វើអំពីនាមរូបដើមនោះក៏ទេ ព្រោះថានាមរូបដើមនោះជួនកាលជាមនុស្ស វេលាដល់ស្លាប់ទៅក៏ក្លាយទៅជាតិរច្ឆានជាប្រេត ឬ ជាទេវបុត្រទេវតា ក៏មានតាមផលបាប ឬ ផលបុណ្យនោះឯង ឯនាមរូបដើម ប្រៀបដូចទឹកដោះគោដែលក្លាយទៅជាតក្រៀជា នវនិត ជា ទធិ ក៏មិនមែនទឹកដទៃ ពីរអាស្រ័យនូវតែទឹកដោះនោះម៉្យាង សេចក្តីដូច្នេះសូមមហារាជស្តេចជ្រាប។

ម - លោកម្ចាស់សំដែងមកនេះពិរោះណាស់ អស់សង្ស័យហើយ សមគួរពេកណាស់ ។

បុនបដិសន្ធិគហណបញ្ហា ១ ទី ៧

ព្រះមហាក្សត្រ ស្តេចទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏ចម្រើន អង្គលោកម្ចាស់និងកាន់យកបដិសន្ធិទៀតដែរឬ ១ ដូចម្តេច ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជឱង្ការទ្រង់បុច្ឆាមកនេះ  វាញ្ញាភាពលំបាកនិងថ្វាយព្រះពរពេកណាស់ តែនឹងខានថ្វាយពុំបាន  សូមថ្វាយព្រះពរជាសេចក្ដីសង្ខេបបន្តិចថា  ឯខ្លួនវាញ្ញាភាពនេះ បើប្រសិនណាជាវាញ្ញាភាពនៅប្រកបដោយឧបាទាននៅឡើយ  ពីថានៅពោរចិត្តជាប់ជំពាក់ដោយឧទ្ធទាំង ៥ ប្រការនេះ វាញ្ញាភាពត្រូវកើតទៀត  បើវាញ្ញាភាពនេះមិនប្រកបដោយឧបាទានពីថាចិត្តមិនពោរជាប់ជំពាក់ដោយគ្រុះក្នុងវរមោចឧទ្ធទាំង  ៥ ប្រការនោះទេ វាញ្ញាភាពមិនបានកើតទៀតឡើយ  សូមមហារាជត្រាប ។

៧ - ឧបមំកតោហិ  សូមលោកម្ចាស់ប្រៀបជាសេចក្ដីឧបមាបន្តិចមកមើល ។

៨ - យថាមហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបដូចជារាជបុរសឯណា ១  ជាអ្នកមានចិត្តស្លូតត្រង់និងមហាក្សត្របានធ្វើការរាជការថ្វាយមានថ្វីដែលមហាក្សត្រស្ដេចក៏ទ្រង់ពេញព្រះហឫទ័យនិងបុរសនោះ  ហើយទ្រង់ក៏ប្រោសប្រទានរង្វាន់ជាគុណរាបំណាច់ដល់រាជបុរសនោះ  ឯរាជបុរសនោះ ក៏បានទទួលយកនូវរាជទាយជ្ជទាំងនោះ  ហើយក៏សេពសោយនូវកាមគុណទាំងឡាយ ៥ ប្រការ ជារង្វាន់ ដែលមហា

www.budinst.gov.kh www.elibraryofcambodia.org

ក្យព្រះទ្រង់ប្រោសប្រទានអោយនោះ ហើយបុរសនោះប្រែជានិយាយប្រាប់គេប្រាប់ឯងថា មហាក្សត្រស្តេចគ្មានអ្វីអោយវត្ថុជាប្រយោជន៍បន្តិចបន្តួចដល់ខ្លួនទេ ដូច្នេះវិញជាគួរ ឬពុំគួរបរមបពិត្រ ។

រ . នហិភន្តេ មិនគួរទេលោកម្ចាស់ គឺបុរសនោះមិនអាចនិងនិយាយបំផ្លោះទេ ។

ន . ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ រាជបុរសនោះមិនអាចនិងពោលបានយ៉ាងណា អាត្មាភាពក៏មិនអាចនិងថ្វាយព្រះពរបានយ៉ាងនោះដែរ ម្យ៉ាងទៀតមហាបពិត្រ ស្តេចមិនគួរនិងយករឿងនេះមកសួរទេ ព្រោះមិនដឹងបើសួរទៅដើម្បីប្រយោជន៍អ្វី តែឥឡូវនេះទ្រង់បានជាបុច្ឆាមកហើយ អាត្មាភាពនិងខានវិសជ្ជនាថ្វាយឯណាក៏បាន សូមថ្វាយសេចក្តីថា សឧបាទានោ បើអាត្មាភាពនៅប្រកបដោយឧបាទានជាខ្សែតណ្ហានៅឡើយនោះ អាត្មាភាពមុខជានឹងកើតទៀត អនុបាទានោ បើអាត្មាភាពនេះមិនប្រកបដោយឧបាទានមិនមានខ្សែតណ្ហានោះ អាត្មាភាពមិនបានកើតទៀតឡើយសូមមហារាជស្តេចជ្រាប ។

រ . កល្លោសិ លោកម្ចាស់វៀងវៃណាស់ ចេះឆ្លើយ

www.budinst.gov.kh www.elibraryofcambodia.org

ដោះសារសមសេចក្តីស្រួលល្អស្តាប់ហើយ ។

នាគសេនបញ្ហា ១ ពី ៨

មហាក្សត្រស្តេចទ្រង់សួរទៅព្រះនាគសេនថេរថាបពិត្រព្រះនាគសេនថេរដ៏ចំរើន , លោកម្ចាស់បានសំដែងប្រាប់ខ្ញុំថា ធម៌មានពីរយ៉ាង គឺនាមធម៌ និងរូបធម៌ ចុះនាមធម៌នោះមានសណ្ឋានដូចម្តេច រូបធម៌នោះមានសណ្ឋានទ្រង់ទ្រាយដូចម្តេចលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ សភាវឯណាមានសណ្ឋានរឹង ៗ គ្រោតគ្រាត សភាវនោះឈ្មោះថារូបធម៌ ។ សភាវឯណាដែលគតមានសណ្ឋានទ្រង់ទ្រាយជារបស់ល្អិតជាចិត្តនឹងចេតសិកសភាវនោះ ឈ្មោះថា នាមធម៌ សូមទ្រង់ជ្រាប ។

ម - ចុះហេតុអ្វីលោកម្ចាស់ នាមធម៌ ទើបកាន់យកបដិសន្ធិបាន ព្រង់រូបធម៌ ក៏មិនអាចកាន់យកបដិសន្ធិ ។

ន - បពិត្រមហារាជ មិនដូច្នោះទេ ធម៌ទាំងពីរប្រការនេះ តែងអាស្រ័យនូវគ្នានិងគ្នាទៅវិញទៅមក វេលាដល់កើតក៏កើតក្នុងទីជាមួយគ្នា មិនដែលលះលែងគ្នាឡើយ សូមទ្រង់ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ម - សូមលោកម្ចាស់ប្រៀបឧបមាបន្តិចមកមើល ។

ន - យថាមហារាជ បពិត្រមហារាជ ធម៌ទាំងពីរប្រការនេះ ប្រៀបដូចជាធម្មជាតិដែលផ្កាសើម ជាកលលរូបនិងធម្មជាតិផ្កាសើមក៏មិនមានខាន់ខាប់ទៅជាពងបាន លុះតែមានវត្ថុផ្កាសើមបន្តិចបន្តួចជាហេតុដើម ទើបផ្តួចឡើងជាពងទៅបាន ធម្មជាតិទាំងពីរ គឺ កលល នឹង អណ្ឌនេះ តែងអាស្រ័យនូវគ្នានិងគ្នាទៅវិញទៅមក វេលាដែលកើតក៏កើតក្នុងទីជាមួយគ្នាមិនដែលឃ្លាតគ្នាឡើយ ឯវមេវខោ មហារាជ បពិត្រមហារាជ ឯធម៌ទាំងពីរប្រការនេះ មិនដែលលះបង់គ្នាឡើយ ជាបើនាមធម៌មិនមានហើយ រូបធម៌ក៏មិនមានដែរ ព្រោះនាមធម៌និងរូបធម៌ទាំងពីរនេះតែងអាស្រ័យនូវគ្នានឹងគ្នាហើយកើតជាមួយគ្នាមិនដែលខាន ក៏មានឧបមេយ្យដូចកលលរូប នឹងអណ្ឌនោះឯង ព្រោះធម៌ទាំងពីរនេះតែងកើតឡើងព្រមគ្នាមកអស់កាលយូរអង្វែងហើយ ដូចមានពុទ្ធភាសិតត្រាស់ហៅថាទីឃមទ្ធាន ដូច្នេះ សូមព្រះមហារាជស្តេចជ្រាប ។

ម - កល្លោសិ លោកម្ចាស់ឆ្លៀវឆ្លាស់ វាងវៃណាស់ ប្រសប់វិសជ្ជនាដោះប្រស្នាល្អស្តាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទមិលិន្ទរាជ ស្តេចទ្រង់សួរទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់បានពោលថាការដែលបង្គួរវង្វេងនោះគេហៅថា អទ្ធា-ន ១ នេះប្រែថា ការវែងការឆ្ងាយ ការដែលវែងឆ្ងាយ នេះពីការឬអ្វីយ៉ាងលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចបរមរាជ សំការនេះនោះមាន ៣យ៉ាង គឺអតីតអទ្ធាន១ អនាគតអទ្ធាន ១ បច្ចុប្បន្នអទ្ធាន ១ សូមទ្រង់ជ្រាប ។

ក . បពិត្រលោកម្ចាស់ដ៏ចំរើន ការនេះទាំងពាំ ប្រការនេះ ចេះតែមាននៅជានិច្ចឬ ១ ដូចម្តេច ។

ខ . សូមថ្វាយព្រះពរ បពិត្រការនេះទាំង ៣ ប្រការនោះ ការនេះខ្លះមាននៅតែ ១ នៅការនេះខ្លះមិនមាននៅឡើយ សូមទ្រង់ជ្រាប ។

គ . ការដូចម្តេចដែលមាននៅ ការដូចម្តេចដែលមិនមាននៅលោកម្ចាស់ ។

ឃ . បពិត្រមហារាជ សង្ខារធម៌ទាំងឡាយណា ដែល

www.budinst.gov.kh www.elibraryofcambodia.org

រលត់កន្លងទៅហើយ សំខារធម៌ទាំងឡាយនោះបានឈ្មោះ
ថា ជាកាលមិនមាននៅ ធម៌ទាំងឡាយឯណា ដែលជាផលនៃ
កុសលនិងអកុសលធម៌ទាំងឡាយនោះ ជាអ្នកកាន់យកនូវ
បដិសន្ធិក្នុងភពដទៃទៀត ធម៌ទាំងនោះ ក៏បានឈ្មោះថាជា
កាលមាននៅ ។ ម្យ៉ាងទៀតថា សត្វទាំងឡាយឯណាដែលធ្វើ
កាលកិរិយាស្លាប់ទៅហើយ សត្វទាំងឡាយនោះតែងកើត
ក្នុងភពដទៃ ៗ សត្វនោះបានឈ្មោះថា ជាសត្វមានកាលប្រែ
ទៅ សត្វទាំងឡាយឯណា ដែលបានចូលបរិនិព្វានរំលត់នូវខន្ធ
៥ ប្រការហើយ សត្វទាំងឡាយនោះមិនបានកើតទៀតសត្វ
ទាំងនោះ ក៏បានឈ្មោះថា ជាសត្វមានកាលមិនមាននៅ
ឡើយសូមមហារាជស្តេចជ្រាប ។

ម - លោកម្ចាស់វិសជ្ជនាមកនេះពិរោះណាស់ អស់
សង្ស័យហើយ ។

ធម្មសន្តតិវគ្គ

## តតិយវគ្គមានប្រស្នា ១៤

អទ្ធានបញ្ហា ១ ទី ១

ព្រះបាទមិលិន្ទាធិបតី ស្តេចទ្រង់មានព្រះរាជឱង្ការបុច្ឆា
ចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏ចំរើន

www.budinst.gov.kh www.elibraryofcambodia.org

ធម្មជាតិអ្វីដែលជាមូលហេតុផ្តើមឡើងនៃកាល ជាអតីតកាល ធម្មជាតិអ្វីដែលជាមូលហេតុនៃកាលជាអនាគត ធម្មជាតិអ្វីដែលជាមូលហេតុនៃកាលជាបច្ចុប្បន្ន សូមលោកព្រាលវិសជ្ជនាមកក្នុងកាលឥឡូវនេះ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ឯមូលហេតុនៃកាលទាំង ៣ ប្រការ គឺអតីតអទ្ធានអនាគតអទ្ធាននិងបច្ចុប្បន្នអទ្ធាននោះ មិនមែនវត្ថុអ្វីឡើយ គឺសេចក្តីមិនចេះមិនដឹងគឺអវិជ្ជានោះឯងជាមូលហេតុនៃកាលទាំង ៣ ប្រការ ឯអវិជ្ជានោះមិនគឺធម៌ឯណាដ៏វែងវៀប គឺបដិច្ចសមុប្បាទធម៌ទាំង ១២ ប្រការ គឺមានអវិជ្ជាជាដើម មានជរាមរណជាទីបំផុតនោះឯង ។ ឯបដិច្ចសមុប្បាទធម៌ទាំង ១២ ប្រការនោះនឹងប្រែជាសេចក្តីខ្លី ១ បន្តិចតទៅគឺចាប់ប្រែអំពីបទខាងចុងច្រាសឡើងមកខាងដើមវិញជាបទបដិលោមថាជរាមរណសោកបរិទេវ ទុក្ខទោមនស្ស ឧបាយាសា សេចក្តីព្រាំព្រា និងកាលកិរិយា និង ការក្រៀមក្រំ នឹងកិច្ចដែលខ្សឹកខ្សួល និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយវេលាដែលនឹងកើតឡើងព្រមជាតិបច្ចយា គឺកើតព្រោះបច្ច័យ គឺជាតិ ១ គឺកំណើតនៃសព្វបានខាង ឯខន្ធទាំង ៥ ប្រការ មានរូបខន្ធជាដើមជាតិកើត

www.budinst.gov.kh www.elibraryofcambodia.org

ឡើង ព្រមភវបច្ច័យា ព្រោះបច្ច័យគឺភព ២ គឺកុសលាកុសលកម្ម ភពកើតឡើង ព្រមឧបាទានបច្ច័យា ព្រោះបច្ច័យ គឺ ឧបាទាន ២ គឺសេចក្តីប្រកាន់មាំនូវខន្ធទាំង ៥ ប្រការ ថាជារបស់ខ្លួនពិតឥតមានសង្ស័យ ឧបាទានកើតឡើងព្រម តណ្ហាបច្ច័យា ព្រោះបច្ច័យគឺតណ្ហា ១ គឺសេចក្តីខ្វះខាត ឬ ស្រេកឃ្លានប្រព្រឹត្តទៅក្នុងភពទាំង ៣ ប្រការ មានកាមភពជាដើម តណ្ហាកើតឡើងព្រមវេទនាបច្ច័យា ព្រោះបច្ច័យ គឺវេទនា វេទនា គឺធម្មជាតិ សំរាប់ដឹងនូវអារម្មណ៍ជាទុក្ខ នឹងជាសុខ និងឧបេក្ខាវេទនាកើតឡើងព្រមផស្សបច្ច័យា ព្រោះបច្ច័យគឺផស្ស ផស្សគឺសភាវសម្រាប់ប៉ះនូវអារម្មណ៍ ឬ គៀងនូវអារម្មណ៍អោយត្រូវត្រង់ទ្វារទាំង ៦ ប្រការ មានចក្ខុទ្វារជាដើម ផស្សកើតឡើងព្រម សឡាយតនបច្ច័យា ព្រោះបច្ច័យគឺសឡាយតន១គឺទីកន្លែងសម្រាប់កើតឡើងនៃចិត្ត ៦ ប្រការ មានចក្ខាយតនជាដើមសឡាយតនកើតឡើងព្រម នាមរូបបច្ច័យា ព្រោះបច្ច័យ គឺនាមនិងរូប នាមគឺវេទនាខន្ធសញ្ញាខន្ធសំខារខន្ធ រូបគឺរូបខន្ធនាមរូបកើតឡើងព្រមវិញ្ញាណបច្ច័យា ព្រោះបច្ច័យគឺវិញ្ញាណ ១ គឺធម្មជាតិសម្រាប់ដឹងផ្សេង ១ វិញ្ញាណកើតឡើងព្រមសំខារបច្ច័យា ព្រោះបច្ច័យគឺសំខារ ១ គឺធម្មជាតិសម្រាប់លៃលកឬតាក់តែងស្និតស្អាងបានខាង ឯសំខារ ៣ យ៉ាង គឺ

www.budinst.gov.kh www.elibraryofcambodia.org

បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ សង្ខារកើតឡើងព្រោះអវិជ្ជាបច្ច័យា ព្រោះបច្ច័យគឺអវិជ្ជា២ គឺធម្មជាតិមិនចេះមិនដឹងបានខាង វត្ថុ ៨ យ៉ាង មានមិនដឹងនូវសេចក្ដីទុក្ខ និងមិនដឹងនូវហេតុជាទីកើតឡើងនៃសេចក្ដីទុក្ខជាដើម ។

ក៏ធម៌ទាំង ១២ ប្រការ នេះតែងអាស្រ័យគ្នាទៅវិញទៅមកទើបកើតឡើងព្រមជាមួយគ្នា ព្រោះតែធម៌ទាំងនេះ កើតឡើងហើយ ទើបកើតជាទីប្រជុំអោយកើតឡើងនៃកងទុក្ខ ឬក៏អស់ទុក្ខគ្រប់យ៉ាងដល់សត្វដែលមានខន្ធ ៥ប្រការ ឯទីបំផុតខាងដើមនៃឬកាលនៃកាលទាំង ៣ នោះ មិនមានប្រាកដឡើយ ដូច្នេះ មហារាជសេចក្ដីប្រាប់ដោយប្រការដូចពណ៌នាមកនេះ ។

កល្លោសិ ភន្តេ លោកម្ចាស់វៀងវៃពេកណាស់ចេះវិសជ្ជនាបដិច្ចសមុប្បាទធម៌យ៉ាងល្អ ហើយយោមស្តាប់បាន ។

បុរិមកោដិបញ្ហា ១ ទី ២

ព្រះបាទមិលិន្ទ្រាធិបតិ ស្តេចទ្រង់ត្រាស់បុច្ឆា ចំពោះទៅព្រះនាគសេនថេរក្នុងបុរិមកោដិបញ្ហានោះថា បពិត្រព្រះនាគសេនថេរដ៏ចំរើន លោកម្ចាស់បានពោលនិងខ្ញុំថា បុរិម-កោដិនបញ្ញាយតិ ថាទីបំផុតខាងដើមនៃកាលនោះ មិនប្រាកដ ឯទីបំផុតខាងដើមនៃកាលមិនប្រាកដនោះ គឺកាលដែល

www.budinst.gov.kh www.elibraryofcambodia.org

កន្លងទៅជាអតីតកាល រាប់ថយចុះទៅខាងក្រោយតាំងអំពីកាលដែលតាំងកកើតនាមនិងរូបឡើងមកនោះ ឬ ប្រការឯណេះលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ទីបំផុតខាងដើមនៃកាលជាអតីតកាលនោះ ដូចព្រះរាជឱង្ការដែលទ្រង់ត្រាស់នោះហើយសូមទ្រង់ជ្រាប ។

អ. លោកម្ចាស់ ទីឯណោះដែលជាទីបំផុតខាងដើម នៃកាលមិននោះ សុទ្ធតែមិនប្រាកដរាំងរស់ ឬដូចម្តេច ។

ន. បពិត្រមហារាជ ឯទីបំផុតខាងដើមនៃកាលនោះនឹងកំណត់មិនបាន ជួនកាលក៏ប្រាកដ ជួនកាលក៏មិនប្រាកដដែរ សូមមហារាជស្តេចជ្រាប ។

ម. ទីដូចម្តេចដែលប្រាកដ ទីដូចម្តេចដែលមិនប្រាកដនោះលោកម្ចាស់ សូមលោកម្ចាស់អធិប្បាយជាសេចក្តីបន្តិចមកមើល ។

ន. បពិត្រព្រះបរមក្សត្រដ៏ប្រសើរ វត្ថុឯណាដែលជារបស់មិនធ្លាប់កើត មិនធ្លាប់មានក្នុងកាលខាងដើមមកយូរយារណាស់ហើយ ។ ត្រឡប់ជាកើតឡើងមានឡើងវត្ថុនោះ

www.budinst.gov.kh www.elibraryofcambodia.org

ហើយដែលហៅថា ជារបស់មានទីបំផុតខាងដើមមិនប្រាកដនោះ ម្យ៉ាងទៀតវត្ថុឯណាដែលជារបស់ធ្លាប់កើត ធ្លាប់មានមកហើយ ៗ ត្រឡប់ជាវិនាសបាត់បង់ទៅវិញ វត្ថុនេះហើយដែលហៅថាជារបស់ប្រាកដខាងដើម សូមទ្រង់ជ្រាប ។

ម - បើដូច្នោះសូមលោកម្ចាស់សំដែងជាសេចក្តីឧបមាត្រង់បទដែលថា មានទីបំផុតខាងដើមមិនប្រាកដនោះមកបន្តិចមើល ។

ន - យថាមហារាជបវិត្តានិវីជានិ បពិត្រសម្តេចមហារាជ សេចក្តីនេះឧបមាដូចពូជទាំងពួង ធម្មតាពូជរុក្ខជាតិទាំងពួងដែលជារបស់តូចក្តីធំក្តីនោះ កាលបើបានមកអាស្រ័យនូវរសជាតិផែនដីហើយ ក៏នឹងដុះនូវសេចក្តីចំរើនឡើងជាលំដាប់ គឺថា នឹងបែកចេញជាស្លឹកជាផ្កាជាផ្លែ ៗ ទៅមិនខាន ចំណែកខាងផ្លែនោះសោតលុះដល់ចាស់ទុំវេលាណាហើយក៏ជ្រុះចាកទងនោះ ទៅដុះជាដើមដ៏ទៃ ៗ បែកចេញជាស្លឹកជាផ្កាជាផ្លែចំរើនជាលំដាប់ ៗ ទៅទៀត បពិត្រមហារាជ ទីបំផុតនៃពូជនៃរុក្ខជាតិនោះ ជានឹងមានទីបំផុតខាងដើម ឬមិនមានទេ ។

ម - នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ទីបំផុតនៃពូជ

www.budinst.gov.kh www.elibraryofcambodia.org

វុក្ខជាតិនោះមិនមានទីបំផុតទេ ។

ន . ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ វិទីបំផុតខាងដើមនៃកំណើតសត្វនោះ មិនមានប្រាកដ មានឧបមេយ្យដូចពូជឈើទាំងពួងនោះឯង សូមទ្រង់ជ្រាប ។

ម . ភិយ្យោភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ឧបមាឱ្យច្រើនតទៅទៀតមើល ។

ន . យថាមហារាជ កុក្កុដិយាអណ្ឌំ បពិត្របរមក្សត្រដ៏ប្រសើរ សេចក្តីនេះបានឧបមាដូចពងមាន់ផង្មាពងមាន់ញីផងមានពូលសត្វអាស្រ័យនៅក្នុងពងនោះ លុះសត្វនោះធំចំរើនឡើង ក៏អាចនិងចោះចិកទំលាយក្រដាសសន្ទះពងនោះចេញមកខាងក្រៅបាន គ្រាដល់ចំរើនធំឡើងៗ មាន់នោះក៏អាចនិងទៅអាស្រ័យគ្នានឹងមាន់ដ៏ទៃ ឱ្យកើតមានជាពង ឬ ជាពូជត ៗ ទៅបើសេចក្តីយ៉ាងនេះតើ វិទីបំផុតខាងដើមនៃពូជនោះ ជាមាន ឬគ្មាន មហាបពិត្រ ។

ម . នត្ថិភន្តេ មិនមានទេលោកម្ចាស់ ។

ន . បពិត្រព្រះបរមក្សត្រខត្តិយវង្ស វិ ឯទីបំផុតនៃកំណើតសត្វដែលបានកើតមកនោះ នឹងរកកំណាត់ថាសត្វនោះ

www.budinst.gov.kh www.elibraryofcambodia.org

តាំងកូរូបកនាមមកអំពីថ្ងៃនោះ ខែនោះ ឆ្នាំនោះ កាលនោះ ៗ មិនអាចនឹងកំណត់បានរកទីប្រាកដខាងដើមនោះ មិនបាន មានឧបមេយ្យដូចពូជមាន់នោះ សូមទ្រង់ជ្រាប ។

ម . សូមលោកម្ចាស់ឧបមាមួយទៀតមើល ។

ន .គ្រានោះព្រះនាគសេនថេរ លោកក៏តាំងគូរជារូបកង់និងផែនជើងកហើយ ទើបថ្វាយព្រះពរទៅព្រះបាទមិលិន្ទរាជ ជាបពិត្រមហារាជ តួកង់នេះមានទីបំផុតខាងដើមត្រង់ណា ត្រឹមណា សូមមហាបពិត្រស្តេចទ្រង់ប្រើប្រាជ្ញាញាណរាជ្ញាភាព បន្តិចមើល ។

ត នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ទីបំផុតខាង ដើមនៃកង់នោះមិនមានទេ ។

ថ . បពិត្រព្រះរាជសម្ភារ សម្តេចព្រះទសពលញាណ ទ្រង់ប្រោសប្រទានព្រះសទ្ធម្មទេសនាថា សត្តនិករទាំងឡាយ ដែលតាំងនាមតាំងរូបកើតមកយូរយារណាស់ហើយនោះ នឹង រកទីបំផុតខាងដើមកំណើតនោះមិនមានប្រាកដឡើយ តែង វិលវល់ត ៗ គ្នាដូចកង់រទេះនោះឯង ព្រោះតែនិងហើយបានជា សម្តេចព្រះភគវាទ្រង់ត្រាស់ទេសនាទុកបកថា ធម៌ ៦ ប្រការ

www.budinst.gov.kh www.elibraryofcambodia.org

គឺចក្ខុ ១ សោត ១ ឃាន ១ ជិវ្ហា ១ កាយ ១ មនោ ១ ធម៌ទាំង ៦ ប្រការ នេះ ពែងបង្វិលសត្វអោយវិលវល់នៅក្នុងវន្តវង់ឱឃសំសារ មានកាលខាងដើមមិនប្រាកដថា សត្វនោះកើតពីត្រឹមណាមកហើយ ទើបទ្រង់ត្រាស់សំដែងបញ្ជាក់សេចក្តីធម៌នោះថា ចក្ខុញ្ចបដិច្ចរូបេចឧប្បជ្ជតិ ចក្ខុវិញ្ញាណដែលនិងកើតឡើង ព្រោះអាស្រ័យនូវធម៌ ២ ប្រការ គឺចក្ខុបសាទ ១ រូបារម្មណ៍ ១ ចក្ខុបសាទ គឺភ្នែកនោះភ្លឺស្អាតមានខ្សែភវង្គឆ្លុសចេញទៅក្រៅ ប៉ះត្រូវនូវអារម្មណ៍ គឺរូបទើបញ៉ូវខ្សែភវង្គនោះចូលមក ក៏ចក្ខុវិញ្ញាណរអាចកើតឡើងក្នុងលំដាប់នោះកំណត់ដឹងនូវរូបារម្មណ៍ប្រាកដបាន បើមានតែចក្ខុបសាទ មិនមានរូបារម្មណ៍ ឬមានតែរូបារម្មណ៍ មិនមានចក្ខុបសាទទេ ក៏មិនអាចនិងញ៉ាំងវិញ្ញាណអោយកើតឡើងបាន លុះតែធម៌ទាំងពីរប្រការនេះ មានជាហេតុមកប្រទះគ្នាទើបកើតឡើងជាចក្ខុវិញ្ញាណ ។ គឺធម្មជាតិ សំរាប់ដឹងនូវអារម្មណ៍ផ្សេង ៗ ប្រព្រឹត្តទៅក្នុងចក្ខុទ្វារ លុះធម៌ទាំង ៣ប្រការគឺចក្ខុវិញ្ញាណ ១ ចក្ខុបសាទ ១ រូបារម្មណ៍១ កើតឡើងហើយក៏ផស្សចេតសិក គឺចេតសិកសម្រាប់ប៉ះពាល់នូវអារម្មណ៍ ឬគៀងប្រមូលនូវអារម្មណ៍អោយត្រូវត្រង់ទ្វារទាំង ៦ ប្រការមានចក្ខុទ្វារជាដើមកើតឡើង លុះផស្សចេតសិកកើតឡើង

www.budinst.gov.kh www.elibraryofcambodia.org

ហើយជាបច្ច័យអោយកើតវេទនាចេតសិក ។ គឺធម្មជាតិសំរាប់ដឹង ឬសោយនូវអារម្មណ៍ដែលជាទុក្ខជាសុខ ឬជាឧបេក្ខា វេទនាចេតសិកកើតឡើងហើយជាបច្ច័យអោយកើតតណ្ហា ។ គឺធម្មជាតិតែងធ្វើចិត្តចេតសិកអោយស្រេកឃ្លាននូវអារម្មណ៍ទាំង ៦ ប្រការ ពពមានស្រេកស្រាន្ត តណ្ហាកើតឡើងហើយជាបច្ច័យអោយកើតឧបាទាន ។ គឺធម្មជាតិសំរាប់ចងភ្ជាប់ទាក់ទុកនូវអារម្មណ៍ថាជារបស់ខ្លួនពិត ។ តតបានឯាកវេឧបាទាន កើតឡើងហើយជាបច្ច័យដឹកនាំសត្វនោះ អោយធ្វើនូវអំពើជាកុសល ឬអកុសលហៅថា «កម្ម» ឯចក្ខុវិញ្ញាណរបស់សត្វដែលនឹងកើតឡើងក្នុងជាតិជាថ្មីទៀត ឬ ក្នុងភពខាងមុខនោះក៏កើតបាន ព្រោះតែផលនៃកុសលកម្ម នឹងអកុសលកម្មដែលសត្វបានធ្វើហើយក្នុងជាតិនេះនោះឯង ព្រះពុទ្ធបរាជបើដំណើរវិលវល់នៃធម៌ទាំង ៦ ប្រការ នេះ មានសភាពយ៉ាងនេះហើយ តើនឹងមានទីបំផុតខាងដើមដែរ ឬ មិនមានទេ បរាបពិត្រ ។

ម . នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើនបើដំណើរ នៃធម៌ទាំងនេះ ដូចលោកម្ចាស់ពណ៌នាមកនេះ និងរកទីបំផុតខាងដើមឯណាក៏មានលោកម្ចាស់គ្មានទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ន . សោតញ្ចៈ មហារាជបដិច្ចសទ្ទេច បពិត្រសម្តេចមហារាជឯសោតវិញ្ញាណ គឺវិញ្ញាណដែលប្រព្រឹត្តទៅក្នុងសោតទ្វារវេលាដែលនិងកើតឡើង ក៏ព្រោះតែធមិទាំង ២ ប្រការ គឺសោតបសាទ និង សទ្ទារម្មណ៍មកផ្តប់គ្នា អោយកើតឡើងជាសោតវិញ្ញាណេ ក៏ធមិទាំង ៣ ប្រការ គឺសោតវិញ្ញាណ និងសោតបសាទ និងសទ្ទារម្មណ៍កើតឡើងហើយក៏ផស្សកើតឡើងព្រមផង ផស្សកើតឡើងហើយជាបច្ច័យអោយវេទនា និង តណ្ហា និង ឧបាទា.. និងកម្មកើតឡើង ។

ឯសោតវិញ្ញាណរបស់សត្វ ដែលនឹងកើតឡើងក្នុងជាតិជាថ្មីទៀត ឬភពខាងមុខនោះក៏កើតឡើង ព្រោះផលនៃកម្មជាកុសល ឬ អកុសលដែលខ្លួនសត្វបានសាងទុកមកក្នុងជាតិនេះនោះឯង ។ ឯឃានវិញ្ញាណក្តី ជីវ្ហាវិញ្ញាណក្តី កាយវិញ្ញាណក្តីក៏ដូចគ្នា។ មនញ្ចបដិច្ចធម្មេចឧប្បជ្ជតិ បពិត្រមហារាជ ឯមនោវិញ្ញាណដែលនឹងកើតឡើង ក៏ព្រោះតែធមិពីរប្រការ គឺមនោបសាទនឹងធម្មារម្មណ៍នោះ ជាហេតុមកផ្តប់គ្នាអោយកើតឡើងជាមនោវិញ្ញាណ លុះធមិទាំង ៣ ប្រការ គឺមនោវិញ្ញាណ និងមនោបសាទនឹងធម្មារម្មណ៍កើតឡើយហើយ ក៏ផស្សចេតសិកកើតឡើងព្រមផង ផស្សចេតសិកកើតឡើងហើយជាបច្ច័យអោយកើតវេទនាចេតសិក១កើតឡើងហើយ

www.budinst.gov.kh www.elibraryofcambodia.org

ជាបច្ច័យអោយកើតតណ្ហា តណ្ហាកើតហើយជាបច្ច័យអោយកើតឧបាទាន ៗ កើតហើយ ជាបច្ច័យអោយកើតកម្ម ឯមនោវិញ្ញាណរបស់សត្វ ដែលនិងកើតក្នុងភពថ្មីទៀត ឬក្នុងភពខាងមុខទៀតនោះក៏កើតឡើងព្រោះតែផលនៃកុសលកម្ម និងអកុសលកម្មដែលសត្វបានធ្វើហើយក្នុងជាតិនេះ ទុកជាពូជអោះឯង បពិត្រសម្តេចមហារាជ បើដំណើរវិលវល់នៃខ្សែធម៌ទាំងនេះមានសភាពដូច្នេះ តើនឹងរកទីបំផុតខាងដើមជាមាន ឬមិនមានទេ មហាបពិត្រ ។

ម - នត្ថិភន្តេ បើយ៉ាងនឹងមិនមានទីបំផុតទេលោកម្ចាស់ ។

ន -ឯវមេវខោមហារាជ បពិត្រព្រះបរមក្សត្រាធិរាជ រីទីបំផុតខាងដើមនៃកាល គឺទីបំផុតខាងដើមនៃកំណើតរបស់សត្វដែលកើតជាដំបូងនោះ មិនមានទីប្រាកដឡើយ មានឧបមេយ្យដូចកង់នៃរថនោះឯង សូមទ្រង់ជ្រាប ។

ម - កល្លោសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ឆ្លៀវឆ្លាស់ពេកណាស់ វិសជ្ជនាសេចក្តីគួរអោយចូលចិត្តហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបរមរក្សត្រាធិរាជ ស្តេចទ្រង់មានព្រះរាជឱង្ការត្រាស់ចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះករុណាម្ចាស់ដ៏ចំរើន លោកម្ចាស់បានពោលចំពោះនឹងខ្ញុំពីមុននោះថា ទីទីបំផុតខាងដើមនៃកាលនោះ ជួនកាលប្រាកដ ជួនកាលមិនប្រាកដ ចុះដែលប្រាកដនោះដូចម្តេច ដែលមិនប្រាកដនោះដូចម្តេចលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជឯទីបំផុតខាងដើមមិនប្រាកដនោះ បានខាងឯវត្ថុទាំងពួងដែលមិនធ្លាប់មានមកក្នុងកាលមុនអំពីកាលនេះ ហើយវត្ថុនោះក៏មកកើតមានប្រាកដឡើង របស់នេះហើយដែលអាត្មាភាពថ្វាយព្រះពរថា ទីបំផុតខាងដើមមិនប្រាកដនោះឯងម៉្យាងទៀតវត្ថុឯណាដែលធ្លាប់មានហើយ បែរទៅជាកើតឡើងមានឡើងហើយវិនាសបាត់ទៅ វត្ថុនោះហើយដែលអាត្មាភាពថ្វាយព្រះពរថាមានទីបំផុតខាងដើមប្រាកដ សូមមហារាជស្តេចជ្រាប ។

ម - លោកម្ចាស់ពាក្យដែលលោកសំដែងថា វត្ថុមិនធ្លាប់មាន ហើយមានឡើងវត្ថុដែលធ្លាប់មានហើយវិនាសទៅពាក្យទាំងពីរម៉ាត់នេះ បានសេចក្តីដូចម្តេច ។

www.budinst.gov.kh www.elibraryofcambodia.org

ន - បពិត្រសម្តេចមហារាជ ពាក្យទាំងពីរម៉ាត់នោះគង់មានសេចក្តីគួរចូលចិត្តបានទេ មហាបពិត្រ ។

ម - បើដូច្នោះ លោកម្ចាស់អាចនឹងញាំងពាក្យទាំងពីរនោះអោយខ្ញុំចូលចិត្តស្តាប់បាន ឬទេ ។

ន - ថ្វាយព្រះពរ អាត្មាភាពអាចនឹងអធិប្បាយសេចក្តីនេះថ្វាយមហារាជអោយទ្រង់ព្រះសណ្តាប់បាន ឥតមានលំបាកទេ ។

ម - នៃលោកម្ចាស់ ខ្ញុំមិនមែនសួរលោកម្ចាស់តែប៉ុណ្ណោះទេ សូមលោកម្ចាស់ញាំងខ្ញុំអោយដឹងនូវទីបំផុតខាងដើមនោះផង ។

ន - អាត្មាភាពនឹងអាចថ្វាយព្រះពរបាន មិនមានអ្វីទាស់អ្វីទេ

ម - ឧបមំ ករោហិភន្តេ បើដូច្នេះសូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមាបន្តិចមកមើល ។

ន - មហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចពូជឈើដែលមិនទាន់កើត មិនទាន់មាននៅឡើយលុះមានមនុស្សនាំយកពូជមកដាក់ដាំ ហើយក៏កើតជាដើម

www.budinst.gov.kh www.elibraryofcambodia.org

បែកចេញជាសន្ទឹកជាមែកមកខាងក្រោយ សេចក្តីនេះ ហើយដែលថាកាលដើមមិនប្រាកដ ហើយមានប្រាកដឡើង។

ម្យ៉ាងទៀតដែលថា វត្ថុដែលមានហើយ ៗ វិនាសទៅវិញនោះ បានខាងឯពូជឈើដែលតែងមានតាមរដូវ លុះអស់រដូវ ឬ ផុតរដូវហើយ ឈើនោះក៏សាបសូន្យបាត់បង់ទៅ សេចក្តីនេះហើយដែលហៅថាទីបំផុតខាងដើមនោះ ប្រាកដដូច្នេះ សូមមហារាជស្តេចជ្រាប ។

ម ـ កល្លោសិភន្តេ លោកម្ចាស់ឆ្លៀវឆ្លាស់ក្នុងវិធីវិសជ្ជនាស្រួលណាស់ ខ្ញុំចូលចិត្តអស់សង្ស័យ ។

សំខារជាយនបញ្ហា ៧ ពី ៤

ព្រះបាទមិលិន្ទ្រាធិបតិ ស្តេចទ្រង់ត្រាស់បុច្ឆាទៅព្រះនាគសេនថេរថា បពិត្រព្រះថេរដ៏ចំរើន សំខារធមិទាំងឡាយនិមួយដែលមាននៅហើយតែងកើតត ៗ ទៅឬដូចម្តេច ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ សំខារធមិទាំងឡាយនិមួយដែលមាននៅហើយ ក៏តែងកើតត ៗ ទៅមិនខាន សូមទ្រង់ជ្រាប ។

ម ـ កតមេភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចុះសំខារ

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ទាំងឡាយដែលមាននៅហើយ តែងកើតព។ ទៅនោះ តើដូចម្ដេច ។

ន-ចក្ខុស្មឹ មហារាជ សតិ រូបេ សតិ ចក្ខុវិញ្ញាណំ ហោតិ បពិត្រសម្ដេចមហារាជ ឯសំខារធម៌ដែលមាននៅហើយ ហើយបង្កើតព ។ ទៅទៀតនោះ មានសេចក្ដីអធិប្បាយថា ដូច្នេះនាកាលចក្ខុបសាទ នឹងរូបារម្មណ៍មានហើយ ។ បានមកជួបប្រទះផ្ទប់គ្នាជាហេតុដំបូងឡើង ចក្ខុវិញ្ញាណក៏នឹងកើតឡើងជាផលនៃហេតុទាំងពីរ ដែលប៉ះពាល់គ្នានោះមិនខាន ព្រោះចក្ខុវិញ្ញាណកើតឡើងហើយ ចក្ខុសម្ផស្សក៏នឹងកើតឡើងព្រមផងព្រោះចក្ខុសម្ផស្សកើតឡើងហើយ វេទនាសម្ផស្សក៏កើតឡើងផង វេទនាកើតឡើងហើយ តណ្ហាក៏កើតឡើងដែរ តណ្ហាកើតឡើងហើយ ឧបាទានក៏កើតឡើងដែរ ឧបាទានកើតឡើងហើយ ភពក៏កើតឡើងដែរ ភពកើតឡើងហើយ ជាតិក៏កើតឡើងដែរ ព្រោះជាតិកើតឡើងហើយ ជរា មរណ សោកបរិទេវ ទុក្ខ នឹង ទោមនស្ស នឹងឧបាយាសក៏កើតឡើងព្រមផង កិរិយាប្រជុំនៃគំនរទុក្ខទាំងអស់ ក៏កើតឡើងមានឡើងពពអាក់ ។ ម្យ៉ាងទៀតថា តើសោតបសាទ នឹង សទ្ទារម្មណ៍មាននៅហើយ ក៏ជាហេតុនឹងអោយកើតសោតវិញ្ញាណជាផលមិនខាន បើសោតវិញ្ញាណជាផលកើតហើយ សោតសម្ផស្សវេទនា តណ្ហា ឧបាទាន ភព ជាតិ ជរា មរណ សោក

www.budinst.gov.kh www.elibraryofcambodia.org

បរិទេវទុក្ខទោមនស្ស នឹងឧបាយាសក៏កើតឡើងព្រមផង លុះអង្គនៃធម៌ទាំង ១២ ប្រការនោះកើតឡើងទើបគំនរនៃសេចក្តីទុក្ខភ័យទាំងអស់ក៏ប្រជុំគ្នាកើតឡើងព្រមផង ។ ឯន័យក្នុងឃានបសាទ នឹងជិវ្ហាបសាទ នឹងកាយបសាទ ក៏ដូចគ្នានឹងន័យក្នុងចក្ខុបសាទដែរ មិនបាច់អធិប្បាយឡើយ នឹងអធិប្បាយតែក្នុងមនោទ្វារដែលជាទ្វារខាងចុងបង្អស់នោះ ជាសេចក្តីថា កាលបើមនោបសាទ នឹង ធម្មារម្មណ៍មាននៅហើយ ក៏ជាហេតុនឹងអោយកើតជាផល គឺមនោវិញ្ញាណមិនខានលុះមនោវិញ្ញាណមានហើយ មនោសម្ផស្សក៏មានឡើង មនោសម្ផស្សមានហើយវេទនាក៏មានឡើង វេទនាមានហើយ តណ្ហាក៏មានឡើង តណ្ហាមានហើយ ឧបាទានក៏មានឡើង ឧបាទានមានហើយភពក៏មានឡើងភពមានហើយជាតិក៏មានឡើង ជាតិមានហើយជរា មរណៈ សោក បរិទេវ ទុក្ខទោមនស្ស នឹងឧបាយាសក៏មានឡើង លុះតែធម៌ទាំង ១២ ប្រការ ជាអង្គនៃបដិច្ចសមុប្បាទធម៌កើតឡើងហើយ ពួកធម៌ជាទុក្ខ ជាទោស ឬជាសត្រូវ ក៏មកប្រជុំគ្នាកើតឡើងគ្រប់ប្រការឥតមានខ្វះឡើយ ។

មហារាជ បពិត្រសម្តេចមហារាជ ម៉្យាងវិញទៀតថា បើ

www.budinst.gov.kh www.elibraryofcambodia.org

ចក្ខុបសាទ នឹងរូបារម្មណ៍មិនមាននៅជាហេតុទេ ចក្ខុវិញ្ញាណដែលជាផល ក៏មិនមានកើតឡើង បើចក្ខុវិញ្ញាណមិនមានហើយ ចក្ខុសម្ផស្សក៏មិនមានដែរ ចក្ខុសម្ផស្សមិនមានហើយវេទនាក៏មិនមាន វេទនាមិនមានហើយ តណ្ហាក៏មិនមាន តណ្ហាមិនមានហើយ ឧបាទានក៏មិនមាន ឧបាទានមិនមានហើយ ភពក៏មិនមាន ភពមិនមានហើយ ជាតិក៏មិនមាន ជាតិមិនមានហើយ ជរា មរណៈ សោក បរិទេវ ទុក្ខ ទោមនស្ស នឹងឧបាយាសក៏មិនមានដែរ ។ ហេតុធម៌ទាំង ១២ ប្រការនេះមិនមានហើយ ទើបសេចក្ដីទុក្ខ នឹងអបវត្តទាំងពួងក៏ការលោបច្បួស្សទៅទាំងអស់ តទោរងសេទ្រឡើយ ។ បពិត្រព្រះបរមក្សត្រអង្គប្រសើរដ៏ប្រសើរ ក៏តាំងអាអធម៌នោះជាធម៌មានកំលាំងអានុភាពពេកពេកាស់ ព្រោះថាជាអ្នកមិនប្រសប់ចេះធ្មេញ ចេះលែលករភាយកើតធម៌ទាំងពួងបានផងហើយអាចចេះទំនុកបំរុងខ្លួនឯង អោយកើត អោយមានផង សេចក្ដីដូចអាត្មាភាពពណ៌នាថ្វាយសេចក្ដីមកនេះ សូមមហាបពិត្រ ស្តេចទ្រង់ជ្រាប ។

ម - កណ្ឌោសិរត្ថេ បពិត្រលោកម្ចាស់ដ៏ចំរើន អង្គលោកម្ចាស់នេះ ច្បាស់ជាអ្នកប្រាជ្ញឆ្លៀវឆ្លាស់ ប្រសើរពេក

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ ហើយចេះអធិប្បាយធម៌ដែលចង្អៀត បែរទៅជាទូលាយអោយងាយចូលចិត្តបាន ។

ភវន្តានំសំខារានំជាយនបញ្ហា ១ បី ៥

ព្រះបាទមិលិន្ទ្រាធិបតិ ស្តេចទ្រង់ត្រាស់បុច្ឆាទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៥ ថា បពិត្រព្រះថេរដ៏ចំរើន វិសំខារធម៌ទាំងឡាយខ្លះ ដែលមិនធ្លាប់មាននឹងកើតឡើងដែរ ឬមិនមានទេលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារៈឯសំខារធម៌ខ្លះដែលមិនមានហើយ នឹងកើតមានឡើងគង់មាន ប្រៀបដូចជាព្រះរាជស្ថាន បើព្រះរាជស្ថានមិនមានហើយ អហោបពិត្រស្តេចនឹងទៅស្ថិតនៅក្នុងទីដូចម្តេចបានឬទេ ។

ម - នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន បើព្រះរាជស្ថានះមិនមាន ខ្ញុំនឹងរកបើនៅនោះមិនបានឡើយ ។

ន - អាត្មាភាព សូមថ្វាយព្រះពរទៀតថា ធម្មតាឈើតែងកើតនៅក្នុងព្រៃ ដីតែងកើតនៅក្នុងប្រថពី ផ្ទះដែលនឹងកើតឡើង ព្រោះកំលាំងព្យាយាមរបស់មនុស្សប្រុសស្រីទាំងឡាយទៅជញ្ជូនយកដីបករពីទីដទៃ មកពូនទីមួយអោយខ្ពស់ ជាភ្នំពីផែនដីឡើង ទៅនាំឈើពីក្នុងព្រៃមករចនាចាក់ចែង

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើជាសសរផ្ទោង ផ្ទាន ប្រកង់ ដែរណែងរហូតចុះមកជញ្ជាំងក្តាក្រាល គ្រប់គ្រឿងប្រុងទាំងអស់ជាស្រេច កើតបានជានិ-វេសនស្ថានឡើងនេះឯង ជានិវេសនស្ថានដែលមិនមានហើយមានឡើង ដោយការចាត់ចែងរបស់មនុស្សនោះ មានឧបមាយ៉ាងណា បពិត្រមហារាជក៏សំខារធម៌ទាំងឡាយខ្លះដែលមិនធ្លាប់មានហើយមានឡើងនោះ ក៏ដូចគ្នានឹងនិវេសនស្ថានដែលមិនមានហើយ មានឡើងដោយកំលាំងមនុស្សចាត់ចែង សូមទ្រង់ជ្រាប ។

ម - សូមលោកម្ចាស់ឧបមាតទៅទៀតមើល ។

ន - បពិត្រសម្តេចមហារាជ សេចក្តីនេះប្រៀបដូចពូជឈើបន្តិចបន្តួច ដែលមិនធ្លាប់មាន ហើយកើតមានឡើងលើផែនដី រាចចំរើនដើម ស្លឹក ផ្កា នឹង ផ្លែ ៗ ទៅ បពិត្រមហារាជ បើយ៉ាងនឹងបានឈ្មោះថា ជាដើមឈើមាន ឬ គ្មានទេមហាបពិត្រ ។

ម - ភន្តេនាគសេន បពិត្រលោកម្ចាស់ដ៏ចំរើន បើឈើទាំងនោះកើតហើយ ឈ្មោះថា ជាដើមឈើមានលោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - ឯរមេរខោមហារាជ បពិត្រព្រះរាជសម្ភារឯ សំខារធម៌ទាំងឡាយខ្លះដែលមិនធ្លាប់មាន ហើយកើតមានឡើងនោះក៏មានឧបមេយ្យដូចដើមឈើនោះឯង សូមទ្រង់ជ្រាប ។

ម - សូមលោកម្ចាស់ ឧបមាអោយច្រើនតទៅទៀតមើល ។

ន - បពិត្រសម្តេចមហារាជ ជាងដែកធ្វើឆ្នាំង ឬ ស្មូនឆ្នាំង កាលដែលនឹងធ្វើអោយកើតជាភាជន៍ទាំងឡាយម៉ានឆ្នាំជាដើមនោះ ស្មូនឆ្នាំងបានទៅជីកយកដីអំពីផែនដីមកចរនាធ្វើជាភាជន៍ផ្សេង ៗ បានកើតឡើងតាមសេចក្តីប្រាថ្នា ឯភាជន៍ទាំងនេះ កាលដើមមិនមានទេ លុះស្មូនឆ្នាំងបានចាត់ចែងធ្វើរួចហើយក៏ជាភាជន៍មានឡើងប្រាកដ សេចក្តីនេះបានឧបមាយ៉ាងណា បពិត្រសម្តេចមហារាជ ក៏សំខារធម៌ខ្លះដែលមិនទាន់មានហើយកើតឡើងមានឡើងក៏មានឧបមេយ្យដូចភាជន៍នោះឯង សូមទ្រង់ជ្រាប ។

ម - សូមលោកម្ចាស់ឧបមាតទៅទៀតមើល ។

ន - បពិត្រសម្តេចមហារាជ គ្រឿងភ្លេងម្យ៉ាងហៅថាចាប៉ី, ចាប៉ីកាលដែលមិនមានក្រាញ មិនមានស្បែកពាស មិន

www.budinst.gov.kh www.elibraryofcambodia.org

បានស្នូក មិនមានជង មិនមានខ្លង់ មិនមានខ្សែ មិនមានព្រ-នួត ទាំងបុរសដែលជាអ្នកដេញចាប៉ីនោះសោត ក៏មិនមានដែរ ចុះសំឡេងរបស់ចាប៉ីនោះនឹងអាចលាន់ឮដែរឬ ។ មិនមានឮទេ មហាបពិត្រ ។

ម - នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចាប៉ី(១) បើមិនមានគ្រឿងគ្រប់ប្រដាប់យ៉ាងនោះហើយ និងមានសំឡេងមកពីទីណាលោកម្ចាស់មិនមានទេ ។

ន - បពិត្រមហារាជ ចុះចាប៉ីនោះបានគ្រឿងប្រដាប់គ្រប់មុខ គឺថាក្រាញចាប៉ីនោះក៏មាន ស្បែកពោសចាប៉ីក៏មាន ស្នូកក៏មាន ដងក៏មានព្រមទាំងខ្លង់នឹងខ្សែ នឹងព្រនួត ហើយថែមទាំងមានមនុស្សដេញផង ចុះឯសំឡេងចាប៉ីនោះនឹងអាចលាន់ឮបានឬទេ បពិត្រមហាបពិត្រ ។

ម - អាមភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចាប៉ីបើប្រកបព្រមយ៉ាងនោះហើយ សំឡេងក៏នឹងលាន់ឮចេញមកប្រាកដមិនខាន ។

ន - ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ ឯសំ-

(១) ប្លះហៅថា (ពេរីពុ)

www.budinst.gov.kh www.elibraryofcambodia.org

ហរធម៌ ចំពូកខ្លះដែលមិនមានហើយបែរទៅជាកើតមានឡើងក៏មានឧបមេយ្យដូចសំឡេងចាប៉ីនេះឯង សូមទ្រង់ជ្រាប ។

ម - សូមលោកម្ចាស់ប្រៀបឧបមាអោយច្រើន ហើយអោយផ្សេង ប្លែកគ្នាទៅទៀតមើល ។

ន - បពិត្រព្រះមហាក្សត្រដ៏ប្រសើរ សេចក្តីនេះប្រៀបដូចភ្លើងដែលអាស្រ័យនឹងពំនូត កាលបើមេពំនូតមិនមានកូនពំនូត ក៏មិនមាន ទាំងខ្សែសម្រាប់ចងពំនូត នឹងច្បូស់សម្រាប់បោះគាបពំនូត នឹងប៉ុយសម្រាប់ដាក់អោយភ្លើងឆេះ ក៏ពុំមានទាំងមនុស្សដែលជាអ្នកព្យាយាមពួតនោះសោត ក៏ពុំមានចុះភ្លើងនឹងអាចកើតឡើងបាន ឬពុំបានទេ មហាបពិត្រ ។

ម - ភ្លើងដែលនឹងអាចកើតឡើង ព្រោះអាស្រ័យនឹងកំដៅ ១ កើតឡើង ព្រោះអាស្រ័យនឹងមានគេពួត ឬសង្កតគ្នាអ្នកពួតនោះទៀត អាស្រ័យនឹងគ្រឿងពួតបើប្រដាប់សម្រាប់ពួតគ្មានហើយភ្លើងនឹងអាចមានមកពីទីណាលោកម្ចាស់គ្មានទេ ។

ន - បពិត្រព្រះរមក្សត្រដ៏ប្រសើរ ហេតុយ៉ាងនោះថា ពុំមានហើយ ចុះបើប្រដាប់សម្រាប់ពួតក៏មានព្រមផង ចំណែក

www.budinst.gov.kh www.elibraryofcambodia.org

ភ្លើងនឹងគប្បីកើត ឬពុំកើតទេមហាបពិត្រ ។

ម - បពិត្រលោកម្ចាស់ដ៏ចំរើន ភ្លើងបើបានគ្រឿងប្រដាប់គ្រប់ប្រុងយ៉ាងនេះហើយ ត្រូវតែកើតពិតៗទេលោកម្ចាស់ ។

ន - ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ ក៏សំខារធម៌ខ្លះដែលមិនធ្លាប់មានពីមុនមកហើយ ត្រឡប់ជាកើតឡើងមានឡើងនោះ ក៏មានសេចក្តីឧបមានុបមេយ្យ ដូចជាភ្លើងនោះឯងសូមទ្រង់ជ្រាប ។

ម - សូមព្រះថេរម្ចាស់ប្រៀបសេចក្តី ១ ទៀត អោយប្លែកពីនេះទៅមើល ។

ន - បពិត្រមហារាជ សេចក្តីនេះប្រៀបដូចភ្លើងដែលកើតអំពីកែវឆ្លុះបើកែវសម្រាប់ឆ្លុះ ពុំបានក៏ដៅព្រះអាទិត្យពុំមានទាំងគោម័យ ឬប៉ុយនោះសោត ក៏ពុំមានចំណែកខាងភ្លើងនឹងអាចកើតបាន ឬមិនអាចកើតបានទេ បពិត្រ ។

ម - មិនអាចកើតបានទេ លោកម្ចាស់ ។

ន - បពិត្រមហារាជ ភ្លើងដែលពុំមានឡើង ព្រោះគ្មានគ្រឿងប្រុងគ្រប់ប្រដាប់ ចុះបើប្រដាប់សព្រាប់អោយកើត

www.budinst.gov.kh www.elibraryofcambodia.org

ភ្លើងនោះមាន ៗ កែវជាដើមគ្រប់ប្រការទាំងអស់ ភ្លើងនឹងរាចកើតបាន ឬពុំបាន ។

ប . បើបានគ្រឿងប្រុងព្រប់ប្រដាប់ហើយ ភ្លើងមុខជានឹងកើតមិនខានទេលោកម្ចាស់ ។

ន . ឯរមេរខោមហារាជ បពិត្រមហារាជ ឯសំខារធមិពួកខ្លះដែលមិនធ្លាប់មាន ហើយត្រឡប់ជាកើតមានឡើងនោះក៏អោនសេចក្ដីប្រៀបដូចជាភ្លើង ដែលអាស្រ័យនូវគ្រឿងប្រុងមានកែវជាដើមនោះសូមទ្រង់ជ្រាប ។

ម . ចុះមានសេចក្ដីប្រៀបដូចម្ដេចទៀត អោយប្លែកពីនោះទៅ ឬទេ លោកម្ចាស់ ។

ន . មានទៀតមហាបពិត្រ សេចក្ដីនេះប្រៀបដូចស្រមោលមុខដែលកើតពីកញ្ចក់ បើកញ្ចក់ពុំមានពន្លឺ ក៏ពុំមានមុខមនុស្សសោតក៏ពុំមានដែរ ចុះចំណែកឯស្រមោលមនុស្សនោះនឹងអាចមានដែរ ឬគ្មានទេ មហាបពិត្រ ។

ម . គ្មានទេលោកម្ចាស់ ។

ន . ចុះបើកញ្ចក់ក៏មាន ពន្លឺក៏មាន មុខមនុស្សប្រុងឆ្លុះក៏មាន ឯស្រមោលរបស់មនុស្សនោះ តើនឹងអាចកើតមាន ឬ

www.budinst.gov.kh www.elibraryofcambodia.org

មិនមានទេ មហាបពិត្រ ។

ម - បពិត្រលោកម្ចាស់ដ៏ចំរើន បើគ្រឿងសម្រាប់ឆ្លុះមានព្រមគ្រប់យ៉ាង ៗ នោះហើយស្រមោលក៏ត្រូវតែមានមិនខានទេ ។

ន - ឯវេទវេះអាចប្រាកដ បពិត្របរមរាជឯសំរេះអារធរីរ្លះ ដែលមិនធ្លាប់មាន ហើយត្រូវប្រជាកោនបានឃើញនោះ ក៏ព្រោះអាស្រ័យនឹងបដិច្ចសមុប្បាទធម៌ ហេតុបច្ច័យដូចជាស្រមោលដែលអាស្រ័យនឹងកញ្ចក់នោះឯង សូមទ្រង់ជ្រាប ។

ម - កល្លោសិ ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើនព្រះករុណាពេញបរិបូណ៌ជាអ្នកប្រាជ្ញ អាចវិសជ្ជនាប្រស្នាយ៉ាងក្រ ៗ បានណាស់ ហើយព្រោះលោកម្ចាស់ប៉ិនប្រសប់ក្នុងការប្រៀបធៀបអោយចូលចិត្តបានដោយងាយ ៗ ។

វេទគូបញ្ហា ១ ធ ៦

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់ត្រាស់បុច្ឆា ចំពោះនឹងព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏ចំរើន សភាវដូចម្តេចដែលហៅថាវេទគូ ដែលប្រែថាដល់នូវត្រើយនៃវេទនោះ លោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនាគសេនថេរថ្វាយព្រះពរថា ចុះចំណែកមហា-
បពិត្រ ស្តេចយល់ថាដូចម្តេចទៅវេទគូនោះ ។

ម : បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំបានគិតសង្កេតមើល
ទៅឃើញថា បណ្តាសត្វដែលមានជីវិតអាស្រ័យនៅក្នុងខាង
ក្នុងរាងកាយនេះ តែងឃើញនូវរូប ដោយចក្ខុ ឮនូវសំឡេង
ដោយសោត ធុំនូវក្លិនដោយឃាន ភ្លក់នូវរសដោយជិវ្ហា
ពាល់ត្រូវនូវផោដ្ឋព្វ ដោយកាយដឹងនូវធម៌ដោយចិត្តយ៉ាងនេះ
ឯងហៅថាវេទគូ ។ ម្យ៉ាងទៀត ខ្ញុំនឹងប្រៀបជាសេចក្តីបង្អិច
ព្រះពរលោកម្ចាស់ ដូចជាយើងរាល់គ្នាដែលអង្គុយនៅក្នុង
ប្រាង្គលើប្រាសាទនោះថា បើមានប្រាថ្នានឹងមើលតាម
បង្អួចណា ៗ ក៏នឹងបើកនូវបង្អួចនោះ ៗ ហើយមើលទៅបើ
ត្រូវការដោយបង្អួចខាងជើង ក៏បើកនូវបង្អួចទិសខាងជើង
ហើយមើលបើត្រូវកិច្ចដោយបង្អួចខាងត្បូង ក៏បើកនូវបង្អួច
ទិសខាងត្បូងហើយមើល បើប្រាថ្នាដោយបង្អួចខាងកើត
ក៏បើកនូវបង្អួចទិសខាងកើតហើយមើល បើប្រាថ្នាដោយ
បង្អួចខាងលិច ក៏បើកនូវបង្អួចទិសខាងលិចហើយមើល ទៅ
តាមប្រាថ្នា ។ បពិត្រលោកម្ចាស់ដ៏ចំរើន ម្យ៉ាងទៀតឯសត្វ
ដែលមានជីវិតខាងក្នុងកាយនោះ បើមានប្រាថ្នានឹងមើលតាម

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវគឺទ្វារទាំង ៦ ទ្វារណាមួយក៏បើកនូវទ្វារនោះៗ ហើយមើល ទៅតាមប្រាថ្នា ក៏នឹងឃើញនូវរូបដោយភ្នែក នឹងឮសំឡេង ដោយត្រចៀក នឹងធុំក្លិនដោយច្រមុះ នឹងភ្លក់រសអាហារ ដោយអណ្តាត នឹងពាល់ត្រូវនូវផោដ្ឋព្វដោយកាយ នឹងដឹង នូវធម៌ដោយចិត្តបានយ៉ាងនេះឬអ្វី ដែលហៅថា វេទគូនោះ លោកម្ចាស់ ។

៨ - បពិត្រមហារាជ សេចក្តីដែលគ្រប់ពាក្យដែលពោលមកនោះ ក៏លើកទុកសិនចុះ អាត្មាភាពនឹងប្រៀបសេចក្តីឲ្យវៀងទៀត ថ្វាយមហាបពិត្រអោយត្រូវិសេសជាងនេះទៀតថា ដូច យើងទាំងរស់គ្នា ដែលអង្គុយនៅក្នុងទីប្រាង្គប្រាសាទនេះ ហើយមានប្រាថ្នានឹងមើលតាមបង្អួចឯណាៗ ក៏ត្រូវបើកនូវ បង្អួចនោះៗ ហើយមើលតាមប្រាថ្នា បើនឹងចង់ឃើញរូប ដោយបង្អួចខាងកើត ឬខាងលិច ខាងជើង ឬខាងត្បូងក៏គប្បី មើលតាមបង្អួចនោះៗ បាន បពិត្រមហារាជ សេចក្តីនេះមាន ឧបមាយ៉ាងណាថា មានឧបមេយ្យដូចជាសត្វដែលមានជីវិត ស្ថិតនៅក្នុងខាងក្នុងនៃកាយនេះ គប្បីឃើញនូវរូបដោយ ចក្ខុឃើញនូវរូប ដោយសោតឃើញនូវរូបដោយឃាន ឃើញ នូវរូបដោយជិវ្ហា ឃើញនូវរូបដោយកាយ ឃើញនូវរូបដោយ

www.budinst.gov.kh www.elibraryofcambodia.org

ចិត្ត ។ ម្យ៉ាងទៀតថា សំឡេងគេគប្បីស្តាប់ដោយចក្ខុគេគប្បីស្តាប់ដោយសោត គេគប្បីស្តាប់ដោយឃាន គេគប្បីស្តាប់ដោយជិវ្ហា គេគប្បីស្តាប់ដោយកាយ គេគប្បីស្តាប់ដោយចិត្ត ឬថាក្លិន គេគប្បីហិតដោយចក្ខុ គេគប្បីហិតដោយសោត គេគប្បីហិតដោយឃាន គេគប្បីហិតដោយជិវ្ហា គេគប្បីហិតដោយកាយ គេគប្បីហិតដោយចិត្ត ឬថា រសារម្មណ៍ក្តី ផោដ្ឋព្វារម្មណ៍ក្តី ធម្មារម្មណ៍ក្តី គេគប្បីភ្លក់ក្តី គេគប្បីពាល់ត្រូវក្តីគប្បីដឹងក្តីដោយចក្ខុ ដោយសោត ដោយឃាន, ដោយជិវ្ហា, ដោយកាយ, ដោយចិត្ត ។ បពិត្រមហារាជ សេចក្តីនេះ អាត្មាភាពប្រៀបតាមព្រះរាជឱង្ការ ដែលមហាបពិត្រស្តេចពណ៌នាមកថាសភាវដែលមានជីវិតស្ថិតនៅក្នុងខាងក្នុងនៃកាយ បើមានប្រាថ្នា នឹងមើលតាមទ្វារណា ១ ក៏គប្បីបើកនៅទ្វារនោះ ១ ហើយមើលទៅនឹងបានឃើញនូវរូបដោយភ្នែក បានឮនូវសំឡេងដោយត្រចៀកបានធុំក្លិនដោយច្រមុះ បានភ្លក់រសដោយអណ្តាត បានពាល់ត្រូវនូវផោដ្ឋព្វដោយកាយ បានដឹងនូវធម៌ដោយចិត្តចំពោះតែត្រង់ទ្វារមួយនោះឯង ឬ អ្វីមហាបពិត្រ ។

ម - នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែន

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូច្រោះទេ ។

ឆ - នខោពេមហារាជ បពិត្របើផ្លូច្រោះ ព្រះអង្គទ្រង់ប្រៀបនោះមិនសមគួរទេឬថា ចន្លោះបង្អួចដែលបើកទុកនោះគេនឹងមើលបានចំពោះតែរូបម្យ៉ាង បើនឹងស្ដាប់សំ-ឡេង ឬស្រូបក្លិន ឬទទួលរសរាពការជាដើមនោះ បាននឹងដោយចន្លោះបង្អួច ដែលបើកទុកនោះមិនសមគួរទេ ព្រោះថាដូចយើងទាំងឡាយ ដែលអង្គុយនៅក្នុងប្រាង្គណ៍ប្រាសាទមានប្រហោងបង្អួចបើកទុកជាប្រក្រតីទិសទាំង ៤ គឺទិសខាងជើង, ទិសខាងត្បូង, ទិសខាងកើត, ទិសខាងលិច បើយើងបែរមុខចេញទៅខាងក្រៅតាមចន្លោះបង្អួច ក៏នឹងឃើញនូវរូបដោយចក្ខុទ្វារយ៉ាងណា តត្វជីវក៏ជាជីវិតនៅខាងក្នុងកាយក៏នឹងឃើញរូបទាំងឡាយដោយចក្ខុទ្វារ ដូចជាយើងឃើញរូបតាមបង្អួច ដែលបើកទុកនោះ បើប្រសិនលោកជាបើកនូវត្រចៀក, នឹងច្រមោះ, នឹងអណ្ដាត, នឹងកាយ, នឹងចិត្ត ក៏ឃើញរូបទាំងឡាយដោយទ្វារនោះ ៦ ដូចជាយើងអង្គុយក្នុងទីនោះហើយ បែរមុខចេញទៅក្រៅឃើញនូវរូបតាមបង្អួចនោះឬទេ មហាបពិត្រ ។

ម - ព្រះរាជាថា មិនមែនដូច្នេះទេលោកម្ចាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ឆ . បពិត្រមហារាជ សេចក្ដីដែលមហាបពិត្រស្ដេចមានព្រះរាជឱង្ការប្រៀបធៀបមកនោះ មិនសមគួរទេ ឯទ្វារទាំង ៦ ប្រការ ដែលមាននៅក្នុងខ្លួនយើងនោះ នឹងលើកយកទៅប្រៀបនឹងប្រហោងបង្អួចនោះមិនគួរទេអាត្មាភាពនឹងប្រៀបសេចក្ដី ១ ទៀត ថ្វាយព្រះរាជសម្ភារថា ដូចមហាបពិត្រស្ដេចទ្រង់ស្ថិតនៅលើព្រះទីនាំង នៅទៀបក្លោងទ្វារប្រាសាទហើយទ្រង់រាជទានរបស់ព្រះរាជទ្រព្យ អោយដល់ស្មូមដែលបានមកទទួលព្រះរាជទាននោះពីរនាក់ ម្នាក់មកពីទិសខាងលិចលុះបានទទួលព្រះរាជទានហើយ ក៏ដើរចេញទៅទិសខាងកើតម្នាក់ទៀតមកពីទិសខាងកើត លុះទទួលព្រះរាជទានហើយក៏ដើរចេញទៅតាមទិសខាងលិច កាលដែលយាចកទាំង ២ អំពីទិសនេះដើរចេញ ១ ទៅទិសនោះវិញ ចំណែកមហាបពិត្រដែលស្ថិតនៅ ១ ត្រង់ទីទៀបក្លោងទ្វារនោះ ទ្រង់នឹងបានទតឃើញនូវយាចកទាំងនោះដែរឬ ដូចម្ដេច ព្រះ-រាជសម្ភារ ។

ម . បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំនឹងបានឃើញនូវយាចកទាំងពីររូបនោះ មិនខានទេលោកម្ចាស់ ។

ន . បពិត្រមហារាជ ម៉្យាងទៀតថា បើយាចកដែលមហាបពិត្រ ទ្រង់ព្រះរាជទានព្រះរាជទ្រព្យអោយទៅនោះ

www.budinst.gov.kh www.elibraryofcambodia.org

បុរសនោះមិនបាននាំចេញទៅខាងក្រៅឡើយ គឺឈរនៅ។ ទី មុខព្រះទីនាំងនោះ ពើមហាបពិត្រ នឹង ជ្រាបថា យាចកនេះ អញបានអោយទានហើយ។ អង្គុយនៅ។ ទើនេះឬដូចម្តេច ។

ម - ករុណាខ្ញុំមុខជានឹងដឹងយ៉ាងនឹងលោកម្ចាស់ ។

ន - បពិត្រមហារាជដ៏ប្រសើរ ពាក្យដែលថាយាចកមក អំពីទិសខាងកើត ទិសខាងលិច បកចូលព្រះរាជទារ ហើយ អង្គុយនៅក្តី ចេញទៅតាមទិសខាងកើត ខាងលិចក្តី មហា បពិត្រស្តេចទ្រង់ជ្រាបទាំងអស់ ហើយសេចក្តីនេះ មានឧប-មាយ៉ាងណាមិញថា សត្វមានជីវិតដែលនៅក្នុងកាយនេះកាល នឹងទទួលរសៈអាហារទាំងឡាយដោយជីវ្ហា សត្វទាំងឡាយ នោះក៏បានដឹងរសអាហារនោះថា អាហារនេះមានរសជូរ ឬ ប្រៃ, ល្វីង. ហិល. ចត់ ឬផ្អែមក្តី ក៏កិច្ចដែលនឹងដឹងនូវរស ទាំងនេះពៃអណ្តាតម្យ៉ាងនោះឯង ដូចគ្នានឹងមហាបពិត្រដែល ទ្រង់ស្ថិតនៅ។ ទីទៀបក្លោងទ្វារមហាប្រាសាទ ទ្រង់បាន ឃើញនូវយាចកកាលចូល នឹងចេញ នឹងអង្គុយនៅយ៉ាងនេះ ឬអ្វីមហាបពិត្រ ។

ម - ករុណាលោកម្ចាស់យ៉ាងនឹងហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ន - សូមថ្វាយព្រះពរថា បើរសអាហារនោះមិនបានចូលទៅដល់ចុងអណ្តាត ចុះសត្វដែលមានជីវិតនៅក្នុងកាយនោះនឹងអាចដឹងថារសអាហារនេះ ជូរ ឬប្រៃ, ល្វីង, ហិល, ចត់ឬផ្អែមដូច្នេះបានឬទេ ។

ម - មិនអាចដឹងទេលោកម្ចាស់ ។

ន - បពិត្រសម្តេចមហារាជ ក៏ព្រះរាជឱង្ការ ដែលទ្រង់ត្រាស់ទុកមកជាសេចក្តីឧបមេយ្យខាងដើមនោះ ក៏ខុសទៅបទេរស់ហើយ ជាពាក្យមិនសមគួរដល់ឧប្រស្នានេះឡើយ ។ ម្យ៉ាងទៀត អាត្មាភាពនិងប្រៀបជាសេចក្តីឧបមា១ ថ្វាយព្រះរាជសម្ភារដូចជាបុរសនិម្មួយ នាំយកនូវទឹកឃ្មុំមកចាក់បំពេញទុកនៅក្នុងស្នូក ឬអាងដ៏ធំ ហើយបុរសម្នាក់ចុះទៅដេកត្រាំក្នុងទឹកឃ្មុំនោះ តែបុរសដែលនឹងដេកត្រាំនោះ បិតមាត់ជិតមិនអោយទឹកឃ្មុំនោះចូលទៅបាន ចុះបុរសនោះនឹងអាចថារសទឹកឃ្មុំនោះផ្អែមយ៉ាងនេះ ៗ ដែរឬ ៗ មិនអាចនិងដឹងបានទេ ។

ម - បពិត្រលោកម្ចាស់ដ៏ចំរើន បើជីវ្ហាមិនបានពាល់ត្រូវជាតិទឹកឃ្មុំនោះសោះទេ នឹងអាចដឹងដូចម្តេចបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ន - ថ្វាយព្រះពរ រឿងនេះមានសេចក្ដីវិសេសទៅយ៉ាងណា ក៏ប្រស្នាដែលមហាបពិត្រប្រៀបធៀប ព្រោះជាបង្អួចក្នុងមហាប្រាសាទដែលបើកបំរុងទុកគ្រប់ទិសទាំង ៤ នោះ នាំយកមកប្រៀបធ្មានិងទ្វារទាំង ៦ ប្រការ ដែលមាននៅក្នុងខ្លួនសព្វរាល់គ្នាមិនសមគួរទេ ឯសេចក្ដីនៃទ្វារទាំង ៦ ប្រការនោះ មិនគួរនឹងយកមកធៀបជាមួយនោះឡើយ សូមទេវបក បពិត្រព្រះស្ដេចជ្រាប ។

ប - នាយរាភទេវបណ្ឌិតទើបថា បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាមិនបានប្រដិតពាក្យនេះទៀតទេ ពិសេសគឺនឹងចរចាជជែកជាមួយនឹងលោកម្ចាស់បានឡើយ សូមនិមន្តលោកម្ចាស់វិសជ្ជនាសេចក្ដីនេះអោយខ្ញុំបានធូរចិត្ត ជាការសាយផងមើល ។

ថេរោអភិធម្មសំយុត្តាយ កថាយ រាជានំ មិលិន្ទំ សញ្ញាបេសិ ចំណែកព្រះនាគសេនថេរ ក៏ធ្វើអោយព្រះបាទមិលិន្ទរាជ ស្ដេចសព្វព្រះរាជហឫទ័យបាន ដោយពាក្យពោលប្រកបដោយព្រះអភិធម្មកថា ថា មហារាជ បពិត្រសម្ដេចព្រះបរបក្សព្រះខត្តិយវង្ស សូមទ្រង់ព្រះរាជសណ្ដាប់ព្រាប់ព្រេងរងយកនូវសេចក្ដីនេះ អោយពេញព្រះរាជហឫទ័យចុះ ឯព្រះ

www.budinst.gov.kh www.elibraryofcambodia.org

រាជឱង្ការដែលព្រះអង្គទ្រង់ត្រាសខាងដើមថា ចក្ខុបានឃើញរូបរាចដឹងថារូបដូច្នោះបានជាដើមនោះ ព្រះរាជឱង្ការនេះមិនសមគួរដល់ពុទ្ធភាសិតឡើយ ឯចក្ខុនោះមិនមែនឃើញរូបហើយដឹងថា «រូបនោះ» ដោយទំនើងខ្លួនឯងបានទេ។ ចក្ខុនេះគ្រាន់តែជានាក់អាស្រ័យនូវរូបជាមុនទេតើ ហើយកើតចក្ខុវិញ្ញាណឡើងទើបដឹងថា វត្ថុនេះវត្ថុនោះដូចពុទ្ធភាសិតទ្រង់សម្តែងទុកមកថា ចក្ខុញ្ចបដិច្ច រូបេឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តំសហជាតា ដូច្នេះជាដើម សេចក្តីថាចក្ខុវិញ្ញាណដែលនឹងកើតឡើង ព្រោះអាស្រ័យនូវចក្ខុបសាទនឹងរូបារម្មណ៍មកប៉ះពាល់ផ្ទប់គ្នា គឺថាភ្នែកនឹងរូបមកប៉ះគ្នាជាហេតុអោយកើតឡើងជាផលគឺវិញ្ញាណ ទើបដឹងថា រូបនេះរូបនោះជាដើមកាលដែលចក្ខុវិញ្ញាណកើតឡើងនោះ មិនមែនកើតតែម្នាក់ឯងទេគឺមានសហជាតធម៌ ជាធម៌សម្រាប់កើតជាមួយគ្នានឹងវិញ្ញាណនោះកើតព្រមផង ឯសហជាតធម៌នោះគឺវេទនាចេតសិក ជាចេតសិកមានលក្ខណសម្រាប់ដឹងនូវអារម្មណ៍ជាសុខ ជាទុក្ខ ជាឧបេក្ខា ១, សញ្ញាចេតសិក ជាចេតសិកមានលក្ខណសម្រាប់កត់ចំណាំនូវអារម្មណ៍ថា អារម្មណ៍នោះមានពណ៌ដូច្នោះ ១ ចេតនាចេតសិក ជាចេតសិកមានលក្ខណ

www.budinst.gov.kh www.elibraryofcambodia.org

សម្រាប់សន្សំនូវអារម្មណ៍១, ផស្ស[១] ចេតសិក ជាចេតសិកមានលក្ខណសម្រាប់ខ្ទប់នូវអារម្មណ៍ ១ , មនសិការចេតសិកជាចេតសិកមានលក្ខណ សម្រាប់ធ្វើទុកក្នុងចិត្តនូវអារម្មណ៍ ឬកាន់យកនូវអារម្មណ៍ ១ ចេតសិកទាំង ៥ប្រការនេះជាសហជាតធម៌ ជាមួយនឹងចក្ខុវិញ្ញាណ វេលានឹងកើតឡើង ក៏កើតព្រោះបច្ច័យ គឺវិញ្ញាណ៍១ ជាប្រធាននៃសហជាតធម៌ទាំងនោះ នឹងចាត់ថា ជាវេទគូថាបណ្តាសត្វដែលមានជីវិតនៅខាងក្នុងកាយតែងដឹងនូវព្រែវេទនោះមិនមែនទេ មហាបពិត្រស្ងួមបហារាជស្តេចជ្រាបដោយប្រការដូច្នេះ ឯសោតទ្វារ , ឃានទ្វារ, ជីវ្ហាទ្វារ, កាយទ្វារ នឹងមនោទ្វារទាំងនេះក៏តែងអាស្រ័យនូវអារម្មណ៍អំពីខាងក្រៅដូចចក្ខុ អាស្រ័យនឹងរូបនោះដែរ មហារាជ បពិត្រមហារាជឯទ្វារទាំង ៥ នោះ ពុទ្ធភាសិតទ្រង់ត្រាស់ថា សោតញ្ច បដិច្ច-សទ្ទេច-ឧប្បជ្ជតិ សោតវិញ្ញាណ៍ថា សោតវិញ្ញាណដែលនឹងកើតឡើងបាន ព្រោះអាស្រ័យនូវសោតបសាទ និងសទ្ទារម្មណ៍មកប៉ះពាល់ដល់គ្នាជាហេតុខាងដើមទើបឡើងបានជាសោតវិញ្ញាណ លុះសោតវិញ្ញាណកើត

---

(១) ក្នុងបាលីធម្មសង្គណីក្តី អភិធម្មត្ថសង្គហក្តី លោករៀងផស្សចេតសិកដាក់ខាងដើមរបស់ តែក្នុងគម្ពីរនេះ ឃើញលោកដាក់ផស្សចេតសិកនៅបន្ទាប់អំពីមនសិការវិញ ។

ឡើងហើយ ក៏សហជាតធម៌ទាំង ៥ ប្រការ មានវេទនាចេតសិកជាដើមកើតឡើងព្រមផង ។ ឃានបសាទ និងគន្ធារម្មណ៍មកផ្ទប់គ្នាទើបកើតជាឃានវិញ្ញាណឡើង សហជាតធម៌ ក៏កើតព្រមផង ។ ជីវ្ហាបសាទ នឹងរសារម្មណ៍មកផ្ទប់គ្នា ទើបកើតឡើងជាជីវ្ហាវិញ្ញាណ សហជាតធម៌ទាំងនោះ ៧ ក៏កើតព្រមផង ។ កាយបសាទនឹងផោដ្ឋព្វារម្មណ៍មកផ្ទប់គ្នា ទើបកើតជាកាយវិញ្ញាណឡើង ព្រមទាំងសហជាតធម៌ផង។ មនោបសាទ នឹងធម្មារម្មណ៍មកផ្ទប់គ្នា ទើបកើតជាមនោវិញ្ញាណឡើង ព្រមទាំងសហជាតធម៌ផង ។ ឯអាយតនទាំង ៦ ប្រការគឺចក្ខុ, សោត, ឃាន, ជីវ្ហា, កាយ, មនោ, នេះ ដែលនិងដឹងនូវអារម្មណ៍ថាដូច្នេះ ដូច្នោះមិនមែនដឹងដោយទំនើងខ្លួនឯងពែម៉្យាងនោះទេ គឺដឹងនោះ ព្រោះតែវិញ្ញាណដែលកើតអំពីកិរិយាផ្ទប់គ្នានៃអាយតនខាងក្នុង និង អាយតនខាងក្រៅ ឯវិញ្ញាណនោះសោត នឹងថាដឹងនូវអារម្មណ៍ដោយកំលាំងខ្លួនឯងពែម៉្យាងនោះក៏ទេដែរ ពោងអាស្រ័យនូវសហជាតធម៌ដែលតែងកើតព្រមជាមួយនឹងខ្លួននោះ មកជួយឧបត្ថម្ភគាំទ្រផងទើបដឹងបាន ឯសហជាតធម៌នោះ បានខាងឯវេទនា, សញ្ញា, ចេតនា, ផស្សៈ, មនសិការវាតែងកើតព្រមជាមួយនឹងវិញ្ញាណនោះ ទើបនឹងដឹងនូវរូបដោយភ្នែក,ដឹងនូវសំឡេង

www.budinst.gov.kh www.elibraryofcambodia.org

ដោយត្រចៀក , ដឹងនូវក្លិនដោយច្រមុះ , ដឹងនូវរសដោយអណ្តាត , ដឹងនូវកិរិយាផ្សប់ផ្សាយ ដោយកាយ , ដឹងនូវធមិដោយចិត្ត សេចក្តីនេះមានមកក្នុងព្រះវរភិធម្មបិដក ដែលជាពុទ្ធភាសិតទ្រង់ត្រាសទុកមកនឹងបានចាត់ថា សព្វដែលមានជីវិតពាំងនៅខាងក្នុងផៃកាយទាំងឡាយនេះថា ជាវេចព្វជាគុណសម្រាប់ដឹងនូវសីល្បសាស្ត្រ នឹងព្រៃវេទនោះក៏ទេ សូមមហាបពិត្រស្តេចជ្រាបតាមសេចក្តី ដែលវិសជ្ជនាថ្វាយមកនេះចុះ ។

ម - ព្រះបាទមិលិន្ទ្រាធិរាជ ជាបរមក្សត្រស្តេចបានទ្រង់សវនាការនូវសេចក្តីវិសជ្ជនានោះហើយ ទ្រង់ក៏មានព្រះហឫ-ទ័យសោមនស្សត្រេកអរជាអនេកប្បការ ទើបទ្រង់បានព្រះរាជឱង្ការត្រាស់សរសើរថា កល្លោសិ អើលោកម្ចាស់នេះបានប្រាជ្ញាឆ្លៀវឈ្លាស់ណាស់ពេក ចេះវិសជ្ជនាដោះប្រស្នាទូ-លាយល្អណាស់ ខ្ញុំចូលចិត្តឥតមានសង្ស័យតទៅទៀតឡើយលោកម្ចាស់ ។

ចក្ខុវិញ្ញាណមនោវិញ្ញាណបញ្ហា ១ ធ ៧

ព្រះបាទមិលិន្ទ្រាធិរាជ ទ្រង់បានព្រះរាជឱង្ការសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៧នេះថា បពិត្រព្រះថេរដ៏ចំរើន

www.budinst.gov.kh www.elibraryofcambodia.org

ចុះចក្ខុវិញ្ញាណកើតឡើងក្នុងទីណា ចំណែកមនោវិញ្ញាណនិងពាំមទៅកើតក្នុងទីនោះដែរ ឬដូចម្ដេចលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា អាត្មាមហារាជ បពិត្រមហារាជ ថាបើចក្ខុវិញ្ញាណបានទៅកើតក្នុងទីណាហើយ មនោវិញ្ញាណក៏នឹងទៅកើតក្នុងទីនោះជាមួយគ្នាដែរ សូមទ្រង់ជ្រាប ។

ម ‑ ករបនភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចក្ខុវិញ្ញាណកើតឡើងមុន មនោវិញ្ញាណកើតឡើងក្រោយ ឬ នឹងមនោវិញ្ញាណកើតឡើងមុន ចក្ខុវិញ្ញាណកើតឡើងក្រោយ ដូច្នេះវិញជាធ្លាប់មានដែរ ឬមិនមានទេលោកម្ចាស់ ។

ន ‑ ពុំនដូច្នោះទេ មហាបពិត្រ ចក្ខុវិញ្ញាណតែងតែកើតឡើងមុន មនោវិញ្ញាណធ្លាប់តែកើតជាខាងក្រោយដោយលំ‑ដាប់គ្នា ។

ម ‑ លោកម្ចាស់ ខ្ញុំមានសេចក្ដីសង្ស័យពេកណាស់ ចុះហេតុអ្វីចក្ខុវិញ្ញាណ តែងតែកើតមុន ចំណែកមនោវិញ្ញាណតែងតែកើតជាក្រោយដោយលំដាប់គ្នា ហាក់ដូចជាដឹងគ្នា ឬដូចម្ដេច ឬមួយចក្ខុវិញ្ញាណបានបង្គាប់ទៅមនោវិញ្ញាណថា បើខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org

ទៅកើតក្នុងទីណា អ្នកឯងក៏ត្រូវចូលទៅកើតក្នុងទីនោះជាមួយគ្នាកុំខាន បើមិនដូច្នេះទេ មនោវិញ្ញាណបានបង្គាប់ព្រេជ្ញាចំពោះទៅលើចក្ខុវិញ្ញាណថា បើអ្នកឯងទៅកើតក្នុងទីណា ចំណែកខ្ញុំក៏នឹងទៅកើតក្នុងទីនោះដែរ ជាមួយនឹងអ្នក ឬ ១ ដូចម្ដេចលោកម្ចាស់ ។

ន -នហិមហារាជ បពិត្រសម្ដេចមហារាជ ឬកិរិយាចរចាជាពាក្យមព៌សន្យាដល់គ្នានឹងគ្នា នៃចក្ខុវិញ្ញាណ នឹង មនោវិញ្ញាណទាំងពីរនោះ ឥតអង្គមានឡើយ ។

ម - កថំភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន អ្នកទាំងពីរបើមិនបានព្រេជ្ញានឹងគ្នាទេ ចុះហេតុអ្វីក៏ចក្ខុវិញ្ញាណកើតក្នុងទីណា មនោវិញ្ញាណក៏ទៅកើតក្នុងទីនោះដែរ លោកម្ចាស់ ។

ន - និន្នត្តាចមហារាជ បពិត្រសម្ដេចមហារាជបានជាចក្ខុវិញ្ញាណកើតឡើងក្នុងទីណា មនោវិញ្ញាណក៏កើតក្នុងទីនោះដែរ និន្នត្តាច ហេតុភាវចក្ខុវិញ្ញាណ នឹងមនោវិញ្ញាណរំតែងប្រព្រឹត្តទៅតាមទីចំនោបទីជំរៀលផង ទ្វារត្តាច ព្រោះភាវនៃធម្មជាតិទាំងពីរនោះ តែងប្រព្រឹត្តទៅតាមទ្វារផង ចិណ្ណត្តាច-ព្រោះភាវនៃវិញ្ញាណទាំងពីរនោះ ធ្លាប់នឹកធ្លាប់សន្សំជាមួយគ្នាផង សមុទាចរណត្តាច ព្រោះភាវនៃអាមធមិទាំងពីរនោះ

www.budinst.gov.kh www.elibraryofcambodia.org

មានអាការហាក់ដូចជានឹងហៅនឹងបបួលគ្នាជាមួយផង ដោយធ្លាប់ស្និទ្ធស្នាលនិងគ្នាមកយូរយារហើយ ។

ម - កថំភន្តេនាគសេន បពិត្រព្រះនាគសេន ដ៏ចំរើនលោកម្ចាស់ថា ចក្ខុវិញ្ញាណនឹងមនោវិញ្ញាណធ្លាប់កើតជាមួយគ្នា ព្រោះធម្មជាតិទាំងពីរនោះ តែងប្រព្រឹត្តទៅកាន់ទីជំរៀលទីចំនោប សេចក្តីនេះខ្ញុំករុណាស្តាប់ពុំទាន់ចូលចិត្តនៅឡើយសូមលោកម្ចាស់ឧបមាជាបែបបន្តិចមកមើល ។

ន-ពំកីមញ្ញសិមហារាជ បពិត្រមហារាជ ចុះព្រះអង្គទ្រង់ព្រះដំរិះដូចម្តេច ភ្លៀងកាលដែលធ្លាក់ចុះមកលើផែនដីនេះទឹកភ្លៀងនោះ តើនឹងហៀរហូរទៅកាន់ទីដូចម្តេច ។

ម - យេនភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ចំណែកទីផែនដីឯណាជាទីទំនាប ទឹកភ្លៀងក៏នឹងហូរទៅកាន់ទីនោះតាមទំនួល ។

ន - អបរេនសមយេន បពិត្រមហារាជចុះបើមានភ្លៀងធ្លាក់ចុះមកក្នុងសម័យក្រោយទៀតទឹកភ្លៀវនោះ នឹងប្រព្រឹត្តទៅកាន់ទីណា មហាបពិត្រ ។

ម - យេនភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកភ្លៀងដែលធ្លាក់ចុះមកមុននោះជោជន់ ហូរទៅកាន់ទីណា ទឹកភ្លៀង

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងកាលក្រោយក៏នឹងហូរទៅតាមគ្នានោះឯង សូមលោកម្ចាស់ជ្រាប ។

ន . កិរុខោមមហារាជ បពិត្រសម្តេចមហារាជ ចុះទឹកភ្លៀងមុននោះនឹងបានបង្គាប់ទឹកភ្លៀងក្រោយថា នៃអ្នកបើខ្ញុំបានចូលទៅនៅក្នុងទីណា អ្នកឯងក៏ត្រូវចូលទៅនៅត្រង់ទីនោះតាមខ្ញុំ ឬថាទឹកភ្លៀងក្រោយបានផ្តាំទឹកភ្លៀងមុនថា នែអ្នក។ ឯងនឹងទៅក្នុងទីណា ខ្ញុំក៏នឹងទៅតាមអ្នកក្នុងទីនោះដែរ ដូច្នេះឬអ្វី មហាបពិត្រ ។

ម . អហិរាគេះ បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកភ្លៀងទាំងនោះនឹងបានធ្វើកតិកាសញ្ញាដូច្នោះក៏ទេ គឺទឹកទាំងនោះតែងប្រព្រឹត្តទៅតាមទីទំនាបទីទំនួល ដែលត្រូវតែនឹងហូរទៅតាមនោះឯង សូមលោកម្ចាស់ជ្រាប ។

ន . ឯវមេវ ខោ មហារាជ បពិត្រមហារាជ សេចក្តីនេះការឧបមាយ៉ាងណាថា ការឧបមេយ្យ ចុតិចិត្តវិញ្ញាណនឹងបដិសន្ធិវិញ្ញាណទាំងពីរ ដែលកើតមុន នឹងកើតក្រោយ ដោយភាវៈនៃចុតិវិញ្ញាណ នឹងបដិសន្ធិវិញ្ញាណ តែងប្រព្រឹត្តទៅការ៉មីរាបដូចគ្នានោះឯង នឹងថាចុតិវិញ្ញាណបានបង្គាប់ទៅបដិសន្ធិវិញ្ញាណថា « បើខ្ញុំទៅកើតក្នុងទីណា ចំណែកអ្នកឯងក៏ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ទៅកើតតាមខ្ញុំក្នុងទីនោះ » ដូច្នោះក៏ទេឬនឹងថាមនោវិញ្ញាណបានផ្តាំចក្ខុវិញ្ញាណថា « បើអ្នកឯងនឹងទៅកើតក្នុងទីណាចំណែកខ្ញុំ ក៏នឹងទៅកើតក្នុងទីជាមួយនោះដែរ » យ៉ាងនេះក៏ទេ ធម្មតាទាំងពីរនោះ នឹងបានមត់សន្យាគ្នាទេវិញទៅមកក៏ពុំអង្គមានឡើយ សូមមហាបពិត្រជ្រាប ។

ម .កថិភន្តេ បពិត្រព្រះនាគសេនថេរដ៏ចំរើន ឯវិញ្ញាណដែលលោកម្ចាស់សំដែងថា តែងប្រព្រឹត្តទៅកាន់ទីជំរៀលនោះ ខ្ញុំក៏ចូលចិត្តហោប់បាន តែខ្ញុំសូមសួរវំពីវិញ្ញាណដែលប្រព្រឹត្តទៅតាមទ្វារនោះតទៅទៀត ព្រោះលោកម្ចាស់បានវិសជ្ជនាមកហើយថា « បើចក្ខុវិញ្ញាណកើតក្នុងទីណានោះវិញ្ញាណក៏កើតក្នុងទីនោះដែរ ព្រោះវិញ្ញាណទាំងពីរនោះតែងប្រព្រឹត្តទៅតាមទ្វារជាមួយគ្នា » សេចក្តីនេះ នឹងមានឧបមាដូចម្តេច សូមលោកម្ចាស់ប្រៀបធៀបជាពាក្យឧបមាបន្តិចមកមើល ។

ន . យថាមហារាជ បពិត្រព្រះបមរវាជាធិរាជ សេចក្តីនេះ មានឧបមាបីដូចជាបុរសម្នាក់ មានប្រាថ្នានឹងចេញពីបច្ចន្តិមនគររបស់ស្តេច ដែលមានទ្វារតែ ១ ប្រកបដោយប៉ម នឹងកំពែងក្លោងទ្វារដ៏ក្រាស់មាំមួន រាជ្ញារាភាពសូមថ្វាយព្រះពរថា

ចុះបុរសនោះនឹងរកចេញទៅតាមផ្លូវដូចម្តេច បរោបពិត្រ ។

ម - ទ្វារនេះភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯបុរសនោះនឹងចេញទៅតាមទ្វារសម្រាប់ចេញនោះឯង លោកម្ចាស់ ។

ន - ចុះបើមានបុរសម្នាក់ទៀត មានបំណងនឹងចេញពីនគរដ៏ដែលនោះដែរ តើនឹងទៅតាមទ្វារដូចម្តេចបរោបពិត្រ ។

ប - យោនភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន បុរសដែលចេញទៅមុននោះតាមទ្វារណា ចំណែកបុរសខាងក្រោយនោះ ក៏នឹងចេញទៅបណ្តោយតាមទ្វារនោះដែរលោកម្ចាស់ ។

ន - កិន្នុខោមហារាជ បពិត្រព្រះរាជសម្ភារ ចុះបុរសដែលចេញទៅមុននោះ បានផ្តាំទុកនឹងបុរសដែលចេញខាងក្រោយនោះថា « បើខ្ញុំចេញពីព្រះបរមរាជនគរនេះ តាមទ្វារណា អ្នកឯងក៏ត្រូវចេញតាមទ្វារនោះកុំខាន » បើមិនដូច្នោះទេ ចំណែកបុរសដែលនឹងចេញក្រោយនោះ បាននិយាយផ្តាំទុកនឹងបុរសដែលចេញទៅមុននោះថា « បើអ្នកទៅតាមទ្វារណា, ខ្លួនខ្ញុំក៏នឹងទៅតាមទ្វារនោះដែរ » ដូច្នេះ ឬអ្វីមហាបពិត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ម - នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯបុរសទាំងនោះនឹងបានផ្ដែផ្ដាំគ្នាទៅវិញទៅមក ដូចពាក្យលោកម្ចាស់ថានេះមិនមានទេ គឺបុរសមុន នឹងបុរសក្រោយ អាចចេញទៅបណ្ដោយតាមគ្នាព្រោះតាមទ្វារតែ ១ នោះឯង ។

ន - ឯវមេវខោមហារាជ បពិត្រសម្ដេចមហារាជសេចក្ដីនេះមានឧបមាយ៉ាងណាមិញថា មានឧបមេយ្យដូចជាចក្ខុវិញ្ញាណ នឹងមនោវិញ្ញាណ ដែលកើតក្នុងទីជាមួយគ្នា ព្រោះភាវនៃចក្ខុវិញ្ញាណ នឹងមនោវិញ្ញាណ តែងប្រព្រឹត្តទៅតាមទ្វារនោះឯង តែថាចក្ខុវិញ្ញាណនឹងបានបង្គាប់ទៅមនោវិញ្ញាណថា «បើខ្ញុំទៅកើតក្នុងទីណា អ្នកឯងក៏ត្រូវទៅកើតក្នុងទីនោះចុះ » បើមិនដូច្នោះទេថា មនោវិញ្ញាណ នឹងបានផ្ដាំផ្ញើទុកថា « បើអ្នកឯងទៅកើតក្នុងទីណា ខ្ញុំក៏នឹងទៅកើតក្នុងទីនោះដែរ » ឯធម្មជាតទាំងពីរនេះ នឹងបានធ្វើកតិកសញ្ញានឹងគ្នាទៅមកដូច្នេះ ក៏ឥតវរង្គិមានឡើយ ដែលនឹងប្រព្រឹត្តទៅតាមគ្នានោះ ព្រោះតែអាស្រ័យនឹងទ្វារជាមួយគ្នាប៉ុណ្ណោះទេ សូមមហាបពិត្រជ្រាប ។

ម - កថំភន្តេបពិត្រព្រះថេរដ៏ចំរើន ត្រង់វិញ្ញាណទាំងពីរដែលតែងប្រព្រឹត្តទៅតាមទ្វារជាមួយគ្នានោះ ខ្ញុំករុណាចូល

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តរបស់សង្ស័យហើយ ពៃខ្ញុំសូមសួររំពឹងវិញ្ញាណទាំងពីរដ៏ដែលនោះទៀត ដែលលោកម្ចាស់បានអធិប្បាយមកហើយថា « បើចក្ខុវិញ្ញាណកើតក្នុងទីណាមនោវិញ្ញាណក៏កើតក្នុងទីនោះដែរ ព្រោះវិញ្ញាណទាំងពីរនោះធ្លាប់ស្និទ្ធស្នាលធ្លាប់សន្សំនូវកិច្ចជាមួយគ្នាមកជាយូរហើយ » សេចក្តីនេះនឹងមានឧបមាដូចម្តេចពទៅទៀតលោកម្ចាស់ សូមលោកម្ចាស់ឧបមេយ្យអោយខ្ញុំចូលចិត្តផងមើល ។

ន - ពំពឹមញ្ញលិមហារាជ បពិត្រមហារាជចុះព្រះអង្គស្តេចទ្រង់សំគាល់នូវហេតុនោះថា ដូចម្តេចអេះ ឯវិញ្ញាណបាំងពីរនេះ ប្រៀបដូចជារទេះពីរបំរុងនឹងទៅតាមផ្លូវតែមួយក៏រទេះមួយជាដំបូងនោះបានចេញទៅមុនហើយ ចុះរទេះជាគំរប់ពីរនោះ តើនឹងចេញទៅតាមផ្លូវដូចម្តេចទៀតមហាបពិត្រ ។

ម - យេនភន្តេ បពិត្រព្រះថេរដ៏ចំរើន រទេះទី ១ នោះចេញទៅតាមផ្លូវណា ក៏រទេះទី ២ នឹងទៅតាមផ្លូវនោះដែរលោកម្ចាស់ ។

ន - កីនុខោមហារាជ បពិត្រសម្តេចមហារាជ ចុះរទេះមុនបានបង្គាប់ចំពោះរទេះក្រោយនោះថា «បើខ្ញុំចេញទៅតាម

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវណា អ្នកឯងក៏ត្រូវទៅតាមផ្លូវនោះកុំខាន » បើមិនដូច្នោះទេ រទេះក្រោយនឹងបានផ្តាំរទេះមុននោះទុកថា « អ្នកទៅតាមផ្លូវណា ចំណែកខ្ញុំក៏នឹងទៅតាមផ្លូវនោះដែរ » ដូច្នេះ ឬ អ្វីមបពិត្រ ។

ម - នត្ថិភន្តេ មិនមែនដូច្នោះទេលោកម្ចាស់ ឯរទេះទាំងពីរនោះ នឹងបាននិយាយមត់សន្យាដល់គ្នា នឹងគ្នាដូច្នោះនោះមិនមែនទេ តែបានជារទេះទាំងនោះអាចទៅតាមគ្នាបាន ព្រោះរទេះទាំងនោះ តែងប្រព្រឹត្តទៅតាមផ្លូវដូចគ្នា សូមលោកម្ចាស់ជ្រាប ។

ន - ឯវមេវខោមហារាជ បពិត្រមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ឯចក្ខុវិញ្ញាណ នឹងមនោវិញ្ញាណតែងកើតតាមគ្នាក៏មានឧបមេយ្យដូច្នោះឯង ឥតមាននិយាយផ្តែផ្តាំគ្នាទេ សូមទ្រង់ជ្រាប ។

ម - កថំភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ឯវិញ្ញាណទាំងពីរដែលលោកម្ចាស់សំដែងថាជាធម្មជាតិតែងប្រព្រឹត្តទៅតាមសេចក្តីសន្សំនោះ ខ្ញុំករុណាចូលចិត្តស្តាប់បានហើយតែសូមសួរអំពីវិញ្ញាណទាំងពីរដ៏ដែល ដែលលោកម្ចាស់បានអធិប្បាយថា « វិញ្ញាណទាំងពីរនេះ តែងកើតក្នុងទីជាមួយគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ថាបើចក្ខុវិញ្ញាណកើតក្នុងទីណា មនោវិញ្ញាណក៏កើតក្នុងទីនោះដែរ បញ្ចូលគ្នារលាយទៅជាមួយផង» សេចក្តីនេះនឹងឧបមាដូចជារបស់អ្វី សូមលោកម្ចាស់ប្រៀបឧបមាជាបែបអោយខ្ញុំចូលចិត្តផងមើល ។

ថ - យថាមហារាជ បពិត្រមហារាជ សេចក្តីនេះប្រៀបដូចជាការប៉ិនប្រសប់របស់មនុស្ស ដែលស្ទាត់ជំនាញក្នុងកិច្ចដែលនឹងល្បែងផ្លូវសិល្បសាស្ត្រទាំងពួង មានសិល្បសាស្ត្រសម្រាប់រាប់ដោយវិធីក្បាច់ដៃ ឬរាប់ដោយបន្ទាត់នឹងលេខគិតគូរគុណហារជាដើម គេអាចធ្វើអោយឆាប់ អោយរហ័សស្មើគ្នា ឬប្រព្រឹត្តទៅព្រមគ្នាបាន យ៉ាងណាមិញបពិត្រមហារាជ ក៏ចក្ខុវិញ្ញាណដែលកើតបានក្នុងទីណា មនោវិញ្ញាណអាចនឹងកើតបានក្នុងទីនោះដែរ ព្រោះចក្ខុ នឹងមនោវិញ្ញាណទាំងពីរនេះជាធម្មជាតិ ធ្លៀវឆ្លាសអាចប្រព្រឹត្តទៅស្មើគ្នា ឬព្រមគ្នាបានមិនមានកិច្ចដោយផ្តាំផ្ញើ ឬ បត់សញ្ញានោះឡើយ ឬអហារបពិត្រយល់ថា ព្រោះតែបានបត់សញ្ញានឹងគ្នា ទើបកើតព្រមគ្នាបាន ។

ន - នបារិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើនខ្ញុំមិនទាន់យល់ដូច្នោះទេ ព្រោះខ្ញុំបានស្តាប់លោកម្ចាស់វិសជ្ជនាមកនោះចួបេ

www.budinst.gov.kh www.elibraryofcambodia.org

251

ចិត្តសព្វគ្រប់ហើយ តែខ្ញុំម្ចាស់សូមសួរលោកម្ចាស់តទៅ ទៀតនូវពីវិញ្ញាណទាំង ៥ ប្រការ បន្ទាប់ៗ គ្នានេះថាចក្ខុ សោត វិញ្ញាណកើតក្នុងទីណា ឃានវិញ្ញាណកើតក្នុងទីណា ជិវ្ហា វិញ្ញាណកើតក្នុងទីណា នឹងកាយវិញ្ញានកើតក្នុងទីណា មនោ វិញ្ញាណក៏តែងទៅកើតក្នុងទីនោះៗ តាមគ្នា ដូចជាចក្ខុវិញ្ញាណ នឹងមនោវិញ្ញាណនោះដែរ ឬដូចម្តេចលោកម្ចាស់ ។

ន - អាមមហារាជ បពិត្រមហារាជ មហាបពិត្រ ស្តេច មានព្រះរាជឱង្ការមកនេះត្រូវយ៉ាងនឹងហើយ ឯមនោវិញ្ញាណ តែងកើតតាមចក្ខុវិញ្ញាណ ឬ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ នឹងកាយវិញ្ញាណ ក្នុងវិញ្ញាណទាំង ៥ប្រការ តាម វិញ្ញាណណា ១ មិនខានឡើយ បពិត្រមហារាជ ឯបទទាំង ៦ ប្រការ ព្រមទាំងសេចក្តីឧបមានុបមេយ្យផងនោះ ក៏ដូចអាត្មា ព្រមមហាបពិត្រជ្រាបដោយសេចក្តីពិស្តារចុះ តែថាវិញ្ញាណ ទាំងនោះនឹងបាននិយាយចរចាទៅវិញទៅមកអាត្មាក៏ទេ សូម ទ្រង់ជ្រាប ។

ម - កល្លោសិភន្តេ បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់ ឆ្លៀវឆ្លាស់វាងវៃពេកណាស់ ចេះវិសជ្ជនាដោះប្រស្នាស្រួល ដូចលេឥតមានឆ្កាំក្នុងឡើង ខ្ញុំចូលចិត្តអស់សង្ស័យប៉ុណ្ណោះ ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់បុច្ឆាចំពោះទៅកាន់ព្រះនាគសេនថេរ ក្នុងប្រស្នាទី ៨ នេះតទៅទៀតថា បពិត្រព្រះនាគសេនថេរដ៏ចំរើន ថាបើចក្ខុវិញ្ញាណកើតឡើងក្នុងទីណា ចំណែកវេទនាចេតសិកកើតតាមក្នុងទីនោះដែរ ឬ ដូចម្តេចលោកក្តោល់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជបើចក្ខុវិញ្ញាណកើតក្នុងពេលណា ចំណែកវេទនាចេតសិកក៏កើតក្នុងពេលនោះដែរ ហើយមិនមែនវេទនាចេតសិកប៉ុណ្ណោះទេ ថែមទាំងសញ្ញាចេតសិក ចេតនាចេតសិក ផស្សចេតសិក មនសិការចេតសិក វិតកចេតសិក ក៏កើតព្រមគ្នាក្នុងពេលនោះដែរ មហាបពិត្រសូមទ្រង់ជ្រាប ។

ម - កឹលក្ខណោភន្តេផស្សោ បពិត្រលោកម្ចាស់ដ៏ចំរើនចុះផស្សានោះ តើមានអ្វីជាលក្ខណសម្រាប់ដឹងលោកម្ចាស់ ។

ន - ផុស្សលក្ខណោ បពិត្រមហារាជឯផស្សនោះមានកិរិយាផ្សប់ផ្សាយ ឬពាល់ត្រូវជាលក្ខណសូមទ្រង់ជ្រាប ។

ម -ឧបមំករោហិ សូមព្រះថេរធ្វើនូវសេចក្តីឧបមាបន្តិចបកបើលអំពីផស្សលក្ខណនោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ន . យថាមហារាជ បពិត្រមហារាជផស្សនេះមានកិរិយាកើតមកអំពីបីប៉ះគ្នា ឬ ផ្ចប់គ្នា នៃចក្ខុបសាទ នឹងរូបារម្មណ៍ ប្រៀបដូចសត្វពពែទាំងពីរជល់គ្នា ពពែ ១ នោះ ឧបមាដូចចក្ខុបសាទពពែ ១ ទៀត ឧបមាដូចរូបារម្មណ៍ត្រង់ទីប្រជុំ នៃក្បាលពពែទាំងពីរនោះ ឧបមាដូចផស្សបណ្ឌិតគប្បីឃើញថា ពៃចក្ខុបសាទ និងរូបារម្មណ៍ មកប្រទះគ្នាក្នុងវេលាណាហើយ ក៏កើតជាផស្សឡើងក្នុងវេលានោះ សូមមហាបពិត្រជ្រាប ។

ប . សូមលោកម្ចាស់ឧបមាអោយច្រើនទៅមើល ។

ន . បពិត្រមហារាជ សេចក្តីនេះមានឧបមាដូចបាទដៃទាំងពីរដែលបុគ្គលទះផ្ចប់គ្នា ឯបាទដៃទាំងពីរដូចចក្ខុបសាទ និងរូបបារម្មណ៍មកប៉ះគ្នា ត្រង់ឮសូរសំឡេងនោះដូចផស្សពុំនោះសោត ប្រៀបដូចឆ្នាំទាំងពីរ គឺឆ្នាំចាស់ នឹងឆ្នាំថ្មីដែលពគា ឯឆ្នាំទាំងពីរនោះ ដូចចក្ខុនឹងរូប ឯត្រង់ទីបន្តនៃឆ្នាំទាំងពីរនោះ ដូចផស្សនោះឯង សេចក្តីដែលអាត្មាភាពឧបមាមកប៉ុណ្ណេះនេះ សូមទ្រង់ជ្រាប ។

ម . ខ្ញុំចូលចិត្តស្តាប់បានហើយ លោកម្ចាស់ៗ ឈ្លាសណាស់ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមហាក្សត្រ ស្ដេចទ្រង់មានព្រះរាជឱង្ការបុច្ឆាចំ-ពោះទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៩ នេះថា បពិត្រព្រះថេរដ៏ចំរើនចុះវេទនាចេតសិកនោះ រោងរបស់អ្វីជាលក្ខណជាគ្រឿងសំគាល់លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជឯវេទនាចេតសិក កាលដែលនឹងកើតឡើងនោះតែងបានកិរិយាដឹងនូវអារម្មណ៍ និងសោយនូវអារម្មណ៍ជាសុខ ជាទុក្ខឬជាឧបេក្ខា ជាលក្ខណ សូមមហារាជជ្រាប ។

ម - ឧបមំករោហិ សូមលោកម្ចាស់ឧបមាជាសេចក្ដីបន្តិចមកមើល ។

ន - យថាមហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបដូចរាជបុរសណា ១ ជាអ្នកមានសេចក្ដីឧស្សាហ៍ប្រឹងប្រែងខំធ្វើការរាជការ ជាគុណបំណាច់ដើម្បីបំពេញព្រះរាជបរិយ៍យនៃព្រះបរអក្សត្រ ១ ស្ដេចក៏មានព្រះហឫទ័យសោមនស្សត្រេកអរ នឹងការនោះ ទ្រង់ក៏ព្រះរាជទាននូវព្រះរាជទ្រព្យអោយជារង្វាន់ដល់បុរសនោះ បុរសនោះក៏បានសេពសោយប្រើប្រាសនូវកាមគុណទាំង ៥ ប្រការ ដែលជា

www.budinst.gov.kh www.elibraryofcambodia.org

វង្វាន់អំពីព្រះមហាក្សត្រ ទ្រង់ប្រោសប្រទានអោយដោយបរិបូណ៌ ដោយរាជបុរសនោះមានគំនិតគិតថា អាត្មាអញដែលបានសោយនូវទុក្ខវេទនាដោយបរិបូណ៌យ៉ាងនេះ ក៏មិនព្រោះហេតុអ្វី គឺព្រោះតែអាត្មាអញបានធ្វើរាជការដែលជាការបំពេញព្រះរាជចិន្តាពីកាលមុន ទើបទ្រង់ប្រោសប្រទានរបស់ទាំងនេះដល់ខ្លួនអញនេះឯង បពិត្រមហារាជ ន័យ ១ ទៀតប្រៀបដូចជាបុរសឯណា ១ បានធ្វើការងារជាកុសលល្អហើយ វេលាដល់ធ្វើកាលកិរិយាដោះចិត្តចេញចាករូបនេះទៅគ្រាណាក៏បានឡើងទៅកើតស្ថានសួគ៌ទេវលោក ឯណោះលុះបុរសនោះបានទេ កើតក្នុងស្ថានទិព្វយ៉ាងនេះហើយ ក៏បានសោយនូវកាមគុណដ៏ជាទិព្វទាំងឡាយ ៥ ប្រការ មានរូបទិព្វជាដើមដោយបរិបូណ៌ ទើបមានគំនិតដូច្នេះកើតឡើងដល់បុរសនោះថា អាត្មាអញបានកសាងនូវកុសលកម្មរួចហើយក្នុងជាតិមុនដល់មកឥឡូវនេះ ខ្លួនអញនេះ បានសោយនូវសុខវេទនានេះដោយពេញលេញ បពិត្រមហារាជ ឯវេទនាចេតសិកនេះមានដឹងនូវអារម្មណ៍ឬសោយនូវអារម្មណ៍ជាលក្ខណដូចរឿងដែលអាត្មាភាព ថ្វាយព្រះពរមកប៉ុណ្ណោះនេះ សូមមហាបពិត្រជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ម . កល្លោសិ ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ប៉ិនប្រសប់វិសជ្ជនាត្រូវហើយ ខ្ញុំលែងចិត្តរសាសង្ស័យ ។

សញ្ញាលក្ខណបញ្ហា ១ ពី ១០

មហាក្សត្រស្តេចទ្រង់បុច្ឆាទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ១០នេះតទៅថា បពិត្រព្រះថេរដ៏ចំរើន ឯផស្សចេតសិក និងវេទនាចេតសិក មានលក្ខណដូចលោកម្ចាស់វិសជ្ជនាមកនោះហើយ ចុះសញ្ញាចេតសិក តើមានអ្វីជាលក្ខណសម្រាប់សំគាល់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ ឯសញ្ញាចេតសិកនោះ មានសេចក្តីកត់ចំណាំជាលក្ខណ សូមព្រះអង្គជ្រាប ។

ម . បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះករុណាម្ចាស់បានវិសជ្ជនាថាសញ្ញាចេតសិក មានការកត់ចំណាំជាលក្ខណ ចុះដែលកត់សំគាល់នោះ តើកត់ចំណាំនូវវត្ថុអ្វីលោកម្ចាស់ ។

ន . បពិត្រមហារាជ ឯសញ្ញាចេតសិកដែលថា បានលក្ខណសម្រាប់កត់ចំណាំនូវវត្ថុនោះ គឺវត្ថុដែលមានពណ៌ខៀវ ឬពណ៌ក្រហម ឬពណ៌ផ្សេងៗជាដើម សូមទ្រង់ជ្រាប ។

www.budinst.gov.kh www.elibraryofcambodia.org

ម - ឧបមំភន្តេ សូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមាបន្តិចមកនឹងបានស្តាប់មើល ។

ន - យថាមហារាជ បពិត្រមហារាជ សេចក្តីនេះប្រៀបដូចនាយឃ្លាំងរបស់មហាក្សត្រ នាយឃ្លាំងនោះគ្រាដែលបានចូលទៅក្នុងភណ្ឌាគារិកស្ថាននោះ វេលាណាក៏បានឃើញនូវរបស់ព្រះរាជទ្រព្យទាំងឡាយច្រើនមុខ មានរបស់ដែលមានពណ៌ខៀវ ពណ៌ក្រហម ពណ៌ស ពណ៌ហើ សិប្បាតជាដើម ហើយបានកំណត់ចំណាំទុកនូវរបស់ទាំងនោះក្នុងចិត្ត បានយ៉ាងណា ក៏សញ្ញាចេតសិកដែលសម្រាប់កំណត់សំគាល់នូវវត្ថុមានពណ៌ខៀវជាដើម ជាលក្ខណក៏យ៉ាងនោះដែរ សូមមហារាជស្តេចជ្រាប ។

ម - ត្រូវហើយ ៗ លោកម្ចាស់ ៗ ឆ្លៀវឈ្លាសពេកពេកណាស់ ។

ចេតនាលក្ខណបញ្ហា ៧ បី ១១

ព្រះបាទមិលិន្ទ្រាធិបតី ស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះថេរដ៏ចំរើន ចុះចេតសិកនោះតើមាននវត្ថុអ្វីជាលក្ខណៈលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ ឯ

www.budinst.gov.kh www.elibraryofcambodia.org

ចេតនា ចេតសិកនេះ មានកិរិយាញ៉ាំងខ្លួនឯងនឹងអ្នកឯទៀត អោយសន្សំនូវអារម្មណ៍ និងទាក់ទែងចំពោះដោយខ្លួនឯងផង ជាលក្ខណៈ សូមមហាបពិត្រជ្រាប ។

ម . ឧបមំករោហិ សូមលោកម្ចាស់ឧបមាជាសេចក្តីបន្តិចមកមើល ។

ន . យថាមហារាជ បពិត្រមហារាជ សេចក្តីនេះប្រៀបដូចជាបុរសណា ១ បានពាក់ពែងផ្សំថ្នាំស្រវឹង ឬថ្នាំពុលហើយក៏ផឹកលេបដោយខ្លួនឯងផង បបួលបង្ខំអ្នកដទៃរោយផឹកអោយលេបនូវថ្នាំពុលនោះផង ឯខ្លួនបុរសនោះ ក៏ដល់នូវសេចក្តីទុក្ខវេទនាជាទម្ងន់ ចំណែកអ្នកដ៏ទៃដែលផឹកលេបនូវថ្នាំពុលតាមនោះ ក៏បាននូវទុក្ខវេទនាដូចគ្នា សេចក្តីនេះមានឧបមាយ៉ាងណា បពិត្រមហារាជ ឯមនុស្សចំពួកខ្លះ ក្នុងលោកនេះ បានសន្សំធ្វើនូវអកុសលកម្មដោយចេតនាខ្លួនឯងផង ញ៉ាំងអ្នកដ៏ទៃអោយធ្វើតាមខ្លួនផង វេលាដល់ផុតជីវិតិន្ទ្រិយ៍ធ្វើនូវមរណកាលកន្លងទៅ ក៏តែងទៅកើតក្នុងចតុរាបាយដោយខ្លួនឯង ឯអ្នកដ៏ទៃដែលប្រព្រឹត្តធ្វើតាមនោះ ក៏ត្រូវទៅសោយទុក្ខវេទនាដូចគ្នា ។

ម្យ៉ាងទៀត ប្រៀបដូចបុរសម្នាក់ ជាអ្នកចេះពាក់ពែង

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើនូវវត្ត ៥ យ៉ាង គឺទឹកដោះថ្លា, ទឹកដោះខាប់, ប្រេងទឹកឃ្មុំ, ទឹកអំពៅអោយទៅជារបស់ផ្អែមពិសារមានរសតែមួយហើយ ផឹកស៊ីដោយខ្លួនឯង បបួលអ្នកដ៏ទៃអោយផឹកស៊ីផង ឯខ្លួនឯងក៏បានសេចក្តីសុខស្រួល ចំណែកអ្នកដ៏ទៃ ដែលផឹកស៊ីតាមនោះក៏បានសុខស្រួលដូចគ្នាដែរ សេចក្តីនេះប្រៀបដូចអ្វីថា ប្រៀបដូចមនុស្សចំពូកខ្លះក្នុងលោកនេះ ចេះសន្សំធ្វើនូវកុសលកម្មដោយខ្លួនឯង នឹងបបួលអ្នកដ៏ទៃអោយធ្វើផង វេលាដល់ខ្លួនធ្វើកាលកិរិយាទៅ ក៏បានឡើងទៅកើតក្នុងសុគតិភព ឬសគ្គស្ថាន ចំណែកអ្នកដែលប្រព្រឹត្តធ្វើតាម ក៏បានឡើងទៅកើតស្ថានស្មើគ្នានោះផង បពិត្រមហារាជ ឯចេតនាចេកសិកនេះ មានលក្ខណសន្សំនូវបាបកម្មនឹងបុញ្ញកម្មយ៉ាងនេះ សូមមហាបពិត្រជ្រាប ។

ម - កល្លោសិភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់ឆ្លៀវឆ្លាស់មែន ។

( សំដែងបកក្នុងបិបេន្ទបញ្ហាខ្សែ ១ ចប់តែប៉ុណ្ណេះ )

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org